MALIS
២០១៤



# សៀវភៅសម្រាប់អ្នកសម្របសម្រួលម្របសម្រួល

# សាលាអាជីវកម្មកសិកម្ម
# កម្មវិធីបណ្តុះបណ្តាល

គម្រោងម្លិះ - គម្រោងកែលម្អសន្តិសុខស្បៀង និងការភ្ជាប់ទីផ្សារសម្រាប់កសិករខ្នាតតូច
នៅក្នុងខេត្តឧត្តរមានជ័យ និងព្រះវិហារ ព្រះរាជាណាចក្រកម្ពុជា ២០១២-២០១៥

សហភាពអឺរ៉ុប

# តារាងមាតិកា


មេរៀនទី៤ ៖ ការសិក្សាទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាសៈ ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រ ការវិភាគទៅលើប្រព័ន្ធ ក្សេត្របរិស្ថាន ការបន្ថែមតម្លៃ ដែលមានសក្តានុពល សេវាកម្មព័ត៌មានបច្ចេកទេស ..... 41

មេរៀនទី៤ ៖ លទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស (បន្ត) ..... 63

មេរៀនទី៤ ៖ លទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស (បន្ត) ..... 72

មេរៀនទី៥ ៖ ការស្វែងរកប្រភពថវិកា ..... 81

មេរៀនទី៥ ៖ ការប៉ាន់ប្រមាណប្រភពថវិកា (បន្ត) ..... 87

មេរៀនទី៦ ៖ ការរៀបចំទស្សនកិច្ចសិក្សាប្រៀបធៀប ..... 89

មេរៀនទី៦ ៖ ការរៀបចំដំណើរទស្សនកិច្ចសិក្សាប្រៀបធៀប (បន្ត) ..... 98

មេរៀនទី៧ ៖ ការណែនាំអំពីជម្រើសសកម្មភាពក្រុម និងផែនការថវិកា ..... 100

មេរៀនទី៨ ៖ ការចរចាទៅលើកិច្ចសន្យាទិញ និងលក់ ..... 123

មេរៀនទី៩ ៖ ការបង្កើតកិច្ចសន្យាសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ ..... 127

មេរៀនទី១០៖ ការរៀបចំផែនការអាជីវកម្មសហគ្រាសជាក្រុម ..... 131

មេរៀនទី១១ ៖ ការរក្សាកំណត់ត្រា ..... 138

មេរៀនទី១២៖ ការត្រួតពិនិត្យទៅលើដំណាក់កាលអនុវត្តរបស់សហគ្រាស ..... 150

មេរៀនទី១៣ ៖ ការវាយតម្លៃទៅលើដំណើរការផែនការអាជីវកម្មរបស់កសិករលក្ខណៈបុគ្គល និងផែនការអាជីវកម្មសហគ្រាសជាក្រុម ..... 154

មេរៀនទី១៤ ៖ ការជ្រើសរើសសហគ្រាសមួយសម្រាប់រដូវកាលបន្ទាប់ ..... 158

មេរៀនទី១៥ ៖ ការត្រួតពិនិត្យឡើងវិញទៅលើផែនការយុទ្ធសាស្ត្រអាជីវកម្មថ្មី ..... 160

មេរៀនទី១៦ ៖ ការវាយតម្លៃវគ្គ សាលាអាជីវកម្មកសិកម្ម និងការបញ្ចប់វគ្គ ..... 162

# តារាងមាតិកា ទំព័រ


**បុព្វកថា** ...ii

**ឯកសារយោង ៖** ...iv

**តារាងមាតិកា** ...v

**ផ្នែកទី១ ៖ និដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម សម្រាប់អ្នកសម្របសម្រួល** ...1

អំពីសៀវភៅសម្រាប់អ្នកសម្របសម្រួល និងសៀវភៅលំហាត់៖ ...1

ឯកសារបណ្តុះបណ្តាលសម្រាប់វគ្គ សាលាអាជីវកម្មកសិកម្ម ...2

វដ្តនៃអាជីវកម្មកសិកម្ម និង ពេលវេលានៃវគ្គ សាលាអាជីវកម្មកសិកម្ម ...2

ការអភិវឌ្ឍន៍កម្មវិធី សាលាអាជីវកម្មកសិកម្ម ...5

ការគ្រប់គ្រង និងការសម្របសម្រួលវគ្គសាលាអាជីវកម្មកសិកម្ម ...6

ជំនាញសម្របសម្រួល និងបច្ចេកទេសបណ្តុះបណ្តាល ...7

**ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍** ...8

ជំហាននៅក្នុងការគៀងគរសហគមន៍ ...8

ដំបូន្មានសម្រាប់ការគៀងគរសហគមន៍ប្រកបដោយប្រសិទ្ធភាព ...9

សំនួរដែលត្រូវសួរមុនពេលកិច្ចប្រជុំ សាលាអាជីវកម្មកសិកម្ម លើកដំបូង ...9

ការកំណត់អត្តសញ្ញាណ និងការជ្រើសរើសកសិករ ... 14

លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសកសិករ ... 14

គុណសម្បត្តិ និងគុណវិបត្តិនៃការចូលរួមនៅក្នុងក្រុម ... 16

រចនាសម្ព័ន្ធរបស់ក្រុម សាលាអាជីវកម្មកសិកម្ម ... 17

**ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម** ... 20

មេរៀនទី១ ៖ ការណែនាំអំពីវគ្គសាលាអាជីវកម្មកសិកម្ម និងការវិភាគទៅលើសេចក្តីត្រូវការបណ្តុះបណ្តាល 20

មេរៀនទី២ ៖ មូលហេតុ និងការរៀបចំវគ្គបណ្តុះបណ្តាលសាលាអាជីវកម្មកសិកម្ម ... 28

មេរៀនទី៣ ការគ្រប់គ្រងក្រុម និងការធ្វើកសិកម្ម ក្នុងលក្ខណៈជាអាជីវកម្ម... 35

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម

### *ឯកសារបណ្តុះបណ្តាលសម្រាប់វគ្គ សាលាអាជីវកម្មកសិកម្ម*

| សៀវភៅសម្រាប់អ្នកសម្របសម្រួល | សៀវភៅសម្រាប់សិក្ខាកាម |
| --- | --- |
| សៀវភៅនេះ ផ្តល់នូវការណែនាំជាជំហានៗ ដែលបង្ហាញជូនដល់អ្នកសម្របសម្រួលអំពី មាតិកាសំខាន់ៗនៃកម្មវិធីបណ្តុះបណ្តាល កសិករអំពីសាលាអាជីវកម្មកសិកម្ម។ | សៀវភៅលំហាត់សម្រាប់សិក្ខាកាមនេះ ប្រើប្រាស់ក្នុងអំឡុងពេល និងក្រោយពេលកិច្ចប្រជុំ សាលាអាជីវកម្មកសិកម្ម។ សៀវភៅនេះ គូសបញ្ជាក់អំពីគោលគំនិតសំខាន់ៗ ព្រមទាំងលំហាត់មួយចំនួនដែលផ្អែកលើបទពិសោធន៍ ដើម្បីជួយសម្របសម្រួលដល់ការរៀនសូត្ររបស់កសិករ។ |

សម្ភារៈសម្រាប់កម្មវិធី សាលាអាជីវកម្មកសិកម្ម ត្រូវបានរៀបចំឡើងជាពិសេស ដើម្បីធ្វើការងារជាមួយធនធានដែលមានកម្រិត។

បើទោះបីជាសិក្ខាកាមត្រូវចេះអក្សរ និងលេខនព្វន្តកម្រិតមូលដ្ឋានក៏ដោយ ប៉ុន្តែពួកគេមិនចាំបាច់ត្រូវមានការអប់រំ ក្នុងប្រព័ន្ធក្នុងកម្រិតមួយដែលគួរឱ្យកត់សម្គាល់ឡើយ។ សិក្ខាកាមនឹងត្រូវបានលើកទឹកចិត្តឱ្យបង្កើតជាអនុក្រុមតូចៗ ដែលមានសមាជិកចន្លោះពី៣-៥នាក់ ដោយអនុក្រុមតូចៗនីមួយៗត្រូវមានសមាជិកម្នាក់ ដែលចេះអក្សរ ចេះលេខនព្វន្ត និងសរសេរបានលឿន។ តាមរយៈទង្វើបែបនេះ គេអាចបំពេញលំហាត់ និងកត់ត្រានៅក្នុងអនុក្រុមតូចៗនីមួយៗ ដោយបទពិសោធន៍រៀនសូត្រចម្បងៗ កើតឡើងតាមរយៈការស្តាប់ និងការពិភាក្សា។ សមាជិកអនុក្រុមទាំងឡាយណាដែល រៀនសូត្រមិនទាន់លំហាត់លេខនព្វន្ត និងលំហាត់សំណេរ អាចបន្តសិក្សាទៅលើលំហាត់ទាំងនោះតាមក្រោយ ដោយមាន ជំនួយពីប្រធានអនុក្រុមក្រោយពេលបញ្ចប់វគ្គសិក្សា នៅពេលដែលពួកគេទំនេរ។ ដូច្នេះ ដំណើរការនៃកិច្ចប្រជុំរៀនសូត្រនេះ អាចបន្តទៅមុខ ជារៀងរហូត ហើយប្រធានអនុក្រុមគ្រប់រូប ក៏កំពុងតែរៀនសូត្រដើម្បីឱ្យក្លាយទៅជាអ្នកសម្របសម្រួលមិនផ្លូវការដោយខ្លួនឯងផងដែរ។

### *វដ្តនៃអាជីវកម្មកសិកម្ម និង ពេលវេលានៃវគ្គ សាលាអាជីវកម្មកសិកម្ម*

កម្មវិធីបណ្តុះបណ្តាលសិក្ខាកាមរបស់វគ្គសាលាអាជីវកម្មកសិកម្ម រួមមានកិច្ចប្រជុំក្រុមដែលជាធម្មតាត្រូវបានប្រារព្ធធ្វើឡើងរៀងរាល់សប្តាហ៍ និងមានរយៈពេលចន្លោះពី២-៣ម៉ោង ហើយកម្មវិធីនេះ ត្រូវបានរៀបចំជារចនាសម្ព័ន្ធនៅចំពោះមុខ និងជុំវិញវដ្តនៃកសិផល ឬសត្វពាហនៈ។ បើទោះបីជាការសិក្សារៀនសូត្រភាគ

# ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម

## *អំពីសៀវភៅសម្រាប់អ្នកសម្របសម្រួល និងសៀវភៅលំហាត់៖*

កម្មវិធីសាលាអាជីវកម្មកសិកម្ម មានសៀវភៅ ចំនួន២ ដែលគាំទ្រដល់ដំណើរការផ្តល់វគ្គបណ្តុះបណ្តាលអំពីសាលាអាជីវកម្មនេះ។ សៀវភៅទាំងពីរនោះ រួមមាន សៀវភៅសម្រាប់អ្នកសម្របសម្រួល និងសៀវភៅលំហាត់សម្រាប់សិក្ខាកាម។ សៀវភៅសម្រាប់អ្នកសម្របសម្រួល (ឯកសារនេះ) មានគោលបំណងផ្តល់ការណែនាំជូនដល់អ្នកសម្របសម្រួល ដើម្បីពង្រឹងសមត្ថភាពរបស់កសិករលើជំនាញភាពជាសហគ្រិន និងជំនាញគ្រប់គ្រង តាមរយៈវិធីសាស្ត្រ "រៀនសូត្របណ្តើរធ្វើបណ្តើរ"។ សៀវភៅនេះ គូសបញ្ជាក់អំពី គោលបំណងនៃវគ្គបណ្តុះបណ្តាល រយៈពេល និងធនធានសម្ភារៈដែលត្រូវការ ព្រមទាំងពណ៌នា អំពីកម្រង ប្រធានបទពិភាក្សា និងលំហាត់អនុវត្តមួយចំនួនផងដែរ។ លំហាត់ទាំងនេះ មានគោលបំណងអភិវឌ្ឍន៍ជំនាញ និងសមត្ថភាពរបស់កសិករក្នុងការធ្វើអាជីវកម្ម ហើយស្របពេលជាមួយគ្នានោះ ក៏មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងរបស់ពួកគេ ផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ ដើម្បីឱ្យក្រឡេកមើលទៅការធ្វើកសិកម្មជាអាជីវកម្មរួមមួយដែលមានតួអង្គខ្សែសង្វាក់ផ្គត់ផ្គង់ ដែលផលិតទំនិញ ក្នុងគោលដៅផ្គត់ផ្គង់ទៅឱ្យទីផ្សារ។ កសិករនឹងទទួលបានសៀវភៅលំហាត់សម្រាប់សិក្ខាកាម ដែលសៀវភៅលំហាត់នេះ រួមមានលំហាត់ និងកំណត់សម្គាល់មួយចំនួន ដែលមានលក្ខណៈស្របគ្នាទៅនឹងប្រធានបទនៅក្នុងសៀវភៅសម្រាប់អ្នកសម្របសម្រួល។ ដំណើរការវគ្គសាលាអាជីវកម្មកសិកម្ម ជួយឱ្យកសិកររៀនសូត្រពីគ្នាទៅវិញទៅមកនៅក្នុងក្រុមតូចៗ អំពីប្រធានបទដែលពាក់ព័ន្ធទៅនឹងបរិយាកាសប្រកបរបរកសិកម្មផ្ទាល់ខ្លួនរបស់ពួកគេ ទៅតាមល្បឿននៃការរៀនសូត្ររបស់ពួកគេ។

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម

**ជំហានទី៤ - ការវាយតម្លៃ និងការធ្វើផែនការថ្មី៖** ត្រូវបានធ្វើឡើងក្រោយរដូវកាលផលិត។ កសិករត្រូវធ្វើការវាយតម្លៃទៅលើអ្វីដែលមានដំណើរការប្រព្រឹត្តទៅបានល្អ និងអ្វីដែលមានដំណើរការប្រព្រឹត្តទៅមិនសូវបានល្អ។ ពួកគេត្រូវធ្វើការប៉ាន់ប្រមាណជាថ្មីឡើងវិញ ទៅលើអាជីវកម្មជាក្រុមរបស់ពួកគេ និងធ្វើផែនការ កសិដ្ឋានដែលមានលក្ខណៈជាបុគ្គល និងផែនការជាក្រុមជាថ្មីឡើងវិញ សម្រាប់រដូវកាលបន្ទាប់។

កម្មវិធីសាលាអាជីវកម្មកសិកម្ម មានទំនាក់ទំនងទៅនឹងរដូវកាលផលិតកសិផល ឬសត្វពាហនៈ (ឧទាហរណ៍ ៖ ការធ្វើរដូវវស្សា ប៉ុន្តែវាអាចមានភាពខុសគ្នាសម្រាប់សហគ្រាសដទៃទៀត)

| ជំហាននៃវដ្តអាជីវកម្មកសិកម្ម | មេរៀន | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មុនរដូវកាលផលិត៖ ជំហានទី១ ៖ ការវិនិច្ឆ័យ ជំហានទី២ ៖ ការធ្វើផែនការ | ១-១១ | ■ | ■ | ■ | | | | | | | | | |
| ក្នុងអំឡុងពេលនៃរដូវកាលផលិត ៖ ជំហានទី៣៖ ការអនុវត្ត | ១២ | | | | ■ | ■ | ■ | ■ | ■ | ■ | | | |
| ក្រោយរដូវកាលផលិត៖ ជំហានទី៤៖ ការវាយតម្លៃ និងការរៀបចំផែនការឡើងវិញ | ១៣-១៦ | | | | | | | | | | ■ | ■ | ■ |

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម

ច្រើនត្រូវបានធ្វើឡើងនៅក្នុងបន្ទប់សិក្សាក៏ដោយ ប៉ុន្តែវគ្គបណ្តុះបណ្តាលក៏រួមមានដំណើរទស្សនកិច្ចទៅកាន់កសិដ្ឋានដែលនៅជុំវិញ និងអ្នកផ្តល់សេវាខ្សែសង្វាក់ផ្គត់ផ្គង់ផងដែរ ក្នុងគោលបំណងផ្តល់នូវការតភ្ជាប់ទំនាក់ទំនងជីវិតពិតសម្រាប់ការអភិវឌ្ឍន៍ទីផ្សារ។ កម្មវិធីសិក្សារួមមានប្រធានបទ និងលំហាត់អនុវត្តជាច្រើន ដែលទាក់ទងទៅនឹងស្ថានភាពជីវិតពិតរបស់ក្រុមនីមួយៗ។ ផ្នែកនៃការបណ្តុះបណ្តាល និង ប្រធានបទត្រូវបានរៀបចំឡើងជុំវិញជំហាននៃវដ្តអាជីវកម្មកសិកម្មចំនួន៤ ដែលរួមមានដូចតទៅ៖

**វដ្តអាជីវកម្មកសិកម្ម**




**ជំហានទី១ - ការវិនិច្ឆ័យ ត្រូវបានធ្វើឡើងមុនពេលចាប់ផ្តើមរដូវកាលផលិត៖** នៅក្នុងកម្មវិធីផ្នែកនេះ សិក្ខាកាមត្រូវវិភាគទៅលើស្ថានភាពបច្ចុប្បន្នរបស់ពួកគេ និងកំណត់រកអន្តរាគមន៍ដែលអាចធ្វើទៅបាន ព្រមទាំងសេចក្តីត្រូវការបណ្តុះបណ្តាល។ ពួកគេត្រូវរៀបចំបង្កើតសាលាអាជីវកម្មកសិកម្ម និងរៀនសូត្រអំពីរបៀបធ្វើឱ្យវាមានដំណើរការទៅបាន។ កសិករត្រូវឯកភាពទៅលើប្រធានបទនៅក្នុងកម្មវិធីដែលពួកគេចង់សិក្សារៀនសូត្រ និងតើពួកគេត្រូវរៀបចំកិច្ចប្រជុំនៅពេលណា។

**ជំហានទី២ - ការរៀបចំផែនការ៖** ជួយណែនាំដល់សិក្ខាកាម ឱ្យកំណត់គោលដៅសម្រាប់កសិដ្ឋាន និងក្រុមរបស់ពួកគេ និងបន្ទាប់មក ត្រូវរៀបចំបង្កើតផែនការកសិដ្ឋានដែលមានលក្ខណៈជាបុគ្គល និងផែនការជាក្រុមដើម្បីសម្រេចគោលដៅរបស់ពួកគេ។

**ជំហានទី៣ - ការអនុវត្ត និងការត្រួតពិនិត្យ៖** ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃរដូវកាលផលិត។ នៅក្នុងកម្មវិធីផ្នែកនេះ សិក្ខាកាមត្រូវអនុវត្តផែនការបុគ្គល និងផែនការក្រុមរបស់ពួកគេ បន្ទាប់មកត្រូវធ្វើការត្រួតពិនិត្យវឌ្ឍនភាពរបស់ពួកគេ ដោយធៀបទៅនឹងផែនការទាំងនេះ និងធ្វើការកែសម្រួលក្នុងករណីចាំបាច់ដើម្បីសម្រេចគោលដៅរបស់ពួកគេ។

## *ការគ្រប់គ្រង និងការសម្របសម្រួលវគ្គសាលាអាជីវកម្មកសិកម្ម*

**ការបង្រៀន ធៀបទៅនឹងការសម្របសម្រួល ៖** គោលការណ៍ស្នូលមួយនៃដំណើរការ សាលាអាជីវកម្មកសិកម្ម គឺគេចូលចិត្តការសម្របសម្រួលជាងការផ្តល់បទបាឋកថា។ ភាពខុសគ្នារវាងវិធីសាស្ត្រទាំងពីរនេះ ត្រូវបានគូសបញ្ជាក់ដូចខាងក្រោម៖

**ការបង្រៀន ធៀបទៅនឹងការសម្របសម្រួល**

| ការបង្រៀន | ការសម្របសម្រួល |
|---|---|
| ការបង្រៀនចាប់ផ្តើមចេញពីចំណេះដឹងផ្ទាល់ខ្លួនរបស់គ្រូបង្រៀន | អ្នកសម្របសម្រួលចាប់ផ្តើមតាមរយៈការប៉ាន់ប្រមាណ ទៅលើចំណេះដឹងរបស់ក្រុម |
| ការបង្រៀនអនុវត្តតាមកម្មវិធីសិក្សាមួយដែលត្រូវបានរៀបចំទុកជាមុន | អ្នកសម្របសម្រួលធ្វើការដោះស្រាយបញ្ហាដែលក្រុម ឬ សហគមន៍បានកំណត់រកឃើញ និងជ្រើសរើស ប្រើប្រាស់គំនិតថ្មីៗ ដែលស្របទៅតាមសេចក្តីត្រូវការ និងវប្បធម៌របស់ក្រុម |
| គ្រូបង្រៀនផ្តល់បទបាឋកថាជូនដល់សិស្សមួយក្រុម ដែលជាធម្មតា គាត់ផ្តល់បទបកថាពីផ្នែកខាងមុខ នៃបន្ទប់សិក្សា | អ្នកសម្របសម្រួលប្រើប្រាស់វិធីសាស្ត្រអនុវត្តជាក់ស្តែង ដែលមានការចូលរួមពីសិក្ខាកាម ឧទាហរណ៍ដូចជា ក្រុមពិភាក្សា និងសកម្មភាពដែលសិក្ខាកាមគ្រប់រូប នៅក្នុងក្រុមអាចចូលរួមបាន |
| លំហូរនៃព័ត៌មាន មានទិសដៅជាឯកទិសប៉ុណ្ណោះ ដែលទិសដៅនោះ មានលំហូរពីគ្រូទៅសិស្ស | លំហូរនៃព័ត៌មាន មានចលនានៅក្នុងទិសដៅជាច្រើនផ្សេងៗគ្នា រវាងអ្នកសម្របសម្រួលនិងសិក្ខាកាម និងរវាងសមាជិកក្រុមនីមួយៗ |
| គ្រូបង្រៀនមានការព្រួយបារម្ភចំពោះការយល់ឃើញរបស់សិស្សទៅលើចម្លើយដែលត្រឹមត្រូវ | អ្នកសម្របសម្រួលលើកទឹកចិត្ត និងផ្តល់តម្លៃចំពោះទស្សនៈផ្សេងៗគ្នា |

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម

វគ្គបណ្តុះបណ្តាលភាគច្រើន ស្ថិតនៅក្នុងផ្នែកទី១ និងផ្នែកទី២ នៃសាលាអាជីវកម្មកសិកម្ម និងផ្តោតយកចិត្តទុកដាក់ទៅលើការរៀនសូត្រ ថាតើអាជីវកម្មទំនងនឹងទទួលបានជោគជ័យ (អាចអនុវត្តធ្វើទៅបាន និងទំនងជាចំណេញ) ដែរឬទេ មុនពេលដែលកសិករចាប់ផ្តើម ដោយពុំមែនក្រឡេកមើលទៅលើភាពជោគជ័យនៅពេលដែលធ្វើដំណើរបានពាក់កណ្តាលផ្លូវ ឬនៅចុងបញ្ចប់នៃវដ្តផលិតកម្ម នៅពេលដែលកសិករបានវិនិយោគទៅលើសហគ្រាសរួចទៅហើយនោះទេ។

### *ការអភិវឌ្ឍន៍កម្មវិធី សាលាអាជីវកម្មកសិកម្ម*



## ជំហាននៅក្នុងការគៀងគរសហគមន៍

ចំណុចខាងក្រោមនេះ បង្ហាញអំពីជំហានសំខាន់ៗមួយចំនួនក្នុងការផ្តល់ការតម្រង់ទិស និងគៀងគរសហគមន៍ សម្រាប់កម្មវិធីសាលាអាជីវកម្មកសិកម្ម ។ អ្នកសម្របសម្រួលគួរ៖

1 រៀបចំកិច្ចប្រជុំលើកកម្ពស់ការយល់ដឹងមួយនៅក្នុងភូមិ ដើម្បីរៀនសូត្រអំពីវិធីប្រសើរបំផុត ក្នុងការបង្កើតការយល់ដឹងក្នុងចំណោមសិក្ខាកាម អំពីគោលគំនិតរបស់វគ្គសាលាអាជីវកម្មកសិកម្ម។ វាអាចត្រូវការឱ្យមានកិច្ចប្រជុំលើកកម្ពស់ការយល់ដឹងលើសពីមួយ ដើម្បីឱ្យកសិករមានចំណាប់អារម្មណ៍ និងមានការលើកទឹកចិត្តឱ្យចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម។

2 កំណត់រកជនដែលមានឥទ្ធិពលដែលអាចជួយដល់អ្នក ក្នុងការរៀបចំកិច្ចប្រជុំលើកដំបូង។ ធានាថាជនទាំងនោះ មានការយល់ដឹងមូលដ្ឋានអំពីប្រយោជន៍នៃវគ្គសាលាអាជីវកម្មកសិកម្ម។ ប្រសិនបើអ្នកពុំមែនជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ ចូរអ្នកស្នើសុំជំនួយពីបុគ្គលផ្សព្វផ្សាយក្នុងមូលដ្ឋាន។

3 ចូរអនុញ្ញាតឱ្យប្រជាជនធ្វើការសាកសួរសំនួរទៅកាន់អ្នកដែលជាអ្នកសម្របសម្រួល។ ព្យាយាមជម្រុញឱ្យពួកគេចូលរួមនៅក្នុងការពិភាក្សា។ ពុំមែនកសិករគ្រប់រូប សុទ្ធសឹងតែនឹងមានចំណាប់អារម្មណ៍នោះទេ។ កសិករមួយចំនួនក៏អាចប្រឆាំងទៅនឹងគំនិតនៃការផ្តល់វគ្គបណ្តុះបណ្តាលបែបនេះដែរ។ ចូរស្តាប់ទស្សនៈរបស់មនុស្សគ្រប់រូប និងសម្រេចចិត្ត ថាតើមានមនុស្សគ្រប់គ្រាន់ដែលចាប់អារម្មណ៍ក្នុងការបង្កើតវគ្គសាលាអាជីវកម្មកសិកម្ម មួយដែរឬទេ។

4 ប្រសិនបើអ្នកទទួលបានការឆ្លើយតបជាវិជ្ជមានចំពោះជំហានទី៣ ចូរអ្នកស្នើឱ្យធ្វើការពិភាក្សាអំពីវគ្គសាលាអាជីវកម្មកសិកម្ម នៅឯកិច្ចប្រជុំសហគមន៍នៅក្នុងភូមិ។ សូមអញ្ជើញអាជ្ញាធរមូលដ្ឋានឱ្យចូលរួមជាផ្លូវការនៅក្នុងកិច្ចប្រជុំនេះ។ ទង្វើបែបនេះ ធ្វើឱ្យកិច្ចប្រជុំទទួលបាននូវឋានៈកាន់តែខ្ពង់ខ្ពស់ និងបង្ហាញថា អ្នកមានភាពម៉ឺងម៉ាត់ចំពោះអ្វីដែលអ្នកត្រូវនិយាយ។

5 ចូរសរសេរឈ្មោះ និងលេខទូរស័ព្ទទំនាក់ទំនងរបស់អ្នកដែលចូលរួម។ លើកទឹកចិត្តកសិករដែលមានចំណាប់អារម្មណ៍ពិតប្រាកដចំពោះវគ្គសាលាអាជីវកម្មកសិកម្ម។ ពួកគេអាចជា "ក្បាលម៉ាស៊ីន" ក្នុងការជម្រុញវគ្គសាលាអាជីវកម្មកសិកម្ម។

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណើរការវគ្គបណ្តុះបណ្តាលកសិករអំពីការធ្វើអាជីវកម្ម

| | |
|---|---|
| គ្រូបង្រៀនមានទំនាក់ទំនងផ្លូវការមួយជាមួយសិស្ស ដោយផ្អែកលើឋានៈជាគ្រូបង្រៀន | អ្នកសម្របសម្រួល ត្រូវបានចាត់ទុកថាមានឋានៈស្មើទៅនឹងសិក្ខាកាមដែលចូលរួម និងអភិវឌ្ឍន៍ទំនាក់ទំនង ដោយផ្អែកលើមូលដ្ឋាននៃទំនុកចិត្ត ការគោរព និង ឆន្ទៈ ក្នុងការបម្រើការងារជូន។ |

### *ជំនាញសម្របសម្រួល និងបច្ចេកទេសបណ្តុះបណ្តាល*

| | |
|---|---|
| **ត្រូវត្រៀមខ្លួនឱ្យរួចជាស្រេច** | អភិវឌ្ឍន៍ និងអនុវត្តផែនការបណ្តុះបណ្តាលរបស់អ្នកជាមុន |
| **ត្រូវមានភាពច្បាស់លាស់** | ត្រូវកំណត់ និងបញ្ជាក់អំពីគោលបំណងនៃវគ្គបណ្តុះបណ្តាលរបស់អ្នកឱ្យបានច្បាស់លាស់ មុនពេលផ្តល់វគ្គបណ្តុះបណ្តាល |
| **ត្រូវបង្ហាញការគោរព** | តាមរយៈជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរបស់អ្នក (តាមរយៈពាក្យសម្តី និងមិនមែនតាមរយៈពាក្យសម្តី) |
| **ត្រូវមានភាពរួសរាយរាក់ទាក់** | ក្នុងការឆ្លើយទៅនឹងសំនួរ និងទំនាក់ទំនង |
| **ត្រូវមានភាពស្មោះត្រង់** | តាមរយៈកាយវិការមួយដែលមានភាពវិជ្ជាជីវៈប្រកបដោយទំនុកចិត្ត |
| **លើកទឹកចិត្តឱ្យមានការចូលរួម** | លើកទឹកចិត្តសិក្ខាកាមដែលមានភាពស្ងប់ស្ងាត់ ឱ្យចែករំលែកគំនិតយោបល់នានា និងសួរសំនួរ ព្រមទាំងអនុញ្ញាតឱ្យសិក្ខាកាមនិយាយឱ្យបានច្រើន ដោយប្រើប្រាស់ ប្រភេទសំនួរបើកឱ្យបានញឹកញាប់ ជាជាងសំនួរដែលគ្រាន់តែតម្រូវឱ្យផ្តល់ចម្លើយថា បាទ ឬចាសទេ |
| **ធ្វើការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព** | ប្រើប្រាស់ពាក្យពេចន៍ និងទឹកសម្លេងដែលសាមញ្ញ និងសមស្រប - រក្សាទំនាក់ ទំនងក្រសែភ្នែក និងស្តាប់ដោយយកចិត្តទុកដាក់ទុក |
| **យកចិត្តទុកដាក់** | ដោះស្រាយចំពោះសេចក្តីត្រូវការ និងអារម្មណ៍របស់ក្រុម |
| **ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពេលវេលា** | ត្រូវធានាថា ផែនការវគ្គបណ្តុះបណ្តាលរបស់អ្នក ស្របទៅនឹងពេលវេលារបស់ក្រុម ដែលមាន |
| **ប្រើប្រាស់ពហុវិធីសាស្ត្រ** | ប្រើប្រាស់សម្ភារៈ និងឧបករណ៍បណ្តុះបណ្តាលពាក់ព័ន្ធផ្សេងៗគ្នាដើម្បីជួយក្នុងការបញ្ជូនសារ |
| **សង្ខេប** | សង្ខេបឡើងវិញអំពីចំណុចសិក្សារៀនសូត្រសំខាន់ៗ នៅចុងបញ្ចប់នៃវគ្គសិក្សា |

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការតៀងគរសហគមន៍

ឈ្មោះអ្នកសម្របសម្រួលវគ្គសាលាអាជីវកម្មកសិកម្ម ៖

________________________________________

ចូរគិតអំពីសំនួរខាងក្រោម និងសរសេរចម្លើយស្មោះត្រង់នៅក្នុងចន្លោះដែលផ្តល់ជូន៖

**ទម្រង់ទី១ ៖ ការយល់ដឹងអំពីសមត្ថភាពរបស់អ្នកសម្របសម្រួល**

១.១ តើខ្ញុំកំពុងខិតខំធ្វើអ្វី?

________________________________________

________________________________________

១.២ តើចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្ញុំមានអ្វីខ្លះ?

________________________________________

________________________________________

១.៣ តើអ្នកដទៃយល់ឃើញចំពោះខ្ញុំដូចម្តេចដែរ?

________________________________________

________________________________________

១.៤ តើខ្ញុំមានជំនឿដូចម្តេចដែរ ចំពោះលទ្ធភាពរបស់មនុស្សក្នុងការផ្លាស់ប្តូរ?

________________________________________

________________________________________

១.៥ តើសកម្មភាពរបស់ខ្ញុំ ឆ្លុះបញ្ចាំងអំពីជំនឿរបស់ខ្ញុំដែរឬទេ?

________________________________________

________________________________________

១.៦ តើខ្ញុំមានបញ្ហាក្នុងការធ្វើការងារជាមួយអ្នកដទៃដែរឬទេ?

________________________________________

________________________________________

១.៧ តើខ្ញុំបានត្រៀមខ្លួនរួចជាស្រេច ដើម្បីចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម ហើយឬនៅ?

________________________________________

________________________________________

## *ដំបូន្មានសម្រាប់ការគៀងគរសហាគមន៍ប្រកបដោយប្រសិទ្ធភាព*

- ពង្រឹងបន្ថែមទៅលើបទពិសោធន៍ក្នុងមូលដ្ឋាន៖ អ្នកត្រូវជឿថា ប្រជាជនក្នុងមូលដ្ឋានអាចរួបរួមគ្នា ដើម្បីបង្កើតឱ្យមាននូវការផ្លាស់ប្តូរជាវិជ្ជមានមួយ សម្រាប់ខ្លួនពួកគេនិងសហាគមន៍ដែលពួកគេរស់នៅ។

- ស្វែងរកមេដឹកនាំផ្លូវការក្នុងមូលដ្ឋាន៖ ជាធម្មតា មេដឹកនាំក្នុងមូលដ្ឋានមានទំនាក់ទំនងល្អនៅក្នុងសហាគមន៍ យល់អំពីវគ្គសាលាអាជីវកម្មកសិកម្ម គឺជាអ្វី និងមានឆន្ទៈក្នុងការគាំទ្រដល់វគ្គបែបនេះ។ ជាទូទៅ មេដឹកនាំក្នុងមូលដ្ឋាន អាចជាមេភូមិ ប្រធានក្រុម ព្រឹទ្ធាចារ្យ ព្រះសង្ឃ ឬ អាចារ្យ។ល។ និងមានតួនាទីដឹកនាំមួយចំនួន ដែលគេទទួលស្គាល់ "ជាផ្លូវការ"។ ពួកគេយល់អំពីសេចក្តីត្រូវការ និងឱកាសរបស់សហាគមន៍ និងទទួលបានការជឿទុកចិត្ត និងការគោរពពីកសិករឈានមុខគេ អ្នកភូមិសមាជិកសហាគមន៍។ល។ ប៉ុន្តែ ក៏មិនត្រូវភ្លេចមេដឹកនាំយុវជនឡើយ អាស្រ័យដោយពួកគេតំណាងឱ្យគំនិតរបស់មនុស្សជំនាន់ក្រោយ។

- ស្វែងរកមេដឹកនាំក្នុងមូលដ្ឋានដែលមានលក្ខណៈមិនផ្លូវការ៖ មេដឹកនាំដែលមានលក្ខណៈមិនផ្លូវការ គឺជាបុគ្គលទាំងឡាយដូចជា កសិករដែលបានចូលរួមតាំងពីដំបូង ឬបុគ្គលដែលគេគោរព និងស្តាប់មតិយោបល់របស់ បុគ្គលទាំងនោះនៅក្នុងសហាគមន៍មូលដ្ឋាន។ ពួកគេគឺជាអ្នកដែលនឹងធ្វើឱ្យអ្វីៗលេចជារូបរាងឡើងនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម។

- ស្តាប់ ៖ ដើម្បីកសាងទំនាក់ទំនង អ្នកចាំបាច់ត្រូវស្តាប់។

- ត្រូវមានភាពអត់ធ្មត់៖ ការប្រមូលប្រជាជនឱ្យជួបជុំគ្នាលើកដំបូង នៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម គឺជាដំណើរការមួយដែលមានភាពយឺតយ៉ាវយ៉ាងខ្លាំង។ ដូច្នេះ អ្នកត្រូវយល់អំពីល្បឿននៃរបៀបដែលប្រជាជនក្នុងមូលដ្ឋានរៀបចំការងាររបស់ពួកគេ និងអនុវត្តទៅតាមរបៀបរបបការងារក្នុងមូលដ្ឋាន។

## *សំនួរដែលត្រូវសួរមុនពេលកិច្ចប្រជុំ សាលាអាជីវកម្មកសិកម្ម លើកដំបូង*

**ការវាយតម្លៃទៅលើឥរិយាបថរបស់អ្នកសម្របសម្រួល៖** ដើម្បីឱ្យក្លាយជាអ្នកសម្របសម្រួលម្នាក់ដ៏ល្អ អ្នកត្រូវមានឥរិយាបថត្រឹមត្រូវ។ ចូរអានសំនួរនៅទំព័របន្ទាប់ និងឆ្លើយសំនួរទាំងនោះនៅក្នុងចន្លោះដែលផ្តល់ជូន។

**ទម្រង់វាយតម្លៃឥរិយាបថរបស់អ្នកសម្របសម្រួលវគ្គសាលាអាជីវកម្មកសិកម្ម ៖**

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការកៀរគរសហគមន៍

៣.៣ តើមានមនុស្សប៉ុន្មាននាក់ ដែលខ្ញុំគិតថានឹងមានការប្តេជ្ញាចិត្តចូលរួមក្នុងវគ្គសាលាអាជីវកម្មកសិកម្ម?

________________________________________

________________________________________

៣.៤ តើពេលណា ទើបជាកាលបរិច្ឆេទមួយដ៏ល្អ សម្រាប់រៀបចំកិច្ចប្រជុំលើកដំបូងនេះ?

________________________________________

________________________________________

៣.៥ តើពេលវេលាណាមួយ ទើបជាពេលវេលាដ៏ល្អនៅក្នុងថ្ងៃនោះ? តើខ្ញុំធ្វើការកំណត់ដោយរបៀបណា?

________________________________________

________________________________________

៣.៦ តើទីកន្លែងណាមួយដែលប្រសើរបំផុត សម្រាប់រៀបចំកិច្ចប្រជុំនេះ?

________________________________________

________________________________________

៣.៧ តើខ្ញុំអាចប្រាប់មនុស្សគ្រប់គ្នាអំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំដោយរបៀបណា?

________________________________________

________________________________________

៣.៨ តើខ្ញុំគួរផ្តល់ព័ត៌មានតាមផ្ទះចំនួនប៉ុន្មានដង ដើម្បីធានាថាប្រជាជនដឹងអំពីកិច្ចប្រជុំនេះ?

________________________________________

________________________________________

៣.៩ តើខ្ញុំត្រូវរៀបចំសម្រាប់កិច្ចប្រជុំនេះ ដោយរបៀបណា?

________________________________________

________________________________________

**ទម្រង់ទី៤ ៖ ការបង្ហាញអំពីវគ្គសាលាអាជីវកម្មកសិកម្ម នៅក្នុងសហគមន៍**

៤.១ តើអ្វីខ្លះជាចំណុចចម្បងៗដែលខ្ញុំត្រូវធ្វើការប្រាស្រ័យទាក់ទងអំពីវគ្គសាលាអាជីវកម្មកសិកម្ម?

________________________________________

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

**ទម្រង់ទី២ ៖ របៀបបង្កើតទំនាក់ទំនងលើកដំបូងនៅក្នុងភូមិ**

២.១ តើខ្ញុំអាចទាក់ទងនរណាដំបូងគេបង្អស់ ដើម្បីនិយាយអំពីវគ្គសាលាអាជីវកម្មកសិកម្ម ក្នុងលក្ខណៈមួយបែបមិនផ្លូវការ?

______________________________________________________________

______________________________________________________________

២.២ តើខ្ញុំនឹងត្រូវនិយាយអ្វីខ្លះនៅក្នុងកិច្ចសន្ទនារបស់ខ្ញុំ?

______________________________________________________________

______________________________________________________________

២.៣ តើជនទំនាក់ទំនងទាំងនេះ ទំនងនឹងឯកភាព ឬមិនឯកភាពទៅនឹងគោលគំនិតនៃវគ្គ សាលាអាជីវកម្មកសិកម្ម?

______________________________________________________________

______________________________________________________________

២.៤ តើខ្ញុំនឹងត្រូវនិយាយជាមួយមនុស្សប៉ុន្មាននាក់?

______________________________________________________________

______________________________________________________________

២.៥ តើកិច្ចសន្ទនានេះ នឹងត្រូវចំណាយរយៈពេលយូរប៉ុណ្ណា?

______________________________________________________________

______________________________________________________________

**ទម្រង់ទី៣ ៖ ការរៀបចំកិច្ចប្រជុំលើកដំបូង**

៣.១ តើខ្ញុំគិតថា នឹងមានមនុស្សប៉ុន្មាននាក់ មកចូលរួមនៅក្នុងកិច្ចប្រជុំនេះ?

______________________________________________________________

______________________________________________________________

៣.២ តើមានមនុស្សប៉ុន្មាននាក់ដែលខ្ញុំគិតថា គ្រាន់តែចាប់អារម្មណ៍ធម្មតា ប៉ុន្តែ ពុំមានការការប្តេជ្ញាចិត្តចូលរួម?

______________________________________________________________

______________________________________________________________

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

### *ការកំណត់អត្តសញ្ញាណ និងការជ្រើសរើសកសិករ*

ភាពបត់បែន គឺជាធាតុផ្សំចម្បងនៃវគ្គសាលាអាជីវកម្មកសិកម្ម។ កម្មវិធីសាលាអាជីវកម្មកសិកម្ម អាចធ្វើការកែសម្រួលទៅតាមស្ថានភាពក្នុងមូលដ្ឋាន ភាពចាំបាច់របស់កសិករ និងពិពិធភាពរបស់ពួកគេ។ គេគួរធ្វើការគូសបញ្ជាក់ថា ស៊ីណារីយ៉ូខាងក្រោម ពុំមែនជាស៊ីណារីយ៉ូដោយឡែកឡើយ ហើយស៊ីណារីយ៉ូទាំងនេះ ទំនងជាស្ថានភាពដែលកសិករអាចមានទំនាក់ទំនងជាមួយប្រភេទគំរូលើសពីមួយ។

**ស៊ីណារីយ៉ូទី១៖** សិក្ខាកាមមិនធ្លាប់ត្រូវបានបង្កើតជាក្រុម និងពុំមានចំណេះដឹងអំពីប្រភេទសហគ្រាសណាមួយ ដែលពួកគេត្រូវផ្តោតការយកចិត្តទុកដាក់ឡើយ។

**ស៊ីណារីយ៉ូទី២៖** សិក្ខាកាមមិនធ្លាប់ត្រូវបានបង្កើតជាក្រុម ប៉ុន្តែសមាជិកដឹងថាតើពួកគេត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើសហគ្រាសប្រភេទណា។

**ស៊ីណារីយ៉ូទី៣៖** សិក្ខាកាមធ្លាប់ត្រូវបានបង្កើតជាក្រុមរួចទៅហើយ ប៉ុន្តែពួកគេពុំមានចំណេះដឹងថាត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើសហគ្រាសណាមួយឡើយ។

**ស៊ីណារីយ៉ូទី៤៖** សិក្ខាកាមធ្លាប់ត្រូវបានបង្កើតជាក្រុម និងបានជ្រើសរើសសហគ្រាសមួយរួចទៅហើយ។

### *លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសកសិករ*

ចូរផ្តល់ព័ត៌មានជូនដល់មេដឹកនាំសហគមន៍ អំពីលក្ខណៈវិនិច្ឆ័យដូចខាងក្រោម សម្រាប់ជ្រើសរើសសិក្ខាកាមឱ្យចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម។ ចូរផ្តល់ឱ្យប្រធានក្រុមនូវឯកសារ ឬផ្ទាំងក្រដាសមួយសន្លឹកដែលមានសរសេររាយនាមអំពីលក្ខណៈវិនិច្ឆ័យ ដើម្បីឱ្យពួកគេអាចពិនិត្យឡើងវិញទៅលើលក្ខណៈវិនិច្ឆ័យទាំងនោះនៅពេលដែលពួកគេទំនេរ និងជ្រើសរើសសិក្ខាកាមដែលមានល័ក្ខខ័ណ្ឌស្របទៅនឹងលក្ខណៈវិនិច្ឆ័យទាំងនោះ។

- មេដឹកនាំ និងកសិករសំខាន់ៗនៅក្នុងក្រុមមួយដែលកំពុងមានដំណើរការ និងមានការគ្រប់គ្រងល្អ ដែលចាប់អារម្មណ៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងការតភ្ជាប់ទំនាក់ទំនងទីផ្សារសម្រាប់កសិករខ្នាតតូច។
- អាចជាអ្នកតំណាងក្រុមធំៗដែលអាចផ្តល់ព័ត៌មានបន្តអំពីវគ្គសាលាអាជីវកម្មកសិកម្ម និងបញ្ចូលក្រុមដែលមាន លក្ខណៈទូលំទូលាយជាងនេះទៅក្នុងផែនការសហគ្រាស ប្រសិនបើចាំបាច់។

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

______________________________________________

៩.២ តើត្រូវធ្វើបទបង្ហាញរបស់ខ្ញុំ ដោយរបៀបណា?

______________________________________________

______________________________________________

៩.៣ តើខ្ញុំនឹងត្រូវឆ្លើយតបទៅនឹងសំនួរនានា ដោយរបៀបណា?

______________________________________________

______________________________________________

៩.៤ តើខ្ញុំត្រូវបញ្ចប់កិច្ចប្រជុំនេះ ដោយរបៀបណា?

______________________________________________

______________________________________________

៩.៥ តើខ្ញុំត្រូវរៀបចំកិច្ចប្រជុំលើសពីមួយដងដែរឬទេ? ប្រសិនបើដូច្នេះ តើខ្ញុំត្រូវរៀបចំកិច្ចប្រជុំចំនួនប៉ុន្មានដង?

______________________________________________

______________________________________________

៩.៦ ប្រសិនបើខ្ញុំត្រូវរៀបចំកិច្ចប្រជុំដទៃទៀត តើខ្ញុំត្រូវរៀបចំផែនការកិច្ចប្រជុំទាំងនោះ ដោយរបៀបណា?

______________________________________________

______________________________________________

៩.៧ តើខ្ញុំត្រូវរៀបចំបញ្ជីរាយនាមឈ្មោះអ្នកដែលមានឆន្ទៈក្នុងការចូលរួមសកម្ម នៅក្នុងវគ្គសាលាអាជីវកម្មកសិកម្មដែរឬទេ? តើខ្ញុំត្រូវធ្វើការងារនេះ ដោយរបៀបណា?

______________________________________________

______________________________________________

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការតៀ្រងគរសហគមន៍

### *គុណសម្បត្តិ និងគុណវិបត្តិនៃការចូលរួមនៅក្នុងក្រុម*

ចូរពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិខាងក្រោម ជាមួយក្រុម ឬមេដឹកនាំក្រុមសហគ្រាស ដើម្បីបង្ហាញពួកគេអំពីប្រយោជន៍ទូទៅនៃការធ្វើការងារជាក្រុម។

- កសិករអាចទទួលបានប្រាក់ចំណេញកាន់តែច្រើន តាមរយៈការធ្វើការងារជាក្រុម ជាជាងការធ្វើការងារជាលក្ខណៈបុគ្គល ឧទាហរណ៍ដូចជា ក្នុងករណីការទិញសម្ភារៈកសិកម្ម ការដឹកជញ្ជូន និងការស្វែងរកទីផ្សារ សម្រាប់ផលិតផលរបស់ពួកគេ ដើម្បីទទួលបានតម្លៃកាន់តែប្រសើរ។
- កសិករអាចចែករំលែកបទពិសោធន៍ និងចំណេះដឹង។
- កសិករអាចជួយគ្នាទៅវិញទៅមក (ឧ. ផ្លាស់ប្តូរកម្លាំងពលកម្មគ្នាទៅវិញទៅមក)។
- គេអាចចែករំលែកធនធាន និងប្រយោជន៍រវាងមនុស្សជាច្រើននាក់ ជាជាងការពឹងផ្អែកទៅលើបុគ្គលដែលមានទ្រព្យធន ឬមានអំណាចមួយចំនួនតូច។
- វាមានភាពគួរឱ្យទាក់ទាញជាង និងមានប្រសិទ្ធភាពខ្ពស់ជាង សម្រាប់សេវាគាំទ្រមួយចំនួនដូចជា សេវាឥណទាន និងអ្នកផ្តល់សេវាផ្សព្វផ្សាយក្នុងការធ្វើការងារជាមួយក្រុម។
- កសិករមួយក្រុម អាចនិយាយក្នុងសម្លេងមួយដែលមានភាពកាន់តែរឹងមាំ។
- កសិករទាំងបុរស និងស្ត្រីអាចទទួលបានជំនាញដឹកនាំ។
- សមាហរណកម្មសង្គម ជួយធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងបណ្តាញអាជីវកម្ម។

**គុណវិបត្តិ៖**

- ការពិភាក្សាជាក្រុម និងការធ្វើសេចក្តីសម្រេចចិត្ត ត្រូវប្រើប្រាស់ពេលវេលាច្រើន។
- អាចខ្វះជំនាញ និងចំណេះដឹងលើការដឹកនាំ។
- កសិករមួយចំនួនមិនអនុវត្តតាមវិន័យ។
- អ្នកខ្លះធ្វើការងារច្រើន ដោយឡែក អ្នកខ្លះទៀតមិនធ្វើការងារអ្វីទាល់តែសោះ។
- សមាជិកមួយចំនួន អាចជា"អ្នកដែលមានគំនិតមិនស្មើភាព" ដែលរួមចំណែកផ្តល់វិភាគទាន តិចតួច ប៉ុន្តែរំពឹងទទួលបានផលតបស្នងស្មើគេឯង។
- ការផ្តល់វិភាគទានរួមចំណែកស្មើភាពគ្នា អាចមានការលំបាក។
- អាចពុំមានមូលធនគ្រប់គ្រាន់ក្នុងការចាប់ផ្តើមសហគ្រាស។

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

- សហគ្រិនជាបុគ្គលឈានមុខ ដែលមានឥទ្ធិពលក្នុងលក្ខណៈមួយបែបមិនផ្លូវការ ទៅលើកសិករដែលនៅជុំវិញពួកគេ។
- ដើម្បីឱ្យការបណ្តុះបណ្តាលមានប្រសិទ្ធភាពខ្ពស់ ល្អបំផុតគួរមានសិក្ខាកាមចន្លោះពី ១៥-២០នាក់ បើទោះបីជាសិក្ខាកាមអាចមានចំនួនតិចជាងនេះ អាស្រ័យទៅតាមស្ថានភាពក៏ដោយ។
- បុរស ឬស្ត្រីនៅក្នុងគ្រួសារដែលមានពេលវេលា និងចំណាប់អារម្មណ៍ក្នុងការចូលរួមនៅក្នុងក្រុម និង/ឬការធ្វើផែនការអាជីវកម្មលក្ខណៈបុគ្គលអាចចូលរួមបាន ហើយពួកគេគួរចូលរួមគ្រប់វគ្គទាំងអស់។
- តួអង្គដទៃទៀតនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ដែលអាចត្រូវបានជ្រើសរើសរួមមាន (អ្នកប្រមូល ឈ្មួញ ឬ អ្នក ផ្គត់ផ្គង់សម្ភារៈកសិកម្ម)
- កសិករខ្នាតតូច ដែលមានដី និងធនធានសម្រាប់ផលិតកម្មកសិកម្ម។
- សិក្ខាកាមដែលចេះអក្សរ និងលេខនព្វន្ត។
- អ្នកដែលមានគំនិត និងគោលបំណងសហគ្រាសស្រដៀងគ្នា។
- អ្នកដែលមានចំណាប់អារម្មណ៍ពិតប្រាកដទៅលើការធ្វើកសិកម្មសម្រាប់ផ្គត់ផ្គង់ទៅឱ្យទីផ្សារ ដើម្បីទទួលបាន ប្រាក់ចំណេញ។
- សិក្ខាកាមដែលចាប់អារម្មណ៍នៅក្នុងការរៀបចំផែនការសម្រាប់សកម្មភាពក្រុម ដូចជាការទិញ ការលក់ ការដឹកជញ្ជូន ការបន្ថែមតម្លៃ និងកិច្ចសន្យា។
- អ្នកដែលមានចំណាប់អារម្មណ៍ក្នុងការប្តេជ្ញាចិត្តចូលរួមនៅក្នុងកាលវិភាគកម្មវិធីសាលាអាជីវកម្មកសិកម្ម។
- អ្នកដែលមានចំណាប់អារម្មណ៍ចំពោះវិធីសាស្ត្រកសិកររៀនសូត្រពីគ្នាទៅវិញទៅមក នៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម។
- អ្នកដែលមានភាពស្មោះត្រង់ និងគួរឱ្យជឿជាក់ទុកចិត្តបាន។

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

3 មុនពេលរៀបចំបង្កើតវគ្គសាលាអាជីវកម្មកសិកម្ម តើអ្នកចាំបាច់ត្រូវគិតគូរពិចារណាទៅលើកត្តាភាសារ កុលសម្ព័ន្ធ ឬកត្តាវប្បធម៌ ដែរឬទេ? ប្រសិនបើអ្នកត្រូវពិចារណា តើកត្តាទាំងនោះមានអ្វីខ្លះ?

______________________________________________

______________________________________________

______________________________________________

4 តើកត្តាមួយចំនួនដូចជា ទំហំផ្ទៃដីដាំដុះ ឬចំនួនសត្វពាហនៈ មានសារៈសំខាន់ដែរឬទេ? តើកសិករខ្នាតធំនឹងគ្របដណ្តប់ទៅលើកសិករខ្នាតតូចដែរឬទេ? តើកត្តាទាំងនេះ អាចត្រូវបានយកមកពិចារណាយ៉ាងដូចម្តេច?

______________________________________________

______________________________________________

______________________________________________

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

**ដំណោះស្រាយមួយចំនួន អាចរួមមានដូចជា៖**

- រៀបចំកិច្ចប្រជុំដែលមានការសម្របសម្រួលល្អ ដោយពុំចំណាយពេលយូរ។
- អនុញ្ញាតឱ្យកសិករធ្វើការជ្រើសរើសប្រធានបទ និងកាលវិភាគដោយខ្លួនឯង។
- ត្រូវមានការកំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។
- ផ្តល់ការបណ្តុះបណ្តាលជូនដល់ប្រធានក្រុម ដើម្បីឱ្យពួកគេអាចធ្វើការងាររបស់ពួកគេបានល្អ។
- កំណត់ទណ្ឌកម្មសម្រាប់អ្នកដែលមិនបានបំពេញតាមតួនាទី។
- អនុញ្ញាតឱ្យសមាជិកផ្សេងៗគ្នាផ្តល់វិភាគទានក្នុងទំហំទ្រង់ទ្រាយផ្សេងៗគ្នា។
- រៀបចំឱ្យមានគោលនយោបាយច្បាស់លាស់មួយ សម្រាប់បែងចែកប្រយោជន៍ ដោយយោងទៅតាមការរួម ចំណែករបស់បុគ្គលនីមួយៗ។
- ពិនិត្យស្វែងរកប្រភពមូលធនពីខាងក្រៅ។

## *វចនាសម្ព័ន្ធរបស់ក្រុម សាលាអាជីវកម្មកសិកម្ម*

ប្រសើរបំផុត គួរពិគ្រោះយោបល់ជាមួយមេដឹកនាំសហគមន៍ និងកសិករសំខាន់ៗ មុនពេលកិច្ចប្រជុំលើកដំបូង និងសរសេរចម្លើយសម្រាប់ឆ្លើយតបទៅនឹងបញ្ហារសើបផ្នែកវប្បធម៌ដូចខាងក្រោម

1 តើបុរស និងស្ត្រី គួរស្ថិតនៅក្នុងក្រុមតែមួយដែរឬទេ? ប្រសិនបើពួកគេ មិនគួរស្ថិតនៅក្នុងក្រុមតែមួយ តើហេតុអ្វី?

________________________________________

________________________________________

________________________________________

2 ប្រសិនបើអ្នករៀបចំឱ្យមានក្រុមមួយ ដែលមានសមាសភាពចូលរួមទាំងបុរស និងស្ត្រី តើបុរសនឹងគ្របដណ្តប់ទៅលើស្ត្រីដែរឬទេ? ប្រសិនបើបុរសមានការគ្របដណ្តប់ តើគេអាចកាត់បន្ថយបញ្ហាបែបនេះ បានដោយរបៀបណា?

________________________________________

________________________________________

________________________________________

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

ទម្រង់មេរៀនខាងក្រោមនេះ គឺជាសេចក្តីណែនាំមួយសម្រាប់ជួយដល់អ្នកសម្របសម្រួលៈ

## មេរៀនទី១ ៖ ការណែនាំអំពីវគ្គនិងការវិភាគទៅលើសេចក្តីត្រូវការបណ្តុះបណ្តាល



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គសិក្សានេះ សិក្ខាកាមនឹងយល់អំពីគោលគំនិតនៃវគ្គសាលាអាជីវកម្មកសិកម្ម និងដឹងអំពីវិធីចាប់ផ្តើមវគ្គសាលាអាជីវកម្មកសិកម្ម។



២ម៉ោង

| | | |
|---|---|---|
| ១ | ការណែនាំដោយអាជ្ញាធរមូលដ្ឋាន៖ ចូរអញ្ជើញអាជ្ញាធរថ្នាក់ឃុំ ឬថ្នាក់ភូមិ ដើម្បីជួយណែនាំរូបអ្នកឱ្យក្រុមគោលដៅបានស្គាល់។ | អាហារសម្រន់ សម្ភារៈ |
| ២ | គោលគំនិតនៃវគ្គសាលាអាជីវកម្មកសិកម្ម ៖ ពន្យល់ទៅកាន់សិក្ខាកាមថា អ្នកមានបំណងចង់ណែនាំអំពីគោលគំនិតនៃវគ្គបណ្តុះបណ្តាលកសិករ អំពីសាលាអាជីវកម្មកសិកម្ម (សាលាអាជីវកម្មកសិកម្ម) ជូនដល់ពួកគេ។ ចូរនិយាយថា គោលបំណងនៃវគ្គសាលាអាជីវកម្មកសិកម្ម គឺដើម្បីជួយដល់ពួកគេ ក្នុងការជ្រើសរើសសហគ្រាសមួយដែលធ្វើឱ្យពួកគេទទួលបានប្រាក់ចំណេញ បង្កើតផែនការអាជីវកម្មលក្ខណៈបុគ្គល និងលក្ខណៈជាក្រុម ត្រួតពិនិត្យការអនុវត្តផែនការ និងវាយតម្លៃសហគ្រាសនៅពេលបញ្ចប់ផែនការ ដើម្បីពិនិត្យមើលថា តើពួកគេគួរ ឬមិនគួរអនុវត្តផែនការនេះជាថ្មីម្តងទៀត (ចូរបង្ហាញពួកគេអំពីវដ្តនៃអាជីវកម្មកសិកម្មខាងក្រោមនៅលើផ្ទាំងក្រដាសធំមួយ)។ ចូរធ្វើការគូសបញ្ជាក់ថា វដ្តនេះមានចលនា វិលទៅវិលមក ហើយវាមានសារៈប្រយោជន៍សម្រាប់រៀបចំអាជីវកម្មនៅក្នុងរដូវកាលនីមួយៗ។ ចូរជម្រាបពួកគេឱ្យបានដឹងថា កម្មវិធីសាលាអាជីវកម្មកសិកម្ម ត្រូវបានធ្វើឡើងតាមរយៈ ការរៀបចំកិច្ចប្រជុំទៀងទាត់ | ផ្ទាំងក្រដាសធំ បង្ហាញអំពីវដ្តនៃអាជីវកម្មកសិកម្ម ដែលត្រូវបានរៀបចំទុកជាមុន។ |

## ផ្នែកទី២ ៖ ការតម្រង់ទិស និងការគៀងគរសហគមន៍

### បញ្ជីរាយនាមសិក្ខាកាម៖

បញ្ចប់ការត្រួតពិនិត្យរបស់អ្នក ដោយសរសេរឈ្មោះ និងព័ត៌មានលម្អិតរបស់សិក្ខាកាមដែលអាចចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម នៅក្នុងទម្រង់ខាងក្រោម៖

| ឈ្មោះបុគ្គលដែលចាប់អារម្មណ៍វគ្គ សាលាអាជីវកម្មកសិកម្ម | ភេទ | អាយុ | ឈ្មោះប្តីឬប្រពន្ធ | ចេះអាន ចេះសរសេរ ចេះលេខនព្វន្ត | ទំហំផ្ទៃដី | ព័ត៌មានទំនាក់ទំនងលម្អិត |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ផែនការបុគ្គល និងផែនការក្រុមរបស់ពួកគេ បន្ទាប់មក ត្រូវធ្វើការត្រួតពិនិត្យ វឌ្ឍនភាពរបស់ពួកគេ ដោយធៀបទៅនឹងផែនការទាំងនេះ និង ធ្វើការកែសម្រួលក្នុងករណីចាំបាច់ដើម្បី សម្រេចគោលដៅរបស់ពួកគេ។<br><br>**ជំហានទី៤ - ការវាយតម្លៃ និងការធ្វើផែនការថ្មី៖** ត្រូវបានធ្វើឡើងក្រោយរដូវកាលផលិត។ កសិករត្រូវធ្វើការវាយតម្លៃទៅលើអ្វីដែលមានដំណើរការប្រព្រឹត្តទៅបានល្អ និងអ្វីដែលមានដំណើរការប្រព្រឹត្តទៅមិនសូវបានល្អ។ ពួកគេត្រូវធ្វើការប៉ាន់ប្រមាណ ជាថ្មីឡើងវិញទៅលើអាជីវកម្មជាក្រុមរបស់ពួកគេ និងធ្វើផែនការកសិដ្ឋានដែលមានលក្ខណៈជាបុគ្គល និងផែនការជាក្រុមជាថ្មីឡើងវិញ សម្រាប់រដូវកាលបន្ទាប់។ | |
| ៤ | **ការជ្រើសរើសសហគ្រាសមួយសម្រាប់វគ្គ សាលាអាជីវកម្មកសិកម្ម:**<br>ចូរសាកសួរទៅកាន់សិក្ខាកាមអំពីសកម្មភាពបុគ្គល និងសកម្មភាពក្រុមទាក់ទងទៅនឹងវិស័យកសិកម្ម ដែលពួកគេកំពុងធ្វើនាពេលបច្ចុប្បន្ន ក្នុងកម្រិតវិសាលភាពនៃការធ្វើពាណិជ្ជកម្ម (ផលិតផលសម្រាប់លក់)។ ចូរសរសេរវាយនាមសកម្មភាពទាំងនោះ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ចូរសួរសំនួរទៅកាន់សិក្ខាកាមអំពីសហគ្រាសនីមួយៗ ដោយប្រើប្រាស់ សំនួរនាំមុខមួយចំនួន ដូចជា៖ តើជាអ្វី, នរណា, កន្លែងណា, ហេតុអ្វី, នៅពេលណា, ដោយរបៀបណា, ច្រើនប៉ុណ្ណា។ សូមកុំភ្លេចស្វែងរកព័ត៌មានលម្អិតអំពីសំនួរដែលសួរអំពី តើច្រើនប៉ុណ្ណា ព្រោះតួលេខទាំងនេះអាចជួយដល់យើងក្នុងការណែនាំអន្តរាគមន៍បរិមាណវិស័យមួយចំនួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់ពួកគេ នៅពេលរៀបចំផែនការសកម្មភាព និងផែនការថវិកានៅពេលបន្ទាប់ ក្នុងវគ្គសាលាអាជីវកម្មកសិកម្ម។<br><br>សួរទៅកាន់សិក្ខាកាមនៅក្នុងក្រុមតូចៗ ដោយបំបែកពួកគេទៅតាមភេទផ្សេងៗគ្នា ដើម្បីជ្រើសរើសសហគ្រាសមួយ សម្រាប់រដូវកាលបន្ទាប់ដែលពួកគេចង់ឱ្យវគ្គបណ្តុះបណ្តាលសាលាអាជីវកម្មកសិកម្ម ធ្វើការផ្តោតយកចិត្តទុកដាក់ទៅលើសហគ្រាសនោះ។ ចូរប្រាប់ពួកគេថា យើងប្រើប្រាស់ក្រុមដែលមានភេទខុសគ្នាដើម្បីធានាថា គំនិតរបស់បុរស និងស្ត្រី ត្រូវបានគេស្តាប់ឮ ដោយពុំមានភេទណាមួយគ្របដណ្តប់ទៅលើភេទដទៃ។ | <br>លំហាត់ ១.២ និង ១.៣ នៃសៀវភៅ លំហាត់៖<br>បញ្ជីវាយនាម<br>សហគ្រាស |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ដែលមានរយៈពេល ២-៣ ម៉ោង រៀងរាល់សប្តាហ៍ ដែលកិច្ចប្រជុំទាំងនេះ ផ្តល់ការណែនាំជូនដល់កសិករតាមរយៈវដ្តនៃអាជីវកម្មកសិកម្ម។ | |

**វដ្តនៃអាជីវកម្មកសិកម្ម៖** ចូររៀបចំដ្យាក្រាមខាងក្រោមនៅលើផ្ទាំងក្រដាសធំមួយ។ ចូរពន្យល់ថា ការបណ្តុះបណ្តាល និងប្រធានបទនៃវគ្គសាលាអាជីវកម្មកសិកម្ម ត្រូវបានរៀបចំឡើងជុំវិញជំហានចំនួន៤ ដូចខាងក្រោម៖

**វដ្តនៃអាជីវកម្មកសិកម្ម**




| | | |
|---|---|---|
| ៣ | **ជំហានទី១ - ការវិនិច្ឆ័យ៖** ត្រូវបានធ្វើឡើងមុនពេលចាប់ផ្តើមរដូវកាលផលិត។ នៅក្នុងកម្មវិធីផ្នែកនេះ៖ សិក្ខាកាមត្រូវវិភាគទៅលើស្ថានភាពបច្ចុប្បន្នរបស់ពួកគេ និងកំណត់រកអន្តរាគមន៍ដែលអាចធ្វើទៅបាន ព្រមទាំងសេចក្តីត្រូវការបណ្តុះបណ្តាល។ ពួកគេត្រូវរៀបចំបង្កើតសាលាអាជីវកម្មកសិកម្ម និងរៀនសូត្រអំពីរបៀបធ្វើឱ្យវាមានដំណើរការទៅបាន។ កសិករ ត្រូវឯកភាពទៅលើប្រធានបទនៅក្នុងកម្មវិធី ដែលពួកគេចង់សិក្សារៀនសូត្រ និងតើពួកគេត្រូវរៀបចំកិច្ចប្រជុំនៅពេលណា។<br><br>**ជំហានទី២ - ការរៀបចំផែនការ៖** ជួយណែនាំដល់សិក្ខាកាមឱ្យកំណត់គោលដៅសម្រាប់កសិដ្ឋាន និងក្រុមរបស់ពួកគេ និងបន្ទាប់មក ត្រូវរៀបចំបង្កើតផែនការកសិដ្ឋានដែលមានលក្ខណៈជាបុគ្គល និងផែនការជាក្រុម ដើម្បីសម្រេចគោលដៅរបស់ពួកគេ។<br><br>**ជំហានទី៣ - ការអនុវត្ត និងការត្រួតពិនិត្យ៖** ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃរដូវកាលផលិត។ នៅក្នុងកម្មវិធីផ្នែកនេះ៖ សិក្ខាកាមត្រូវអនុវត្ត | <br>លំហាត់ ១.១៖ វដ្តនៃអាជីវកម្ម កសិកម្ម និង ពេលវេលានៃវគ្គសាលាអាជីវកម្មកសិកម្ម |

| | | |
|---|---|---|
| | បណ្តាល។ ចូរចែកជូនសំណើបញ្ជីវាយនាមប្រធានបទសម្រាប់វគ្គសាលាអាជីវកម្មកសិកម្ម ដែលត្រូវបានចម្លងចេញពីតារាង មាតិកាលំហាត់ ១.៥។ ចូរពន្យល់អំពីប្រធានបទនីមួយៗជូនដល់ក្រុមទាំងមូល។<br><br>បែងចែកសិក្ខាកាមជាក្រុមដែលមានភេទដូចគ្នា ដែលក្រុមនីមួយៗមានបុរសចំនួន៣រូប និងស្ត្រីចំនួន៣រូប និងស្នើឱ្យក្រុមតូចៗនីមួយៗពិភាក្សាអំពីប្រធានបទនានា និងជ្រើសរើសប្រធានបទដែលមានសារៈសំខាន់បំផុតសម្រាប់ពួកគេដើម្បីធ្វើការសិក្សា។ ស្នើឱ្យពួកគេផ្តល់ពិន្ទុចំណាត់ថ្នាក់ចំនួន១០លេខ ទៅឱ្យប្រធានបទនោះ។ បន្ទាប់មក ស្នើឱ្យពួកគេក្រឡេកមើលបញ្ជីវាយនាមជាថ្មីម្តងទៀត និងជ្រើសរើសប្រធានបទដែលសំខាន់បំផុតបន្ទាប់ និងផ្តល់ពិន្ទុចំណាត់ថ្នាក់លេខ៩។ ចូរបន្តដំណើរការនេះរហូត ដល់ពួកគេបានផ្តល់ពិន្ទុចំណាត់ថ្នាក់លេខរៀងទី១ រហូតដល់លេខរៀងទី១០ ដែលជាប្រធានបទសំខាន់បំផុត។ ស្នើឱ្យក្រុមនីមួយៗផ្តល់ក្រដាសរបស់ពួកគេ ដើម្បីឱ្យអ្នកសម្របសម្រួលធ្វើការវិភាគ។<br><br>**សម្គាល់៖** លទ្ធផលនៃការផ្តល់ចំណាត់ថ្នាក់នេះ នឹងជួយដល់គ្រូបណ្តុះបណ្តាលក្នុងការផ្តោតយកចិត្តទុកដាក់ទៅលើប្រធានបទទាំង១០ ដែលសំខាន់ជាងគេបំផុត ដើម្បីឱ្យ ការបណ្តុះបណ្តាលមានភាពពាក់ព័ន្ធទៅនឹងចំណាប់អារម្មណ៍ និងសេចក្តីត្រូវការរបស់សិក្ខាកាម។ | ឯកសារជាប្រធានបទពីបញ្ជីមាតិកា |
| ៧ | **ការផ្តល់ពិន្ទុទៅលើជំនាញរបស់បុគ្គល ធៀបទៅនឹងប្រធានបទនីមួយៗ៖**<br>ចូរពន្យល់ថា អ្នកចង់ឱ្យសិក្ខាកាមនីមួយៗដាក់ពិន្ទុទៅលើចំណេះដឹងរបស់ពួកគេ ពីលេខ ១ ដល់លេខ ៥ សម្រាប់ប្រធានបទនីមួយៗ ក្នុងចំណោមប្រធានបទអាទិភាពទាំង១០ នៅលើសន្លឹកទំព័រដែលនិយាយអំពីការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល នៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ សិក្ខាកាមគួរផ្តល់ពិន្ទុលេខ១ សម្រាប់ចំណេះដឹងទាប និងពិន្ទុ លេខ២ លេខ៣ ឬ លេខ៤ សម្រាប់ចំណេះដឹងកម្រិតមធ្យម និងលេខ៥ សម្រាប់ចំណេះដឹងកម្រិតខ្ពស់។<br><br>ក្រោយពេលដែលពួកគេបានធ្វើការផ្តល់ពិន្ទុដោយខ្លួនឯង ទៅលើប្រធានបទចំនួន២ ឬ ៣ រួចរាល់ហើយនោះ ចូរបញ្ឈប់ដំណើរការនេះ និងស្នើសុំឱ្យ | <br>លំហាត់ ១.៥ ការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល - ការជ្រើសរើសប្រធានបទ |

| | | |
|---|---|---|
| | អញ្ជើញប្រធានក្រុមតូចៗឱ្យឡើងរាយការណ៍អំពីសហគ្រាសដែលពួកគេចង់បាន ជូន ដល់ក្រុមធំ និងបញ្ជាក់អំពីមូលហេតុ។<br><br>បន្ទាប់មក អ្នកសម្របសម្រួល ត្រូវសរសេរលទ្ធផលនៅលើផ្ទាំងក្រដាសធំមួយសន្លឹក និងជ្រើសរើសសហគ្រាសដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ។<br><br>រក្សាផ្ទាំងក្រដាសធំទាំងនោះ ជាមួយនឹងបញ្ជីរាយនាមសហគ្រាសដែលមាននាពេលបច្ចុប្បន្ន និងសហគ្រាសដែលត្រូវបានជ្រើសរើស និងស្នើឱ្យសមាជិកក្រុមចម្លងព័ត៌មានលម្អិតទាំងនេះតាមក្រោយ នៅពេលដែលពួកគេទទួលបានសៀវភៅ និងលំហាត់របស់ពួកគេនៅក្នុងកិច្ចប្រជុំលើក ទី២។ | |
| ៥ | **ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់៖**<br>ចូរគូរប្រអប់រាងការ៉េចំនួន៥ នៅលើផ្ទាំងក្រដាសធំមួយ ដែលស្រដៀងគ្នាទៅនឹង លំហាត់ ១.៤ នៅក្នុងសៀវភៅលំហាត់សម្រាប់សិក្ខាកាម។ នៅក្នុងប្រអប់ទី២ ផ្នែកខាងឆ្វេង ចូរសរសេរឈ្មោះសហគ្រាសដែលសាលាអាជីវកម្មកសិកម្មចង់ផ្តោតការយកចិត្តទុកដាក់ -ឧ. អង្ករ ឬមាន់ ឬបន្លែ ។ល។ បន្ទាប់មក ស្នើឱ្យសិក្ខាកាមរាយនាមតួអង្គចម្បងៗដទៃទៀតនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដោយបញ្ចប់ជាមួយនឹងចំណងជើងធំៗមួយចំនួន ដូចជា៖ អ្នកលក់សម្ភារៈកសិកម្ម -អ្នកផលិត - អ្នកប្រមូល - អ្នកបន្ថែមតម្លៃ - អ្នកលក់ដុំ/លក់រាយ។<br>បន្ទាប់មក ចូរស្នើសុំឱ្យពួកគេរាយនាមអំពីបញ្ហាដែលពួកគេកំពុងជួបប្រទះជាមួយតួអង្គនីមួយៗនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ ចូរសរសេរអំពីគោលគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំក្រោមចំណងជើងសមស្រប។<br><br>ធ្វើការបូកសរុបបញ្ចប់ ដោយនិយាយថាសាលាអាជីវកម្មកសិកម្ម នឹងជួយណែនាំដល់សិក្ខាកាមឱ្យស្វែងរកដំណោះស្រាយ ចំពោះបញ្ហាដែលពួកគេបានកំណត់រកឃើញនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ដែលពួកគេបានជ្រើសរើស ហើយទង្វើបែបនេះ ជួយឱ្យពួកគេទទួលបានប្រាក់ចំណេញ កាន់តែច្រើនជាងមុន សម្រាប់សកម្មភាពលក្ខណៈបុគ្គល និងសកម្មភាពជាក្រុមរបស់ពួកគេ។ | <br>លំហាត់ ១.៤ ៖ ប្រអប់ខ្សែសង្វាក់ផ្គត់ផ្គង់ |
| ៦ | **ការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល៖**<br>ជ្រើសរើសប្រធានបទដែលសំខាន់បំផុតចំនួន ១០ សម្រាប់ការបណ្តុះ | |

# ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ការចូលរួម នៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម ផ្តល់ផលល្អចំពោះពួកគេដែរឬទេ? អ្នកត្រូវធានាកត់ត្រានូវរាល់មូលហេតុនានាដែលពួកគេ បានផ្តល់ជូននៅក្នុងចម្លើយរបស់ពួកគេ។<br><br>លើកទឹកចិត្តសិក្ខាកាមឱ្យគិតអំពីអ្វីដែលពួកគេសង្ឃឹមថា នឹងអាចសម្រេចបាននៅក្នុង សាលាអាជីវកម្មកសិកម្ម និងសហគ្រាសមួយដែលមានលក្ខណៈជាក្រុម។ ចូរកត់ត្រាចម្លើយរបស់ពួកគេ។<br><br>ត្រូវឯកភាពទៅលើចំណុចមួយចំនួន ដូចជា តើនរណាខ្លះនឹងមកចូលរួមនៅក្នុងកិច្ចប្រជុំបន្ទាប់ នៅពេលណា ថ្ងៃណា និងទីកន្លែងណា ដែលត្រូវជួបគ្នាជាថ្មីម្តងទៀត។<br><br>ចូររក្សាទុកបញ្ជីវគ្គមានសាលាអាជីវកម្មកសិកម្ម ជាមួយអាជ្ញាធរថ្នាក់ភូមិ ឬថ្នាក់ក្រុម ដើម្បីឱ្យអ្នកដែល មានចំណាប់អារម្មណ៍ចង់ចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម អាចចុះឈ្មោះរបស់ពួកគេបាន។ ចូរប្រើប្រាស់ទម្រង់នៅក្នុងសៀវភៅលំហាត់របស់ពួកគេ (សូមសំដៅយោងចំពោះលំហាត់ ១.៧)។<br><br>មុនពេលកិច្ចប្រជុំលើកក្រោយ ចូរចុះសួរសុខទុក្ខតាមភូមិជាថ្មីម្តងទៀត និងព្យាយាមទាក់ទងសិក្ខាកាមដែលមានឈ្មោះនៅក្នុងបញ្ជី ដើម្បីធ្វើការប៉ាន់ប្រមាណទៅលើភាពសមស្របរបស់ពួកគេ និង រំលឹកពួកគេអំពីពេលវេលា កាលបរិច្ឆេទ និង ទីកន្លែងនៃកិច្ចប្រជុំ។<br><br>ធានាថា អ្នកបានរំលឹកសិក្ខាកាមឱ្យនាំយកមកជាមួយពួកគេ នូវសៀវភៅកត់ត្រា/ សៀវភៅលំហាត់ និងប៊ិច/ខ្មៅដៃ នៅពេលដែលពួកគេទៅចូលរួមកិច្ចប្រជុំ សាលាអាជីវកម្មកសិកម្ម។ | លំហាត់ ១.៧ បញ្ជីរាយនាមសិក្ខាកាមចូលរួម |
| ១១ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុច សំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖ | |

| | | |
|---|---|---|
| | ពួកគេបញ្ចប់ការផ្តល់ពិន្ទុ របស់ពួកគេនៅឯផ្ទះ និងនាំយកសន្លឹកឯកសារផ្តល់ពិន្ទុ (សន្លឹកឯកសារដែលនិយាយអំពី ការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល) ដែលពួកគេបានបំពេញរួច នៅឯកិច្ចប្រជុំលើកក្រោយ។ | |
| ៨ | **ការកំណត់ថេរវេលានៃវគ្គ សាលាអាជីវកម្មកសិកម្ម៖**<br>ចូរបង្ហាញទៅកាន់សិក្ខាកាមនូវផ្ទាំងក្រដាសធំមួយសន្លឹក ដែលអ្នកបានរៀបចំជាមុនរួចជាស្រេច (ឧទាហរណ៍នៅក្នុងសៀវភៅលំហាត់របស់ ពួកគេ) អំពីប្រតិទិនមួយដែលបង្ហាញឱ្យឃើញថា ប្រធានបទបណ្តុះ បណ្តាលភាគច្រើន គួរផ្តល់ជូនមុនពេលដែលពួកគេចាប់ផ្តើមសហគ្រាសរបស់ពួកគេ។ ទង្វើបែបនេះ គឺដើម្បីធានាថាសហគ្រាសនោះ អាចទទួលបានជោគជ័យ មុនពេលដែលពួកគេធ្វើផែនការសហគ្រាស។<br><br>បន្ទាប់មកចូរពន្យល់ថា ជាទូទៅការបណ្តុះបណ្តាលអំពីការត្រួតពិនិត្យរមែងតែងផ្តល់ជូនក្នុងអំឡុងពេលវដ្តនៃការផលិត ហើយមេរៀនដែលទាក់ទងទៅនឹងការវាយតម្លៃ និងការរៀបចំផែនការអាជីវកម្មថ្មី រមែងតែងផ្តល់ជូននៅចុងបញ្ចប់នៃវគ្គសាលាអាជីវកម្មកសិកម្ម។ | <br>លំហាត់ ១.៦ ការភ្ជាប់ទំនាក់ទំនងកម្មវិធីសាលាអាជីវកម្មកសិកម្ម ទៅនឹងប្រតិទិនរដូវកាលធ្វើកសិផល |
| ៩ | **ការពិចារណាលើបញ្ហាយេនឌ័រ៖**<br>➢ ចូរប្រាប់សិក្ខាកាមថា នៅក្នុងវគ្គមួយចំនួន វាមានសារៈប្រយោជន៍ក្នុងការបំបែកក្រុមបុរស និងក្រុមស្ត្រីឱ្យនៅដាច់ដោយឡែកពីគ្នា ដើម្បីធានាថាសម្លេងរបស់ពួកគេត្រូវបានគេស្តាប់ឮ ដោយពុំមានភេទណាមួយគ្របដណ្តប់ទៅលើភេទដទៃ។<br>➢ ចូរប្រាប់ពួកគេថា ការបំបែកជាអនុក្រុមតូចៗដែលមានភេទផ្ទុយគ្នាយ៉ាងដូច្នេះ ក៏ជួយដល់បុរស និងស្ត្រីដែលជាប្រធានអនុក្រុមតូចៗទាំងនោះ ក្នុងការអភិវឌ្ឍន៍ផងដែរ អាស្រ័យដោយទង្វើបែបនេះ ជួយឱ្យពួកគេក្លាយជាមេដឹកនាំដែល មានលក្ខណៈកាន់តែប្រសើរជាងមុននៅក្នុងសហគមន៍ ដែលមានភាពកាន់តែទូលំទូលាយជាងនេះ នៅពេល អនាគត។<br>➢ ចូរផ្តល់មតិយោបល់ថា ពេលវេលា និងទីកន្លែងបណ្តុះបណ្តាល អាចមានភាពបត់បែនទន់ភ្លន់ ដើម្បីឱ្យស្របទៅតាមកាលវិភាគការងារប្រចាំថ្ងៃរបស់បុរស ឬ ស្ត្រី យោងទៅតាមការបោះឆ្នោតសម្លេងភាគច្រើនពីអ្នកដែលចូលរួមនៅក្នុងការបណ្តុះបណ្តាល។ | ក្រដាស់ផ្ទាំងធំ និងប៊ិច |
| ១០ | **ការរៀបចំកំណត់ពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំបន្ទាប់៖**<br>ចូរសាកសួរទៅកាន់សិក្ខាកាម ដើម្បីឱ្យពួកគេធ្វើការគិតគូពិចារណាថាតើ |  |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

### មេរៀនទី២ ៖ មូលហេតុ និងការរៀបចំវគ្គបណ្តុះបណ្តាលសាលាអាជីវកម្មកសិកម្ម



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងអាចកំណត់អំពីប្រយោជន៍នៃការចូលរួមជាផ្នែកមួយនៃក្រុម (FBS) ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | ស្វាគមន៍សិក្ខាកាមគ្រប់រូបដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ ចូររំលឹកពួកគេថា ពួកគេត្រូវបានអញ្ជើញឱ្យចូលរួម ដោយសារតែពួកគេមានចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍន៍ និងចែករំលែកជំនាញអាជីវកម្មកសិកម្មរបស់ពួកគេ ដើម្បីឱ្យពួកគេអាចធ្វើ ឱ្យប្រសើរឡើងនូវការទទួលបានប្រាក់ចំណេញចំពោះកសិដ្ឋាន និងក្រុមរបស់ពួកគេ។ ចូរណែនាំសិក្ខាកាមអំពីសៀវភៅលំហាត់របស់ពួកគេ។ ចូរពន្យល់ថា សៀវភៅនេះ មានលំហាត់សំខាន់ៗមួយចំនួនដែលនឹងអនុញ្ញាតឱ្យពួកគេអាចធ្វើការអនុវត្តទៅលើគោលគំនិតសំខាន់ៗ និងជាទីកន្លែងអចិន្ត្រៃយ៍មួយ សម្រាប់ពួកគេសរសេរនូវចម្លើយគំនិតនានា និងមេរៀនដែលបានរៀនសូត្រ។ ចូរប្រាប់សិក្ខាកាមថា ពួកគេមិនត្រូវភ្លេច យកសៀវភៅនេះទៅជាមួយពួកគេជាដាច់ខាត នៅពេលដែលពួកគេទៅចូលរួមនៅក្នុងរាល់កិច្ចប្រជុំទាំងអស់។ |  សៀវភៅលំហាត់សាលាអាជីវកម្មកសិកម្មសម្រាប់សិក្ខាកាម |
| ២ | **ការស្គាល់គ្នាទៅវិញទៅមក៖** ស្នើឱ្យសិក្ខាកាមធ្វើការណែនាំខ្លួនដោយសង្ខេប ដូចជា ជម្រាប់អំពីឈ្មោះ តើពួកគេមកពីកន្លែងណា ផ្ទៃដីដាំដុះ សហគ្រាសវិស័យកសិកម្មដែលពួកគេចូលរួម និងតើពួកគេប្រកបមុខរបរជាកសិករអស់រយៈពេលប៉ុន្មានឆ្នាំហើយ។<br><br>បូកបញ្ចូលគ្នានូវចំនួនឆ្នាំដែលសិក្ខាកាមបានប្រកបរបរជាកសិករ។ ឧទាហរណ៍ កសិករ ចំនួន២៥នាក់ បានមានបទពិសោធន៍រយៈពេល១០ឆ្នាំ = បទពិសោធន៍រយៈពេល ២៥០ឆ្នាំ។ ចូរប្រាប់សិក្ខាកាមថាជាមួយនឹងបទពិសោធន៍រយៈពេល ២៥០ឆ្នាំនេះ ក្រុមមានចំណេះដឹង និងជំនាញជាច្រើនដែលពួកគេអាចចែករំលែកជាមួយគ្នាទៅវិញទៅមក និងប្រាប់ពួកគេថា អ្នករំពឹងថានឹងបានធ្វើការងារជាមួយពួកគេ ព្រមទាំងរៀនសូត្រពីពួកគេ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្មនេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និង មាតិកា នៃវគ្គ សាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | សៀវភៅលំហាត់របស់ពួកគេ (លំហាត់ ២.១) ព្រមទាំងអញ្ជើញសិក្ខាកាមឱ្យបន្ថែមគំនិតនានា ពីបញ្ជីរាយនាមរបស់ក្រុមនៅលើផ្ទាំងក្រដាសធំទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។<br>ពិនិត្យមើលទៅលើបញ្ជីរាយនាមចុងក្រោយ ដោយសង្កត់ធ្ងន់អំពីសារៈប្រយោជន៍នៃដំណើរការ និងមាតិការបស់វគ្គ សាលាអាជីវកម្មកសិកម្ម។ | |
| ៤ | **មេរៀន និងកាលវិភាគបណ្តុះបណ្តាល៖**<br>សម្គាល់៖ អ្នកសម្របសម្រួលត្រូវការបញ្ជីរាយនាមដាក់ពិន្ទុទៅលើប្រធានបទទាំង១០ ដែលសំខាន់បំផុត ដែលមានការឯកភាពគ្នាពីវគ្គប៉ាន់ប្រមាណសេចក្តីត្រូវការបណ្តុះបណ្តាលកាលពីលើកមុន។<br>ចូរចាប់ផ្តើមតាមរយៈការស្នើសុំឱ្យសិក្ខាកាមពិនិត្យមើលទៅលើបញ្ជីរាយនាមមេរៀន វគ្គសាលាអាជីវកម្មកសិកម្ម ទៅតាមលំដាប់លំដោយនៅក្នុងសៀវភៅលំហាត់សម្រាប់សិក្ខាកាម។<br>ចូរពន្យល់ដោយសង្ខេបអំពីប្រធានបទនីមួយៗ ទៅកាន់សិក្ខាកាម។ ចូរនិយាយថា ខណៈពេលដែលសិក្ខាកាមភាគច្រើនបាននិយាយថា ប្រធានបទ ទាំងអស់សុទ្ធសឹងតែមានសារៈសំខាន់ នៅក្នុងវគ្គវិភាគសេចក្តីត្រូវការបណ្តុះបណ្តាលកាលពីលើកមុន ពួកគេត្រូវបានស្នើសុំឱ្យធ្វើការងារជាក្រុមដើម្បីកំណត់រកប្រធានបទចំនួន១០ ដែលសំខាន់ជាងគេបំផុត។ ចូរហៅលេខរៀងលំដាប់លំដោយ ខណៈពេលដែលអ្នកកំពុងពន្យល់អំពី ប្រធានបទនីមួយៗ។ ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការកត់ត្រាអំពីលេខរៀងលំដាប់លំដោយ ដែលបានឯកភាពគ្នាទាំងនេះ នៅក្នុងគូឡោនទី២ នៃតារាងក្នុងសៀវភៅ លំហាត់របស់ពួកគេ។ ចូរបង្ហាញថាលេខ១ គឺជាប្រធានបទដែលសំខាន់បំផុត និង លេខ២ គឺជាប្រធានបទដែលសំខាន់បន្ទាប់។ល។<br>ចូរនិយាយថា ថេរវេលានៃមេរៀនគួរមានទំនាក់ទំនងទៅនឹងវដ្តនៃអាជីវកម្មកសិកម្ម (ស្នើឱ្យសិក្ខាកាមក្រឡេកមើល លំហាត់១.១ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ) លទ្ធផលនៃការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាលរបស់ពួកគេ និង ពេលវេលាដែលពួកគេមានមុនពេល ក្នុងអំឡុងពេល និងក្រោយពេលរដូវកាលផលិត (សូមពិនិត្យមើលលំហាត់ ១.៦ សម្រាប់ | បញ្ជីរាយនាមប្រធានបទទាំង១០ ដែលសំខាន់បំផុត ពីការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល (មេរៀនទី១)<br><br>លំហាត់ ២.២ (ក) មេរៀនបណ្តុះបណ្តាល<br> |

 

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ផងដែរ។<br><br>ចូរនិយាយថា វគ្គសាលាអាជីវកម្មកសិកម្ម ត្រូវបានរៀបចំរចនាសម្ព័ន្ធដើម្បីបង្កលក្ខណៈឱ្យកសិករអាចរៀនសូត្រពីគ្នា តាមរយៈការជជែកគ្នាទៅវិញទៅមក ដែលសកម្មភាពជជែកគ្នាបែបនេះ នឹងប្រើប្រាស់ពេលវេលាបណ្តុះបណ្តាលរហូតដល់ ៨០% ដោយឡែក ការណែនាំពីអ្នកសម្របសម្រួល ឬវាគ្មិន នឹងប្រើប្រាស់ពេលវេលាត្រឹមតែ ២០% ប៉ុណ្ណោះ។<br><br>ចូរនិយាយថា កិច្ចប្រជុំលើកទី១នេះ ផ្តោតយកចិត្តទុកដាក់ទៅលើការវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល។ ចូរផ្តល់ព័ត៌មានឱ្យសិក្ខាកាមបានជ្រាបថា កិច្ចប្រជុំលើកទី២ នឹងផ្តោតទៅលើគោលបំណងនៃវគ្គបណ្តុះបណ្តាល ព្រមទាំងអត្ថប្រយោជន៍នៃវគ្គបណ្តុះបណ្តាលចំពោះបុគ្គល និងក្រុម និងរបៀបរបបនៃដំណើរការវគ្គនេះ។ បន្ទាប់មក សិក្ខាកាមនឹងចាប់ផ្តើមរៀនសូត្រអំពីការធ្វើកសិកម្មក្នុងលក្ខណៈជាអាជីវកម្ម។ | |
| ៣ | **ហេតុអ្វីចាំបាច់ត្រូវមានវគ្គបណ្តុះបណ្តាលកសិករអំពីសាលាអាជីវកម្មកសិកម្ម?**<br><br>ចូររំលឹកសិក្ខាកាមអំពីកិច្ចប្រជុំណែនាំដែលអ្នកបានជួបជាមួយពួកគេ កាលពីលើកមុន ដែលអ្នកបានប្រាប់ពួកគេអំពីវគ្គសាលាអាជីវកម្មកសិកម្ម។ ចូរធ្វើតេស្តសាកល្បងទៅលើចំណេះដឹង និងការរំពឹងទុករបស់ពួកគេ តាមរយៈការស្នើសុំឱ្យ ពួកគេធ្វើការពិភាក្សាជាក្រុម ដែលមានសមាជិកចន្លោះពី ៣-៥នាក់ និងរាយការណ៍ជូនដល់ក្រុមធំវិញ ចំពោះសំនួរដូចខាងក្រោម។ ចូរផ្តល់សំនួរចំនួន១ ទៅឱ្យក្រុមនីមួយៗដើម្បីសន្សំពេលវេលា។<br><br>សំនួររួមមាន៖<br>១. តើមានដំណើរការអ្វីខ្លះដែលពាក់ព័ន្ធក្នុងការអនុវត្តវគ្គ សាលាអាជីវកម្មកសិកម្ម?<br>២. តើសិក្ខាកាមរំពឹងថានឹងទទួលបានអ្វីខ្លះពីការចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>ស្នើសុំឱ្យសិក្ខាកាម ២-៣នាក់ ឱ្យផ្តល់មតិយោបល់របស់ពួកគេ។ ចូរសរសេរមតិយោបល់ទាំងនោះនៅលើផ្ទាំងក្រដាសមួយដោយឡែក។<br><br>ចូរធ្វើការប្រៀបធៀបចម្លើយនៅលើផ្ទាំងក្រដាស ជាមួយចម្លើយនៅក្នុង | <br>លំហាត់ ២.១៖ កម្រងសំនួរ៖ ហេតុអ្វីបានជាមានវគ្គបណ្តុះបណ្តាលកសិករអំពីសាលាអាជីវកម្មកសិកម្ម? |

| | | |
|---|---|---|
| | កសិកម្មនេះ អាចបន្តដំណើរទៅមុខទៀតបាន។ ស្នើឱ្យក្រុមទាំងអស់ប្រើប្រាស់លំហាត់២.៣ នៅក្នុងសៀវភៅលំហាត់របស់ពួកគេជាបញ្ជីផ្ទៀងផ្ទាត់ និងបន្ថែមទៅលើបញ្ជីនោះនូវវិស័យគាំទ្រដទៃទៀត ដែលពួកគេអាចនឹកឃើញ។ សូមផ្តល់ការបញ្ជាក់ថា មនុស្សច្រើននាក់អាចផ្តល់វិភាគទានដូចគ្នាដោយឆ្លាស់គ្នាផ្តល់វិភាគទាននោះ - ឧ. ផ្តល់ទឹកតែដើម្បីទទួលទាន។<br>ក្រោយរយៈពេល១៥នាទី ចូរធ្វើការកត់ត្រាអំពីការប្តេជ្ញាចិត្តរបស់សិក្ខាកាម និងការ ប្តេជ្ញាចិត្តរបស់គម្រោងនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ដើម្បីទុកជាឯកសារយោងខ្លឹមសារសង្ខេបនៃតារាងនេះ គួររក្សាទុកនៅក្នុងបន្ទប់ប្រជុំដើម្បីឱ្យគេអាចមើលឃើញគ្រប់ៗគ្នា។ | <br>លំហាត់ ២.៣៖ កិច្ចគាំទ្រចំពោះសាលាអាជីវកម្មកសិកម្ម របស់អ្នក តើនរណាអាច ផ្ត" ល់អ្វីខ្លះ?” |
| ៦ | **វិន័យរបស់វគ្គ សាលាអាជីវកម្មកសិកម្ម :**<br>នៅក្នុងក្រុមធំ ចូរធ្វើការសាកសួរសិក្ខាកាមថា តើវិន័យសម្រាប់រៀបចំដំណើរការក្រុមសាលាអាជីវកម្មកសិកម្មឱ្យមានប្រសិទ្ធភាព គួរមានអ្វីខ្លះ។ ចូរធ្វើការកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តារខៀន ឬផ្ទាំងក្រដាស។ នៅពេលដែលទទួលបានចម្លើយគ្រប់គ្រាន់ហើយ ចូរប្រាប់ឱ្យសិក្ខាកាមមើលលំហាត់ ២.៤ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ និងសូមឱ្យពួកគេសរសេរបន្ថែមចំណុចពីផ្ទាំងក្រដាស ដែលពុំមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ ធានាថា មានការយល់ឃើញ និងការឯកភាពជារួមមួយនៅលើចំណុចនីមួយៗ។<br>នៅពេលដែលពួកគេបានបញ្ចប់រួចរាល់ ចូរសរសេររាល់វិន័យទាំងអស់ដែលបានឯកភាពគ្នានៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ សូមឱ្យសិក្ខាកាមគ្រប់រូបឡើងមកចុះហត្ថលេខា នៅលើផ្ទាំងក្រដាសដែលបិតនៅលើជញ្ជាំង ដើម្បីឱ្យគ្រប់គ្នាបានមើលឃើញ។ ចូរប្រាប់ពួកគេថា ការចុះហត្ថលេខាដោយបញ្ជាក់អំពីឈ្មោះរបស់ពួកគេបែបនេះ បង្ហាញអំពីការប្តេជ្ញាចិត្តអនុវត្តតាមវិន័យទាំងនេះ។ | ផ្ទាំងក្រដាសធំ និង ប៊ិច<br><br>លំហាត់ ២.៤៖ វិន័យសម្រាប់សាលាអាជីវកម្មកសិកម្ម |
| ៧ | **ការរៀបចំបង្កើតអនុក្រុមតូចៗ៖**<br>ចូរប្រាប់សិក្ខាកាមថា ប្រសើរបំផុតគួរធ្វើការងារជា "អនុក្រុមតូចៗ ដែលស្ថិត | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ប្រតិទិនតាមរដូវកាល)។<br>ធ្វើការត្រួតពិនិត្យឡើងវិញទៅលើបញ្ជីរាយនាមមេរៀន និងកាលវិភាគនៅលើផ្ទាំងក្រដាសធំ និងឯកភាពទៅលើ៖<br>➢ តើមេរៀនគួរត្រូវបានគ្របដណ្តប់ទៅតាមលំដាប់លំដោយដូចម្តេចខ្លះ? អ្នកសម្របសម្រួលអាចមានផែនការមួយដែលរៀបចំទុកជាមុន និងសួរទៅកាន់សិក្ខាកាម ថាតើពួកគេអាចឯកភាពដែរឬទេ។<br>➢ តើនរណាខ្លះគួរចូលរួម - បុរស ឬស្ត្រី? សំខាន់គួរមានអ្នកអនុវត្តការងារ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត (ប្រសិនបើបុគ្គលទាំងពីរនេះជាមនុស្សផ្សេងគ្នា) ចូលរួមនៅក្នុងកិច្ចប្រជុំ។ ក្នុងលក្ខណៈបែបនេះ ពួកគេអាចរៀនសូត្រតាំងពីដំបូង អំពីព័ត៌មានដែលមានសារៈប្រយោជន៍ចំពោះពួកគេ។ ចូរនិយាយថា សិក្ខាកាមដដែលគួរចូលរួមនៅក្នុងកិច្ចប្រជុំលើកក្រោយទៀត អាស្រ័យដោយប្រធានបទនីមួយៗពង្រឹងបន្ថែមទៅលើចំណេះដឹងដែលទទួលបានពីវគ្គមុនៗ។<br>➢ (សកម្មភាពដែលអាចជ្រើសរើសយកមកធ្វើក៏បាន ឬមិនធ្វើក៏បាន៖ លេងល្បែងកំសាន្តខ្សិបបន្តគ្នាមួយ ដើម្បីបង្ហាញថា ព័ត៌មានអាចបាត់បង់នៅ ពេលបញ្ជូនព័ត៌មានពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត - ១៥នាទី)។<br>➢ តើក្រុមគួរជួបជុំគ្នានៅថ្ងៃណា? ចូរសំដៅចំពោះប្រតិទិនដែលបានធ្វើការ កត់សម្គាល់ទៅលើចំណង់ចំណូលចិត្តរបស់បុរស និងស្ត្រី និងពិធីបុណ្យ ថ្ងៃឈប់សម្រាកពិសេស។ល។ ដែលពួកគេមិនអាចជួបជុំគ្នាបាន។<br>➢ តើពួកគេគួរជួបជុំគ្នានៅកន្លែងណា? ចូរកត់ត្រាអំពីចំណង់ចំណូលចិត្តរបស់បុរស និងស្ត្រី។<br>➢ តើកិច្ចប្រជុំគួរចាប់ផ្តើមនៅម៉ោងប៉ុន្មាន? ចូរសួរទៅកាន់បុរស និងស្ត្រីដាច់ដោយឡែកពីគ្នា អាស្រ័យដោយពួកគេមានមានចំណង់ចំណូលចិត្តខុសគ្នា ចំពោះបញ្ហាពេលវេលា។ | បំពេញលំហាត់ ២.២ (ខ) ដោយសំដៅយោងចំពោះ លំហាត់ ១.១៖ វដ្តនៃអាជីវកម្មកសិកម្ម និងលំហាត់ ១.៦ ៖ ប្រតិទិនតាមរដូវកាល<br><br>ផ្ទាំងក្រដាសធំដែលរួមមានបញ្ជីរាយនាមចំណុចសម្រាប់ពិភាក្សាដែលត្រូវបានរៀបចំទុកជាមុន |
| ៥ | **កិច្ចគាំទ្រចំពោះវគ្គ សាលាអាជីវកម្មកសិកម្ម :**<br>បែងចែកសិក្ខាកាមជា៤ក្រុម និងស្នើសុំឱ្យពួកគេពិភាក្សាទៅលើសំនួរ៖ តើ"នរណាអាចផ្តល់អ្វីខ្លះ?" ដើម្បីជម្រុញឱ្យការផ្តួចផ្តើមវគ្គសាលាអាជីវកម្ម | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និង មាតិកា នៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | នៅក្នុងសហគ្រាសដូចគ្នាតែមួយ” ដែលមានសមាជិកចន្លោះពី ៣-៥នាក់ ដើម្បីធ្វើឱ្យការពិភាក្សា រវាងសិក្ខាកាមកាន់តែមានភាពងាយស្រួល។ ពួកគេគួរស្ថិតនៅក្នុងអនុក្រុមតូចៗទាំងនេះ នៅក្នុងកម្មវិធីសាលាអាជីវកម្មកសិកម្ម តាំងពីដើមរហូតដល់ចប់។ ចូរប្រាប់ពួកគេថា យ៉ាងហោចណាស់ពួកគេគួរមានមនុស្សម្នាក់ដែលជាអ្នកពូកែសរសេរ ពូកែអាន និង ពូកែខាងលេខនព្វន្ត (ពួកគេអាចជាមនុស្សតែម្នាក់ ឬមនុស្សផ្សេងគ្នា)។ អ្នកទាំងនេះនឹងក្លាយជាប្រធាន អនុក្រុមតូចៗទាំងនោះក្នុងភារកិច្ច ជួយដល់សមាជិកអនុក្រុមរបស់ពួកគេក្នុងការពិភាក្សា និងស្វែងយល់អំពីមេរៀនសាលាអាជីវកម្មកសិកម្ម ក្នុងលក្ខណៈបែបមិនផ្លូវការ ក្រោយពេលវគ្គបណ្តុះបណ្តាលសាលាអាជីវកម្មកសិកម្មនីមួយៗ។<br><br>ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការពិចារណា ថាតើពួកគេចង់ចូលរួមជាមួយនរណា ដើម្បីបង្កើតជាអនុក្រុមតូចមួយ។ ក្រុមអាចរួមមានសមាសភាពបុរស និងស្ត្រី ឬតែបុរស ឬតែស្ត្រី។ ស្នើសុំឱ្យពួកគេគិតអំពីបញ្ហានេះក្រោយពេលកិច្ចប្រជុំ និងក្រោយមក ត្រូវ ត្រៀមខ្លួនចូលរួមនៅក្នុងអនុក្រុមតូចៗទាំងនេះ ក្នុងកម្មវិធីសាលាអាជីវកម្មកសិកម្ម តាំងពីដើមរហូតដល់ចប់។ | |
| ៨ | **រៀបវារៈសម្រាប់កិច្ចប្រជុំបន្ទាប់៖**<br><br>លើកទឹកចិត្តសិក្ខាកាមឱ្យចំណាយពេលវេលាមួយចំនួននៅឯផ្ទះ ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើមេរៀន និងប្រធានបទកម្មវិធីសាលាអាជីវកម្មកសិកម្ម ព្រមទាំងសួរសំនួរអំពីភាពពាក់ព័ន្ធ និងសារៈប្រយោជន៍នៃប្រធានបទទាំងនោះ ទៅនឹងសេចក្តីត្រូវការជាក់លាក់របស់សមាជិកក្រុម។<br><br>ចូរប្រាប់សិក្ខាកាមថា នៅក្នុងកិច្ចប្រជុំបន្ទាប់ ពួកគេនឹងបានរៀនសូត្រអំពីចំណុចបន្ទាប់ ដែលមានរាយនាមនៅក្នុងកាលវិភាគរបស់ពួកគេ។ | |
| ៩ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br><br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br><br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ? | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | មួយចំនួន អាចធ្វើការផលិតក្នុងកម្រិតស្មើភាពគ្នា ដើម្បីទទួលបានស្បៀងអាហារ និងប្រាក់ ដោយឡែក កសិករដទៃទៀត អាចជាធ្វើការផលិតច្រើនជាង ដើម្បីលក់ផលិតយកប្រាក់ ហើយកសិករដទៃទៀត អាចជាធ្វើការ ផលិតច្រើនជាង ដើម្បីប្រើប្រាស់ជាស្បៀងអាហារ និងមិនសូវផលិតសម្រាប់លក់យកប្រាក់ឡើយ។ | |
| ២.២ | សង្ខេបការពិភាក្សាដោយសង្កត់ធ្ងន់ថា ការអនុវត្តធ្វើកសិកម្មបានផ្លាស់ប្តូរក្នុងរយៈកាល ប៉ុន្មានឆ្នាំកន្លងមកនេះ អាស្រ័យដោយសេចក្តីត្រូវការរបស់មនុស្សបានផ្លាស់ប្តូរ។ កាលពីអតីតកាល កសិករភាគច្រើនផលិតស្បៀងអាហារទុកសម្រាប់តែទទួលទាន ហើយពួកគេលក់ ឬប្តូរនឹងវត្ថុដទៃទៀត ចំពោះតែបរិមាណស្បៀងអាហារដែលមាន ចំនួនលើសលុបបន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែបច្ចុប្បន្ន គ្រួសារជាច្រើនចង់បានវត្ថុជាច្រើន បន្ថែមទៀត ដូចជា ម៉ូតូ ទូរស័ព្ទ ទូរទស្សន៍ ការអប់រំដែលប្រសើរជាងមុន ដូច្នេះនាំឱ្យមានសម្ពាធច្រើនជាងមុន ក្នុងការប្រើប្រាស់វិស័យកសិកម្មដើម្បីទទួលបានផលចំណេញជាសាច់ប្រាក់ សម្រាប់ផ្គត់ផ្គង់គ្រួសារ។ ដូច្នេះ គេចាំបាច់ត្រូវចាប់ផ្តើមក្រឡេកមើលវិស័យកសិកម្ម ក្នុងលក្ខណៈជាការធ្វើអាជីវកម្មដែលបង្កើតឱ្យមាននូវប្រាក់ចំណេញជាជាងគ្រាន់តែជាប្រភពនៃស្បៀងអាហារ។ | |
| ៣ | **កសិករក្នុងនាមជាសហគ្រិន៖**<br>ចូរប្រាប់សិក្ខាកាមថា កសិករខ្លួនឯងផ្ទាល់គឺជាទ្រព្យសម្បត្តិ ឬធាតុផ្សំដ៏សំខាន់បំផុត នៅក្នុងអាជីវកម្មកសិកម្មរបស់ពួកគេ។ កសិករម្នាក់ដ៏ល្អ= អាជីវកម្មមួយដ៏ល្អ។នៅក្នុងក្រុមធំ ចូរសូមឱ្យសិក្ខាកាមបិទភ្នែករបស់ពួកគេ និងគិតអំពីកសិករ ឬអ្នកជំនួញដែលពួកគេស្គាល់ថា មានភាពជោគជ័យខ្លាំងបំផុត។ ក្រោយរយៈពេល ១-២ នាទី ចូរសូមឱ្យសិក្ខាកាមគ្រប់រូបបើកភ្នែករបស់ពួកគេ និងចែករំលែកជាមួយសិក្ខាកាមដទៃទៀត ថាហេតុអ្វីបានជាពួកគេគិតថា មនុស្សម្នាក់គឺជាសហគ្រិនមួយរូបដ៏ជោគជ័យ ឧទាហរណ៍ ដូចជា តើនៅក្នុងទស្សនៈរបស់ពួកគេ មានអ្វីខ្លះជាសមត្ថភាព ឬ លទ្ធភាពសំខាន់ៗដែលធ្វើឱ្យមនុស្សម្នាក់នោះក្លាយជាអ្នកជំនួញម្នាក់ដ៏ជោគជ័យ។ ចូរធ្វើការកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើផ្ទាំងក្រដាស ឬ ក្តាខៀន។ | |

# ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

## មេរៀនទី៣ ការគ្រប់គ្រងក្រុម និងការធ្វើកសិកម្ម ក្នុងលក្ខណៈជាអាជីវកម្ម



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងមានក្រុមគ្រប់គ្រងមួយ និងអនុក្រុមតូចៗមួយចំនួន យល់អំពីរបៀបនៃការធ្វើពាណិជ្ជកម្មទៅលើវិស័យកសិកម្ម និងដឹងអំពីជំហានសមស្របដែលពាក់ព័ន្ធក្នុងការរៀបចំបង្កើត និងគ្រប់គ្រងអាជីវកម្មកសិកម្មមួយ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | ស្វាគមន៍សិក្ខាកាម និងធ្វើការចែករំលែកជាមួយពួកគេអំពីគោលបំណងនៃកិច្ចប្រជុំ។ ធានាថា សិក្ខាកាមគ្រប់រូបបានយកសៀវភៅលំហាត់របស់ពួកគេមកជាមួយ។ | |
| ២ | **ការធ្វើពាណិជ្ជកម្មទៅលើវិស័យកសិកម្ម៖**<br>ចូរគូររង្វង់ចំនួន២ នៅក្បែរគ្នាដែលមានទំហំប៉ុនគ្នានៅលើក្ដាខៀន។ នៅក្នុងរង្វង់ខាងឆ្វេង ចូរសរសេរពាក្យ "អាហារ"។ នៅក្នុងរង្វង់ខាងស្ដាំ ចូរសរសេរពាក្យ "ប្រាក់"។ ចូរប្រើប្រាស់គំនូសនេះជាគម្រូយសម្រាប់ណែនាំការពិភាក្សាដូចខាងក្រោម។ ស្នើសុំឱ្យសិក្ខាកាមពិនិត្យមើលដ្យាក្រាមនៅក្នុងសៀវភៅលំហាត់របស់ពួកគេ និងធ្វើការពិភាក្សាជាគូ ថាតើដ្យាក្រាមនោះបង្ហាញអំពីអ្វី។ អញ្ជើញសិក្ខាកាមឱ្យផ្ដល់ចម្លើយរបស់ពួកគេ។ ដ្យាក្រាមបង្ហាញថា ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ មានការផ្លាស់ប្ដូរកាន់តែច្រើនឡើងពីការធ្វើកសិកម្ម ដើម្បីទទួលបានស្បៀងអាហារ ទៅជាការធ្វើកសិកម្មដើម្បីទទួលបាននូវសាច់ប្រាក់។ ចូរសួរទៅកាន់សិក្ខាកាមអំពីមូលហេតុនៃការផ្លាស់ប្ដូរនេះ នៅក្នុងការអនុវត្តធ្វើកសិកម្ម ព្រមទាំងជម្រុញឱ្យមានការពិភាក្សា។ | <br>លំហាត់ ៣.១៖ បរិយាកាសនៃការធ្វើកសិកម្ម សម្រាប់គោលបំណងពាណិជ្ជកម្ម |
| ២.១ | ស្នើឱ្យសិក្ខាកាមគិតអំពីស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ និងឆ្លើយទៅនឹងសំនួរខាងក្រោម ដែលមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ ៖ លំហាត់ ៣.២។<br>ហេតុអ្វីបានជាអ្នកធ្វើជាកសិករ? តើការដែលអ្នកធ្វើជាកសិករ គឺដើម្បីផលិតស្បៀងអាហារសម្រាប់ខ្លួនអ្នក និងគ្រួសាររបស់អ្នកឬ? តើការដែលអ្នកធ្វើជាកសិករ គឺដើម្បីរកប្រាក់ឬ? ឬក៏ទាំងពីរតែម្ដង - ដើម្បីផលិតស្បៀងអាហារ និងដើម្បីរកប្រាក់? តើចំពោះអ្នកការរកប្រាក់មានសារៈសំខាន់ជាងការដែលគ្រាន់តែផលិតស្បៀងអាហារឬ? តើអ្នកប្រើប្រាស់ប្រាក់សម្រាប់ធ្វើអ្វីខ្លះ?<br>អញ្ជើញសិក្ខាកាមឱ្យចែករំលែកចម្លើយរបស់ពួកគេជាមួយក្រុមធំ។<br>អ្នកអាចនឹងទទួលបានចម្លើយជាច្រើនផ្សេងៗគ្នា ឧទាហរណ៍ដូចជា កសិករ | <br>លំហាត់ ៣.២៖ ចូរក្រឡេកមើលស្ថានភាពគ្រួសាររបស់អ្នក |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | រឹងមាំ និងសិក្ខាកាមដែលមានភាពទន់ខ្សោយ អាចជួបគ្នាក្រៅផ្លូវការនៅសប្តាហ៍បន្ទាប់ ដើម្បីពិភាក្សាអំពីវិធីពង្រឹងទៅលើចំណុចសមត្ថភាពដែលនៅមានភាពទន់ខ្សោយ។ | |
| ៤ | **គុណសម្បត្តិនៃក្រុមសហគ្រាសកសិកម្ម៖**<br><br>ចូរប្រាប់សិក្ខាកាមថា ពួកគេបានជ្រើសរើសរួបរួមគ្នាជាក្រុមមួយ ឬបុគ្គលកសិករឈានមុខ ដើម្បីអនុវត្តសហគ្រាសកសិកម្មមួយក្នុងលក្ខណៈដែលធ្វើឱ្យពួកគេទទួលបានប្រាក់ចំណេញច្រើនជាងមុន។<br><br>ចូរប្រាប់កសិករថា អ្នកនឹងអានអត្ថបទករណីសិក្សាអំពី "ការបង្កើតក្រុមកសិករធ្វើអាជីវកម្ម" នៅក្នុងសៀវភៅលំហាត់របស់សិក្ខាកាម។ សូមឱ្យ សិក្ខាកាមស្តាប់សាច់រឿងករណីសិក្សានេះ និងកត់ត្រាអំពីអត្ថប្រយោជន៍នានាដែលពួកគេបានរៀនសូត្រពីករណីសិក្សានេះ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។<br><br>សូមឱ្យពួកគេធ្វើការប្រៀបធៀបអត្ថប្រយោជន៍ទាំងនេះ ជាមួយនឹងអត្ថ-ប្រយោជន៍ ដែលមានរាយនាមរួចជាស្រេចនៅក្នុងសៀវភៅលំហាត់របស់ពួកគេ ដោយដាក់សញ្ញាមួយនៅក្បែរចំណុចទាំងឡាយណាដែលពួកគេបានជ្រើសរើសរួចទៅហើយ។<br><br>ចូរធ្វើការសង្ខេបដោយនិយាយថា តាមរយៈការចូលរួមនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្មនេះ អ្នកសង្ឃឹមថា សិក្ខាកាមនឹងទទួលបានជោគជ័យ ក្នុងការធ្វើឱ្យប្រសើរឡើងនូវកសិដ្ឋាននីមួយៗ ក៏ដូចជាផលចំណេញនៅក្នុងក្រុមដូចការពណ៌នានៅក្នុងករណីសិក្សា។ | <br>លំហាត់ ៣.៩៖<br>ករណីសិក្សា<br><br><br>លំហាត់ ៣.៩៖<br><br>(ត) អត្ថប្រយោជន៍ នៃការចូលរួម នៅក្នុងក្រុម |
| ៥ | **គុណវិបត្តិនៃការចូលរួមនៅក្នុងសហគ្រាសជាក្រុម៖**<br><br>ចូរប្រាប់សិក្ខាកាមថា មានគុណវិបត្តិមួយចំនួនក្នុងការចូលរួមនៅក្នុងសហ-គ្រាសជាក្រុម។ ចូរប្រមូលផ្តុំគំនិតអំពីគុណវិបត្តិនានា និង សរសេរគុណវិបត្តិទាំងនោះនៅលើផ្ទាំងក្រដាស។<br><br>ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការប្រៀបធៀបគំនិតទាំងនេះ ជាមួយនឹងគំនិតដែលមានរាយនាមនៅក្នុងលំហាត់ ៣.៩ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ និង បន្ថែមគុណវិបត្តិនានាដែលទទួលបានពីការប្រមូលផ្តុំគំនិត ទៅក្នុងសៀវភៅ | ក្រដាសផ្ទាំងធំ និងប៊ិច |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ៣.១ | សូមឱ្យសិក្ខាកាមពិនិត្យមើលលំហាត់ ៣.៣ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ និង អាន ព្រមទាំងពន្យល់អំពីចំណុចដែលរាយនាមអំពីសមត្ថភាព។ ប្រៀបធៀបចំណុច ទាំងនោះជាមួយចម្លើយរបស់ក្រុមដែលសរសេរនៅលើផ្ទាំងក្រដាស និងបន្ថែមចំណុចដទៃទៀត ទាក់ទងទៅនឹងសមត្ថភាពដែលពួកគេបានកំណត់រកឃើញ ប៉ុន្តែមិនទាន់បានសរសេររាយនាមនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ |  លំហាត់ ៣.៣ ៖ សមត្ថភាពដែលតម្រូវឱ្យមានដើម្បីទទួលបានជោគជ័យនៅក្នុងអាជីវកម្ម |
| ៣.២ | រៀបចំសិក្ខាកាមជាក្រុម ដែលមួយក្រុមមានសមាជិក២នាក់។ ចូរពន្យល់ថា នៅក្នុងលំហាត់នេះ ការងាររបស់ពួកគេគឺត្រូវសម្ភាសន៍គ្នាទៅវិញទៅមក ដើម្បីជួយគ្នាធ្វើការវាយតម្លៃ ថាតើភាគីម្ខាងទៀតមានសមត្ថភាពជាសហគ្រិនដល់កម្រិតណា។ ចូរចាប់ផ្តើមជាមួយសមត្ថភាពដំបូងគេ។ សូមឱ្យពួកគេជជែកគ្នាទៅវិញទៅមក អំពីចំណុចមួយនេះ។ ចូរសួរថា៖ តើអ្នកមានសមត្ថភាពនេះដែរឬទេ? តើអ្នកមានភាពរឹងមាំ ចំពោះសមត្ថភាពនេះដែរឬទេ? ប្រសិនបើសិក្ខាកាមមានភាពរឹងមាំចំពោះសមត្ថភាពនេះ សិក្ខា-កាមគួរគូសសញ្ញា (✓) នៅក្នុងគូឡោន "ស្នាមញញឹមខ្លាំង" ក្នុងសៀវភៅលំហាត់របស់ពួកគេ។ ប្រសិនបើសិក្ខាកាមពុំមានភាពរឹងមាំចំពោះ សមត្ថភាពនេះទេ ពួកគេគួរគូសសញ្ញា (✓) នៅក្នុងគូឡោន "ទឹកមុខក្រៀមក្រំខ្លាំង"។ ប្រសិនបើពួកគេស្ថិតនៅត្រង់ចំណុចកណ្តាល ពួកគេគួរគូសសញ្ញា (✓) នៅក្នុងគូឡោន "ទឹកមុខស្មើធម្មតា"។ ចូរធ្វើរបៀបនេះសម្រាប់សមត្ថភាពនីមួយៗ ដែលត្រូវបានរាយនាមនៅក្នុងបញ្ជី។ សិក្ខាកាមអាចឯកភាព ឬមិនឯកភាពទៅនឹងការដាក់ពិន្ទុរបស់អ្នកដទៃ។ ចំណុចនេះ មិនសំខាន់ឡើយ ប៉ុន្តែអ្វីដែលសំខាន់នោះគឺសិក្ខាកាមពិភាក្សាអំពីសមត្ថភាពទាំងនេះជាមួយគ្នា និងខិតខំព្យាយាមធ្វើការវាយតម្លៃមួយដ៏ស្មោះត្រង់។ | |
| ៣.៣ | ចូរពន្យល់ថា លំហាត់នេះគួរតែបានជួយដល់ពួកគេក្នុងការកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយរបស់ពួកគេ ក្នុងនាមជាសហគ្រិន។<br><br>សូមឱ្យសិក្ខាកាមដែលមានភាពរឹងមាំនៅក្នុងសមត្ថភាពនីមួយៗ ឱ្យលើកដៃរបស់ពួកគេឡើង ដើម្បីឱ្យសមាជិកក្រុមដទៃទៀតអាចមើលឃើញពួកគេ។ ចូរផ្តល់មតិយោបល់ទៅកាន់សិក្ខាកាមថា សមាជិកក្រុមដែលមានភាពរឹងមាំនៅក្នុងវិស័យជាក់លាក់មួយចំនួន គួរដឹកនាំក្រុមលើវិស័យសមត្ថភាពទាំងនោះ។ បន្ថែមពីនេះទៀត អ្នកគួរផ្តល់យោបល់ថា សិក្ខាកាមដែលមានភាព | |

| | | |
|---|---|---|
| | ផ្សេងៗគ្នា។<br>➢ រៀបចំឱ្យមានគោលនយោបាយច្បាស់លាស់មួយ សម្រាប់បែងចែកប្រយោជន៍ ដោយយោងទៅតាមការរួមចំណែករបស់បុគ្គលនីមួយៗ។<br>➢ ពិនិត្យស្វែងរកប្រភពមូលធនពីខាងក្រៅ។ | |
| ៦ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្ដប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និង មាតិកា នៃវគ្គ សាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលារៀនអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | លំហាត់របស់ពួកគេ ដែលពុំទាន់មានរាយនាមនៅក្នុងសៀវភៅរបស់ពួកគេនៅឡើយ៖<br>➢ ការពិភាក្សាជាក្រុម និងការធ្វើសេចក្ដីសម្រេចចិត្ត ត្រូវប្រើប្រាស់ពេលវេលាច្រើន។<br>➢ អាចខ្វះជំនាញ និង ចំណេះដឹងលើការដឹកនាំ។<br>➢ កសិករមួយចំនួនមិនអនុវត្តតាមវិន័យ។<br>➢ អ្នកខ្លះធ្វើការងារច្រើន ដោយឡែកអ្នកខ្លះទៀតមិនធ្វើការងារអ្វីទាល់តែសោះ។<br>➢ សមាជិកមួយចំនួនអាចជា "អ្នកដែលមានគំនិតមិនស្មើភាព" ដែលរួមចំណែកផ្ដល់វិភាគទានតិចតួច ប៉ុន្តែរំពឹងទទួលបានផលតបស្នងស្មើគេឯង។ការផ្ដល់វិភាគទានរួមចំណែកស្មើភាពគ្នា អាចមានការលំបាក។<br>➢ អាចពុំមានមូលធនគ្រប់គ្រាន់ក្នុងការចាប់ផ្ដើមសហគ្រាស។<br>**ចូរសាកសួរទៅកាន់កសិករអំពីដំណោះស្រាយមួយចំនួន ដែលអាចឆ្លើយតបទៅនឹងបញ្ហាទាំងនោះ៖**<br>ពិនិត្យមើលទៅលើដំណោះស្រាយ ដែលមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ និងអញ្ជើញឱ្យសិក្ខាកាមបន្ថែមគំនិតដទៃទៀត ប្រសិនបើគំនិតទាំងនោះ ពុំទាន់មានរាយនាមនៅក្នុងសៀវភៅលំហាត់នៅឡើយ៖<br>➢ រៀបចំកិច្ចប្រជុំដែលមានការសម្របសម្រួលល្អ ដោយពុំចំណាយពេលយូរ។<br>➢ អនុញ្ញាតឱ្យកសិករធ្វើការជ្រើសរើសប្រធានបទ និងកាលវិភាគដោយខ្លួនឯង។<br>➢ ត្រូវមានការកំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។<br>➢ ផ្ដល់ការបណ្ដុះបណ្ដាលជូនដល់ប្រធានក្រុម ដើម្បីឱ្យពួកគេអាចធ្វើការងាររបស់ពួកគេបានល្អ។<br>➢ កំណត់ទណ្ឌកម្មសម្រាប់អ្នកដែលមិនបានបំពេញតាមតួនាទី។<br>➢ អនុញ្ញាតឱ្យសមាជិកផ្សេងៗគ្នាផ្ដល់វិភាគទានក្នុងទំហំទ្រង់ទ្រាយ | <br>លំហាត់ ៣. ៤ (បន្ត)៖ គុណវិបត្តិដែលអាចកើតមាន និងដំណោះស្រាយ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ➢ លទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ<br>➢ ល័ក្ខខ័ណ្ឌតម្រូវនៃលំហូរសាច់ប្រាក់<br>➢ ប្រភពមូលនិធិ<br>➢ ផលប៉ះពាល់នៃសហគ្រាសទៅលើបុរស និងស្ត្រី<br><br>ចូរបញ្ជាក់ចំពោះពាក្យពេចន៍មួយចំនួននៅលើបញ្ជីវាយនាមនេះ និងពន្យល់ទៅកាន់ សិក្ខាកាមថា ឥឡូវនេះ ពួកគេនឹងបានសិក្សារៀនសូត្រអំពីសហគ្រាសដែលពួកគេបានជ្រើសរើស ទៅតាមចំណងជើងនីមួយៗ ដើម្បីធ្វើការសម្រេចចិត្ត ថាតើវាមានភាពសមស្របក្នុងការបន្តបោះជំហានទៅមុខ ជាមួយនឹងសហគ្រាសនេះដែរ ឬក៏មិនអាចបន្តទៀតបាន។ | |
| ២ | **ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រ៖**<br>ចូរពន្យល់ថា សមាសធាតុទី១ នៃការសិក្សាទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យ របស់សហគ្រាស គឺត្រូវធ្វើការសម្រេចចិត្តទៅលើទស្សនវិស័យ និងគោលដៅរបស់ សហគ្រាស។<br><br>ចូរសួរទៅកាន់សិក្ខាកាម ថាតើពួកគេយល់ដូចម្តេចដែរ ចំពោះពាក្យថា ទស្សនវិស័យ និងគោលដៅ? ចូរសរសេរគំនិតទាំងនេះនៅលើផ្ទាំងក្រដាសធំមួយសន្លឹក បន្ទាប់មក ចូរធ្វើការប្រៀបធៀបជាមួយនិយមន័យនៅក្នុងសៀវភៅលំហាត់របស់ពួកគេ (លំហាត់ ៤.២)។ ចូរពន្យល់ថា ទស្សនវិស័យមួយ អាចលើកទឹកចិត្តពួកគេឱ្យពង្រីកការគិតរបស់ពួកគេក្នុងការធ្វើអ្វីម៉្យាងឱ្យកាន់តែប្រសើរជាងមុន សម្រាប់ខ្លួនពួកគេ និង គ្រួសារ របស់ពួកគេ។ ជាទូទៅ អ្នកដែលគ្មានទស្សនវិស័យ បន្តស្ថិតនៅកម្រិតដដែលក្នុងមួយជីវិតរបស់ពួកគេ ដោយឡែក អ្នកដែលមានទស្សនវិស័យ និងគោលដៅ រមែងតែងធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានភាពប្រសើរឡើង។<br><br>នៅក្នុងអនុក្រុមសហគ្រាសរបស់ពួកគេ ចូរស្នើឱ្យពួកគេឆ្លើយទៅនឹង សំនួរដូចខាង ក្រោម៖<br>១. តើការផលិត និង ប្រាក់ចំណេញ នឹងមានរូបភាពយ៉ាងដូចម្តេចក្នុងរយៈពេល៥ឆ្នាំទៅមុខទៀត?<br>២. តើនៅក្នុងរដូវកាលនេះ អ្នកមានគោលដៅផលិតអ្វី និង គ្រោងទទួលបានប្រាក់ចំណេញប៉ុន្មានដែរ? | ផ្ទាំងក្រដាសធំ និងប៊ិច<br><br><br><br>លំហាត់ ៤.២៖ ទស្សនវិស័យ គោលដៅ និង យុទ្ធសាស្ត្រ |

# ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

## មេរៀនទី៤ ៖ ការសិក្សាទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស

ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រ ការវិភាគទៅលើប្រព័ន្ធ គ្សេត្របរិស្ថាន ការបន្ថែមតម្លៃដែលមានសក្តានុពល សេវាកម្មព័ត៌មានបច្ចេកទេស



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងអាចធ្វើការវាយតម្លៃបាននូវប្រភេទសហគ្រាសដែលសមស្របសំរាប់ពួកគេក្នុងការជ្រើសរើសយកមកប្រកបរបរអាជីវកម្ម និងធ្វើការសម្រេចចិត្តបន្តឬក៏មិនបន្តដំណើរការសហគ្រាស



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ចំណងជើងនៃការសិក្សាទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យ៖**<br>ចូរប្រាប់សិក្ខាកាមថា ពួកគេត្រូវកំណត់ ថាតើសហគ្រាសរបស់ពួកគេ ទំនងនឹងទទួលបានជោគជ័យដែរឬទេ មុនពេលដែលពួកគេបន្តបោះជំហានទៅមុខ ដើម្បីបង្កើតក្រុមសហគ្រាសមួយ។<br><br>ចូរចាប់ផ្តើមតាមរយៈការសួរសំនួរទៅកាន់ក្រុម ថាតើពួកគេត្រូវពិចារណាទៅលើអ្វីខ្លះក្នុងការប៉ាន់ប្រមាណថាតើសហគ្រាសរបស់ពួកគេទំនងនឹងទទួលបានជោគជ័យ ឬ ក៏មិនទទួលបានជោគជ័យ។ ចូរសរសេរចម្លើយរបស់ពួកគេនៅលើ ក្រដាសផ្ទាំងធំមួយសន្លឹក។ ប្រៀបធៀបចម្លើយទាំងនេះទៅនឹងចម្លើយដែលមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ (លំហាត់ ៤.១) ដូចមានរាយនាមខាងក្រោម៖<br><br>➢ ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រ<br>➢ ការវិភាគទៅលើប្រព័ន្ធ គ្សេត្របរិស្ថាន<br>➢ ការវិភាគទៅលើបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់<br>➢ ការបន្ថែមតម្លៃ<br>➢ ការទទួលបានព័ត៌មានបច្ចេកទេស និងសេវាផ្សព្វផ្សាយ<br>➢ តម្រូវការធនធាន និងធនធានដែលមាន<br>➢ លទ្ធភាពក្នុងការស្វែងរកទីផ្សារ<br>➢ ផលប៉ះពាល់ទៅលើបរិស្ថាន<br>➢ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ **(DRR)**<br>➢ ការពិចារណាទៅលើកត្តាសង្គម/វប្បធម៌<br>➢ ហានិភ័យ | ផ្ទាំងក្រដាសធំ និងប៊ិច<br><br><br><br>លំហាត់ ៤.១ ៖ ការដឹកនាំការសិក្សាលើលទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស |

| | | |
|---|---|---|
| | បញ្ចូលទៅក្នុងផែនការថវិកាសហគ្រាសរបស់ពួកគេ ប្រសិនបើសកម្មភាពទាំងនោះមានសារៈសំខាន់ ដើម្បីឱ្យសហគ្រាសរបស់ពួកគេ ទទួលបានជោគជ័យ។<br><br>នៅពេលដែលក្រុមបានបញ្ចប់ការងាររបស់ពួកគេរួចរាល់ ចូរស្នើសុំឱ្យក្រុមនីមួយៗចែក រំលែកលទ្ធផលពិភាក្សារបស់ពួកគេ។ ប្រសិនបើក្រុមសហគ្រាសណាមួយរកឃើញថា សហគ្រាសដែលពួកគេបានជ្រើសរើស មិនស្របទៅនឹងប្រព័ន្ធកេក្សត្របរិស្ថាន សម្រាប់ការងារកសិកម្មរបស់ ពួកគេទេនោះ ពួកគេត្រូវជ្រើសរើសសហគ្រាសមួយផ្សេងទៀត និងធ្វើ លំហាត់នេះឡើងវិញ។<br><br>ប្រសិនបើសិក្ខាកាមពុំមានភាពច្បាស់លាស់អំពីប្រព័ន្ធកេក្សត្របរិស្ថាន និងល័ក្ខខ័ណ្ឌតម្រូវបច្ចេកទេសដទៃទៀតនៃសហគ្រាសដែលពួកគេបានជ្រើសរើសនោះទេ ពួកគេគួរស្វែងរកព័ត៌មាននេះពីបុគ្គលិកផ្សព្វផ្សាយ ឬ ជំនាញការដទៃទៀត។ | |
| ៤ | **ប្រតិទិនសម្មភាពកសិដ្ឋានឬចំការៈ**<br><br>ចូររៀបចំផ្ទាំងក្រដាសមួយសន្លឹក នៅក្នុងទម្រង់ជាប្រតិទិនសកម្មភាពកសិកម្ម។ ចូរអញ្ជើញក្រុមសហគ្រាសឱ្យប្រាប់អំពីឈ្មោះសហគ្រាសដែលពួកគេបានជ្រើសរើស និង ពេលវេលាអនុវត្តសហគ្រាសនោះ ថាតើសហគ្រាសនោះត្រូវអនុវត្តចាប់ពីខែណាដល់ខែណា នៅក្នុងរយៈពេលមួយឆ្នាំនេះ។ ចូរបំពេញព័ត៌មាននេះនៅលើផ្ទាំងក្រដាស។ បន្ថែមពីនេះទៀត អ្នកក៏ត្រូវបំពេញព័ត៌មានអំពីសហគ្រាសដទៃទៀតដែលពួកគេចូលរួម ដើម្បីបង្កើតជាប្រតិទិនសកម្មភាពមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងរយៈពេលមួយឆ្នាំ។<br><br>ចូរប្រាប់សិក្ខាកាមថា វាមានសារៈសំខាន់ខ្លាំងណាស់ ដែលត្រូវយល់អំពីការកំណត់ ពេលវេលានៃសហគ្រាសរបស់ពួកគេផ្សេងៗគ្នា និង សម្រេចចិត្តថាតើសហគ្រាសទាំងនេះ មានភាពប្រកួតប្រជែងគ្នា ឬ បំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ ចូរសរសេរ ពាក្យទាំងពីរនេះ ៖ "ការប្រកួតប្រជែងគ្នា" និង "ការបំពេញបន្ថែមឱ្យគ្នា" នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ឬ ក្ដាខៀន និងសួរទៅកាន់សិក្ខាកាម ថាតើពាក្យទាំងនេះ មានន័យដូចម្ដេច។ នៅក្រោមពាក្យ | ផ្ទាំងក្រដាសធំជាមួយនឹងគំនូសបញ្ជាក់អំពីប្រតិទិនសកម្មភាពកសិកម្ម<br><br><br><br>លំហាត់ ៤.៤៖ ប្រតិទិនសកម្មភាពការងារ |

| | | |
|---|---|---|
| | ៣. តើពួកគេមានបំណងចង់អនុវត្តយុទ្ធសាស្ត្រ (សកម្មភាព) អ្វីខ្លះ ដើម្បីសម្រេច ឱ្យបាននូវទស្សនវិស័យរយៈពេលវែងរបស់ពួកគេ និង គោលដៅសម្រាប់រដូវកាលនេះ?<br><br>ចូរស្នើសុំឱ្យសមាជិកក្រុមធ្វើការចែករំលែកទស្សនវិស័យ គោលដៅ និង យុទ្ធសាស្ត្រ របស់ពួកគេជាមួយសមាជិកដទៃទៀតនៅក្នុងក្រុមធំ។<br><br>ចូរប្រាប់សិក្ខាកាមថា ពួកគេគួរឯកភាពទៅលើទស្សនវិស័យមួយរបស់សហគ្រាស គោលដៅ និងយុទ្ធសាស្ត្រ និងកត់ត្រាចំណុចទាំងអស់នេះទុកនៅក្នុងសៀវភៅលំហាត់របស់ពួកគេ ក្នុងលំហាត់ ៤.២ ដើម្បីជាការណែនាំសម្រាប់ពួកគេនៅក្នុងវគ្គបន្ទាប់។ | |
| ៣ | **ការវិភាគទៅលើប្រព័ន្ធក្សេត្របរិស្ថាន៖** ចូរប្រាប់សិក្ខាកាមថា ពួកគេ ត្រូវពិនិត្យមើល ថាតើប្រព័ន្ធក្សេត្របរិស្ថាន មានភាពសមស្របសម្រាប់ សហគ្រាសដែលពួកគេបានជ្រើសរើសដែរឬទេ។<br><br>ចូរធ្វើការប្រមូលផ្តុំគំនិតតើពាក្យថា ប្រព័ន្ធក្សេត្របរិស្ថាន មានន័យដូចម្តេច។ ចូរសរសេរគំនិតរបស់សិក្ខាកាម នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ឬ ក្តាខៀន។ ឧទាហរណ៍ ចម្លើយរួមមានដូចជា៖ ដី, អាកាសធាតុ, សណ្ឋានដី, ទឹក ។ល។ ដែល សមស្របសម្រាប់សហគ្រាស។<br><br>ស្នើឱ្យសិក្ខាកាមពិនិត្យមើល "ការប៉ាន់ប្រមាណទៅលើប្រព័ន្ធ ក្សេត្រ- បរិស្ថាន" នៅក្នុងលំហាត់ ៤.៣។ ស្នើសុំឱ្យពួកគេធ្វើការងារ ជាក្រុមតូចៗ ដើម្បីពិនិត្យមើល លក្ខណៈវិនិច្ឆ័យ និងសួរសំនួរ ទៅកាន់ ពួកគេ ថាតើមានចំណុចដទៃផ្សេងទៀតពីលទ្ធផលក្រុមធំដែលពួកគេអាចយកមកបញ្ចូល បន្ថែមពីលើចម្លើយនៅក្នុងសៀវភៅលំហាត់នេះដែរឬទេ។ នៅពេលដែលបញ្ជីរាយនាមនេះត្រូវបានពិនិត្យមើល និងបំពេញបន្ថែម រួចរាល់ ចូរស្នើសុំឱ្យពួកគេធ្វើការងារជាក្រុមធំ (តាមរយៈការលើកដៃ ឬ ស្រែក បញ្ចេញសម្លេង) ដើម្បីបញ្ជាក់ថា តើចំណុចណាខ្លះនៅក្នុងលក្ខណៈវិនិច្ឆ័យដែលមានភាព "សមស្រប" ឬ "មិនសមស្រប"។<br><br>ចូរប្រាប់ពួកគេថា ពួកគេអាចធ្វើការផ្លាស់ប្តូរលក្ខណៈសម្បត្តិបន្ថែមមួយចំនួន។ ឧទាហរណ៍ ដូចជា តាមរយៈការ "មានទឹក" អាចប្តូរទៅជា "គ្មានទឹក" ផ្តល់ប្រព័ន្ធធារាសាស្ត្រ។ ពួកគេគួរធ្វើការកត់ត្រាអំពីការផ្លាស់ប្តូរដែល ចាំបាច់ សម្រាប់សហគ្រាសរបស់ពួកគេ នៅក្នុងតួឡោនទី៣ នៅផ្នែកខាងស្តាំ។ សកម្មភាពដែលចាំបាច់ដើម្បីផ្លាស់ប្តូរស្ថានភាពរបស់ពួកគេ នឹងត្រូវ | ផ្ទាំងក្រដាសធំ និងប៊ិច<br><br><br><br>លំហាត់ ៤.៣ ៖ ការវិភាគទៅលើ ប្រព័ន្ធក្សេត្រសាស្ត្រ បរិស្ថាន |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | គំនិតចុងក្រោយ។ ចូរសរសេរាល់គំនិតទាំងអស់នៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរប្រាប់សិក្ខាកាមថា ដំណោះស្រាយមួយចំនួនដែលត្រូវបានកំណត់រកឃើញនៅក្នុងការវិភាគនេះ អាចត្រូវបញ្ចូលនៅក្នុងសកម្មភាព និងខ្ទង់ចំណាយចវិការបស់ពួកគេ ដើម្បីឱ្យសហគ្រាសដែលត្រូវបានជ្រើសរើសទទួលបានជោគជ័យ។ | |
| ៦ | **ការបន្ថែមតម្លៃ៖**<br><br>មុនពេលចាប់ផ្តើមវគ្គនេះ អ្នកសម្របសម្រួល (ឬ សិក្ខាកាម) គួរយកមកជាមួយនូវ ផលិតផលដែលពួកគេបានជ្រើសរើស និង ឧទាហរណ៍នៃដំណាក់កាលនីមួយៗ នៃផលិតផលដែលតម្លៃត្រូវបានគេបន្ថែម។ ឧទាហរណ៍ ៖ ស្រូវ ៥គីឡូក្រាម និងកញ្ចប់ អង្ករ ៥គីឡូក្រាម ដែលគេលក់នៅក្នុងផ្សារទំនើប និងការពន្យល់អំពីរាល់គ្រប់ជំហាន ទាំងអស់ដែលបានកើតឡើងនៅចន្លោះពេលនោះ។<br><br>អ្នកសម្របសម្រួល (ឬ សិក្ខាកាមដែលត្រូវបានជ្រើសរើស) គួរបង្ហាញអំពីឧទាហរណ៍ និងសួរគ្នាទៅវិញទៅមក ៖ "ប្រសិនបើពួកគេមានជម្រើសក្នុងការទទួលបាននូវផលិតផល ដើម ឬ ផលិតផលដែលកែច្នៃរួច តើពួកគេចង់បានផលិតផលមួយណា?" (សិក្ខាកាមភាគច្រើននឹងនិយាយថា ពួកគេចង់បានផលិតផលដែលមានការបន្ថែមតម្លៃរួចជាស្រេច)។ ចូរសួរសំនួរថា តើផលិតផលណាមួយដែលទំនងនឹងទទួលបានតម្លៃខ្ពស់ជាង? ចូរពិភាក្សាអំពីមូលហេតុ។ | |
| ៧ | ចូរណែនាំ ពីការពិភាក្សាលើករណីដែលពិតប្រាកដបានកើតឡើងដែលផលិតផលលក់បានតម្លៃខ្ពស់ជាងមុនតាមរយៈអត្ថប្រយោជន៍ដូចខាងក្រោម៖<br><br>➢ គុណភាពខ្ពស់ជាង<br>➢ បរិមាណសមស្រប<br>➢ រយៈពេលរក្សាទុកកាន់តែយូរជាងមុន | <br>លំហាត់ ៤.៧៖ យុទ្ធសាស្ត្រ បន្ថែមតម្លៃ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | នីមួយៗនេះ ចូរកត់ត្រាចម្លើយរបស់សិក្ខាកាម បន្ទាប់មក ចូរស្នើសុំឱ្យពួកគេពិនិត្យមើលលំហាត់ ៤.៥ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ និងផ្តល់ការពន្យល់ដូចខាងក្រោម ៖<br>➢ សហគ្រាសដែលប្រកួតប្រជែងគ្នា ទាញធនធានពីសហគ្រាសដទៃទៀត - ឧ. សណ្តែកបាយ និង សណ្តែកសៀង ត្រូវបានដាំដុះនៅក្នុងរដូវកាលតែមួយ នៅលើប្រភេទដីតែមួយដូចគ្នា។ ដូច្នេះ ពួកគេប្រកួតប្រជែងគ្នាលើបញ្ហាដី ដាំដុះកម្លាំងពលកម្ម និងធនធាន។<br>➢ សហគ្រាសដែលបំពេញបន្ថែមឱ្យគ្នា ជួយដល់សហគ្រាសដទៃទៀត - ឧ. ជ្រូកដែលចិញ្ចឹមនៅលើស្រះត្រី ជួយបំពេញបន្ថែមដល់ចំណីត្រី។<br>ចូរធ្វើការបូកសរុបដោយស្នើសុំឱ្យសិក្ខាកាមសម្រេចចិត្ត ថាតើសហគ្រាសដែលពួកគេបានជ្រើសរើស មានលក្ខណៈស្របទៅនឹងប្រតិទិនសកម្មភាពរបស់ពួកគេ កម្លាំងពលកម្ម ដែលមាន និងធនធានដទៃទៀត ព្រមទាំងមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន ទៅលើប្រព័ន្ធកសិកម្មរបស់ពួកគេ ដែរឬទេ។ | <br>លំហាត់ ៤.៥ ៖ ការវាយតម្លៃសហគ្រាសមួយធៀបទៅនឹងសកម្មភាពដទៃទៀត |
| ៥ | **ការវិភាគបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់៖**<br>ចូររំលឹកសិក្ខាកាមថា នៅពេលពិភាក្សាអំពីការធ្វើកសិកម្មក្នុងលក្ខណៈជាអាជីវកម្មពួកគេគួរទទួលស្គាល់ថា មានខ្សែសង្វាក់តួអង្គមួយចំនួនចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការអាជីវកម្មកសិកម្មជាក់លាក់មួយ។<br>ចូរអញ្ជើញសិក្ខាកាមឱ្យរៀបចំបង្កើតអនុក្រុមរបស់ពួកគេ និង បំពេញតួអង្គផ្សេងៗគ្នានៅក្នុងខ្សែសង្វាក់សហគ្រាស ដែលពួកគេបានជ្រើសរើសទៅក្នុងប្រអប់ទទេ ក្នុងសៀវភៅលំហាត់របស់ពួកគេ (លំហាត់ ៤.៦) ក្នុងលក្ខណៈមួយដែលស្រដៀងគ្នា ទៅនឹងមេរៀនទី១ អំពីសកម្មភាពវិភាគសេចក្តីត្រូវការបណ្តុះបណ្តាល កាលពីលើកមុនដូច្នោះដែរ។ ចូរស្នើសុំឱ្យអនុក្រុមសហគ្រាសនីមួយៗ សរសេររាយនាមបញ្ហាដែលអាចកើតមានជាមួយតួអង្គនីមួយៗ។ សម្រាប់បញ្ហានីមួយៗ ចូរអញ្ជើញឱ្យពួកគេផ្តល់ដំណោះស្រាយចំពោះបញ្ហាទាំងនោះ (ដើម្បីសន្សំសំចៃពេលវេលាពិភាក្សាក្រុមចូរស្នើសុំឱ្យអនុក្រុមនីមួយៗជ្រើសរើសយកតួអង្គតែមួយប៉ុណ្ណោះព្រមជាមួយនឹងបញ្ហានិង ដំណោះស្រាយ)។ នៅក្នុងក្រុមធំចូរស្នើសុំឱ្យតំណាងក្រុមនីមួយៗរាយការណ៍អំពីគំនិតរបស់ពួកគេមួយចំនួន ក្រោមចំណងជើងនីមួយៗ និងលើកទឹកចិត្តឱ្យមានការពិភាក្សា និងប្រមូលយក | ផ្ទាំងក្រដាសធំ ជាមួយនឹង ចំណងជើង អំពីខ្សែសង្វាក់ផ្គត់ផ្គង់<br><br>លំហាត់ ៤.៦៖ ការសិក្សាពីបញ្ហា ខ្សែសង្វាក់ផ្គត់ផ្គង់និងស្វែងរកដំណោះស្រាយ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | នឹងការងារ និងតម្លៃបន្ថែមដែរឬទេ និង ត្រូវធានាថាពួកគេមានទីផ្សារសម្រាប់ផលិតផល សម្រេចចុងក្រោយរបស់ពួកគេ។ | |
| ៨ | **ការទទួលបានព័ត៌មានបច្ចេកទេស និងសេវាផ្សព្វផ្សាយ៖**<br><br>ចូរផ្តោតយកចិត្តទុកដាក់ទៅលើផលិតផលដែលបានជ្រើសរើស និងធ្វើការប្រមូលផ្តុំ គំនិតជាមួយសិក្ខាកាម ដោយឆ្លើយទៅនឹងសំនួរខាងក្រោម។ ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>➢ តើពួកគេត្រូវការព័ត៌មានបច្ចេកទេសអ្វីខ្លះ?<br>➢ តើពួកគេអាចទទួលបានព័ត៌មានបច្ចេកទេសទាំងនោះ ពីកន្លែងណា?<br>➢ តើការទទួលបានព័ត៌មានទាំងនេះ នឹងត្រូវចំណាយថវិកាប៉ុន្មាន?<br><br>សូមអញ្ជើញឱ្យសិក្ខាកាមសរសេរចម្លើយទៅក្នុងសៀវភៅលំហាត់របស់ពួកគេក្រោម លំហាត់ ៩.៨។<br><br>ស្នើឱ្យសិក្ខាកាមដាក់ពិន្ទុទៅលើសេវាព័ត៌មានបច្ចេកទេស ដោយផ្តល់លេខ ១ សម្រាប់សេវាដែលល្អបំផុត និង លេខ២ សម្រាប់សេវាដែលល្អបន្ទាប់.... ។ល។<br><br>សួរទៅកាន់ក្រុមថា ហេតុអ្វីបានជា................គឺជាសេវាដែលល្អជាងគេ និង ហេតុអ្វី បានជា...............គឺជាសេវាដែលល្អបន្ទាប់។ បន្ទាប់មក ចូរសួរទៅកាន់ពួកគេអំពី របៀបដែលពួកគេនឹងភ្ជាប់ទំនាក់ទំនងទៅនឹងប្រភពព័ត៌មានបច្ចេកទេស ដែលពួកគេចូលចិត្ត។<br><br>ចូររំលឹកពួកគេថា សកម្មភាពក្នុងការទទួលបានព័ត៌មានបច្ចេកទេស និង ថ្លៃចំណាយរបស់វា គួរបញ្ចូលទៅក្នុងផែនការអាជីវកម្មរបស់សិក្ខាកាម។ | <br>លំហាត់ ៩.៨ ៖ ការទទួលបានព័ត៌មានបច្ចេកទេស និង សេវាផ្សព្វផ្សាយ |

- ការវេចខ្ចប់មានភាពគួរឱ្យទាក់ទាញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់
- រួចរាល់សម្រាប់ការប្រើប្រាស់ភ្លាមៗ (សន្សំពេលវេលា)

សូមអញ្ជើញសិក្ខាកាមឱ្យបន្ថែមអត្ថប្រយោជន៍ដទៃទៀតនៃការបន្ថែមតម្លៃនៅក្នុងចន្លោះដែលមានផ្តល់ជូននៅក្នុងលំហាត់ ៤.៧ នៃសៀវភៅលំហាត់របស់ពួកគេ (ឧទាហរណ៍៖ រសជាតិប្រសើរជាងមុន )។

បន្ទាប់មក ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយសិក្ខាកាមអំពីដំណាក់កាលនៃការបន្ថែម តម្លៃចំពោះផលិតផលដែលពួកគេបានជ្រើសរើស។ ចូរសរសេរចម្លើយទាំងនោះ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក និង សូមឱ្យអនុក្រុម តួចៗចម្លងចំណាងជើងទាំងនេះ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ក្រោយមក ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការគណនាតម្លៃនៃដំណាក់កាលកែច្នៃនីមួយៗរបស់ផលិតផលដែលពួកគេបានជ្រើសរើស។ ដើម្បីជួយដល់ការអនុវត្តលំហាត់នេះ ចូរស្នើសុំ ឱ្យអនុក្រុមនីមួយៗធ្វើការប៉ាន់ប្រមាណទៅលើការប្រែប្រួលតម្លៃពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត ទៅលើឧទាហរណ៍អំពីអង្ករដែលបានពិភាក្សាខាងដើម។ បន្ទាប់មក ពួកគេគួរសរសេរអំពីភាពខុសគ្នានៃតម្លៃពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀតនៃការកែច្នៃផលិតផលរបស់ពួកគេ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

បន្ទាប់មក ចូរស្នើសុំឱ្យអនុក្រុមសរសេរអំពីសកម្មភាពដែលពួកគេត្រូវធ្វើដើម្បីសម្រេចឱ្យបាននូវការបន្ថែមតម្លៃនៅដំណាក់កាលនីមួយៗនៃដំណើរការបន្ថែមតម្លៃ។ ចូរចំណាយពេលប្រមាណពី ៥-១០នាទី ដើម្បីធ្វើសកម្មភាពនេះ បន្ទាប់មក ចូរពិភាក្សាអំពីគំហើញរបស់ពួកគេនៅក្នុងក្រុមធំ។ ប្រសិនបើអនុក្រុមមិនទាន់បានបញ្ចប់ភារកិច្ចនេះនៅឡើយទេនោះ ពួកគេអាចធ្វើពេលក្រោយបាន។

ជាចុងក្រោយ ចូរសួរទៅកាន់សិក្ខាកាម ថាតើពួកគេមានបំណង "បន្ថែមតម្លៃ" ទៅលើផលិតផលដែលពួកគេបានជ្រើសរើស មុនពេលលក់ដែរឬទេ។ ប្រសិនបើដូច្នេះ ពួកគេគួរបញ្ចូលសកម្មភាព សម្ភារៈកសិកម្មពលកម្ម និង ថ្លៃចំណាយដទៃទៀត និង តម្លៃដែលខ្ពស់ជាងមុនសម្រាប់ផលិតផលទៅក្នុងខ្ទង់ចរិការបស់ពួកគេ។

ចូររំលឹកពួកគេឱ្យធ្វើការពិចារណាថាតើអត្ថប្រយោជន៍មានតម្លៃសក្តិសមទៅ

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

### មេរៀនទី៤៖ លទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស (បន្ត)

**ធនធានដែលត្រូវការ និងអាចរកបាន សិក្សាពីទីផ្សារ ផលប៉ះពាល់ទៅលើបរិស្ថាន ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ការពិចារណា ទៅលើផលប៉ះពាល់ផ្នែកសង្គម/វប្បធម៌ និងហានិភ័យ**



គោលបំណង

ដើម្បីបន្តពិនិត្យមើលទៅលើលទ្ធភាពនៃការទទួលបានជោគជ័យ ចំពោះសហគ្រាសដែលត្រូវបានជ្រើសរើស រាប់បញ្ចូលធនធានដែលមាន និងគុណភាពទីផ្សារ ផលប៉ះពាល់ទៅលើបរិស្ថាន ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ការពិចារណាទៅលើផលប៉ះពាល់ ផ្នែកសង្គម/វប្បធម៌ និងហានិភ័យ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **សម្គាល់៖** ប្រសិនបើសិក្ខាកាមមិនសូវប្រាកដក្នុងចិត្តអំពីសេចក្ដីត្រូវការ សម្ភារៈផលិតកម្មកសិកម្មរបស់ពួកគេទេនោះ សូមអញ្ជើញទីប្រឹក្សាបច្ចេកទេសមួយរូបដើម្បីឱ្យបង្ហាញអំពីគោលការណ៍ណែនាំ "ការអនុវត្តល្អ" សម្រាប់សិក្ខាកាមពិចារណា។ធនធាននិងសម្ភារៈដែលអាចរកបាន និងមានគុណភាពខ្ពស់៖<br><br>ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការពិភាក្សានៅក្នុងអនុក្រុមតូចៗរបស់ពួកគេ អំពីតើសហគ្រាសរបស់ពួកគេត្រូវការសម្ភារៈ អគារ ឧបករណ៍ និងគ្រឿងចក្រអ្វីខ្លះសម្រាប់ដំណាំ។ សម្ភារៈទាំងនេអាចរួមមាន សម្ភារៈម្មកសិកម្មមួយចំនួនដូចជា គ្រាប់ពូជ ជី និង ថ្នាំសម្លាប់សត្វល្អិត ឧបករណ៍ ដូចជា រនាស់/នង្គ័ល ឧបករណ៍ប្រើប្រាស់ដោយដៃ និងជង្រុក ព្រមទាំងសត្វពាហនៈសម្រាប់ជាកម្លាំងអូសទាញ។ សម្ភារៈ ផលិតកម្មសម្រាប់ការចិញ្ចឹមសត្វអាចរួមមានដូចជា ចំណីសត្វ ថ្នាំ ឧបករណ៍នានា របង និង សម្ភារៈតូចៗ។ ធនធានទាំងនេះ គួររាប់បញ្ចូលធាតុចូល ឬសម្ភារៈដែលមាននៅឯកសិដ្ឋាន ឬស្រែចម្ការព្រមទាំងសម្ភារៈដែលទិញពីប្រភពខាងក្រៅ។<br><br>សូមអញ្ជើញឱ្យសិក្ខាកាមពិភាក្សាអំពីគំនិតរបស់ពួកគេនៅក្នុងក្រុមធំ និង | ផ្ទាំងក្រដាសធំ និងប៊ិច<br><br><br><br>លំហាត់ ៤.៩ ៖ ធនធានត្រូវការនិងដែលអាចរកបាន |

| | | |
|---|---|---|
| ៩ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗ ដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br><br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br><br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកានៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | ចូរប្រាប់សិក្ខាកាមថា នៅក្នុងគូឡោនទី៣ នៃតារាងរបស់ពួកគេ ពួកគេគួរធ្វើការ វាយតម្លៃទៅលើគុណភាពនៃសម្ភារៈផលិតកម្មកសិកម្មរបស់ពួកគេ។<br><br>ចូរសង្ខេបដោយនិយាយថា ប្រសិនបើកសិករអាចទទួលបាននូវរាល់ធនធានប្រកបដោយគុណភាពដែលពួកគេត្រូវការ នៅពេលនោះ ពួកគេអាចចាប់ផ្តើមធ្វើសហគ្រាស ដែលពួកគេជ្រើសរើសបានហើយ។ ប្រសិនបើពួកគេមិនអាចរកបាននូវធនធានមួយចំនួនពួកគេត្រូវស្វែងរកប្រភពនៃការផ្គត់ផ្គង់ថ្មីដទៃទៀត។ ប្រសិនបើពួកគេមិនអាចរកបានប្រភពផ្គត់ផ្គង់ដទៃទៀតទេនោះ ពួកគេអាចត្រូវជ្រើសរើសសហគ្រាសមួយទៀត។ | |
| ២ | **ការសិក្សាពីទីផ្សារ៖**<br>**សម្គាល់៖** ប្រសិនបើវាមានភាពច្បាស់លាស់ថា សិក្ខាកាមពុំមានភាពប្រាកដក្នុងចិត្ត អំពីផលិតផលដែលពួកគេត្រូវផលិតទេនោះ ពួកគេគួរធ្វើការអង្កេតទីផ្សារពេញលេញមួយ ដើម្បីទទួលបានតម្លៃរបស់ផលិតផលជាច្រើនផ្សេងៗគ្នារៀងរាល់ខែក្នុងរយៈពេលមួយឆ្នាំពេញ សម្រាប់ធ្វើការប្រៀបធៀប និងពិនិត្យមើល ថាតើផលិតផលណាមួយដែលផ្តល់ឱ្យពួកគេនូវ ឱកាសទីផ្សារប្រសើរបំផុត។ អនុក្រុមតូចៗនីមួយៗ អាចជ្រើសរើសផលិតផលខុសពីគ្នា ឧទាហរណ៍ ដូចជា ប្រភេទបន្លែផ្សេងគ្នា ឬ ប្រភេទអង្ករ ផ្សេងគ្នា ដើម្បីធ្វើការសិក្សា និងរាយការណ៍ទៅឱ្យក្រុមវិញ។ ចូរប្រាប់ពួកគេឱ្យរក្សាឈ្មោះ និង លេខទូរស័ព្ទទំនាក់ទំនងរបស់អ្នកដែលផ្តល់ព័ត៌មានឱ្យពួកគេ។ ព័ត៌មានទំនាក់ទំនងទាំងនេះ នឹងមានសារៈប្រយោជន៍សម្រាប់ ពួកគេដើម្បីធ្វើការត្រួតពិនិត្យតម្លៃផលិតផល ក្នុងរយៈពេលពេញមួយឆ្នាំ។<br><br>ចូរណែនាំគំនិតអំពីការដែលត្រូវមានផែនការទីផ្សារមួយ។ ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការពិភាក្សានៅក្នុងអនុក្រុមតូចៗរបស់ពួកគេអំពី តើកត្តាអ្វីខ្លះដែលបង្កឱ្យមានផលប៉ះពាល់ទៅលើតម្លៃផលិតដែលពួកគេចង់លក់។ ៥នាទីក្រោយមក ចូរអញ្ជើញសិក្ខាកាមឱ្យរាយការណ៍ត្រឡប់ទៅកាន់ក្រុមធំវិញ។ ចូរប្រមូលផ្តុំចម្លើយរបស់ពួកគេ ដាក់ជាក្រុមទៅលើផ្ទាំងក្រដាសធំមួយសន្លឹក ក្រោមចំណងជើងដែលត្រូវបានគូសបញ្ជាក់ដូចខាងក្រោម៖<br><br>១. ទីផ្សារមួយអាចមានវត្តមានទៅបាន លុះត្រាណាតែនរណាម្នាក់មានឆន្ទៈក្នុងការទិញផលិតផល។ នេះគេហៅថា តម្រូវការទីផ្សារ។ | <br>លំហាត់ ៤.១០ ៖ ការសិក្សាពីទីផ្សារ |

| | | |
|---|---|---|
| | សរសេរគំនិតទាំងនោះនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ បន្ទាប់មក ចូរស្នើឱ្យសិក្ខាកាមសរសេរបញ្ជីរាយនាមចុងក្រោយ អំពីសេចក្តីត្រូវការធនធានរបស់ពួកគេ នៅក្នុងសៀវភៅលំហាត់របស់ពួកគេក្នុងលំហាត់ ៤.៩។ នៅចុងបញ្ចប់នៃលំហាត់នេះ សិក្ខាកាមគួរទទួលបានបញ្ជីរាយនាមគ្រប់ជ្រុងជ្រោយមួយ អំពីធនធានដែលពួកគេត្រូវការសម្រាប់សហគ្រាសដែល ពួកគេបានជ្រើសរើស។ | |
| ១.១ | នៅពេលដែលបញ្ជីរាយនាមអំពីសម្ភារៈផលិតកម្មកសិកម្ម ត្រូវបានធ្វើបញ្ចប់រួចរាល់ឥឡូវនេះ សិក្ខាកាមគួរបំពេញនៅក្នុងគូឡោនទី២៖ ប្រភពនៃការផ្គត់ផ្គង់។ ពួកគេគួរធ្វើការកត់ត្រាថា ធាតុចូល ឬសម្ភារៈទាំងនេះ មានប្រភពមកពីកសិដ្ឋាន ឬស្រែចម្ការរបស់ពួកគេ ឬសរសេររាយនាមអំពីប្រភពផ្គត់ផ្គង់ពីខាងក្រៅ។<br><br>ចូរសួរទៅកាន់សិក្ខាកាមថា៖ "ប្រសិនបើពុំមានធនធាននៅក្បែរភូមិ តើពួកគេនឹងត្រូវស្វែងរកធនធានទាំងនោះពីកន្លែងណា?" ចូរលើកទឹកចិត្តសិក្ខាកាមឱ្យចែករំលែកបញ្ជីរាយនាមអំពីព័ត៌មានទំនាក់ទំនង និងរក្សាទុកនូវទិន្នន័យនេះ សម្រាប់ជាឯកសារយោង នៅពេលក្រោយ។ | <br>លំហាត់ ៤.៩ ៖ ធនធានត្រូវការនិងដែលអាចរកបាន |
| ១.២ | **គុណភាពនៃសម្ភារៈផលិតកម្មកសិកម្ម៖**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើវាមានសារៈសំខាន់ដែរឬទេ ក្នុងការទទួលបានសម្ភារៈផលិតកម្មកសិកម្មដែលមានគុណភាពល្អ? ហេតុអ្វី?<br><br>ចូររំលឹកសិក្ខាកាមថា ប្រសិនបើពួកគេទិញសម្ភារៈផលិតកម្មកសិកម្មក្នុងតម្លៃទាប ជាទូទៅ សម្ភារៈផលិតកម្មកសិកម្មទាំងនោះ តែងមានគុណភាពទាប។ សម្ភារៈផលិតកម្មកសិកម្មដែលមានគុណភាពទាប មិនអាចប្រើប្រាស់បានយូរអង្វែង ផ្តល់នូវសក្តានុពលទិន្នផលទាប និងមិនសូវធន់ទៅនឹងសត្វល្អិតចង្រៃ និងជំងឺឡើយ។ កសិករអាចជាសន្សំថវិកាបានមួយចំនួន នៅពេលចាប់ផ្តើមសហគ្រាសរបស់ពួកគេដំបូង ដោយការទិញសម្ភារៈផលិតកម្មកសិកម្មដែលមានគុណភាពទាប ប៉ុន្តែ ពួកគេនឹងខាតបង់ នៅពេលចុងក្រោយ ដោយសារតែពួកគេទទួលបានទិន្នផលទាប តម្លៃទាប និងត្រូវចំណាយថវិកាច្រើនទៅលើការជួសជុលជង្រុក ឬ ទ្រុងសត្វ និងការគ្រប់គ្រងទៅលើ សត្វល្អិតចង្រៃ និងជំងឺនានា។ ចូរប្រាប់កសិករថា ពួកគេត្រូវថ្លឹងថ្លែងរវាងតម្លៃជាមួយនឹងគុណភាព នៅពេលដែលពួកគេសម្រេចចិត្តទិញធនធានរបស់ពួកគេ សម្រាប់ប្រើប្រាស់។ | <br>លំហាត់ ៤.៩ ៖ ធនធានត្រូវការនិងដែលអាចរកបាន |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ចូរសួរទៅកាន់សិក្ខាកាម ថាតើមានលក្ខខ័ណ្ឌតម្រូវណាមួយ ដែលទាក់ទងទៅនឹងគុណភាពដើម្បីឱ្យស្របទៅនឹងសេចក្ដីត្រូវការរបស់ទីផ្សារដែល ពួកគេបានជ្រើសរើស ដែរឬទេ។ ប្រសិនបើយ៉ាងដូច្នេះ តើលក្ខខ័ណ្ឌតម្រូវទាំងនោះមានអ្វីខ្លះ? ចូរកត់ត្រាលក្ខខ័ណ្ឌតម្រូវទាំងនោះនៅលើផ្ទាំងក្រដាសធំមួយសន្លឹក និង ប្រាប់សិក្ខាកាមឱ្យចម្លងលក្ខខ័ណ្ឌតម្រូវទាំងនោះ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ ក្រោមសកម្មភាពទី២ លំហាត់៤.១០។<br><br>ចូររំលឹកសិក្ខាកាមថា ប្រសិនបើពួកគេត្រូវអនុវត្តសកម្មភាព និងប្រើប្រាស់ថ្លៃចំណាយមួយចំនួន ដើម្បីឱ្យស្របទៅនឹងលក្ខខ័ណ្ឌតម្រូវផ្នែកគុណភាពទាំងនោះ ពួកគេគួរបញ្ចូលសកម្មភាព និងថ្លៃចំណាយទាំងអស់នេះ ទៅក្នុងផែនការសកម្មភាពនិងខ្ទង់ថវិកាសហគ្រាសរបស់ពួកគេផងដែរ។<br>ឧទាហរណ៍ ការទិញគ្រាប់ពូជសុទ្ធល្អ ដើម្បីទទួលបានតម្លៃកាន់តែខ្ពស់នៅពេលលក់ ជាជាងការប្រើប្រាស់គ្រាប់ពូជចម្រុះ ដែលនាំឱ្យទទួលបានតម្លៃទាប។ | <br>លំហាត់ ៤.១០<br>សកម្មភាពទី២ ៖<br>តម្រូវការគុណភាព |
| ២.៣ | **តម្លៃលក់នៅឯកសិដ្ឋាន ឬ ស្រែចម្ការ និងតម្លៃលក់នៅឯទីផ្សារ៖**<br>ចូរពន្យល់ថា តម្លៃដែលសិក្ខាកាមទទួលបានសម្រាប់ផលិតផលរបស់ពួកគេទទួលរងឥទ្ធិពលពីកត្តាជាច្រើន។ កត្តាមួយ គឺទីកន្លែងដែលពួកគេលក់ផលិតផលរបស់ពួកគេ។ កសិករអាចលក់ផលិតផលរបស់ពួកគេ ទៅឱ្យអ្នកទិញដែលមកដល់កសិដ្ឋាន ឬ ស្រែចម្ការរបស់ពួកគេផ្ទាល់ នៅឯទីផ្សារដែលជិតពួកគេបំផុត ឬ នៅឯទីផ្សារដទៃទៀត ដែលនៅឆ្ងាយ។ អ្នកទិញនីមួយៗ នឹងផ្ដល់តម្លៃខុសៗគ្នាសម្រាប់ផលិតផលរបស់ពួកគេ អាស្រ័យទៅលើកន្លែងដែលពួកគេលក់ផលិតផល។<br><br>ចូរប្រាប់សិក្ខាកាមថា នៅពេលដែលអ្នកទិញមកកសិដ្ឋាន ឬស្រែចម្ការរបស់ពួកគេ ដើម្បីទិញផលិតផលពួកគេផ្ដល់ឱ្យកសិករនូវ "តម្លៃនៅឯ កសិដ្ឋាន ឬស្រែចម្ការ"។ ជាធម្មតា នេះគឺជាតម្លៃទាបបំផុត ដែលកសិករនឹងទទួលបានសម្រាប់ផលិតផលរបស់ពួកគេ។ យ៉ាងណាមិញ ការលក់ផលិតផលនៅឯកសិដ្ឋាន ឬស្រែចម្ការ ពុំមានពាក់ព័ន្ធ ទៅនឹងការដឹកជញ្ជូន ការវេចខ្ចប់ និងថ្លៃចំណាយដទៃទៀតដែលទាក់ទងទៅនឹងទីផ្សារឡើយ ដូច្នេះ ខណៈពេលដែលតម្លៃលក់ផលិតផលមានកម្រិតទាប ថ្លៃចំណាយ | |

| | | |
|---|---|---|
| | ជាធម្មតា កាលណាមានតម្រូវការខ្ពស់ មានន័យថាទទួលបានតម្លៃកាន់តែខ្ពស់។<br>២. ប្រសិនបើមានការផ្គត់ផ្គង់ (បរិមាណ) ច្រើនលើសលុប ផលិតផលនឹងទទួលបានតម្លៃទាប ឬ លក់មិនដាច់។ ជាធម្មតា ការផ្គត់ផ្គង់កម្រិតមួយទាប តែងមានន័យថា ទទួលបានតម្លៃកាន់តែប្រសើរ។<br>៣. នៅក្នុងករណីភាគច្រើន គុណភាពរបស់ផលិតផល តែងបង្កឱ្យមានផលប៉ះពាល់ទៅលើតម្លៃ។ កាលណាមានគុណភាពល្អ នាំឱ្យទទួលបានតម្លៃកាន់តែ ប្រសើរ។<br>៤. ពេលវេលានៃការលក់ ក៏មានសារៈសំខាន់ខ្លាំងផងដែរ ដើម្បីទទួលបានតម្លៃប្រសើរបំផុត។ ប្រសិនបើពួកគេលក់ផលិតផលនៅលើទីផ្សារនៅពេលដែលមានផលិតផលប្រភេទដូចគ្នាច្រើនហួសប្រមាណនោះ ពួកគេនឹងទទួលបានតម្លៃទាប។នៅពេលដែលពួកគេលក់ផលិតនៅលើទីផ្សារ មិនសូវមានផលិតផលប្រភេទដូចគ្នា ពេលនោះពួកគេនឹងទទួលបានតម្លៃខ្ពស់ជាង។ នៅពេលដែលមានឱកាសពិសេសៗ ដូចជាពិធីបុណ្យអ្វីមួយ ពេលនោះ តម្លៃរមែងតែងនៅតែខ្ពស់ដដែល។<br>ចូរសង្ខេបដោយនិយាយថា សិក្ខាកាមត្រូវមានផែនការមួយដើម្បីទទួលបានតម្លៃខ្ពស់ ល្មមសម្រាប់ផលិតផលរបស់ពួកគេ ដើម្បីឱ្យពួកគេអាចទូទាត់ថ្លៃចំណាយ និងទទួលបានប្រាក់ចំណេញមួយចំនួន។ | |
| ២.១ | ស្នើសុំឱ្យសិក្ខាកាមធ្វើការពិភាក្សានៅក្នុងអនុក្រុមតូចៗរបស់ពួកគេ ទៅលើសំនួរនៅក្នុងសកម្មភាពទី១ អំពីច្រកចេញទៅកាន់ទីផ្សារ ឬ អ្នកទិញផលិតផល (លំហាត់ ៤.១០) នៅក្នុងសៀវភៅលំហាត់របស់ពួកគេ និងធ្វើការកត់ត្រាចម្លើយ។<br>- តើពួកគេស្គាល់បណ្តាញ និងច្រកចេញទៅកាន់ទីផ្សារ ឬ អ្នកទិញណាខ្លះ សម្រាប់ផលិតផល ដែលពួកគេបានជ្រើសរើស?<br>- ចូរសរសេរឈ្មោះ និងគុណសម្បត្តិ និងគុណវិបត្តិនៃច្រកចេញទៅកាន់ទីផ្សារ ឬ អ្នកទិញនីមួយៗ។<br>សូមអញ្ជើញឱ្យសិក្ខាកាមរាយការណ៍ទៅកាន់ក្រុមធំ។ | <br>លំហាត់ ៤.១០<br>សកម្មភាពទី១ ៖<br>សំនួរអំពីទីផ្សារ |
| ២.២ | គុណភាព៖ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ២.៤ | **ពេលវេលានៃការលក់៖**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើពេលវេលានៃការលក់ផលិតផលរបស់ពួកគេនាំឱ្យប៉ះពាល់ទៅលើតម្លៃដែរឬទេ? ចូរសួរពួកគេថា ហេតុអ្វីបានជាពួកគេនិយាយដូច្នេះ? ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក បន្ទាប់មក សូមឱ្យពួកគេចម្លងចម្លើយទៅក្នុងសកម្មភាពទី៤ លំហាត់ ៤.១០ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ។<br><br>សូមឱ្យសិក្ខាកាមបំពេញនៅក្នុងតារាងតម្លៃប្រចាំឆ្នាំ ក្រោមសកម្មភាពទី៤ លំហាត់ ៤.១០ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ ដើម្បីជួយឱ្យពួកគេយល់ថា តម្លៃរមែងតែងមានការប្រែប្រួលពីមួយពេលទៅមួយពេលជានិច្ចជាធម្មតា តម្លៃធ្លាក់ចុះទាបនៅពេលដែលបរិមាណនៃការផ្គត់ផ្គង់មានកម្រិតខ្ពស់ ហើយតម្លៃឡើងខ្ពស់ នៅពេលដែលការផ្គត់ផ្គង់មានកម្រិតទាប។ ប្រសិនបើមានផលិតផលច្រើន (ដូចជា បន្លែ) ចូរធ្វើការបែងចែកប្រភេទបន្លែមួយមុខ ទៅឱ្យក្រុមនីមួយៗដើម្បីសន្សំពេលវេលា។ ចូរប្រាប់ពួកគេថា វារមែងតែងមានការពិបាកក្នុងការព្យាករណ៍តម្លៃសម្រាប់ឆ្នាំបន្ទាប់ ឱ្យបានពិតប្រាកដណាស់ (លើកលែងតែពួកគេមានកិច្ចសន្យាមួយដែលកំណត់តម្លៃជាក់លាក់)។ ចូរនិយាយថា វិធីប្រសើរបំផុត ក្នុងការព្យាករណ៍តម្លៃនៅពេលអនាគត គឺត្រូវសិក្សា ទៅលើនិន្នាការរយៈពេល៣ឆ្នាំចុងក្រោយ ស្ថានភាពផ្គត់ផ្គង់/តម្រូវការបច្ចុប្បន្ន និង បន្ទាប់មក ទើបធ្វើការព្យាករណ៍ថា តើតម្លៃនឹងស្ថិតនៅកម្រិតដដែល ឡើង ឬ ចុះសម្រាប់ឆ្នាំបន្ទាប់។<br><br>**សម្គាល់៖** ចូរប្រាប់សិក្ខាកាមថា វិធីមួយដ៏ល្អ គឺត្រូវសួរអ្នកប្រមូលទិញផលិតផល និង អ្នកលក់នៅឯទីផ្សារ អំពីការយល់ឃើញរបស់ពួកគេចំពោះតម្លៃ សម្រាប់ឆ្នាំបន្ទាប់ អាស្រ័យដោយពួកគេមានចំណេះដឹងល្អប្រសើរអំពីទីផ្សារ។ ចូរសួរពួកគេឱ្យបានច្រើននាក់ ដើម្បីឱ្យអ្នកអាចធ្វើការប្រៀបធៀបចម្លើយរបស់ពួកគេបាន។ អ្នកក៏ប្រហែលជាអាចអញ្ជើញអ្នកទិញផលិតផល/អ្នកលក់នៅឯទីផ្សារ ដើម្បីឱ្យមកចូលរួមនៅក្នុងកិច្ចប្រជុំសាលាអាជីវកម្មកសិកម្ម ដើម្បីពិភាក្សាអំពីតម្លៃផងដែរ។<br><br>ស្នើឱ្យក្រុមធ្វើសេចក្តីរាយការណ៍ទៅកាន់ក្រុមធំ និងធ្វើការសម្រេចចិត្តជា | <br>លំហាត់ ៤.១០<br>សកម្មភាពទី៤ ៖<br>សំនួរអំពីពេលវេលា<br>និង<br>តារាងតម្លៃប្រចាំឆ្នាំ |

| | | |
|---|---|---|
| | ផ្សេងៗទៀតរបស់កសិករ ក៏មានកម្រិតទាបផងដែរ។<br><br>ចូរពន្យល់ថា "តម្លៃទីផ្សារ" គឺជាតម្លៃដែលកសិករនឹងទទួលបានសម្រាប់ការលក់ផលិតផលរបស់ពួកគេទៅឱ្យអ្នកលក់ដុំ ឬ អ្នកលក់នៅឯទីផ្សារមួយដែលឆ្ងាយពីកសិដ្ឋាន ឬ ស្រែចម្ការរបស់ពួកគេ។ "តម្លៃទីផ្សារ" គួរមានកម្រិតខ្ពស់ជាង "តម្លៃលក់ផលិតផលនៅឯកសិដ្ឋាន ឬ ស្រែចម្ការ" ដើម្បីគ្របដណ្តប់ទៅលើថ្លៃចំណាយបន្ថែមចំពោះការដឹកជញ្ជូនផលិតផលដែលខូចខាតក្នុងអំឡុងពេលនៃការដឹកជញ្ជូន កម្លាំងពលកម្មរបស់អ្នកប្រមូលនិងចំណេះដឹងរបស់បណ្តាញលក់ផលិតផល ព្រមទាំងការវេចខ្ចប់។ ថ្លៃចំណាយបន្ថែមនេះ គេហៅថា "ថ្លៃចំណាយទីផ្សារ"។<br><br>នៅពេលដែលកសិករបន្ថែមថ្លៃចំណាយទីផ្សារទាំងនេះ ទៅលើតម្លៃលក់ផលិតផល នៅឯកសិដ្ឋាន ឬ ស្រែចម្ការ ពួកគេនឹងដឹងអំពីតម្លៃទាបបំផុតដែលពួកគេរំពឹងថានឹង ទទួលបាន ក្នុងការលក់ផលិតផលទៅឱ្យអ្នកលក់នៅក្នុងទីផ្សារ។<br><br>ជួយដល់សិក្ខាកាមក្នុងការកំណត់តម្លៃទីផ្សារ។ ចូរសរសេរឧទាហរណ៍ខាងក្រោម នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ៖<br><br>**ផលិតផល៖ អង្ករ /១គីឡូក្រាម**<br><br>តម្លៃនៅឯកសិដ្ឋាន ឬ ស្រែចម្ការ៖ ៨០០ រៀល<br>ថ្លៃចំណាំយទីផ្សាររបស់អ្នក៖ ២០០ រៀល<br>តម្លៃទាបបំផុតដែលអ្នកអាចទទួលយកបាននៅឯទីផ្សារ៖ ១.០០០ រៀល<br><br>ចូរពន្យល់ថា នៅក្នុងឧទាហរណ៍នេះ ប្រសិនបើតម្លៃដែលពួកគេអាចទទួលបានសម្រាប់ផលិតផលអង្កររបស់ពួកគេពីអ្នកលក់នៅឯទីផ្សារ មានតម្លៃលើសពី ១.០០០រៀល មានន័យថា ការយកផលិតផលរបស់ពួកគេទៅលក់ឱ្យអ្នកលក់នៅឯទីផ្សារគឺជាការល្អ ព្រោះពួកគេអាចទទួលបានប្រាក់ចំណេញច្រើនជាងការលក់ផលិតផលរបស់ពួកគេនៅឯកសិដ្ឋាន ឬ ស្រែ ចម្ការ។ ប៉ុន្តែ ប្រសិនបើតម្លៃដែលពួកគេទទួលបានពីអ្នកលក់នៅឯទីផ្សារទាបជាង ១.០០០រៀល វាជាការល្អជាង ក្នុងការលក់ផលិតផលរបស់ពួកគេ ក្នុងតម្លៃ ៨០០រៀល នៅឯកសិដ្ឋាន ឬ ស្រែចម្ការរបស់ពួកគេ។សូមអញ្ជើញឱ្យសិក្ខាកាមឆ្លើយសំនួរអំពី តម្លៃលក់" និង "តម្លៃលក់នៅឯកសិដ្ឋាន ឬ ស្រែចម្ការ" ចំពោះផលិតផល "ឯទីផ្សារនៅដែលពួកគេបាន ជ្រើសរើសនៅក្នុងសកម្មភាពទី៣ លំហាត់ ៤.១០ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៤.១០<br>សកម្មភាពទី៣ ៖<br>តម្លៃនៅឯកសិដ្ឋាន ឬស្រែចម្ការ និង តម្លៃទីផ្សារ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ➢ ភាពចម្រុះដែលកាន់តែសម្បូរបែបនៃកសិផល និងសត្វពាហនៈ<br>➢ ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទឹក<br>➢ តុល្យភាពរវាងដី និងអាហារូបត្ថម្ភសម្រាប់រុក្ខជាត<br>➢ ប្រភេទពូជប្រសើរជាងមុនដែលផ្តល់ទិន្នផលខ្ពស់ និងការប្រឆាំងទៅនឹងជំងឺ<br>➢ ការកាត់បន្ថយការប្រើប្រាស់ថ្នាំពុលសម្លាប់សត្វល្អិត<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលទំព័រដែលនិយាយអំពីផលប៉ះពាល់ទៅលើបរិស្ថាន នៅក្នុងលំហាត់ ៤.១១ នៃសៀវភៅលំហាត់របស់ពួកគេ។ ស្នើសុំឱ្យពួកគេធ្វើការចង្អុលបង្ហាញអំពីផលប៉ះពាល់នៃសហគ្រាសដែលពួកគេបានជ្រើសរើសទៅលើបរិស្ថាន តាមរយៈ ការដាក់សញ្ញា (√) សម្រាប់ផលប៉ះពាល់វិជ្ជមាន និងសញ្ញា X សម្រាប់ផលប៉ះពាល់អវិជ្ជមាន។ បន្ទាប់មក សូមអញ្ជើញសិក្ខាកាមឱ្យផ្តល់មតិយោបល់ ដើម្បីសម្រេចឱ្យបាននូវផលប៉ះពាល់វិជ្ជមាន ទាក់ទងទៅនឹងចំណងជើងនីមួយៗនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។<br><br>ចូររំលឹកសិក្ខាកាមថា ពួកគេត្រូវបញ្ចូលសកម្មភាពដែលពួកគេបានផ្តល់មតិយោបល់ និង ថ្លៃចំណាយក្នុងការកែលម្អបរិស្ថាន ដើម្បីឱ្យការធ្វើកសិកម្មមាននិរន្តរភាព ទៅក្នុងផែនការសកម្មភាព និងខ្ទង់ចំណាយថវិការបស់ពួកគេ។ | |
| ៤ | **ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយៈ**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើពាក្យ ការកាត់បន្ថយ " និង "គ្រោះមហន្តរាយ" មានន័យដូចម្តេច "គ្រោះភ័យនៃគ្រោះមហន្តរាយ? ចូរសរសេរការយល់ឃើញរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>សូមឱ្យពួកគេពិនិត្យមើលនិយមន័យនៅក្នុងសកម្មភាពទី១ លំហាត់៤.១២ នៃសៀវភៅ លំហាត់របស់ពួកគេ។<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេធ្លាប់បានជួបប្រទះគ្រោះមហន្តរាយប្រភេទណាខ្លះ ទាក់ទងទៅនឹងសហគ្រាសដែលពួកគេគ្រោងអនុវត្ត។ | <br>លំហាត់ ៤.១២ សកម្មភាពទី១៖ និយមន័យ និង តារាងស្តីពីការកាត់បន្ថយ គ្រោះភ័យនៃ គ្រោះមហន្តរាយ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ក្រុម ទៅលើតារាងតម្លៃប្រចាំឆ្នាំមួយ។ បន្ទាប់មក ចូរសួរទៅកាន់ពួកគេថា តើពួកគេចង់លក់ ផលិតផលរបស់ពួកគេនៅពេលណាក្នុងតម្លៃប៉ុន្មាន និង ហេតុអ្វី ដោយកត់ត្រាគំនិតរបស់ពួកគេទៅក្នុងសៀវភៅលំហាត់ - លំហាត់ ៤.១០ សកម្មភាពទី៤៖ សំនួរអំពី ពេលវេលា និងតម្លៃនៃការលក់ផលិតផល។<br><br>សូមឱ្យសិក្ខាកាមបញ្ចូលគំនិតរបស់ពួកគេទៅក្នុងខ្សែបន្ទាប់ចន្លោះទទេ នៅក្នុងតារាង "ផែនការទីផ្សារ"ក្នុងលំហាត់ ៤.១០ សកម្មភាពទី៥ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ ដែលរួមមានដូចជា ឈ្មោះផលិតផល កាលបរិច្ឆេទនៃការលក់ផលិតផល ទីកន្លែងលក់ផលិតផល និង តម្លៃ រំពឹងទុក។ ចូរធ្វើការពិនិត្យបង្ហាញណែនាំអំពីគូឡោនទាំងនោះ ដើម្បីធានាថា សិក្ខាកាមយល់អំពីរបៀបបំពេញព័ត៌មានទាំងនេះ។<br><br>ចូរពន្យល់ថា ប្រសិនបើសិក្ខាកាមពន្យារពេលលក់ផលិតផលរបស់ពួកគេ ដើម្បីទទួលបានតម្លៃខ្ពស់ជាងមុន ពួកគេនឹងត្រូវខាតបង់នូវថ្លៃរក្សាទុកផលិតផល និងការពន្យារពេលក្នុងការទទួលបានប្រាក់ចំណូលរបស់ពួកគេ។ ការពន្យារពេល និង ថ្លៃចំណាយបន្ថែមដែលបានកើតឡើង គួរបញ្ចូលទៅក្នុងការគណនាថវិកា និងលំហូរសាច់ប្រាក់របស់ពួកគេនៅពេលក្រោយ នៅក្នុងការសិក្សាអំពីលទ្ធភាពក្នុងការទទួលបានជោគជ័យ។ | <br>លំហាត់ ៤.១០ សកម្មភាពទី៥ ៖ លំហាត់ផែនការទីផ្សារ |
| ៣ | **ការពិចារណាទៅលើផលប៉ះពាល់បរិស្ថាន ៖**<br><br>ចូរពន្យល់ទៅកាន់កសិករថា រាល់សហគ្រាសកសិកម្មទាំងអស់សុទ្ធសឹងតែបង្កឱ្យមានផលប៉ះពាល់ទៅលើបរិស្ថាន។ ចូរសូមឱ្យពួកគេបំបែកជាក្រុមតូចៗ និង សរសេររាយនាមអំពី ៖<br>➢ ផលប៉ះពាល់ល្អនៃសហគ្រាសរបស់ពួកគេទៅលើបរិស្ថាន<br>➢ ផលប៉ះពាល់អាក្រក់នៃសហគ្រាសរបស់ពួកគេទៅលើបរិស្ថាន<br><br>សូមឱ្យក្រុមទាំងអស់ធ្វើការចែករំលែកចម្លើយរបស់ពួកគេនៅក្នុងក្រុមធំ។ ចូរសរសេរចម្លើយនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>បន្ទាប់មក ចូរសូមឱ្យសិក្ខាកាមធ្វើការពិភាក្សាអំពីរបៀបដែលពួកគេអាចធ្វើឱ្យបរិស្ថានកាន់តែមានភាពប្រសើរឡើង ខណៈពេលដែលពួកគេកំពុងតែអនុវត្តការងារសហគ្រាសរបស់ពួកគេ។ ចូរសរសេរអំពីអន្តរាគមន៍ដែលអាចធ្វើទៅបាន ក្រោមចំណងជើង សង្គ្រោះ និង ដាំដុះ របស់អង្គការ **FAO** ដែលរួមមានដូចខាងក្រោម៖ | <br>លំហាត់ ៤.១១ ៖ ការពិចារណាទៅលើផលប៉ះពាល់បរិស្ថាន |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

ចូរប្រមូលផ្តុំគំនិតអំពីហានិភ័យ ឬ ការប្រឈមក្នុងការអនុវត្តសហគ្រាសដែលសិក្ខាកាមបានជ្រើសរើស។ ចូរសរសេររាយនាមហានិភ័យទាំងនោះនៅលើ ក្រដាសផ្ទាំងធំមួយសន្លឹក។ ចូរស្នើឱ្យសិក្ខាកាមចម្លងបញ្ជីរាយនាមនេះទៅក្នុងសៀវភៅលំហាត់របស់ពួកគេ ក្នុងគូឡោនទី១ "ការរាយនាមអំពីហានិភ័យ និងការប្រឈម"។

បន្ទាប់មក ចូរសូមឱ្យសិក្ខាកាមសរសេរអំពីភាពញឹកញាប់ដែលហានិភ័យ ឬ ការប្រឈមនីមួយៗបានកើតឡើង (ឧ. តើវាកើតឡើងញឹកញាប់ដល់កម្រិតណា) នៅក្នុងគូឡោន បន្ទាប់។ ឧទាហរណ៍ ៖

| ហានិភ័យ | ភាពញឹកញាប់ | ការប៉ាន់ប្រមាណ<br>ខ្ពស់<br>មធ្យម<br>ទាប | តើត្រូវកាត់បន្ថយហានិភ័យដោយរបៀបណា? |
|---|---|---|---|
| ទឹកជំនន់ | ២ឆ្នាំ ក្នុងរយៈពេល៥ឆ្នាំ | ខ្ពស់ | លើកទំនប់ |

សូមឱ្យសិក្ខាកាមធ្វើការងារជាអនុក្រុមតូចៗ ដើម្បីពិភាក្សា និងសរសេរអំពីវិធានការ ដើម្បីកាត់បន្ថយហានិភ័យ ឬការប្រឈម។ ចូរផ្តល់ហានិភ័យចំនួនពីរ-បីប្រភេទ ទៅឱ្យ ក្រុមនីមួយៗ និងបន្ទាប់មក សូមឱ្យពួកគេរាយការណ៍ត្រឡប់ទៅកាន់ក្រុមធំវិញ។ ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ។ ចូរប្រាប់ក្រុមទាំងអស់ថា ពួកគេអាចចម្លងចម្លើយនៅលើផ្ទាំងក្រដាសធំ ក្រោយពេលចប់កិច្ចប្រជុំនេះ។

ចូររំលឹកសិក្ខាកាមថា ប្រសិនបើពួកគេអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យទាំងនេះ រាល់សកម្មភាព និង ថ្លៃចំណាយទាំងអស់ ត្រូវបញ្ចូលទៅក្នុងផែនការថវិការបស់ពួកគេ។

ចូរសូមឱ្យសិក្ខាកាមធ្វើការសង្ខេបអំពីការប៉ាន់ប្រមាណជារួមរបស់ពួកគេទៅលើហានិភ័យដោយកំណត់ថា តើសហគ្រាសរបស់ពួកគេមានហានិភ័យខ្ពស់ មធ្យម ឬ ទាប។ សិក្ខាកាមគួរគូសរង្វង់ជ្រើសរើសយកចម្លើយនៅក្នុង



លំហាត់ ៤.១៤
សកម្មភាពទី២ ៖
ការប៉ាន់ប្រមាណទៅលើហានិភ័យសហគ្រាស

| | | |
|---|---|---|
| | ចម្លើយរបស់ពួកគេ ទំនងរួមមាន ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ការផ្ទុះសត្វល្អិតចង្រៃ ឬជំងឺធ្ងន់ធ្ងរ។ ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ។<br><br>បន្ទាប់មក ចូរសូមឱ្យពួកគេធ្វើការងារជាក្រុមតូចៗ ដើម្បីពិភាក្សាអំពីគ្រោះមហន្តរាយទាំងនេះ (អនុក្រុមមួយត្រូវពិភាក្សាអំពីគ្រោះមហន្តរាយមួយប្រភេទ) ដើម្បីពិនិត្យមើលថា តើសិក្ខាកាមអាចចាត់វិធានការអ្វីខ្លះ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ។ សមាជិកក្រុម គួររាយការណ៍ទៅកាន់ក្រុមធំវិញ ដើម្បីពិភាក្សាបន្ថែម។ ចូរសរសេរអំពីគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរធ្វើការត្រួតពិនិត្យឡើងវិញជាមួយសិក្ខាកាម ទៅលើតារាង "ឧទាហរណ៍នៃគ្រោះមហន្តរាយ ឥទ្ធិពលនៃគ្រោះមហន្តរាយ និងវិធានការដែលអាចកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ" នៅក្នុងសកម្មភាពទី២ លំហាត់ ៤.១២ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរបន្ថែមគំនិតរបស់សិក្ខាកាមនៅក្នុងចន្លោះក្រោមតារាង ប្រសិនបើចំណុចទាំងអស់នោះ មិនទាន់ត្រូវបានរៀបរាប់។<br><br>ចូរផ្ដល់ដំបូន្មានដល់សិក្ខាកាមថា សកម្មភាពមួយចំនួននៃសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ គួរត្រូវបានយកមកពិចារណានៅពេលអនុវត្តការកាត់បន្ថយគ្រោះភ័យ ដែលចំណុចនេះ មានពិភាក្សាបន្ថែមទៀតនៅក្នុងប្រធានបទបន្ទាប់។<br><br>ចូរប្រាប់សិក្ខាកាមថា សកម្មភាព និងថ្លៃចំណាយនៃសកម្មភាពដែលត្រូវបានជ្រើសរើសទាំងនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងសកម្មភាព និងថវិកាសហគ្រាសរបស់ពួកគេ។ | |
| ៩ | **ការសិក្សាពីហានិភ័យរបស់សហគ្រាស ៖**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេយល់ដូចម្ដេចដែរ ចំពោះអត្ថន័យពាក្យ "ហានិភ័យ ឬ ការប្រឈម"? ចូរសរសេរចម្លើយយល់ឃើញរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>បន្ទាប់មក ចូរធ្វើការត្រួតពិនិត្យឡើងវិញទៅលើនិយមន័យ នៅក្នុងសកម្មភាពទី១ លំហាត់ ៤.១៤ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៤.១៤<br>សកម្មភាពទី១ ៖<br>និយមន័យនៃ<br>ហានិភ័យ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ៧ | **ចូរធ្វើការសង្ខេបតាមរយៈការសាកសួរសំនួរ៖**<br>"តើសិក្ខាកាមមានឆន្ទៈក្នុងការបន្តធ្វើអាជីវកម្មនេះដែរឬទេ ក្រោយពេលដែលបានពិចារណារួចរាល់ទៅលើហានិភ័យ ឬ ការប្រឈមទាំងនោះ? ហេតុអ្វីបានជាពួកគេនិយាយដូច្នេះ?" | |
| ៨ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទីដើម្បីពិនិត្យឡើងវិញទៅលើចំណុច សំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួល គួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកានៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | សៀវភៅលំហាត់របស់ពួកគេ។ ចូរធ្វើការត្រួតពិនិត្យដើម្បីឱ្យមានការឆ្លើយតបនៅក្នុងក្រុមធំ។ | |
| ៦ | **ការពិចារណាទៅលើកត្តាសង្គម-វប្បធម៌ ៖** ចូរបំបែកសិក្ខាកាមជាក្រុមតូចៗ ដែល មានភេទផ្ទុយគ្នា និងសួរសំនួរដូចខាងក្រោម ៖<br><br>"តើអ្នកបានដឹងអំពីបញ្ហាឧបសគ្គរាំងស្ទះផ្នែកសង្គម ឬវប្បធម៌ ក្នុងការ អនុវត្តសហគ្រាស ដែលអ្នកបានជ្រើសរើសដែរឬទេ?"<br><br>ចូរប្រើប្រាស់ចំណុចខាងក្រោមនេះជាតម្រុយ ដើម្បីទទួលបានមូលហេតុសម្រាប់ឧបសគ្គ រាំងស្ទះនានា។ មិនត្រូវទទួលយកចម្លើយ "បាទ/ចាស៎" ឬ "ទេ" ប៉ុណ្ណោះទេ៖<br><br>➢ តើមានឧបសគ្គរាំងស្ទះនៅក្នុងឋានានុក្រមគ្រួសារ (ឧ. មនុស្សចាស់ ក្មេង) ដែលរិតបន្តឹងចំពោះការចូលរួម និង ការទទួលបានប្រយោជន៍ពីសហគ្រាស ដែលអ្នកបានជ្រើសរើសដែរឬទេ?<br>➢ តើមានឧបសគ្គរាំងស្ទះចំពោះ បុរស ឬ ស្ត្រី ក្នុងការអនុវត្តសហគ្រាសនេះ ដែរឬទេ? (ឧ. ស្ត្រី ឬ បុរស មិនចង់ចូលរួមនៅក្នុងសហគ្រាសនេះ , ការធ្វើចំណាកស្រុក)<br>➢ តើកសិករខ្នាតធំ និង កសិករខ្នាតតូច អាចចូលរួមនៅក្នុងសហគ្រាសនេះ បានដែរឬទេ?<br>➢ តើមានឧបសគ្គផ្នែកភាសាដែលរាំងស្ទះចំពោះការចូលរួមនៅក្នុងសហគ្រាសនេះដែរឬទេ?<br>➢ តើពិធីបុណ្យសាសនា និង ពិធីបុណ្យវប្បធម៌ ធ្វើឱ្យមានកម្រិតទៅលើកម្លាំងពលកម្ម និងធនធានដទៃទៀត សម្រាប់សហគ្រាសនេះដែរឬទេ?<br><br>ចូរសង្ខេបដោយស្នើសុំឱ្យប្រធានក្រុមនីមួយៗ ឡើងផ្តល់សេចក្តីរាយ ការណ៍ជូនដល់ក្រុមធំ។ប្រមូលគំនិតដើម្បីដោះស្រាយបញ្ហាឧបសគ្គរាំងស្ទះនានាផ្នែកសង្គម-វប្បធម៌និងសរសេរគំនិតទាំងនោះនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរប្រាប់សិក្ខាកាមថា យុទ្ធសាស្រ្តក្នុងការកាត់បន្ថយឧបសគ្គរាំងស្ទះនានាគួរបញ្ចូលទៅក្នុងសកម្មភាព និងខ្វង់ចំណាយថវិការបស់សហគ្រាស។ | <br>លំហាត់ ៩.១៣៖ ឧបសគ្គរាំងស្ទះផ្នែកសង្គម-វប្បធម៌ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ជាងថ្លៃចំណាយ នៅពេលនោះ គេនឹងទទួលបានប្រាក់ចំណេញ និង នៅពេលដែលប្រាក់ចំណូលមានចំនួនតិចជាងថ្លៃចំណាយ នៅពេលនោះ គេនឹងទទួលរងនូវការខាតបង់។<br><br>ចូរសង្ខេបដោយនិយាយថា នៅពេលដែលយើងសរសេរការគណនាអំពីប្រាក់ចំណេញ ឬ ការខាតបង់នៅលើក្រដាស យើងហៅសកម្មភាពនេះថា ។ ការទូទាត់ថវិកាមានសារៈសំខាន់ខ្លាំងណាស់"ការទូទាត់ថវិកា" **មុនពេល** ដែលសិក្ខាកាមចាប់ផ្តើមធ្វើ សហគ្រាសមួយ ដើម្បីឱ្យពួកគេប្រាកដក្នុងចិត្តថា ពួកគេនឹងទទួលបានប្រាក់ចំណេញ ប៉ុន្តែ ពួកគេ**ពុំមែន**ត្រូវធ្វើការទូទាត់ថវិកានៅចុងបញ្ចប់នៃវដ្តផលិតកម្ម នៅពេលដែលពួកគេអាចរកឃើញថា ពួកគេកំពុងទទួលរងនូវការខាតបង់នោះទេ! នៅពេលដែលពួកគេទូទាត់ថវិកា ហើយរកឃើញថាមានការខាតបង់ ឬ ប្រាក់ចំណេញពុំទាន់មានទំហំធំល្មម សិក្ខាកាមមិនគួរចាប់ផ្តើមធ្វើសហគ្រាសនោះឡើយ។ | |
| ៣ | ចូរប្រាប់សិក្ខាកាមថា គេអាចធ្វើការគណនារកប្រាក់ចំណេញ ឬការខាតបង់តាមមូលដ្ឋានជាឯកត្តា ដូចជា នៅក្នុងផ្ទៃដី១ហិកតា ឬ សត្វពាហនៈ ១ ក្បាល សម្រាប់រយៈពេលផលិតណាមួយ។ គេអាចប្រើប្រាស់វាដើម្បីធ្វើការប្រៀបធៀបសហគ្រាសមួយទៅនឹងសហគ្រាសមួយទៀត ដើម្បីពិនិត្យមើលថា តើសហគ្រាសមួយណា ដែលទទួលបានប្រាក់ចំណេញច្រើនបំផុត។<br><br>ចូរពិនិត្យមើលឧទាហរណ៍នៅក្នុងសកម្មភាពទី២ លំហាត់ ៤.១៥ នៃសៀវភៅលំហាត់របស់ពួកគេ ៖ អង្ករ = ២.៥០០.០០០ រៀល/១ហិកតា, បន្លែ = ១២.០០០.០០០ រៀល/១ហិកតា , មាន់ = ៨.០០០រៀល/១ក្បាល | <br>លំហាត់ ៤.១៥ សកម្មភាពទី២៖ ឧទាហរណ៍នៃប្រាក់ចំណេញ និងការខាតបង់ |
| ៤ | **ទម្រង់ផែនការថវិកា៖**<br>ចូរដាក់ផ្ទាំងក្រដាសធំមួយសន្លឹកដែលត្រូវបានរៀបចំទុកជាមុន ដែលបង្ហាញអំពីតារាងថវិកា និងការចូលរួមរបស់បុរស និងស្ត្រី នៅក្នុងកម្លាំងពលកម្ម ដូចមានបញ្ជាក់ក្នុង សកម្មភាពទី៣ លំហាត់ ៤.១៥ នៅក្នុងសៀវភៅលំហាត់សម្រាប់សិក្ខាកាម។<br><br>ពន្យល់ម្តងទៀតថា ធាតុផ្សំសំខាន់ៗនៃរាល់ការទូទាត់ថវិកាទាំងអស់ រួមមាន | |

# ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

## មេរៀនទី៤ ៖ លទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងអាចធ្វើការគណនាអំពីផលចំណេញនិងការខាតបង់របស់សហគ្រាសនិងផលចំណេញក្នុង១គ្រួសារសម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ



៣ម៉ោង

| | | |
|---|---|---|
| ១ | **ការធ្វើផែនការថវិកា(ប្រាក់ចំណេញឬការខាតបង់)៖** នៅក្នុងវគ្គនេះសិក្ខាកាមនឹងពិនិត្យមើលទៅលើវិធីមួយដើម្បីវាស់ស្ទង់ទៅលើការអនុវត្ត លើការគ្រប់គ្រងហិរញ្ញវត្ថុរបស់សហគ្រាសមួយឧទាហរណ៍ "ប្រាក់ចំណេញ" ឬ "ការខាតបង់" | |
| ២ | ចូរគូសប្រអប់ចំនួន៣ ជាជួរនៅលើផ្ទាំងក្រដាសធំមួយសន្លឹក ឬ ក្តាខៀន។ នៅក្នុងប្រអប់ខាងស្តាំ ចូរសរសេរពាក្យ ៖ ដូចខាងក្រោម "ប្រាក់ចំណេញ"<br><br>[ ] [ ] [ប្រាក់ចំណេញ]<br><br>ចូរស្នើឱ្យសិក្ខាកាមធ្វើការប្រមូលផ្តុំគំនិតទៅលើសំនួរខាងក្រោម៖<br>"តើអ្នកគណនាប្រាក់ចំណេញរបស់អ្នក ដោយរបៀបណា?"<br><br>ចូរដឹកនាំការពិភាក្សាឆ្ពោះទៅរកគំនិតថា ប្រាក់ចំណេញកើតចេញមកពីប្រាក់ចំណូលដកថ្លៃចំណាយ។ នៅពេលដែលការប្រមូលផ្តុំគំនិតត្រូវបានធ្វើចប់រួចរាល់ ចូរសរសេរពាក្យ "ប្រាក់ចំណូល" នៅក្នុងប្រអប់ទី១ និង "ថ្លៃចំណាយ" នៅក្នុងប្រអប់ទី២ ដូចខាងក្រោម ៖<br><br>[ប្រាក់ចំណូល] [ប្រាក់ចំណាយ] [ប្រាក់ចំណេញ]<br><br>ចូរស្នើសុំឱ្យសិក្ខាកាមបំពេញនៅក្នុងប្រអប់ក្នុងលក្ខណៈដូចគ្នានេះ នៅក្នុងសកម្មភាពទី១ លំហាត់ ៤.១៥ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>ចូរសរសេរបញ្ចូលពាក្យ **ដក** និង **ស្មើ** ព្រមទាំងសញ្ញា - និង = នៅចន្លោះប្រអប់ទាំងនោះ ដើម្បីបង្ហាញអំពីវិធីគណនាប្រាក់ចំណេញ។ ចូរផ្តល់ឧទាហរណ៍ ដើម្បីបង្ហាញថា នៅពេលដែលប្រាក់ចំណូលមានចំនួនច្រើន | <br>លំហាត់ ៤.១៥<br>សកម្មភាពទី១ ៖<br>ការគណនា<br>ផែនការថវិកា<br>(ចំណេញ/ខាត់) |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | គូឡោនទី១ ចូររៀបរាប់អំពី "ផលិតផល" ដែលត្រូវបានយកទៅលក់ ប្តូរនឹងវត្ថុដទៃទៀត ឬ ប្រើប្រាស់។ ពួកគេគួរបញ្ចូលរាល់ផលិតផលទាំងអស់ និង តម្លៃទីផ្សារនៃផលិតផលទាំងនោះ (បើទោះបីជាផលិតផលទាំងនោះមិនត្រូវបានយកទៅលក់ក៏ដោយ) នៅក្នុងការទូទាត់ថវិកា។ ការធ្វើបែបនេះ ពួកគេអាចគណនារកឃើញនូវតម្លៃពេញលេញនៃផលិតផលរបស់ពួកគេ។<br><br>នៅក្នុងគូឡោនទី២ ចូរដាក់ "កាលបរិច្ឆេទ" នៃការលក់ អាស្រ័យដោយតម្លៃរមែងតែងមានការប្រែប្រួលរៀងរាល់ខែ។ កាលបរិច្ឆេទនេះ ប្រាប់សិក្ខាកាមអំពីពេលណាដែលពួកគេត្រូវធ្វើសកម្មភាព និង ពេលណាដែលគេត្រូវការសាច់ប្រាក់ដើម្បីចំណាយ សម្រាប់សកម្មភាពនោះ។<br><br>នៅក្នុងគូឡោនទី៣ ចូរបញ្ចូល "ឯកតា" នៃការវាស់វែងដែលអាចបង្ហាញតាមរយៈ -គីឡូក្រាម បាវដែលមានទម្ងន់៥០គីឡូក្រាម តោន ក្បាល ។ល។<br><br>នៅក្នុងគូឡោនទី៤ ចូរដាក់ "ចំនួនឯកតា" ដែលត្រូវលក់ ប្រើប្រាស់ ប្តូរនឹងវត្ថុដទៃទៀត ឬ ឱ្យទៅអ្នកដទៃ។<br><br>នៅក្នុងគូឡោនទី៥ ចូរដាក់ "តម្លៃឯកតា" ដែលជាតម្លៃក្នុងមួយឯកតាសម្រាប់លក់ ប្រើប្រាស់ ឬប្តូរនឹងវត្ថុដទៃដូចជា រៀល/១គីឡូក្រាម, រៀល/១តោន។ល។<br><br>នៅក្នុងគូឡោនទី៦ ចូរគណនា "ប្រាក់ចំណូលសរុប" និង "ថ្លៃចំណាយសរុប" តាមរយៈ ការគុណចំនួនឯកតា ជាមួយនឹងតម្លៃក្នុងមួយឯកតា។ | <br>លំហាត់ ៤.១៥<br>សកម្មភាពទី៣៖<br>ឧទាហរណ៍ទំរង់<br>នៃធ្វើផែនការ<br>ថវិកា |
| ៤.៣ | **ថ្លៃចំណាយ៖**<br>ចូរពន្យល់ថា "ថ្លៃចំណាយ" កើតឡើងមកពីថវិកាដែលចំណាយដោយផ្ទាល់ទៅលើរាល់សម្ភារៈផលិតកម្មកសិកម្ម និង សកម្មភាពនានា (រាប់បញ្ចូលការជួលកម្លាំងពលកម្ម និង អ្នកមៅការបន្ត) ដែលចាំបាច់ ដើម្បីធ្វើការដាំដុះប្រភេទកសិផលជាក់លាក់មួយ ឬ ចិញ្ចឹមសត្វនៅក្នុងវដ្តផលិតកម្មមួយ។ ថ្លៃចំណាយទាំងនេះ មិនគួររាប់បញ្ចូល "កម្លាំងពលកម្មគ្រួសារដែលមិនទទួលបានប្រាក់កម្រៃ" ឡើយ។<br><br>ចូរពិនិត្យមើលទៅលើការគណនាថ្លៃចំណាយនៅក្នុងឧទាហរណ៍នៃទម្រង់ទូទាត់ថវិកា មួយជួរម្តងៗ និងមួយគូឡោនម្តងៗ។ | <br>លំហាត់ ៤.១៥<br>សកម្មភាពទី៣៖<br>ឧទាហរណ៍ទំរង់<br>នៃធ្វើផែនការ<br>ថវិកា |

| | | |
|---|---|---|
| | ប្រាក់ចំណូល ថ្លៃចំណាយ និង លទ្ធផលក្រោយការទូទាត់ (ប្រាក់ចំណេញ ឬ ការខាតបង់)។ ចូរប្រាប់សិក្ខាកាមថា នេះគឺជាទម្រង់នៃការទូទាត់ថវិកាស្តង់ដារមួយដែលពួកគេអាចប្រើប្រាស់ដើម្បីធ្វើការប៉ាន់ប្រមាណទៅលើប្រាក់ចំណូល ថ្លៃចំណាយ និងប្រាក់ចំណេញ/ការខាតបង់នៃសហគ្រាសណាមួយរបស់ពួកគេ។ មុនពេលបោះជំហានទៅមុខ ចូរប្រាប់សិក្ខាកាមថា ពួកគេចាំបាច់ត្រូវយល់អំពីធាតុផ្សំសំខាន់ៗនៃការទូទាត់ថវិកា អាស្រ័យដោយចំណុចនេះ នឹងជួយក្នុងការសម្រេចចិត្ត ថាតើពួកគេគួរបន្តបោះជំហានទៅមុខដើម្បីធ្វើសហគ្រាសដែលពួកគេបានជ្រើសរើស ឬ ក៏មិនបន្តបោះជំហានហគ្រាសនេះ។ |  លំហាត់ ៤.១៥ សកម្មភាពទី៣៖ ឧទាហរណ៍នៃការទូទាត់ថវិកា ដែល ត្រូវបានរៀបចំ ទុកជាមុន |
| ៤.១ | **វិធីបំពេញទម្រង់ផែនការថវិកា៖**<br>ជាថ្មីម្តងទៀត ចូរពិនិត្យមើលសកម្មភាពទី៣ ដែលនិយាយអំពីឧទាហរណ៍នៃការទូទាត់ថវិកានៅលើផ្ទាំងក្រដាសធំ។ ចូរពន្យល់អំពីវិធីបំពេញមួយ គូឡោនម្តងៗ ដូចខាងក្រោម។<br><br>នៅផ្នែកខាងលើនៃគូឡោនទី១ ចូរសរសេរប្រភេទផលិតផល៖ ឧទាហរណ៍ អង្ករ ឬ បន្លែ ឬ មាន់។ បន្ទាប់មក ចូរដាក់ឯកតារបស់សហគ្រាស ឧទាហរណ៍ដូចជា ក្នុង១ហិកតា ឬម៉ែត្រការ៉េ ឬ ក្នុងមាន់ចំនួន២០ក្បាល។<br><br>ចូរពន្យល់ថា នៅក្នុងផ្នែកដទៃទៀតនៃគូឡោនទី១ សិក្ខាកាមគួរធ្វើការ កត់ត្រានូវរាល់ប្រភពប្រាក់ចំណូល ដែលរួមមានដូចជា ផលិតផលដែលត្រូវបានយកទៅលក់ ប្រើប្រាស់ ឬ ប្តូរនឹងវត្ថុដទៃទៀត ព្រមទាំងរាល់ថ្លៃចំណាយទាំងអស់ រាប់បញ្ចូលសម្ភារៈផលិតកម្មកសិកម្ម កម្លាំងពលកម្មគ្រួសារ និង ថ្លៃជួលឧបករណ៍ និងគ្រឿងចក្រនានា។ ចូរពិនិត្យមើលឧទាហរណ៍នៅក្នុងទម្រង់នៅលើផ្ទាំងក្រដាស។<br><br>បន្ទាប់មក ចូរបង្ហាញពួកគេអំពីវិធីដក ៖ ប្រាក់ចំណូលសរុប (ក) - ថ្លៃចំណាយសរុប (ខ) ដើម្បីទទួលបានលទ្ធផលក្រោយការទូទាត់ (គ) (ប្រាក់ចំណេញ + ឬ ការខាតបង់ -)។ |  រៀបចំទុកជាមុននូវទំរង់នៃការធ្វើផែនការថវិកាសំរាប់លំហាត់ ៤.១៥ សកម្មភាពទី៣៖ |
| ៤.២ | **ឧទាហរណ៍នៃការគណនាប្រាក់ចំណូល៖**<br>ចូរពិនិត្យមើលទៅលើឧទាហរណ៍នៃការទូទាត់ថវិកាម្តងមួយជួរៗដូចខាងក្រោម៖<br><br>ជាដំបូង ចូរពិភាក្សាអំពីជួរ "ប្រាក់ចំណូល" មួយគូឡោនម្តងៗ។ នៅក្នុង | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ចូរប្រាប់សិក្ខាកាមថា ប្រសិនបើពួកគេត្រូវប្រើប្រាស់ជម្រើសនៃការសន្សំសំចៃកម្លាំងពលកម្មខាងលើ ឬ ការជួលកម្លាំងពលកម្ម និងជម្រើសបណ្តុះបណ្តាលនៅក្នុងសហគ្រាសរបស់ពួកគេ ពួកគេគួរបញ្ចូលសកម្មភាព និងថ្លៃចំណាយទាំងនេះ ទៅក្នុងខ្វង់ចំណាយថវិការបស់ពួកគេ។ | |
| ៤.៥ | **ការគណនាថវិកាសហគ្រាសផ្ទាល់ខ្លួនរបស់ពួកគេ៖**<br>ចូររៀបចំតម្លើងផ្ទាំងក្រដាសធំមួយសន្លឹកដែលបង្ហាញអំពីទម្រង់ទទេមួយអំពីការទូទាត់ថវិកា និងការចូលរួមពីបុរស និងស្ត្រី ដូចនៅក្នុងសកម្មភាពទី៤ លំហាត់ ៤.១៥។<br><br>**ប្រាក់ចំណូល៖** សូមអញ្ជើញសិក្ខាកាម ធ្វើការពិភាក្សាអំពីការផលិត ពេលវេលានៃការលក់ និងតម្លៃទីផ្សារសម្រាប់ផលិតផលរបស់ពួកគេ (ដូចមានពិភាក្សានៅក្នុងលំហាត់ ៤.១០ អំពី "ការធ្វើទីផ្សារ")។ ចូរស្វែងរកការឯកភាពជារួមពីក្រុម និង សរសេរគំនិតរបស់ពួកគេនៅលើទម្រង់នេះ។ ចូរធ្វើការរាប់បញ្ចូលផលិតផលដែលត្រូវបានយកទៅលក់ ប្តូរនឹងទំនិញដទៃ និងផលិតផលដែលត្រូវបានយកមកប្រើប្រាស់។<br><br>**ថ្លៃចំណាយ៖** សូមអញ្ជើញសិក្ខាកាមដែលកំពុងស្ថិតនៅក្នុងអនុក្រុមតូចៗរបស់ពួកគេ ឱ្យងាកមកមើលលំហាត់ ៤.៩ ដែលនិយាយអំពីតារាងនៅក្នុង "ធនធានដែលត្រូវការ"សៀវភៅលំហាត់របស់ពួកគេ។ ចូរជ្រើសរើសកសិករមួយចំនួនដែលអាចអានអក្សរបាន ឱ្យប្តូរវេណគ្នាអានឱ្យក្រុមធំស្តាប់អំពីធនធានដែលត្រូវការសម្រាប់សហគ្រាសដែលគេបានជ្រើសរើស។<br><br>ខណៈពេលដែលពួកគេកំពុងអានអំពីសកម្មភាព និង ធនធានរបស់សហគ្រាស ចូរសរសេរចំណុចទាំងអស់នោះនៅក្នុងគូឡោនទី១ក្រោមចំណងជើង នៅក្នុងផ្ទាំង "ថ្លៃចំណាយ"ក្រដាសធំអំពីទម្រង់ទូទាត់ថវិកា។ ចូរបន្ថែមចំណងជើងបន្ថែមទៀត ប្រសិនបើចាំបាច់រហូតដល់សិក្ខាកាមមានការពេញចិត្តទៅនឹងបញ្ជីរាយនាមនេះ។<br><br>បន្ទាប់មក ចូរស្នើសុំឱ្យអ្នកដែលសរសេរបានលឿនបំផុតនៅក្នុងអនុក្រុមតូចៗបំពេញ នៅក្នុងគូឡោនផ្នែកខាងឆ្វេងនៃទម្រង់ទូទាត់ថវិកា ក្នុងសៀវភៅ លំហាត់របស់ពួកគេ (តារាង ៥.១)។ ចូរពន្យល់ថា ទម្រង់ទី១ គឺដើម្បីឱ្យ ពួក | <br>លំហាត់ ៤.១៥ សកម្មភាពទី៤៖ ទម្រង់ផែនការថវិកានិងការចូលរួមកម្លាំងពលកម្មរបស់យេនឌ័រ<br><br><br>លំហាត់ ៤.១០ ៖ ការធ្វើទីផ្សារ តម្លៃផលិតផល<br><br><br>លំហាត់ ៤.៩៖ តារាងអំពីធនធាន ដែលត្រូវការ |

| | | |
|---|---|---|
| ៤.៤ | **កម្លាំងពលកម្មគ្រួសារ - ការចូលរួមពីបុរស និងស្ត្រី និងកម្លាំងពលកម្មដែលមាន៖**<br><br>ចូរប្រាប់សិក្ខាកាមថា នៅក្នុងប្រទេសកម្ពុជា កម្លាំងពលកម្មភាគច្រើនដែលបម្រើ ការងារនៅក្នុងកសិដ្ឋាន ឬ ស្រែចម្ការ ត្រូវបានផ្តល់ជូនដោយផ្ទាល់ពីកម្លាំងពលកម្មរបស់គ្រួសារ "ដែលមិនទទួលបានប្រាក់កម្រៃ" ឬ ការផ្លាស់ប្តូរកម្លាំងពលកម្មគ្នាទៅវិញទៅមក ជាមួយអ្នកជិតខាង និង មិត្តភក្តិ។ ជាធម្មតា បុរស ឬ ស្ត្រីធ្វើការងារផ្សេងៗគ្នា ឬ ជូនកាល ការងារនោះត្រូវបានធ្វើរួមគ្នា ដោយបុរស និងស្ត្រី។ វាមានសារៈសំខាន់ក្នុងការបង្ហាញថា តើបុរស ឬ ស្ត្រីដែលជាអ្នកធ្វើការងារមួយ ដើម្បីឱ្យយើងអាចដឹងអំពីតួនាទីរបស់ពួកគេ និងធានាថា ពួកគេគឺជាអ្នកដែលមកចូលរួមនៅក្នុងការបណ្តុះបណ្តាល ដែលទាក់ទងទៅនឹងការងាររបស់ពួកគេ និងវិភាគថាតើពួកគេមានពេលវេលាធ្វើសកម្មភាពចាំបាច់នានានៅក្នុងសហគ្រាសរបស់ពួកគេដែរឬទេ។<br><br>ចូរបង្ហាញទៅកាន់សិក្ខាកាមអំពីរបៀបបញ្ចូល "កម្លាំងពលកម្មគ្រួសារដែលមិនទទួលបានប្រាក់កម្រៃ" ទៅក្នុងគូឡោនចំនួនពីរចុងក្រោយនៅក្នុងតារាង។ ពួកគេគួរធ្វើការប៉ាន់ប្រមាណអំពីចំនួនពេលវេលា ដែលគ្រួសារបានចំណាយទៅលើសកម្មភាពនីមួយៗ ដោយធ្វើការកត់ត្រាអំពីចំនួនថ្ងៃដែលបុរសធ្វើការងារនៅក្នុងគូឡោនមួយ និងចំនួនថ្ងៃដែលស្ត្រីធ្វើការងារនៅក្នុងគូឡោនមួយទៀត។ ចូរសន្មត់ថា ចំនួនម៉ោងធ្វើការងារមានរយៈពេល៧ម៉ោង ក្នុងមួយថ្ងៃ។ ឧទាហរណ៍ អាចជាការដកស្ទូង ៖ បុរស ៥ថ្ងៃ, ស្ត្រី ២០ថ្ងៃ។<br><br>ចូរប្រាប់សិក្ខាកាមថា ប្រសិនបើពុំមានកម្លាំងពលកម្មគ្រួសារដែលមិនទទួលបានប្រាក់កម្រៃសម្រាប់ការងារនេះទេ កសិករត្រូវជួលកម្លាំងពលកម្ម ប្រសិនបើពួកគេនៅតែ ចង់ធ្វើសហគ្រាសនេះ។<br><br>ចូរផ្តល់មតិយោបល់ជូនដល់សិក្ខាកាមថា ប្រសិនបើពួកគេពុំមានកម្លាំងពលកម្មគ្រួសារ គ្រប់គ្រាន់ និងមិនអាចស្វែងរកជួលកម្លាំងពលកម្មបានគ្រប់គ្រាន់ទេនោះ ពួកគេនឹងត្រូវពិចារណាប្រើប្រាស់បច្ចេកវិទ្យាសន្សំសំចៃកម្លាំងពលកម្ម ដូចជា ការធ្វើស្រែពង្រួស ជំនួសឱ្យការដកស្ទូង ការភ្ជួររាស់ដោយត្រាក់ទ័រ ការប្រើប្រាស់ម៉ាស៊ីនបោកបែន ការប្រើប្រាស់ម៉ាស៊ីនច្រូតកាត់ និងជួលម៉ាស៊ីនប្រមូលផល។ | <br>លំហាត់ ៤.១៥<br>សកម្មភាពទី៣៖<br>ឧទាហរណ៍ទំរង់<br>នៃធ្វើផែនការ<br>ថវិកា |

| | | |
|---|---|---|
| | ចូរសួរទៅកាន់សិក្ខាកាម ថាតើពួកគេពេញចិត្តទៅនឹងប្រាក់ចំណេញ/ការខាតបង់ដែរ ឬទេ? ប្រសិនបើពួកគេមិនពេញចិត្ត សូមឱ្យពួកគេបញ្ជាក់អំពីមូលហេតុ។ សូមឱ្យសិក្ខាកាមសរសេរចម្លើយរបស់ពួកគេ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ នៅពេលដែលពួកគេបញ្ចប់តារាងថវិកាចុងក្រោយរបស់ពួកគេ។ | |
| ៥ | **ផលចំណេញក្នុង១គ្រួសារសម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ៖**<br><br>ចូរពន្យល់ទៅកាន់សិក្ខាកាមថា គេអាចចែក **"ប្រាក់ចំណេញ"** ទៅនឹង **"ចំនួនសរុបនៃចំនួនថ្ងៃធ្វើពលកម្មរបស់គ្រួសារដោយឥតគិតថ្លៃ"** ដើម្បីទទួលបាន "ផលចំណេញក្នុង១គ្រួសារសម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ ដែលសមាជិកគ្រួសារធ្វើការងារពលកម្មដោយឥតគិតថ្លៃ"។<br><br>សូមឱ្យសិក្ខាកាមធ្វើការគណនាបែបនេះ នៅក្នុងអនុក្រុមរបស់ពួកគេ។ ចូរស្នើឱ្យប្រធានអនុក្រុមមួយរូប ធ្វើសេចក្តីរាយការណ៍អំពីចម្លើយរបស់ពួកគេ ដើម្បីពិភាក្សានៅក្នុងក្រុមធំ។<br><br>ចូរសួរទៅកាន់សិក្ខាកាមថា ៖<br><br>➢ តើពួកគេមានកម្លាំងពលកម្មគ្រួសារពីបុរស និងស្ត្រីគ្រប់គ្រាន់ដែរឬទេ ដើម្បីធ្វើសហគ្រាសរបស់ពួកគេ?<br><br>➢ តើពួកគេមានការភ្ញាក់ផ្អើលដែរឬទេ ចំពោះទំហំការងារដែលបុរស និងស្ត្រី ត្រូវធ្វើ?<br><br>➢ តើពួកគេមានការភ្ញាក់ផ្អើលដែរឬទេ ចំពោះ ផលចំណេញក្នុង១គ្រួសារសម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ?<br><br>➢ តើបុរសរកប្រាក់បានប៉ុន្មានសម្រាប់ការងារពលកម្មនេះ? (ចំនួនថ្ងៃដែលបុរស ធ្វើការងារ x ផលចំណេញក្នុង១គ្រួសារសម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ)<br><br>➢ តើស្ត្រីរកប្រាក់បានប៉ុន្មានសម្រាប់ការងារពលកម្មនេះ? (ចំនួនថ្ងៃដែលស្ត្រី ធ្វើការងារ x ផលចំណេញក្នុង១គ្រួសារសម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ) | <br>លំហាត់ ៤.១៥<br>សកម្មភាពទី៥៖ ប្រើប្រាស់<br>សកម្មភាពទី៤៖ ទំរងការអនុវត្តនៃការធ្វើផែនការថវិកា |

| | | |
|---|---|---|
| | គេហាត់អនុវត្តសរសេរ ហើយការដែលពួកគេធ្វើឱ្យមានកំហុសមួយចំនួន ពុំមែនជាបញ្ហាអ្វីឡើយ។ សមាជិកដទៃទៀត អាចពិភាក្សាអំពីចំណងជើង ខណ:ពេលដែលគេកំពុងធ្វើលំហាត់នេះ។<br><br>នៅពេលដែលក្រុមបានធ្វើការងារចប់រួចរាល់ ចូរបែងចែកជួរដែលនិយាយអំពីថ្លៃ ចំណាយចំនួនមួយជួរ ឬ ពីរជួរផ្សេងគ្នា ទៅឱ្យអនុក្រុមនីមិយ្យៗ ដើម្បីធ្វើការបំពេញ (ដើម្បីសន្សំសំចៃពេលវេលា)។ ចូរផ្តល់ពេលវេលាដល់អនុក្រុមតូចៗទាំងអស់ ចំនួន ១៥នាទី បន្ទាប់មក ចូរស្នើសុំឱ្យពួកគេរាយការណ៍ត្រឡប់ទៅឱ្យក្រុមធំវិញ។ ចូរសរសេរ គំនិតដែលមានការឯកភាពគ្នាជារួមនៅលើផ្ទាំងក្រដាសធំ។<br><br>**ថ្ងៃធ្វើការងារ ដោយមិនទទួលបានប្រាក់"កម្រៃរបស់សមាជិកគ្រួសារជា" បុរស និង ស្ត្រី៖** ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការងារជាក្រុមតូចៗ ដើម្បីសរសេរអំពីចំនួនថ្ងៃធ្វើការងារ "ដោយមិនទទួលបានប្រាក់កម្រៃរបស់សមាជិកគ្រួសារ" ជាបុរស និង ស្ត្រី ខណ:ពេលដែលពួកគេកំពុងអនុវត្តធ្វើសកម្មភាពសហគ្រាស នៅក្នុងគូឡោនចំនួនពីរចុងក្រោយ។ ចូរបែងចែកសកម្មភាពចំនួនមួយ ឬ ពីរទៅឱ្យអនុក្រុមនីមួយៗ។ ប៉ុន្មាននាទីក្រោយមក ចូរស្នើសុំឱ្យតំណាងអនុក្រុមផ្តល់សេចក្តីរាយការណ៍ជូនដល់ក្រុមធំ។ ចូរស្វែងរកការឯកភាពគ្នាជារួមមួយ បន្ទាប់មក ចូរសរសេរតួលេខចុងក្រោយនៅលើផ្ទាំងក្រដាសធំ។<br><br>ចូរបន្ថែមចំនួនថ្ងៃធ្វើការងារសរុប "ដោយមិនទទួលបានប្រាក់កម្រៃរបស់សមាជិក គ្រួសារ" ជាបុរស និង ស្ត្រី។ បន្ទាប់មក ចូរបូកបញ្ចូលគ្នានូវចំនួនថ្ងៃធ្វើការដោយបុរស និង ស្ត្រី ដើម្បីទទួលបានចំនួនសរុបនៃថ្ងៃធ្វើការដោយមិនទទួលបានប្រាក់កម្រៃរបស់សមាជិកគ្រួសារ។ | |
| ៤.៦ | ចូរសួរទៅកាន់កសិករអំពីវិធីគណនា "ប្រាក់ចំណូលសរុប" និង "ថ្លៃចំណាយសរុប"។ ចូរសរសេរចម្លើយនៅលើផ្ទាំងក្រដាសធំ ក្រោមចំណងជើង ក និង ខ។ ត្រូវធានាថា ការគណនាទាំងនោះមានភាពត្រឹមត្រូវ។<br><br>ចូរធ្វើដូចគ្នាសម្រាប់៖<br><br>"ប្រាក់ចំណេញ/ការខាតបង់" (ក - ខ) | <br>លំហាត់ ៤.១៥<br>សកម្មភាពទី៤៖<br>ទំរងការអនុវត្តនៃការធ្វើផែនការថវិកា |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី៤ ៖ លទ្ធភាពក្នុងការទទួលបានជោគជ័យរបស់សហគ្រាស

**លំហូរសាច់ប្រាក់ តម្រូវការថវិកា ការវិភាគឥទ្ធិពលយេនឌ័រ និងតារាងសង្ខេបពីលទ្ធភាពធនធាន ដែលមាន**



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងដឹងអំពីរបៀបបំពេញលំហូរសាច់ប្រាក់ប៉ាន់ប្រមាណទៅលើល័ក្ខខ័ណ្ឌតម្រូវផ្នែកថវិកា និងវាយតម្លៃទៅលើផលប៉ះពាល់របស់សហគ្រាសទៅលើបុរស និងស្ត្រី។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ការគណនានៃលំហូរសាច់ប្រាក់និងតម្រូវការថវិកា៖**<br>សូមឱ្យសិក្ខាកាមពិនិត្យមើលឧទាហរណ៍នៃលំហូរសាច់ប្រាក់នៅក្នុងសកម្មភាពទី១ លំហាត់ ៤.១៦ ក្នុងសៀវភៅលំហាត់របស់ពួកគេ។ ចូរពន្យល់ថា លំហូរសាច់ប្រាក់មួយ ធ្វើការវាស់ស្ទង់ទៅលើ**ប្រាក់ដែលហូរចូល** និង**ប្រាក់ដែលហូរចេញ**ពីសហគ្រាសរបស់ពួកគេ **ក្នុងរយៈពេលណាមួយ** ដើម្បីពិនិត្យមើលថា តើមានសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ដំណើរការសហគ្រាសរបស់ពួកគេដែរឬទេ។<br><br>ចូរពិនិត្យមើលឧទាហរណ៍នៅក្នុងសៀវភៅលំហាត់ ដោយសង្កត់ធ្ងន់ទៅលើចំណុច ដូចខាងក្រោម៖<br><br>➢ គ្រាន់តែធ្វើការកត់ត្រាសកម្មភាពដែលពួកគេចំណាយ ឬទទួលបានសាច់ប្រាក់។ ឧទាហរណ៍៖ គ្រាន់តែកត់ត្រាស្រូវអង្ករដែល គេលក់ប៉ុន្តែ ពុំបានកត់ត្រាអំពីស្រូវអង្ករដែលគេបានយកទៅប្តូរនឹងវត្ថុដទៃ ឬ ទទួលទាន។<br><br>➢ ត្រូវបញ្ចូលថ្លៃចំណាយសម្រាប់រៀបចំចាប់ផ្តើមធ្វើអាជីវកម្ម។ ចំណុចទាំងនេះ នឹងត្រូវយកមកពិភាក្សាលម្អិតជាងនេះ នៅក្នុងផ្នែកបន្ទាប់។<br><br>➢ មិនត្រូវបញ្ចូលថ្លៃចំណាយដែលពុំមែនជាសាច់ប្រាក់ ដូចជា "កម្លាំងពលកម្មដែលមិនទទួលបានប្រាក់កម្រៃ" ឡើយ។ | <br>លំហាត់ ៤.១៦<br>សកម្មភាពទី១<br>៖ការស្វែងយល់អំពីតារាងលំហូរសាច់ប្រាក់ |

| | | |
|---|---|---|
| | ➢ តើពួកគេយល់ដូចម្តេចដែរចំពោះ ផលចំណេញក្នុង១គ្រួសារ សម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ បើធៀបទៅនឹងសហគ្រាសកសិដ្ឋាន ឬ ស្រែចម្ការដទៃទៀត ដែលពួកគេស្គាល់? ឧទាហរណ៍ ៖ បន្លែ សណ្តែកសៀង ដំឡូងមី ការចិញ្ចឹមមាន់។<br>➢ តើពួកគេយល់ដូចម្តេចដែរចំពោះ ផលចំណេញក្នុង១គ្រួសារ សម្រាប់ការធ្វើពលកម្មក្នុង១ថ្ងៃ បើធៀបទៅនឹងការធ្វើការងារនៅក្រៅ កសិដ្ឋាន ឬ ស្រែចម្ការ? ឧទាហរណ៍ដូចជា ការធ្វើការងារនៅក្នុងរោងចក្រកាត់ដេរ ដែលទទួលបាន ប្រាក់កម្រៃចំនួន ១០.០០០រៀល/១ថ្ងៃ។<br>➢ តើពួកគេគួរបន្តធ្វើការងារនៅក្នុងកសិដ្ឋាន ឬ ស្រែចម្ការរបស់ពួកគេ ឬ ធ្វើការងារនៅខាងក្រៅ? | |
| ៦ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទីដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយ សំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួល គួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកានៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | សម្រាប់ចាប់ផ្តើមអាជីវកម្ម" នៅក្នុងលំហាត់ ៤.១៦ នៃសៀវភៅលំហាត់របស់ពួកគេ និង សូមឱ្យពួកគេបន្ថែមឧទាហរណ៍ដទៃទៀត ទៅក្នុងបញ្ជីរាយនាមនេះ ប្រសិនបើពួកគេមានបំណងចង់បន្ថែមឧទាហរណ៍ដទៃទៀត។<br><br>ចូរពិនិត្យមើលបញ្ជីរាយនាមដែលនៅសេសសល់នៃ "ខ្ទង់ចំណាយដទៃទៀត" ដែលត្រូវទិញនៅក្នុងឧទហរណ៍របស់ពួកគេ (គ្រាប់ពូជ ជី ចំបើង ឬវត្ថុសម្រាប់គ្របពីលើរង ការជួលកម្លាំងពលកម្ម)។<br><br>➢ បង្ហាញការពណ៌នាអំពីវត្ថុនោះ តម្លៃរបស់វត្ថុនីមួយៗ និងរយៈពេលដែលត្រូវធ្វើការទូទាត់ថវិកា។<br><br>➢ បង្ហាញអំពីរបៀបគណនា "លំហូរសាច់ប្រាក់ចេញសរុប"(ខ) ក្នុងរយៈពេលណាមួយ។<br><br>➢ បង្ហាញអំពីរបៀបគណនា នៅក្នុងគូឡោន "ថ្លៃចំណាយសរុប" ខាងស្តាំ។<br><br>➢ បង្ហាញអំពីរបៀបគណនាប្រាក់ចំណេញ/ការខាតបង់ (គ) ក្នុងរយៈពេលណាមួយ តាមរយៈការធ្វើប្រមាណវិធីដក (ក - ខ)។ | |
| ១.២ | ចូរពន្យល់ថា តួលេខអវិជ្ជមាន (ការខាតបង់) ក្នុងរយៈពេលណាមួយ បង្ហាញអំពី ចំនួនទឹកប្រាក់បន្ថែមដែលត្រូវការ ដើម្បីផ្តល់ការគាំទ្រមូលនិធិជូនដល់សហគ្រាស។<br><br>សូមស្នើសុំឱ្យសិក្ខាកាមពិនិត្យមើលឧទាហរណ៍អំពីលំហូរសាច់ប្រាក់ នៅក្នុងសកម្មភាពទី១ លំហាត់៤.១៦ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរបង្ហាញពួកគេ តើសហគ្រាសនៅក្នុងឧទាហរណ៍ត្រូវការសាច់ប្រាក់បន្ថែមចំនួនប៉ុន្មាន? ចំនួនសាច់ប្រាក់សរុបដែលគេត្រូវការ គឺជាការបូកបន្ថែមបញ្ចូលគ្នានូវរាល់លំហូរសាច់ប្រាក់អវិជ្ជមានប្រចាំខែ។<br><br>(-២២០.០០០) + (-១៣០.០០០) = (-៣៥០.០០០) រៀល សម្រាប់ផ្គត់ផ្គង់ថវិកាដល់សហគ្រាស។ | <br>លំហាត់ ៤.១៦<br>សកម្មភាពទី១៖<br>ឧទាហរណ៍នៃ<br>លំហូរសាច់ប្រាក់ |
| ២ | **ការគណនាលំហូរសាច់ប្រាក់នៃសហគ្រាសដែលពួកគេបានជ្រើសរើស៖**<br><br>ចូររៀបចំតម្លើងផ្ទាំងក្រដាសធំមួយសន្លឹក ដែលរួមមាន តួលេខថវិការបស់ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ១.១ | **របៀបបំពេញទម្រង់ឧទាហរណ៍នៃលំហូរសាច់ប្រាក់៖**<br><br>១. ចូរសរសេរឈ្មោះសហគ្រាសនៅជួរខាងលើ។<br><br>២. ចូរពិនិត្យមើលរយៈពេលនៃលំហូរសាច់ប្រាក់ (ចំនួនថ្ងៃ ខែ ឆ្នាំ) នៅក្នុងជួរទី១ នៃគួឡោន។ ទម្រង់ឧទាហរណ៍បង្ហាញអំពីចំនួនខែ ប៉ុន្តែសិក្ខាកាមគួរពិភាក្សាអំពីរយៈពេលដែលពាក់ព័ន្ធទៅនឹងសហគ្រាសរបស់ពួកគេ។<br><br>៣. **លំហូរសាច់ប្រាក់ចូល៖**<br><br>ចូរសរសេរអំពីប្រភពនៃចំណូលសាច់ប្រាក់នៅក្នុងផ្នែកដែលនិយាយអំពីលំហូរសាច់ប្រាក់ចូលនៃគួឡោនទី១។ (នៅក្នុងឧទាហរណ៍ ៖ ការលក់ត្រសក់ និងខាត់ណា។)<br><br>ចូរសរសេររាយនាមអំពីចំនួនសាច់ប្រាក់ដែលលក់បាននៅក្នុងរយៈពេលដែលត្រូវធ្វើការទូទាត់ប្រាក់។ (នៅក្នុងឧទាហរណ៍នេះ ចំនួនសាច់ប្រាក់ត្រូវបញ្ចូល ទៅក្នុងគួឡោនទី៥ ប្រសិនបើប្រាក់ដែល<br><br>ចូរបន្ថែម "លំហូរសាច់ប្រាក់សរុប" (ក) សម្រាប់រយៈពេលនីមួយៗ ដាក់ "ប្រាក់ចំណូលសរុប" នៅក្នុងគួឡោនខាងស្តាំ។<br><br>**លំហូរសាច់ប្រាក់ចេញ ៖**<br><br>ចូរសរសេររាយនាមថ្លៃចំណាយសម្រាប់ "ចាប់ផ្តើមអាជីវកម្ម" នៅក្នុងគួឡោនទី១។<br><br>ថ្លៃចំណាយសម្រាប់ **"ចាប់ផ្តើមធ្វើអាជីវកម្ម"** ចូរពន្យល់ទៅកាន់ក្រុមថា សម្រាប់សហគ្រាសថ្មីៗមួយចំនួន សិក្ខាកាមត្រូវប្រើប្រាស់សាច់ប្រាក់ដើម្បីទិញ អគារថ្មី ឬ អគារដែលគេប្រើប្រាស់រួច គ្រឿងចក្រ និងឧបករណ៍នានាដែល គេអាចប្រើប្រាស់នៅក្នុងវដ្តនៃការផលិតមួយចំនួន។ ថ្លៃចំណាយជាសាច់ប្រាក់ទាំងស្រុងនៃសម្ភារៈទាំងនេះត្រូវបញ្ចូលទៅក្នុងលំហូរសាច់ប្រាក់របស់ពួកគេ នៅពេលដែលថវិកាត្រូវបានគេយកមកធ្វើការទូទាត់ សម្រាប់វត្ថុទាំងនេះ។<br><br>ចូរធ្វើការប្រមូលផ្តុំគំនិតនូវឧទាហរណ៍មួយចំនួននៃ "ថ្លៃចំណាយសម្រាប់ចាប់ផ្តើម អាជីវកម្ម" នៃសហគ្រាសរបស់ពួកគេ។<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលបញ្ជីរាយនាមឧទាហរណ៍នៃ "ថ្លៃចំណាយ | <br>លំហាត់ ៤.១៦<br>សកម្មភាពទី១៖<br>ឧទាហរណ៍នៃ<br>លំហូរសាច់ប្រាក់<br><br><br>លំហាត់ ៤.១៦<br>សកម្មភាពទី១៖<br>សេចក្តីណែនាំ<br>អំពីលំហូរសាច់<br>ប្រាក់<br><br><br>លំហាត់ ៤.១៦<br>សកម្មភាពទី១៖<br>ឧទាហរណ៍នៃថ្លៃ<br>ចំណាយចាប់ផ្តើ<br>ម អាជីវកម្ម |

| | | |
|---|---|---|
| ២.២ | **ការផ្លាស់ប្តូរល័ក្ខខ័ណ្ឌតម្រូវស្តង់ដារថវិកាក្នុងមួយឯកតាទៅតាមល័ក្ខខ័ណ្ឌផ្ទាល់ខ្លួនរបស់កសិករ៖**<br><br>ចូរប្រាប់សិក្ខាកាមថា តួលេខនៃតម្រូវការថវិកា គឺសម្រាប់ស្តង់ដារឯកតានៃការផលិត ឧទាហរណ៍ដូចជា ក្នុងមួយហិកតា។ ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេអាចធ្វើការគណនាតម្រូវការថវិកា សម្រាប់ផ្ទៃដីផ្ទាល់ខ្លួនរបស់ពួកគេបានដោយរបៀបណា? (ការគណនារបស់ពួកគេ អាចពុំមែនប្រើប្រាស់ស្តង់ដារឯកតា ដូចជា មួយហិកតាឡើយ)។<br><br>**សកម្មភាពទី៣៖** ចូរជួយដល់កសិករក្នុងការគណនាតម្រូវការថវិកាផ្ទាល់ខ្លួនរបស់ពួកគេ ដោយយោងទៅតាមទំហំ ឬតំបន់សហគ្រាសរបស់ពួកគេ ដោយអនុវត្តតាម ឧទាហរណ៍នៅក្នុងសកម្មភាពទី៣ លំហាត់ ៥.១៦ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>**ការគណនា៖**<br><br>ប្រសិនបើឧទាហរណ៍នៃលំហូរសាច់ប្រាក់ ទាក់ទងទៅនឹងផ្ទៃដីមួយហិកតា (១០.០០០ ម៉ែត្រការ៉េ) ខណៈពេលដែលកសិករមានផ្ទៃដីត្រឹមតែ ៧.៥០០ ម៉ែត្រការ៉េ ចូរចែក ៧.៥០០ម៉ែត្រការ៉េ នឹង ១០.០០០ ម៉ែត្រការ៉េ = ០,៧៥។ ចូរគុណតួលេខនេះ នឹង តួលេខតម្រូវការថវិកាក្នុងមួយហិកតាពីថវិកាសម្រាប់ស្តង់ដារឯកតាមួយ ដើម្បីទទួលបានតម្រូវការថវិកាសម្រាប់ផ្ទៃដី ០,៧៥ហិកតា របស់កសិករ។<br><br>ចូរស្នើសុំឱ្យកសិករធ្វើការគណនាអំពីតម្រូវការថវិកាផ្ទាល់ខ្លួនរបស់ពួកគេ ដែលមានភាពជាក់លាក់ទៅនឹងផ្ទៃដីរបស់ពួកគេ។ ស្នើសុំឱ្យសិក្ខាកាមមួយចំនួនដែលត្រូវបានជ្រើសរើស ឱ្យឡើងធ្វើសេចក្តីរាយការណ៍អំពីតម្រូវការថវិការបស់ពួកគេ។ បន្ទាប់មក ចូរសួរទៅកាន់ពួកគេ ថាតើពួកគេមានប្រាក់គ្រប់គ្រាន់ដើម្បីគាំទ្រដល់សហគ្រាស ដែលពួកគេបានជ្រើសរើសដែរឬទេ ឬពួកគេត្រូវខ្ចីប្រាក់ពីប្រភពដទៃ។<br><br>ប្រសិនបើពួកគេពុំមានប្រាក់គ្រប់គ្រាន់ទេនោះ ចូរផ្តល់មតិយោបល់ថា ពួកគេគួរចូលរួមសិក្សារៀនសូត្រមេរៀនទី៥ ដែលពិនិត្យមើលទៅលើបញ្ហា "ស្វែងរកប្រភពថវិកា"។ | <br>លំហាត់ ៥.១៦<br>សកម្មភាពទី៣៖<br>ការគណនា<br>តម្រូវការថវិកា<br>ផ្ទាល់ខ្លួនរបស់<br>កសិករ |

| | | |
|---|---|---|
| | សិក្ខាកាម នៅក្នុងសកម្មភាពទី៤ លំហាត់ ៤.១៥ ក្នុងសៀវភៅលំហាត់របស់ពួកគេ។<br><br>សូមប្រាប់ឱ្យអនុក្រុមតូចៗទាំងអស់ចម្លងព័ត៌មានពីថវិកាសហគ្រាសរបស់ពួកគេ ដែលរួមមានដូចជា ឈ្មោះសហគ្រាស ប្រាក់ចំណូល និងថ្លៃចំណាយក្នុងរយៈពេលណាមួយ ទៅក្នុងទម្រង់អនុវត្តលំហូរសាច់ប្រាក់ទទេស្អាតមួយ នៅក្នុងសកម្មភាពទី២ លំហាត់ ៤.១៦ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>ស្នើឱ្យសិក្ខាកាមនៅក្នុងក្រុមធំ រាយការណ៍អំពីលទ្ធផលប្រាក់ចំណេញ/ការខាតបង់របស់ពួកគេ ក្នុងរយៈពេលនីមួយៗ និងវដ្តទាំងមូល។ ធានាថាសិក្ខាកាមគ្រប់រូប យល់អំពីដំណើរការនៃការគណនាប្រាក់ចំណេញ/ការខាតបង់ ក្នុងរយៈពេលនីមួយៗ។ | <br>លំហាត់ ៤.១៥<br>សកម្មភាពទី៤ ៖<br>ផែនការថវិកាចុងក្រោយ<br><br><br>លំហាត់ ៤.១៦<br>សកម្មភាពទី២ ៖<br>ការអនុវត្តទម្រង់ផែនការលំហូរសាច់ប្រាក់ |
| ២.១ | **ការគណនាអំពីតម្រូវការថវិកា៖**<br><br>ចូររំលឹកសិក្ខាកាមថា លទ្ធផលអវិជ្ជមានមួយ (ការខាតបង់) បង្ហាញអំពីចំនួនថវិកាដែលគេត្រូវការសម្រាប់ផ្គត់ផ្គង់ដល់សហគ្រាស ក្នុងរយៈពេលនីមួយៗ។<br><br>**សកម្មភាពទី៣៖** សូមឱ្យសិក្ខាកាមនៅក្នុងអនុក្រុមតូចៗរបស់ពួកគេធ្វើការ៖<br>➢ គណនាចំនួនសាច់ប្រាក់បន្ថែមដែលគេត្រូវការ ដើម្បីផ្គត់ផ្គង់ថវិកាដល់សហគ្រាសរបស់ពួកគេជារៀងរាល់ខែ និង ចំនួនសាច់ប្រាក់សរុប។ ចូរធ្វើលំហាត់នេះនៅក្នុងទម្រង់ "អនុវត្ត"លំហូរសាច់ប្រាក់ ក្នុងសៀវភៅលំហាត់របស់ពួកគេ។<br>➢ រាយការណ៍ព័ត៌មាននេះទៅឱ្យក្រុមធំវិញ ដើម្បីធ្វើការពិភាក្សា។<br><br>សូមឱ្យប្រធានអនុក្រុមតូចៗទាំងអស់ ជួយដល់សមាជិកអនុក្រុមរបស់ពួកគេ ក្នុងការសរសេរតួលេខចុងក្រោយ ទៅក្នុងទម្រង់លំហូរសាច់ប្រាក់ចុងក្រោយ បន្ទាប់ពីវគ្គនេះបានបញ្ចប់។<br><br>ផ្នែកបន្ទាប់ នឹងធ្វើការគ្របដណ្តប់ទៅលើវិធីគណនាថវិកាដែលគេត្រូវការសម្រាប់ទំហំសហគ្រាសរបស់សិក្ខាកាមនីមួយៗ។ | |

| | | |
|---|---|---|
| | តើពួកគេមើលឃើញដំណោះស្រាយអ្វីខ្លះ ចំពោះបញ្ហាលំបាកទាំងនោះ? ចូរសរសេរចម្លើយទាំងនេះ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក អំពីកត្តាប្រឈមឬ បញ្ហារាំងស្ទះទាំងនោះ។<br><br>**សកម្មភាពទី៣៖** ចូរសួរសំនួរខ្លីៗដូចខាងក្រោម ដោយសូមឱ្យសិក្ខាកាមបំពេញចម្លើយ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។<br><br>សំនួរខ្លីៗនៅក្នុសៀវភៅលំហាត់៖<br><br>១. ជាទូទៅ តើបុរសមានឆន្ទៈ និងអាចចូលរួមនៅក្នុងសហគ្រាសនេះ ដែរឬទេ? ហេតុអ្វី?<br><br>២. ជាទូទៅតើស្ត្រីមានឆន្ទៈនិងអាចចូលរួមនៅក្នុងសហគ្រាសនេះ ដែរឬទេ? ហេតុអ្វី?<br><br>ជាចុងក្រោយ ចូររំលឹកសិក្ខាកាមថា រាល់ការផ្តល់មតិយោបល់អំពីសកម្មភាព និងថ្លៃចំណាយនានា ដើម្បីធ្វើឱ្យសហគ្រាសផ្តោតយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើបញ្ហាយេនឌ័រ (ជួលកម្លាំងពលកម្មដើម្បីឱ្យស្ត្រីមានពេលទំនេរ) គួរបញ្ចូលទៅក្នុងខ្ទង់ចំណាយថវិការបស់ពួកគេ។ | |
| ៤ | **បញ្ជីផ្ទៀងផ្ទាត់ទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យ៖**<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលបញ្ជីផ្ទៀងផ្ទាត់ទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យ នៅក្នុងសកម្មភាពទី១ លំហាត់ ៤.១៨ នៃសៀវភៅលំហាត់របស់ពួកគេ។ សូមឱ្យសិក្ខាកាមធ្វើការងារនៅក្នុងអនុក្រុមតូចៗរបស់ពួកគេ ដើម្បីបំពេញបញ្ជីផ្ទៀងផ្ទាត់នេះ។<br><br>សូមអញ្ជើញសិក្ខាកាមនីមួយៗ ឱ្យឆ្លើយទៅនឹងសំនួរនៅក្នុងសៀវភៅលំហាត់របស់ពួកគេ នៅចុងបញ្ចប់នៃបញ្ជីផ្ទៀងផ្ទាត់ទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យ ៖<br><br>➢ តើពួកគេមានឆន្ទៈក្នុងការបោះជំហានទៅមុខ ជាមួយនឹងសហគ្រាសនេះ ដែរឬទេ?<br><br>សូមឱ្យសិក្ខាកាមធ្វើការពិភាក្សាអំពីគំនិតរបស់ពួកគេជាមួយក្រុមធំ ដោយពន្យល់អំពីមូលហេតុ ថាហេតុអ្វីបានជាពួកគេនិយាយថា បាទ/ចាស៎ ឬ ទេ។ | |

| | | |
|---|---|---|
| ៣ | **ផលប៉ះពាល់នៃសហគ្រាសទៅលើបុរស និងស្ត្រី៖**<br><br>ចូរប្រាប់សិក្ខាកាមថា ទាំងបុរស និងស្ត្រី ដែលរស់នៅតំបន់ជនបទ រមែងតែងចូលរួមនៅក្នុងសកម្មភាពកសិកម្មក្នុងលក្ខណៈខុសៗគ្នា។ កន្លងមកបុរសធ្វើការងារមួយចំនួនដោយឡែក ស្ត្រីធ្វើការងារមួយចំនួនទៀត។ បើទោះជាដូច្នេះក្តី នៅពេលដែលបុរស ឬ ស្ត្រីត្រូវទៅឆ្ងាយ ពេលនោះបុរសអាចធ្វើការងាររបស់ស្ត្រី ឬ ស្ត្រីអាចធ្វើការងាររបស់បុរស ឧទាហរណ៍ដូចជា ស្ត្រីអាចធ្វើទ្រុងមាន់ ឬ បុរសអាចថែទាំសំណាប។ វាអាស្រ័យទៅលើស្ថានភាពគ្រួសារ។<br><br>ចូរពន្យល់ថា នៅពេលចាប់ផ្តើមធ្វើសហគ្រាសថ្មីមួយ ឬ ពង្រីកសហគ្រាសដែលមានស្រាប់ទាំងបុរស និងស្ត្រី នឹងទទួលរងផលប៉ះពាល់មួយចំនួន។ ផលប៉ះពាល់នៃសហគ្រាស គឺអាស្រ័យទៅលើកត្តាជាច្រើនផ្សេងៗគ្នា ដូចជា តួនាទីដែលពួកគេធ្វើពេលវេលាដែលគេចំណាយទៅលើការអនុវត្តភារកិច្ច តើពួកគេមានតួនាទីដឹកនាំដែរឬទេ តើពួកគេគិតថា ពួកគេនឹងទទួលបានប្រយោជន៍ច្រើនប៉ុណ្ណាពីសហគ្រាសនេះ។ល។<br><br>ចូរប្រាប់ឱ្យសិក្ខាកាមពិនិត្យមើលតារាងវាយតម្លៃផលប៉ះពាល់ទៅលើបុរស និង ស្ត្រី នៅក្នុងលំហាត់ ៩.១៧ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>**សកម្មភាពទី១៖** បំបែកសិក្ខាកាមជាក្រុមដែលមានភេទដូចគ្នា ដើម្បីពិភាក្សាអំពី តើជីវិតរបស់ពួកគេនឹងទទួលរងផលប៉ះពាល់ពីសហគ្រាសនេះយ៉ាងដូចម្តេច។ ស្ត្រីគួរ បំពេញការវាយតម្លៃអំពីផលប៉ះពាល់ទៅលើស្ត្រី ហើយ បុរសគួរធ្វើការវាយតម្លៃទៅ លើបុរស។ បន្ទាប់មក ចូរធ្វើការកត់ត្រាព័ត៌មានរបស់ក្រុមបុរស និងក្រុមស្ត្រីនៅលើផ្ទាំងក្រដាស និងពិភាក្សារួមគ្នាអំពីផលប៉ះពាល់ទៅលើបុរស និងស្ត្រី។<br><br>សូមឱ្យសិក្ខាកាមធ្វើការសង្ខេប ដោយពិភាក្សាអំពីរបៀបដែលសហគ្រាសបង្កឱ្យមាន ផលប៉ះពាល់ទៅលើបុរស និងស្ត្រី។ បន្ទាប់មក ចូរពិភាក្សាថា តើឥទ្ធិពលទាំងនេះ បង្កឱ្យមានផលប៉ះពាល់បន្ថែមទៀតទៅលើគ្រួសារ ឧទាហរណ៍ ដូចជា កូន សាច់ញាតិ ឬ បងប្អូន នៅក្នុងសហគមន៍ដែលទូលំទូលាយជាងនេះដែរឬទេ។ បន្ទាប់មក សូមឱ្យសិក្ខាកាមឆ្លើយទៅនឹងសំនួរខាងក្រោម៖<br><br>**សកម្មភាពទី២** ៖ ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេមិនសប្បាយចិត្តទៅនឹងផលប៉ះពាល់នៃសហគ្រាសនេះឬ? | <br>លំហាត់ ៩.១៧<br>សកម្មភាពទី១៖<br>តារាងវាយតម្លៃ<br>យេនឌ័រ<br><br><br>លំហាត់ ៩.១៨<br>សកម្មភាពទី១៖<br>បញ្ជីផ្ទៀងផ្ទាត់<br>ទៅលើលទ្ធភាព<br>ក្នុងការទទួល<br>បាន ជោគជ័យ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ៦ | **ការវាយតម្លៃមេរៀនទី៤៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ **សាលាអាជីវកម្មកសិកម្ម** នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គ **សាលាអាជីវកម្មកសិកម្ម** នៅពេលអនាគត។ | |

| | | |
|---|---|---|
| ៥ | **ផែនការកសិដ្ឋាន ឬចំការទាំងមូល៖**<br><br>សូមឱ្យសិក្ខាកាមធ្វើការពិភាក្សាអំពីផែនការសម្រាប់ក្រុមតូចៗ នូវអ្វីដែលសហគ្រាសនឹងត្រូវអនុវត្តសម្រាប់កសិដ្ឋាន ឬចំការទាំងមូលនារដូវកាលផលិតកម្មឆ្នាំបន្ទាប់។ចូរសរសេរកំរងសំណួរទៅក្នុងក្រដាសផ្ទាំងធំសម្រាប់ការពិភាក្សារបស់ពួកគេ៖<br><br>១. តើពួកគេបានធ្វើការសិក្សាពីលទ្ធភាពដែលអាចធ្វើបានចំពោះសហគ្រាសដែលជ្រើសរើសដែរឬទេ?<br><br>២. តើអ្នកនឹងធ្វើការជ្រើសរើសសហគ្រាស ដែលទទួលបានប្រាក់ចំណេញច្រើនមែនទេ? តើវាជាសហគ្រាសមួយណា?<br><br>៣. តើអ្នកដែលគិតថាការផ្លាស់ប្តូរពីការដាំដំណាំតែមួយមុខ ទៅជាដំណាំច្រើនមុខសម្រាប់រដូវវស្សាខាងមុខ ដោយចាប់ដាំដំណាំដែលមានអាយុកាលពីខែមេសា- មិថុនា បន្ទាប់មក ដាំដំណាំផ្សេងទៀតពីខែ កក្កដា-ធ្នូ?<br><br>៤. តើអ្នកដែលគិតថាការដាំដំណាំដែលបំពេញបង្គ្រប់អោយគ្នាដូចជាការពូកសណ្តែកដែលមានឫសអាចចាប់អាសូតពីបរិយាកាសអាចផ្តល់ជីជាតិដល់ដីសម្រាប់ដំណាំស្រូវដែលនឹងត្រូវដាំនារដូវបន្ទាប់ដែរឬទេ?<br><br>៥. តើអ្នកដែលគិតថាសេចក្តីត្រូវការកម្លាំងពលកម្មគួរបញ្ចៀសភាពមមាញឹកបានតាមរយៈការធ្វើផលិតកម្មពេញមួយឆ្នាំ?<br><br>៦. តើអ្នកគិតថា ប្រាក់ចំណេញដែលអ្នកទទួលបានពីកសិដ្ឋាន ឬចំការទាំងមូលរបស់អ្នកមានប៉ុន្មាន?<br><br>៧. តើចំណូលទាំងអស់ គ្រប់គ្រាន់សម្រាប់គ្រួសារអ្នក ដើម្បីទប់ស្កាត់ការប្តូរទីលំនៅទៅប្រកបការងារខាងក្រៅដែរឬទេ?<br><br>ស្នើរទៅអ្នកចូលរួម អោយចែករំលែកនូវគំនិតពួកគេសម្រាប់កិច្ចប្រជុំទាំងមូល។ | <br>លំហាត់ ៤.១៩៖ ផែនការកសិដ្ឋាន ឬចំការទាំងមូល |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | (សម្គាល់ ៖ ត្រូវធានាថា ឧទាហរណ៍របស់អ្នក ពុំមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់រាល់តម្រូវការសាច់ ប្រាក់ឡើយ។)<br><br>ចូរគណនាអំពីសាច់ប្រាក់ដែលលើសលុប ឬ ឱនភាពសាច់ប្រាក់នៅក្នុងខែនីមួយៗ ក្រោយពេលដែលកសិករបានដាក់បញ្ចូលសាច់ប្រាក់ផ្ទាល់ខ្លួនរបស់ពួកគេ។ ចូរប្រាប់សិក្ខាកាមថា ប្រសិនបើនៅតែមានឱនភាពថវិកាទៀត គេត្រូវផ្គត់ផ្គង់ថវិកាដល់សហគ្រាសរបស់ពួកគេ ដោយវិធីផ្សេងទៀត។<br><br>ចូរសួរសិក្ខាកាមថា តើថវិការបស់ពួកគេអាចមានប្រភពមកពីណាខ្លះ។ ចូរណែនាំពួកគេថា ជូនកាល ពួកគេក៏ត្រូវការខ្ចីប្រាក់ផងដែរ។ | |
| ៤ | **អត្ថប្រយោជន៍ និងហានិភ័យ ឬ ការប្រឈមនៃការខ្ចីប្រាក់៖**<br>ចូរសរសេរសំនួរខាងក្រោមនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br>➢ តើការខ្ចីប្រាក់មានអត្ថប្រយោជន៍អ្វីខ្លះ?<br>➢ តើការខ្ចីប្រាក់មានហានិភ័យ ឬ ការប្រឈមអ្វីខ្លះ?<br>➢ តើពេលណាដែលយើងមិនគួរខ្ចីប្រាក់?<br><br>ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការងារនៅក្នុងអនុក្រុមតូចៗរបស់ពួកគេ ដើម្បីពិភាក្សាសំនួរទាំងនេះ។ ចូរកត់ត្រាចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ។<br><br>បន្ទាប់មក ប្រៀបធៀបចម្លើយរបស់ពួកគេជាមួយចម្លើយនៅក្នុងសៀវភៅលំហាត់ (លំហាត់ ៥.១)។ ចូរស្នើសុំឱ្យសិក្ខាកាមបន្ថែមគំនិតផ្សេងទៀតទៅក្នុងសៀវភៅលំហាត់របស់ពួកគេ ប្រសិនបើគំនិតទាំងនោះ មិនទាន់មានរៀបរាប់នៅក្នុងសៀវភៅលំហាត់។<br><br>**អត្ថប្រយោជន៍**មួយចំនួន អាចរួមមានដូចជា៖<br>➢ អាចប្រើប្រាស់ឥណទានដើម្បីចាប់ផ្តើមធ្វើមុខជំនួញថ្មីមួយដែលមានសក្តានុពលផ្នែកទីផ្សារល្អប្រសើរ និងទទួលបានប្រាក់ចំណេញ<br>➢ ដើម្បីពង្រីកសហគ្រាសបច្ចុប្បន្ន ដែលកំពុងតែទទួលបានប្រាក់ចំណេញ។ | ក្រដាសផ្ទាំងធំ និងប៊ិច<br><br><br><br>លំហាត់ ៥.១៖ អត្ថប្រយោជន៍ និងហានិភ័យនៃការខ្ចីប្រាក់ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

### មេរៀនទី៥ ៖ ការស្វែងរកប្រភពថវិកា



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងយល់អំពីវិធីស្វែងរកប្រភពមូលនិធិ។




៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **កម្រងសំនួរអង្កេតទៅលើអ្នកផ្តល់ប្រាក់កម្ចី៖**<br>មុនពេលបន្តទៅជំហានទី២ អ្នកសម្របសម្រួលគួរធ្វើការស្វែងយល់បន្តិចបន្តួចអំពីអ្នកផ្តល់ប្រាក់កម្ចីនៅក្នុងតំបន់នេះ ដើម្បីឱ្យអ្នកសម្របសម្រួលអាចផ្តល់ការណែនាំបានកាន់តែល្អប្រសើរ ចំពោះលំហាត់ប្រមូលព័ត៌មានបន្ទាប់។ ប្រសិនបើអ្នកផ្តល់ប្រាក់កម្ចី មានព័ត៌មានបោះពុម្ពផ្សាយអំពីល័ក្ខខ័ណ្ឌនៃការផ្តល់ប្រាក់កម្ចី អ្នកសម្របសម្រួលគួរព្យាយាមស្វែងរកព័ត៌មានទាំងនោះ ដើម្បីជាឯកសារយោងសម្រាប់ពិភាក្សាបន្ត។ | ព័ត៌មានដែលត្រូវបានប្រមូលជាមុនពីអ្នកផ្តល់សេវាឥណទាន |
| ២ | សូមឱ្យសិក្ខាកាមពិនិត្យមើលលំហូរសាច់ប្រាក់សម្រាប់សហគ្រាសរបស់ពួកគេ នៅលើផ្ទាំងក្រដាសអំពីលំហូរសាច់ប្រាក់របស់សហគ្រាស ដែលត្រូវបានរៀបចំបង្កើតឡើង នៅក្នុងលំហាត់ ៤.១៦ កាលពីវគ្គមុន។<br><br>សូមឱ្យសិក្ខាកាមមួយរូប ពិនិត្យមើលផ្ទាំងក្រដាសនេះ និងពន្យល់ទៅកាន់សិក្ខាកាមដទៃ ថាតើគេត្រូវការថវិកាបន្ថែមចំនួនប៉ុន្មាន សម្រាប់ទូទាត់ថ្លៃចំណាយរបស់សហគ្រាសនេះ (ឧទាហរណ៍ ថវិកាបន្ថែមក្នុងខែនីមួយៗ និង ថវិកាបន្ថែមសរុប) និងរបៀបគណនាតួលេខទាំងនេះ។ | <br>លំហាត់ ៤.១៦៖ ផ្ទាំងក្រដាសអំពីលំហូរសាច់ប្រាក់របស់សហគ្រាសបុគ្គលពីមេរៀនទី៤ |
| ៣ | **សាច់ប្រាក់ផ្ទាល់ខ្លួនដែលមាន៖**<br>ចូរពន្យល់ថា នៅក្នុងករណីភាគច្រើន កសិករមានថវិកាផ្ទាល់ខ្លួនមួយចំនួនសម្រាប់ទូទាត់ថ្លៃចំណាយនៅក្នុងសហគ្រាសរបស់ពួកគេ។ ជួនកាល ថវិកានេះស្ថិតនៅក្នុងទម្រង់ជាកញ្ចប់ធំមួយ ហើយជួនកាលទៀត វាមានទម្រង់ជាចំណែកតូចៗ អាស្រ័យទៅតាមប្រភពចំណូល និងប្រភពចំណាយរបស់កសិករ។<br><br>ចូរសរសេរឧទាហរណ៍មួយអំពីវិភាគទានសាច់ប្រាក់របស់កសិករមួយរូបនៅលើផ្ទាំងក្រដាសធំ ក្នុងគូឡោន ១"សាច់ប្រាក់ផ្ទាល់ខ្លួនដែលមាន" | <br>លំហាត់ ៤.១៦៖ **សកម្មភាព ៣៖** លំហូរសាច់ប្រាក់ចុងក្រោយ |

| | | |
|---|---|---|
| | ស្នើសុំឱ្យកសិករសរសេរអំពីប្រភពដែលពួកគេអាចទទួលបានហិរញ្ញវត្ថុនៅក្នុងគូឡោនខាងឆ្វេងនៃតារាងប្រភពឥណទានក្នុងមូលដ្ឋាន (លំហាត់ ៥.២) នៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ ចូរបន្ថែមជួរបន្ថែមទៀតប្រសិនបើចាំបាច់។ ផ្នែកដទៃទៀតនៃតារាងនេះ នឹងត្រូវបានបំពេញនៅក្នុងសកម្មភាពបន្ទាប់។<br><br>ចូរពន្យល់ថា បុគ្គល ឬ ស្ថាប័នដែលផ្តល់ប្រាក់កម្ចី រមែងតែងកំណត់ល័ក្ខខ័ណ្ឌសម្រាប់ការសងប្រាក់ត្រឡប់មកវិញ។<br><br>ចូរស្នើសុំឱ្យសិក្ខាកាមដែលត្រូវបានជ្រើសរើស ធ្វើការចែករំលែកបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ ទាក់ទងទៅនឹងល័ក្ខខ័ណ្ឌសងប្រាក់សំខាន់ៗរបស់អ្នកផ្តល់ប្រាក់កម្ចី។<br><br>បន្ទាប់មក ចូរសូមឱ្យសិក្ខាកាមពិនិត្យមើលបញ្ជីរាយនាមល័ក្ខខ័ណ្ឌនៅក្នុងផ្នែកបន្ទាប់ (លំហាត់ ៥.៣)។ | |
| ៦ | **ការត្រួតពិនិត្យទៅលើល័ក្ខខ័ណ្ឌផ្តល់ប្រាក់កម្ចី៖**<br><br>សូមឱ្យសិក្ខាកាមធ្វើការងារជាគូ និង ពិភាក្សាទៅវិញទៅមកអំពីល័ក្ខខ័ណ្ឌមួយ ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងនេះ។ បន្ទាប់មក ចូរសូមឱ្យពួកគេផ្តល់ការពន្យល់ទៅកាន់សមាជិកដទៃទៀតនៅក្នុងក្រុម ថាតើល័ក្ខខ័ណ្ឌទាំងនេះមានន័យដូចម្តេច។ ចូរផ្តល់ជំនួយនៅពេលដែលចាំបាច់។<br><br>១. **ចំនួនទឹកប្រាក់កម្ចីអតិបរមា៖** អ្នកផ្តល់ប្រាក់កម្ចីមួយចំនួន នឹងផ្តល់ប្រាក់កម្ចីទៅតាមចំនួនដែលអ្នកត្រូវការ ដោយឡែក អ្នកផ្តល់ប្រាក់កម្ចីដទៃទៀត ផ្តល់ប្រាក់កម្ចីក្នុងចំនួនតិចជាងចំនួនដែលអ្នកត្រូវការ។<br><br>២. **អត្រាការប្រាក់៖** ការប្រាក់គឺជាថ្លៃចំណាយទៅលើការខ្ចីប្រាក់។ ជាទូទៅ ការប្រាក់ត្រូវបានគេកំណត់ជាភាគរយ។ អត្រាការប្រាក់អាចមានភាពខុសគ្នា អាស្រ័យទៅលើទីកន្លែងដែលអ្នកខ្ចីប្រាក់។<br><br>៣. **រយៈពេលសងប្រាក់៖**<br>នេះគឺជាពេលវេលាដែលអ្នកត្រូវសងប្រាក់ដែលអ្នកខ្ចីមកវិញ។ រយៈពេលនេះ អាចមានភាពខុសគ្នា អាស្រ័យទៅលើទីកន្លែងដែលអ្នកខ្ចីប្រាក់។ អ្នកគួរជ្រើសរើសរយៈពេលសងប្រាក់មួយ ដែលសម | <br>លំហាត់ ៥.៣ ៖ ល័ក្ខខ័ណ្ឌសំខាន់ៗនៃការផ្តល់ប្រាក់កម្ចី និងរយៈពេលកំណត់ |

| | | |
|---|---|---|
| | **ហានិភ័យ** ឬ ការប្រឈមមួយចំនួននៃការខ្ចីប្រាក់ អាចរួមមានដូចជា ៖<br>➢ តម្លៃការប្រាក់អាចខ្ពស់ជាងប្រាក់ចំណូលបន្ថែម ដែលរកបានតាមរយៈប្រាក់កម្ចីនោះ<br>➢ ប្រសិនបើថវិកាមិនត្រូវបានប្រើប្រាស់ដោយភាពឆ្លាតវៃទេនោះ វាអាចនាំឱ្យមានការខាតបង់ និងបណ្ដាលឱ្យមានភាពលំបាកវេទនានៅក្នុងគ្រួសារ<br>➢ ការដែលមិនអាចសងប្រាក់កម្ចីត្រឡប់មកវិញបាន អាចបណ្ដាលឱ្យបាត់បង់ដី ឬ ទ្រព្យសម្បត្តិដទៃទៀត<br>➢ ការដែលមិនអាចសងប្រាក់ត្រឡប់មកវិញបាន នឹងធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់កសិករធ្លាក់ចុះ។<br>ចូរសួរទៅកាន់សិក្ខាកាមថា តើ**ពេលណាដែលកសិករមិនគួរខ្ចីប្រាក់**។ ចម្លើយមួយចំនួន អាចរួមមានដូចជា៖<br>➢ ពេលដែលកសិករអាចមើលឃើញថា វានឹងមានការលំបាកក្នុងការសងប្រាក់ត្រឡប់មកវិញ<br>➢ នៅពេលដែលល័ក្ខខ័ណ្ឌនៃការខ្ចីប្រាក់ពុំមានភាពល្អប្រសើរ<br>➢ នៅពេលដែលពុំមានផែនការសងប្រាក់ត្រឡប់មកវិញ<br>➢ នៅពេលដែលពុំមានប្រភពចំណូលដទៃទៀត ដើម្បីសងប្រាក់ក្នុងករណីដែលសហគ្រាសបរាជ័យ។ | |
| ៥ | **ប្រភពថវិកា៖**<br>ចូរផ្ដល់មតិយោបល់ថា ជួនកាល កសិករអាចត្រូវការខ្ចីប្រាក់ពីប្រភពដទៃទៀត ដើម្បីទូទាត់ថ្លៃចំណាយនៅក្នុងសហគ្រាស។<br><br>ចូរធ្វើការប្រមូលផ្ដុំគំនិតអំពីទីកន្លែងដែលសិក្ខាកាមអាចទទួលបានហិរញ្ញវត្ថុបន្ថែម ដើម្បីផ្គត់ផ្គង់សហគ្រាសរបស់ពួកគេ។ ចូរសរសេរគំនិតយោបល់ទាំងនេះនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>**សម្គាល់៖** ប្រភពទាំងនោះ អាចរួមមានដូចជា គ្រួសារ មិត្តភក្តិ ក្រុមសន្សំ និងធនាគារ ផ្ដល់ឥណទាន អ្នកចងការប្រាក់ក្នុងមូលដ្ឋាន ស្ថាប័នមីក្រូហិរញ្ញវត្ថុ។ | <br>លំហាត់ ៥.២៖ តារាងប្រភពឥណទានក្នុងមូលដ្ឋាន |

| | | |
|---|---|---|
| | ផែនការអាជីវកម្មជាច្រើនដោយឡែក  អ្នកផ្តល់ប្រាក់កម្ចីដទៃទៀតពុំធ្វើដូច្នេះឡើយ។<br><br>ចូរសូមឱ្យសិក្ខាកាមបន្ថែមលក្ខខ័ណ្ឌសំខាន់ៗដទៃទៀតដែលពួកគេត្រូវការដើម្បីស្វែងយល់ពីអ្នកផ្តល់ឥណទាន។ ចូរសរសេរចម្លើយថ្មីៗនៅលើក្តាខៀន និងប្រាប់ឱ្យសិក្ខាកាមចម្លងទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ | |
| ៧ | **ការរៀបចំការអង្កេតមួយទៅលើប្រភពថវិកា៖**<br><br>ចូរធ្វើការរៀបចំបែងចែកសិក្ខាកាមជាក្រុម ដោយក្រុមនីមួយៗមានសមាជិកចន្លោះពី ៣ ទៅ ៥នាក់ អាស្រ័យទៅតាមចំនួនអ្នកផ្តល់ប្រាក់កម្ចីដែលពួកគេបានរាយនាមនៅក្នុង  តារាងលំហាត់  ៥.២។ចូរធ្វើការបែងចែកឱ្យមានអ្នកផ្តល់ប្រាក់កម្ចី យ៉ាងហោចណាស់ចំនួនម្នាក់  ពីប្រភេទនៃប្រភពថវិកានីមួយៗ សម្រាប់សិក្ខាកាមមួយក្រុមដើម្បីឱ្យ  សិក្ខាកាមអាចប្រមូលព័ត៌មានពីប្រភេទប្រភពឥណទាននីមួយៗផ្សេងៗគ្នាដែលមាន។ បន្ទាប់មក សូមឱ្យសិក្ខាកាមទៅជួបអ្នកផ្តល់ប្រាក់កម្ចីរបស់  ពួកគេ  ដែលត្រូវបានរៀបចំចាត់ចែងរួចជាស្រេច  មុនពេលកិច្ចប្រជុំលើកក្រោយ  និងសម្ភាសន៍ពួកគេអំពីល័ក្ខខ័ណ្ឌនៃការផ្តល់ប្រាក់កម្ចីព្រមទាំង  សំនួរនានាដូចមានរាយនាមនៅក្នុងផ្នែកខាងលើ។<br><br>ចូរលើកទឹកចិត្តសិក្ខាកាមឱ្យសួរសំនួរបន្ថែមអំពីអ្នកផ្តល់ប្រាក់កម្ចី  និងប្រមូលរាល់គ្រប់ព័ត៌មានបោះពុម្ពផ្សាយនានាដែលមាន។  ចូរផ្តល់ដំបូន្មានជូនដល់ក្រុមទាំងអស់ឱ្យមានភាពជាក់លាក់  ក្នុងការស្វែងរកព័ត៌មាន។ ពួកគេគួរបង្ហាញអំពីផែនការអាជីវកម្មថវិកា  និង  លំហូរសាច់ប្រាក់របស់សហគ្រាសពួកគេ  ជូនដល់អ្នកផ្តល់ប្រាក់កម្ចីដើម្បីបង្ហាញអំពីសេចក្តីត្រូវការថវិការបស់ពួកគេ  និងលទ្ធភាពក្នុងការសងត្រឡប់មកវិញ។ត្រូវឯកភាពទៅលើពេលវេលាក្នុងការវិលត្រឡប់ទៅកាន់វគ្គសាលាអាជីវកម្មកសិកម្មវិញជាមួយនឹងព័ត៌មាននេះ  ដើម្បីពិភាក្សាបន្ត។  សូមជូនពរឱ្យសិក្ខាកាមទទួលបានជោគជ័យល្អប្រសើរ ក្នុងការប្រមូលព័ត៌មានរបស់ពួកគេ។ | <br>លំហាត់ ៥.២ ៖ តារាងអង្កេតពីប្រភពប្រភពថវិកា |

ស្របបំផុត សម្រាប់សហគ្រាសរបស់អ្នក។

៤. **រយៈពេលអនុគ្រោះ** ៖ រយៈពេលនេះសំដៅចំពោះរយៈពេលដែលស្ថិតនៅចន្លោះពេលទទួលបានប្រាក់កម្ចី និង ពេលដែលអ្នកត្រូវចាប់ផ្តើមសងប្រាក់ត្រឡប់មកវិញ។
អ្នកផ្តល់ប្រាក់កម្ចីមួយចំនួនយល់ថា សហគ្រាសកសិកម្ម អាចត្រូវការរយៈពេលអនុគ្រោះមួយ (មិនទាន់ត្រូវសង់ប្រាក់) មុនពេលដែលអ្នកអាចសងប្រាក់ត្រឡប់ទៅវិញបាន អាស្រ័យដោយវាត្រូវប្រើប្រាស់ពេលវេលាមួយចំនួនដើម្បីឱ្យកសិផល និងសត្វ អាចលូតលាស់ធំធាត់ ប្រមូលផល និងលក់ បាន។ អ្នកផ្តល់កម្ចីដទៃទៀត ទាមទារឱ្យសងប្រាក់ត្រឡប់មកវិញ ជាទៀងទាត់។ អ្នកគួរជ្រើសរើសយករយៈពេលអនុគ្រោះមួយ ដែលមានភាពសមស្របបំផុត សម្រាប់សហគ្រាសរបស់អ្នក។

៥. **កម្រៃសេវាធនាគារ៖** បន្ថែមពីលើអត្រាការប្រាក់ អ្នកផ្តល់ប្រាក់កម្ចីមួយចំនួនក៏អាចកំណត់កម្រៃសេវាបន្ថែម ក្នុងកម្រិតអត្រាជាក់លាក់មួយ សម្រាប់ការរៀបចំបែបបទផ្តល់ប្រាក់កម្ចី។ កម្រៃសេវានេះអាចត្រូវបានគេទាមទារឱ្យផ្តល់ជូនដោយឡែក ឬ ជាផ្នែកមួយនៃអត្រាការប្រាក់។

៦. **ល័ក្ខខ័ណ្ឌតម្រូវឱ្យមានទ្រព្យធានា៖** អ្នកផ្តល់ប្រាក់កម្ចីមួយចំនួនតម្រូវឱ្យអ្នកខ្ចីប្រាក់ផ្តល់នូវទ្រព្យសម្បត្តិ ដូចជា ដី អគារ ឬ ឧបករណ៍មួយចំនួន ដើម្បីជាការធានាចំពោះករណីមិនសងប្រាក់មកវិញ។

៧. **ភាពបត់បែនក្នុងការសងប្រាក់ត្រឡប់មកវិញ៖** អ្នកផ្តល់ប្រាក់កម្ចីអាចមានភាពតឹងរឹងខ្លាំង និងទាមទារឱ្យសងប្រាក់ឱ្យបានទាន់ពេលវេលា បើពុំនោះសោតទេ ពួកគេនឹងរឹបអូសយកទ្រព្យធានា។ អ្នកផ្តល់ប្រាក់កម្ចីដទៃទៀត មានភាពបត់បែនទន់ភ្លន់ជាង និង អនុញ្ញាតឱ្យអ្នករៀបចំសងប្រាក់ ក្នុងលក្ខណៈមួយដោយឡែក ឱ្យតែអ្នកនៅតែសន្យាសងប្រាក់ត្រឡប់មកវិញ នៅពេលណាមួយ។

៨. **ភាពងាយស្រួលក្នុងការទទួលបានប្រាក់កម្ចី៖**
អ្នកផ្តល់ប្រាក់កម្ចីមួយចំនួន តម្រូវឱ្យអ្នកខ្ចីប្រាក់បំពេញពាក្យសុំ និង

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ២ | **ការជ្រើសរើសប្រភពថវិកាដែលប្រសើរបំផុត៖**<br>សូមឱ្យសិក្ខាកាមឆ្លើយសំនួរនៅក្នុងលំហាត់ ៥.៤។<br>១. តើនរណាគឺជាអ្នកផ្តល់ប្រាក់កម្ចីដែលប្រសើរបំផុត? ហេតុអ្វី?<br>២. តើនរណាគឺជាអ្នកផ្តល់ប្រាក់កម្ចីដែលប្រសើរបន្ទាប់នៅលំដាប់លេខរៀងទី២? ហេតុអ្វី?<br>៣. តើនរណាគឺជាអ្នកផ្តល់ប្រាក់កម្ចីដែលប្រសើរបន្ទាប់នៅលំដាប់លេខរៀងទី៣? ហេតុអ្វី?<br><br>ចូរសង្ខេបការពិភាក្សា ដោយធ្វើការថ្លែងបញ្ជាក់ជាថ្មីម្តងទៀតថា នៅពេលដែលកសិករត្រូវការខ្ចីប្រាក់ ពួកគេគួរស្វែងរកជម្រើសប្រសើរបំផុត ដែលស្របទៅនឹងលំហូរសាច់ប្រាក់នៃសហគ្រាសដែលពួកគេបានជ្រើសរើស។ ពួកគេត្រូវធានាថាពួកគេត្រូវស្វែងរកល័ក្ខខ័ណ្ឌដែលប្រសើរបំផុត ពីអ្នកផ្តល់ប្រាក់កម្ចីនីមួយៗ មុនពេលជ្រើសរើសប្រភពថវិកាបន្ថែមរបស់ពួកគេ។ | <br>លំហាត់ ៥.៤៖ សំនួររំលេចឡើងអំពីការផ្តល់ប្រាក់កម្ចីដែលប្រសើរបំផុត |
| ៣ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br><br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គ សាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

## មេរៀនទី៥ ៖ ការប៉ាន់ប្រមាណប្រភពថវិកា



**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចធ្វើការប៉ាន់ប្រមាណប្រភពធនធានសមស្រប សម្រាប់ផ្គត់ផ្គង់សហគ្រាសដែលពួកគេបានជ្រើសរើស។




៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **របាយការណ៍នៃការអង្កេតប្រភពថវិកា៖**<br>នៅពេលដែលក្រុមត្រឡប់មកពីធ្វើការអង្កេតទៅលើអ្នកផ្តល់ឥណទានរួចមក ចូរសូមឱ្យក្រុមនីមួយៗបង្ហាញអំពីគំហើញរបស់ពួកគេជូនដល់សិក្ខាកាមដទៃទៀត។ ខណៈពេលដែលក្រុមនីមួយៗកំពុងធ្វើសេចក្តីរាយការណ៍ ចូរសរសេរព័ត៌មាននៅក្នុងតារាងមួយ នៅលើផ្ទាំងក្រដាសធំមួយសន្លឹកដែលបានរៀបចំទុកជាមុន ក្នុងទម្រង់ដូចគ្នាទៅនឹងលំហាត់ ៥.២។<br><br>ក្រោយពេលដែលគ្រប់ក្រុមទាំងអស់ បានធ្វើសេចក្តីរាយការណ៍រួចរាល់ ចូរលើកទឹកចិត្តពួកគេឱ្យធ្វើការប្រៀបធៀបព័ត៌មានរបស់អ្នកផ្តល់ប្រាក់កម្ចី។<br><br>តើអ្នកផ្តល់ប្រាក់កម្ចីណាដែលផ្តល់នូវអត្រាការប្រាក់ទាបជាងគេ?<br>តើអ្នកផ្តល់ប្រាក់កម្ចីណាមានអត្រាការប្រាក់ខ្ពស់ជាងគេ?<br>តើអ្នកផ្តល់ប្រាក់កម្ចីទាំងអស់សុទ្ធសឹងតែផ្តល់ រយៈពេលអនុគ្រោះដែរឬទេ? ចុះបើប្រៀបធៀបរយៈពេលសងប្រាក់ត្រឡប់មកវិញ តើវាមានលក្ខណៈខុសគ្នាដូចម្តេចដែរ? ។ល។<br><br>ក្រោយពេលដែលព័ត៌មានលម្អិតនៃល័ក្ខខ័ណ្ឌទាំង៨ (បូកនឹងល័ក្ខខ័ណ្ឌបន្ថែមដទៃទៀត) ត្រូវបានយកមកធ្វើការពិភាក្សា និងប្រៀបធៀបរួចរាល់ ចូរស្នើសុំឱ្យអនុក្រុមនានាសរសេរឈ្មោះអ្នកផ្តល់ប្រាក់កម្ចីចំនួន៣ ដែលពួកគេគិតថាមានលក្ខណៈល្អប្រសើរជាងគេ នៅលើក្រដាសមួយសន្លឹកដាច់ដោយឡែក។ ចូរប្រមូលរាល់សន្លឹកក្រដាសទាំងអស់នោះ និង សរសេរព័ត៌មាននៅលើផ្ទាំងក្រដាសធំ។ ចូរធ្វើការបូកសរុបពិន្ទុ និង ផ្តល់នូវចំណាត់ថ្នាក់ដែលក្រុមយល់ឃើញជារួម ទៅលើអ្នកផ្តល់ប្រាក់កម្ចីដែលមានល័ក្ខខ័ណ្ឌល្អប្រសើរជាងគេ។ | តារាងនៅលើផ្ទាំងក្រដាសធំដែលមានរាយនាមអ្នកផ្តល់ប្រាក់កម្ចី និងសំនួរសំខាន់ៗពីលំហាត់ ៥.២៖ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ទស្សនវិស័យ រមែងតែងស្ថិតនៅកម្រិតដដែល ឬបរាជ័យ ដោយឡែក អ្នកដែលមាន ទស្សនវិស័យ និងគោលដៅ រមែងតែងធ្វើឱ្យស្ថានភាពក្រុមរបស់ពួកគេ មានភាពប្រសើរ ឡើង។<br><br>ចូរស្នើសុំឱ្យពួកគេធ្វើការងារនៅក្នុងអនុក្រុមសហគ្រាសរបស់ពួកគេ និងឆ្លើយទៅនឹងសំនួរខាងក្រោម៖<br>១. តើក្នុងរយៈពេល៥ឆ្នាំទៅមុខ ការផលិត និងប្រាក់ចំណេញរបស់បុគ្គល (ឬក្រុម) នឹងមានលក្ខណៈដូចម្តេច?<br>២. តើគោលដៅផលិត និងប្រាក់ចំណេញរបស់បុគ្គល (ឬក្រុម) នឹងមានលក្ខណៈដូចម្តេចនៅក្នុងរដូវកាលនេះ?<br>៣. តើពួកគេចង់អនុវត្តយុទ្ធសាស្ត្រក្រុម (សកម្មភាព) អ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យរយៈពេលវែងរបស់ពួកគេ និងគោលដៅសម្រាប់រដូវកាលនេះ?<br><br>សូរស្នើសុំសិក្ខាកាមឱ្យធ្វើការចែករំលែក ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ពួកគេជាមួយសិក្ខាកាមដទៃទៀតនៅក្នុងក្រុមធំ។ ចូរសង្ខេបគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរស្នើសុំឱ្យពួកគេចម្លងខ្លឹមសារនៅលើផ្ទាំងក្រដាសធំនេះ ទៅក្នុងលំហាត់ ៦.២ សម្រាប់ បុគ្គល និងលំហាត់៦.៣ សម្រាប់ក្រុមនៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៦.១៖ និយមន័យនៃ ទស្សនវិស័យ គោលដៅ និង យុទ្ធសាស្ត្រ<br><br><br>លំហាត់ ៦.២ ៖ ទស្សនវិស័យ គោលដៅ និង យុទ្ធសាស្ត្ររបស់សហគ្រាសដែលមានលក្ខណៈជាបុគ្គល និង លំហាត់ ៦.៣ ៖ ជាក្រុម |
| ៣ | **មូលហេតុនៃការរៀបចំទស្សនកិច្ចសិក្សាប្រៀបធៀប៖**<br>ចូរប្រាប់សិក្ខាកាមថា ដើម្បីជួយដល់ពួកគេក្នុងការរៀបចំបង្កើតទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រសហគ្រាសរបស់ពួកគេ ដែលមានលក្ខណៈបុគ្គល ឬមានលក្ខណៈជាក្រុម ពួកគេគួរចុះធ្វើទស្សនកិច្ចទៅកាន់សហគ្រាសស្រដៀងគ្នាមួយដែលទទួលបានជោគជ័យ ដើម្បីរៀនសូត្រអំពីអ្វីដែលគេអាចធ្វើបាន។ បន្ទាប់មក សិក្ខាកាមអាចពាំនាំមកជាមួយនូវគំនិតមួយចំនួនដែលពួកគេបានរៀនសូត្រ ដើម្បីជួយដល់ពួកគេក្នុងការពិនិត្យសម្រេចទៅលើទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ពួកគេ។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី៦ ៖ ការរៀបចំទស្សនកិច្ចសិក្សាប្រៀបធៀប



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងយល់អំពី របៀបរៀបចំកម្រងសំនួរទស្សនកិច្ចសិក្សា និងរៀបចំទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រសម្រាប់រយៈពេលខ្លី និង រយៈពេលវែង។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ការរៀបចំទស្សនកិច្ចសិក្សាប្រៀបធៀប៖**<br><br>**សម្គាល់** ៖ មុនពេលចាប់ផ្តើមដំណើរការវគ្គនេះ អ្នកត្រូវកំណត់ថាតើសហគ្រាសកសិដ្ឋាន ឬស្រែចម្ការដែលមានលក្ខណៈជាក្រុម ឬបុគ្គលណាខ្លះដែលមានភាពជោគជ័យសម្រាប់ចុះធ្វើទស្សនកិច្ច និងធ្វើការរៀបចំសម្រាប់ទស្សនកិច្ចសិក្សា។ ទីតាំងសម្រាប់ចុះធ្វើទស្សនកិច្ចសិក្សាដែលត្រូវបានជ្រើសរើស គួរមាន ៖<br><br>➢ ប្រព័ន្ធក្សេត្របរិស្ថានស្រដៀងគ្នា ដើម្បីឱ្យបច្ចេកទេសដែលគេបានមើលឃើញ អាចយកមកប្រើប្រាស់បាននៅពេលដែលសិក្ខាកាមវិលត្រឡប់មកផ្ទះវិញ។<br><br>➢ សកម្មភាពក្រុមដែលពាក់ព័ន្ធទៅនឹងទស្សនវិស័យ និងគោលដៅរបស់សិក្ខាកាម ដែលចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សា។ | អ្នកសម្របសម្រួលគួរធ្វើការជ្រើសរើសជាមុននូវសហគ្រាសកសិដ្ឋាន ឬស្រែចម្ការដែលមានលក្ខណៈជាក្រុម ឬ បុគ្គលសម្រាប់ធ្វើទស្សនកិច្ច |
| ២ | **ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់បុគ្គល ឬក្រុម៖**<br>ចូរពន្យល់ថា សមាសធាតុទី១នៃផែនការសហគ្រាស គឺត្រូវសម្រេចចិត្តទៅលើ ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់សហគ្រាស។<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេយល់ដូចម្តេចចំពោះពាក្យថា ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រ។ ចូរណែនាំឱ្យពួកគេពិនិត្យមើលនិយមន័យ នៅក្នុងលំហាត់៦.១ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរពន្យល់ថា ទស្សនវិស័យមួយ អាចលើកទឹកចិត្តពួកគេឱ្យពង្រីកការគិតរបស់ពួកគេក្នុងការធ្វើអ្វីម៉្យាងឱ្យបានកាន់តែប្រសើរសម្រាប់ខ្លួនឯង និងសម្រាប់ក្រុមរបស់ពួកគេ។ ចូរនិយាយថា បុគ្គល (ឬក្រុម) ដែលពុំមាន | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ក្រដាសធំមួយសន្លឹក។ ចូរប្រៀបធៀបសំនួរទាំងនេះ ទៅនឹងសំនួរក្នុងលំហាត់ ៦.៥ និងលំហាត់ ៦.៦ នៃសៀវភៅលំហាត់របស់ពួកគេ។ សំនួរទាំងនោះ ក៏មានរាយនាមនៅក្នុងផ្នែកចំនួន២ បន្ទាប់ខាងក្រោមនេះដែរ។<br><br>ចូរធ្វើការពិនិត្យសម្រេចទៅលើកម្រងសំនួរ ដែលគួរបញ្ចូលគំនិតយោបល់របស់កសិករ និងគំនិតយោបល់ដែលរួមមាននៅក្នុងឧទាហរណ៍នៃកម្រងសំនួរ។<br><br>សូមឱ្យសិក្ខាកាមចម្លងសំនួរដែលត្រូវបានពិនិត្យសម្រេចរួចរាល់ ទៅក្នុងលំហាត់ ៦.៥ ឬ លំហាត់ ៦.៦ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៦.៦៖<br>កម្រងសំនួរ<br>សម្រាប់<br>សហគ្រាសដែល<br>មាន<br>លក្ខណៈជាក្រុម |
| ៥.១ | **ឧទាហរណ៍នៃកម្រងសំនួរសម្រាប់សហគ្រាសកសិដ្ឋាន ឬស្រែចម្ការដែលមាន លក្ខណៈជាបុគ្គល៖**<br><br>សំនួរខាងក្រោមផ្តោតទៅលើទិដ្ឋភាពដែលទាក់ទងទៅនឹងលទ្ធភាពក្នុងការទទួលបានជោគជ័យនៃសហគ្រាសដែលពួកគេបានជ្រើសរើស៖<br><br>**សំនួរទូទៅ៖**<br>១. ហេតុអ្វីបានជាអ្នកជ្រើសរើសសហគ្រាសនេះ?<br>**សំនួរដែលទាក់ទងទៅនឹងការផលិត៖**<br>២. តើកាលពីឆ្នាំមុន អ្នកទទួលបានទិន្នផលដូចម្តេចដែរ? តើនៅក្នុងរដូវកាលខាងមុខនេះ អ្នកសង្ឃឹមថានឹងទទួលបានទិន្នផលដូចម្តេចដែរ?<br>៣. តើដីរបស់អ្នកគឺជាប្រភេទដីអ្វី? តើអ្នកនឹងធ្វើសកម្មភាពអ្វីខ្លះ និងតើអ្នកត្រូវការសម្ភារៈកសិកម្មអ្វីខ្លះដើម្បីសម្រេចឱ្យបាននូវគោលដៅទិន្នផលរបស់អ្នក?<br>**ការវិភាគបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់៖**<br>៤. តើអ្នកមានបញ្ហាអ្វីខ្លះនៅក្នុងជំហាននីមួយៗនៃខ្សែសង្វាក់ផ្គត់ផ្គង់? តើអ្នកដោះស្រាយបញ្ហាទាំងនេះ ដោយរបៀបណា?<br>**ការបន្ថែមតម្លៃ៖**<br>៥. តើអ្នកបន្ថែមតម្លៃទៅលើផលិតផលរបស់អ្នកដែរឬទេ? | <br>លំហាត់ ៦.៥៖<br>កម្រងសំនួរ<br>សម្រាប់<br>សហគ្រាស<br>កសិដ្ឋាន ឬ<br>ស្រែចម្ការដែល<br>មានលក្ខណៈ<br>ជាបុគ្គល |

| | | |
|---|---|---|
| ៤ | **ចែករំលែកជាមួយសិក្ខាកាមនូវនិយមន័យនៃពាក្យថា "ការប្រៀបធៀប"៖**<br><br>"ការប្រៀបធៀប សំដៅចំពោះការប្រៀបធៀប រវាងកសិដ្ឋាន ឬស្រែចម្ការ របស់សិក្ខាកាម (ឬក្រុម) និងកសិដ្ឋាន ឬស្រែចម្ការ ឬក្រុមដទៃទៀតដែលមានភាពជោគជ័យល្អប្រសើរ។ ការប្រៀបធៀប អាចជួយដល់សិក្ខាកាមឱ្យទទួលបាននូវគំនិតមួយចំនួន អំពីរបៀបធ្វើការងារក្នុងលក្ខណៈមួយដែលប្រសើរជាងមុន និង បញ្ចូលគំនិតទាំងនេះ ទៅក្នុងផែនការអនាគតរបស់ពួកគេ។"<br><br>សូមប្រាប់ឱ្យសិក្ខាកាមពិនិត្យមើលនិយមន័យនៅក្នុងលំហាត់ ៦.៤ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>ចូរពន្យល់ថា អ្នកចង់ធ្វើការសម្របសម្រួលនៅក្នុងការរៀបចំផែនការទស្សនកិច្ចសិក្សាប្រៀបធៀប សម្រាប់ចំណុចដែលនៅសេសសល់នៅក្នុងវគ្គនេះ។ | <br>លំហាត់ ៦.៤៖ និយមន័យនៃការប្រៀបធៀប |
| ៥ | **ការរៀបចំកម្រងសំនួរដើម្បីប្រមូលព័ត៌មានក្នុងអំឡុងពេលចុះធ្វើទស្សនកិច្ចសិក្សា៖**<br><br>ចូរប្រាប់សិក្ខាកាមថា វាគឺជាការល្អដែលពួកគេត្រូវមានកម្រងសំនួរមួយដើម្បីណែនាំពួកគេក្នុងការប្រមូលព័ត៌មានសំខាន់ៗ ក្នុងអំឡុងពេលចុះធ្វើទស្សនកិច្ចសិក្សា។<br>ប្រសិនបើពួកគេពុំបានត្រៀមកម្រងសំនួរមួយរួចជាស្រេចទេនោះ ពួកគេប្រហែលជាអាចភ្លេចសួរចំណុចមួយចំនួន ហើយក្រោយពេលដែលពួកគេវិលត្រឡប់មកផ្ទះវិញ ពួកគេនឹងបាត់បង់ឱកាសក្នុងការសួរសំនួរទាំងនោះ។<br><br>សូមឱ្យសិក្ខាកាមធ្វើការកំណត់អំពីគោលបំណងនៃទស្សនកិច្ចសិក្សា។<br>ចូរសរសេរគំនិតយោបល់របស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br>គោលបំណងមួយដែលគេបានស្នើឡើង រួមមានដូចខាងក្រោម ៖<br><br>"ដើម្បីជួយដល់សិក្ខាកាមក្នុងការរៀបចំទស្សនវិស័យ គោលដៅ និងយុទ្ធសាស្រ្តសម្រាប់សហគ្រាស (ឬក្រុម) របស់ពួកគេ។"<br><br>សូមឱ្យសិក្ខាកាមធ្វើការងារជាអនុក្រុមតូចៗ និងសរសេរអំពីសំនួរសំខាន់ៗដែលពួកគេគួរសួរ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃទស្សនកិច្ចសិក្សាដែលពួកគេបានកំណត់។ ចូរសរសេរគំនិតយោបល់របស់ពួកគេនៅលើផ្ទាំង | <br>លំហាត់ ៦.៥ ៖ កម្រងសំនួរសម្រាប់សហគ្រាសលក្ខណៈបុគ្គល |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | **ប្រភពថវិកា៖**<br>១៩. តើអ្នកមានខ្ចីប្រាក់ដើម្បីផ្គត់ផ្គង់សហគ្រាសរបស់អ្នកដែរឬទេ? តើអ្នកខ្ចីប្រាក់ពីកន្លែងណា? ហេតុអ្វីបានជាអ្នកជ្រើសរើសប្រភពផ្តល់ប្រាក់កម្ចីមួយនេះ? | |
| ៥.២ | **ឧទាហរណ៍នៃកម្រងសំនួរសម្រាប់សហគ្រាសដែលមានលក្ខណៈជាក្រុម៖**<br><br>**សំនួរទូទៅ ៖**<br>១. តើក្រុមរបស់អ្នកឈ្មោះអ្វី?<br>២. តើមានសមាជិកប៉ុន្មាននាក់នៅក្នុងក្រុមនេះ (បុរសប៉ុន្មាននាក់/ស្ត្រីប៉ុន្មាននាក់)?<br>៣. តើនរណាជាប្រធានក្រុម? តើព័ត៌មានទំនាក់ទំនងលម្អិតរបស់ពួកគេមានអ្វីខ្លះ?<br><br>**ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រ របស់ក្រុម៖**<br>៤. តើអ្វីទៅជាទស្សនវិស័យរបស់អ្នកសម្រាប់ក្រុមនេះ ក្នុងរយៈពេល ៥ឆ្នាំ ទៅមុខទៀត?<br>៥. តើក្រុមរបស់អ្នកសង្ឃឹមថានឹងសម្រេចនូវលទ្ធផលអ្វីខ្លះ នៅក្នុងឆ្នាំបន្ទាប់?<br>៦. តើអ្នកនឹងអនុវត្តសកម្មភាពធ្វើទីផ្សារជាក្រុមអ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលទាំងនេះ?<br>៧. តើអ្នកនឹងអនុវត្តសកម្មភាពទិញសម្ភារៈផលិតកម្មកសិកម្មជាក្រុមអ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលទាំងនេះ?<br>៨. តើអ្នកនឹងអនុវត្តសកម្មភាពបន្ថែមតម្លៃជាក្រុមអ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលទាំងនេះ?<br>៩. តើអ្នកនឹងអនុវត្តសកម្មភាពដឹកជញ្ជូនជាក្រុមអ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលទាំងនេះ?<br>១០. តើអ្នកនឹងអនុវត្តការចុះកិច្ចសន្យាជាក្រុមយ៉ាងដូចម្តេច ដើម្បីសម្រេចឱ្យបាននូវលទ្ធផលទាំងនេះ? | <br>លំហាត់ ៦.៦៖ កម្រងសំនួរសម្រាប់សហគ្រាសដែលមានលក្ខណៈជាក្រុម |

៦. តើអ្នកធ្វើការបន្ថែមតម្លៃដោយរបៀបណា?

៧. តើតម្លៃ (ទឹកប្រាក់) មានការប្រែប្រួលចំនួនប៉ុន្មាន នៅក្នុងជំហាននីមួយៗ?

**ការទទួលបានព័ត៌មានបច្ចេកទេស និងសេវាផ្សព្វផ្សាយ៖**

៨. តើអ្នកទទួលបានព័ត៌មានបច្ចេកទេសពីកន្លែងណា?

៩. តើប្រភពព័ត៌មានណាមួយដែលជាប្រភពព័ត៌មានល្អបំផុត?

១០. តើអ្នកអាចផ្តល់ព័ត៌មានទំនាក់ទំនងលម្អិតអំពីប្រភពព័ត៌មានល្អៗបានដែរឬទេ?

**ធនធានដែលត្រូវការ និងធនធានដែលមាន៖**

១១. តើអ្នកទទួលបានប្រភពធនធានសម្ភារៈកសិកម្មដែលមានគុណភាពល្អសម្រាប់សហគ្រាសរបស់អ្នកពីកន្លែងណា? (សូមផ្តល់ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិត)

**ទីផ្សារ៖**

១២. តើអ្នកលក់ផលិតផលរបស់អ្នកនៅកន្លែងណា និងនៅពេលណា? (ព័ត៌មាន ទំនាក់ទំនងលម្អិត)

១៣. តើអ្នកលក់ផលិតផលរបស់អ្នកក្នុងតម្លៃប៉ុន្មាន?

១៤. ហេតុអ្វីបានជាអ្នកជ្រើសរើសយុទ្ធសាស្ត្រទីផ្សារនេះ?

**ផលប៉ះពាល់ទៅលើបរិស្ថាន៖**

១៥. តើអ្នកបានចាត់វិធានការដើម្បីការពារបរិស្ថានដែរឬទេ? តើអ្នកចាត់វិធានការការពារបរិស្ថាន យ៉ាងដូចម្តេច?

**ការកាត់បន្ថយហានិភ័យ ឬការប្រឈម៖**

១៦. តើមានហានិភ័យ ឬការប្រឈមអ្វីខ្លះនៅក្នុងសហគ្រាសរបស់អ្នក? តើអ្នកកាត់បន្ថយហានិភ័យ ឬការប្រឈមទាំងនោះដោយវិធីណា?

**ការពិចារណាទៅលើបញ្ហាសង្គម/វប្បធម៌/យេនឌ័រ៖**

១៧. តើមានកត្តារាំងស្ទះផ្នែកសង្គម វប្បធម៌ ឬយេនឌ័រណាមួយដែលរឹតបន្តឹងទៅលើលទ្ធភាពរបស់អ្នក ក្នុងការធ្វើសហគ្រាសនេះដែរឬទេ? តើអ្នក ដោះស្រាយបញ្ហាទាំងនោះ ដោយរបៀបណា?

**ប្រាក់ចំណេញ៖**

១៨. តើអ្នករំពឹងថានឹងទទួលបានប្រាក់ចំណូល ថ្លៃចំណាយ និងប្រាក់ចំណេញពីសហគ្រាសនេះក្នុងកម្រិតណា?

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ជាងខ្លួន ក្នុងការសាកសួរសំនួរដោយជោគជ័យ និងទទួលបានចម្លើយប្រកបដោយអត្ថន័យ។ ចូរពន្យល់អំពីគោលគំនិតនេះ ទៅកាន់សិក្ខាកាម ហើយប្រសិនបើពួកគេឯកភាព ចូរធ្វើការបែងចែកសំនួរចំនួន ១ ឬ២ ទៅឱ្យសិក្ខាកាមនីមួយៗ។<br><br>ចូររំលឹកសិក្ខាកាមឱ្យអនុវត្តសួរសំនួរទាំងនេះ នៅក្នុងពេលវេលាដែលនៅសេសសល់ក្នុងវគ្គនេះ និងនៅឯផ្ទះដើម្បីឱ្យពួកគេមានទំនុកចិត្តក្នុងការសម្ភាសន៍កសិករ ឬក្រុមនៅក្នុងពេលចុះធ្វើទស្សនកិច្ចសិក្សាតាមមូលដ្ឋាន។<br><br>ចូរសង្ខេបវគ្គនេះ ដោយនិយាយថា ឥឡូវនេះសិក្ខាកាមបានរៀបចំបង្កើតកម្រងសំនួរមួយដែលនឹងផ្តល់ការណែនាំដល់ពួកគេ ឱ្យធ្វើការត្រួតពិនិត្យឡើងវិញទៅលើទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រដែលពួកគេបានកំណត់កាលពីលើកមុន។<br><br>ចូររំលឹកសិក្ខាកាមឱ្យយកមកជាមួយនូវកម្រងសំនួរដែលពួកគេនឹងធ្វើការសាកសួរនៅពេលចុះធ្វើទស្សនកិច្ច។ សូមឱ្យពួកគេកត់ត្រាព័ត៌មានដែលពួកគេនឹងធ្វើការប្រមូល ទៅក្នុងសៀវភៅកត់ត្រាមួយ។<br><br>ចូរប្រាប់សិក្ខាកាមថា ពួកគេត្រូវជ្រើសរើសមនុស្សដែលសមស្របដើម្បីឆ្លើយទៅនឹងសំនួររបស់ពួកគេ ដើម្បីឱ្យពួកគេទទួលបានចម្លើយដែលសុក្រឹត្យ។ ឧទាហរណ៍ ប្រធានក្រុម គួរត្រូវបានសម្ភាសន៍អំពីសកម្មភាពរបស់ក្រុមដោយឡែក គណនេយ្យករគួរត្រូវបានសាកសួរអំពីសំនួរដែលទាក់ទងទៅនឹងបញ្ហាថវិកា ហើយកសិករសំខាន់ៗ គួរត្រូវបានសាកសួរអំពីសំនួរបច្ចេក-ទេស។<br><br>ចូរធ្វើការពិភាក្សា ថាតើវាមានសារៈប្រយោជន៍ដែរឬទេ ក្នុងការសាកសួរសំនួរទៅកាន់ក្រុមបុរស និងក្រុមស្ត្រីនៅក្នុងក្រុមដាច់ដោយឡែកពីគ្នា ដើម្បីធ្វើការវាយតម្លៃទៅលើការយល់ឃើញខុសគ្នា រវាងបុរស និងស្ត្រី។<br><br>បញ្ជាក់អំពីកាលបរិច្ឆេទ និងពេលវេលាសម្រាប់ដំណើរទស្សនកិច្ចសិក្សាប្រៀបធៀបនេះ។ | |

| | | |
|---|---|---|
| | ១១. តើអ្នកនឹងអនុវត្តធ្វើការតភ្ជាប់ទំនាក់ទំនងក្រុម ទៅនឹងសេវាបច្ចេកទេស ឬសេវាហិរញ្ញវត្ថុយ៉ាងដូចម្ដេច ដើម្បីសម្រេចឱ្យបាននូវលទ្ធផលទាំងនេះ?<br>១២. តើអ្នកនឹងអនុវត្តសកម្មភាពក្រុមទាំងនេះ ជាជំហានៗដោយរបៀបណា?<br>១៣. តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះ នៅក្នុងការធ្វើសកម្មភាពជាក្រុម? តើមានដំណោះស្រាយអ្វីខ្លះ?<br>១៤. តើក្រុមទទួលបានប្រយោជន៍អ្វីខ្លះពីការធ្វើសកម្មភាពជាក្រុមទាំងនេះ?<br>១៥. តើក្រុមធ្វើការបែងចែកប្រាក់ចំណេញតដែលទទួលបានយ៉ាងដូចម្ដេច នៅក្នុងចំណោមសមាជិកក្រុម?<br>១៦. តើព័ត៌មានទំនាក់ទំនងលម្អិតរបស់តួអង្គសំខាន់ៗដែលធ្វើការងារផ្នែកទីផ្សារ ផ្គត់ផ្គង់សម្ភារៈកសិកម្ម និងតួអង្គដទៃទៀតដែលក្រុមធ្វើការងារជាមួយ មានអ្វីខ្លះ?<br><br>**ចូរបន្ថែមសំនួរមួយចំនួនរបស់សិក្ខាកាម៖**<br>..............................................................................................<br>..............................................................................................<br>..............................................................................................<br>..............................................................................................<br>.............................................................................................. | |
| ៥.៣ | **តើនរណាខ្លះគួរសួរសំនួរក្នុងអំឡុងពេលនៃទស្សនកិច្ចសិក្សា?**<br>វាជារឿងធម្មតា ដែលអ្នកសម្របសម្រួល ឬកសិករឈានមុខត្រូវធ្វើការសាកសួរសំនួរដែលមានលក្ខណៈផ្លូវការឱ្យបានច្រើន ហើយសិក្ខាកាមដទៃទៀតធ្វើការសាកសួរសំនួរ ក្នុងលក្ខណៈបែបមិនផ្លូវការ។<br><br>បើទោះជាដូច្នេះក្ដី ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមសកម្មពីសិក្ខាកាមនីមួយៗ វាគឺជាការល្អដែលគេគួរបែងចែកការទទួលខុសត្រូវទៅកាន់សិក្ខាកាមម្នាក់ៗឱ្យធ្វើការសាកសួរសំនួរចំនួន១ ឬ២សំនួរ។ ប្រធានអនុក្រុមតូចៗអាចផ្ដល់ជំនួយ និងលើកទឹកចិត្តសមាជិកក្រុមដែលខ្សោយ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី៦ ៖ ការរៀបចំដំណើរទស្សនកិច្ចសិក្សាប្រៀបធៀប



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងអាចធ្វើការ វិភាគព័ត៌មានដែលទទួលបានពីទស្សនកិច្ចសិក្សាមួយ ដើម្បីឱ្យគេអាចកំណត់រកឃើញនូវទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រនានាដែលទទួលបានជោគជ័យ សម្រាប់ផែន កា ររបស់ពួកគេ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | ចូរពន្យល់ទៅកាន់សិក្ខាកាមថា ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចសិក្សា ពួកគេគួរប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ សម្រាប់ធ្វើការប្រៀបធៀបសហគ្រាសរបស់ពួកគេ ទៅនឹងសហគ្រាសដែលពួកគេចុះធ្វើទស្សនកិច្ចសិក្សា។ ចូរប្រាប់ពួកគេថា នៅក្នុងវគ្គបន្ទាប់ ពួកគេនឹងត្រូវធ្វើការវិភាគទៅលើព័ត៌មានដែលទទួលបានពីទស្សនកិច្ចសិក្សាប្រៀបធៀប ដើម្បីកំណត់រកសកម្មភាពជោគជ័យ សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអាជីវកម្មផ្ទាល់ខ្លួន ឬ ផែនការអាជីវកម្មក្រុមរបស់ពួកគេ។ | |
| ២ | **មេរៀនបទពិសោធន៍ដែលបានរៀនសូត្រពីដំណើរទស្សនកិច្ចសិក្សា៖**<br>ចូររៀបចំតម្លើងផ្ទាំងក្រដាសធំមួយសន្លឹក ក្នុងទ្រង់ទ្រាយជា “ទម្រង់សង្ខេបសម្រាប់វិភាគកម្រងសំនួរប្រៀបធៀប” នៅក្នុងលំហាត់ ៦.៧។ ចូរសរសេរឈ្មោះសំនួរដែលបានជ្រើសរើសនៅក្នុងគូឡោនទី១។<br>សូមឱ្យសិក្ខាកាម ឆ្លើយទៅនឹងសំនួរដែលបានបែងចែកទៅឱ្យពួកគេ។ ជាដំបូង សូមឱ្យពួកគេឆ្លើយសំនួរដែលទាក់ទងទៅនឹងសហគ្រាសដែលមានលក្ខណៈជាបុគ្គល ឬជាក្រុមរបស់ពួកគេ នៅក្នុងគូឡោនទី២ បន្ទាប់មកសូមឱ្យពួកគេឆ្លើយទៅនឹងសំនួរដែលទាក់ទងទៅនឹងសហគ្រាសដែលពួកគេចុះធ្វើទស្សនកិច្ចសិក្សា នៅក្នុងគូឡោនទី៣។<br>បន្ទាប់មក ចូរសូមឱ្យអ្នកដែលទទួលខុសត្រូវចំពោះសំនួរនីមួយៗដែលបានបែងចែកជូនពួកគេ ធ្វើការរៀបរាប់អំពីភាពខុសគ្នារវាងស្ថានភាពរបស់ពួកគេ (ឬក្រុមរបស់ពួកគេ) និងស្ថានភាពរបស់សហគ្រាសដែលពួកគេចុះធ្វើ | <br>លំហាត់ ៦.៧៖ ទម្រង់សង្ខេបសម្រាប់វិភាគកម្រងសំនួរប្រៀបធៀប |

| | | |
|---|---|---|
| ៦ | **ការរៀបចំភស្តុភារសម្រាប់ដំណើរទស្សនកិច្ចសិក្សា៖**<br><br>១. ត្រូវបញ្ជាក់ឱ្យប្រាកដថា ក្រុមដែលអ្នកនឹងចុះធ្វើទស្សនកិច្ចនឹងមានពេលទំនេរ ដើម្បីផ្តល់ព័ត៌មានដែលអ្នកត្រូវការ។<br>២. បញ្ជាក់អំពីការរៀបចំធ្វើដំណើរ។<br>៣. បញ្ជាក់ថា សមាជិកសាលាអាជីវកម្មកសិកម្ម ត្រូវត្រៀមខ្លួនឱ្យបានរួចរាល់ និងត្រូវជួបជុំគ្នាឱ្យបានទាន់ពេលវេលា។<br>៤. បញ្ជាក់អំពីការរៀបចំផ្តល់អាហារសម្រន់ និងអាហារទទួលទាន។<br>៥. ធានាថា អនុក្រុមនីមួយៗមានកម្រងសំនួររបស់ពួកគេសម្រាប់ធ្វើការសាកសួរ។<br>៦. នៅពេលដែលដំណើរទស្សនកិច្ចសិក្សាត្រូវបានធ្វើឡើង ត្រូវធានាឱ្យមានការចូលរួមពីអាជ្ញាធរមូលដ្ឋានក្នុងករណីដែលអាចធ្វើទៅបាន។ | កម្រងសំនួរប្រៀបធៀបដែលក្រុមបានរៀបចំ និងពិនិត្យសម្រេច |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី៧ ៖ ការណែនាំអំពីជម្រើសសកម្មភាពក្រុម និងផែនការថវិកា



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងយល់អំពីបញ្ជីសកម្មភាព នៃការធ្វើទីផ្សារជាក្រុម ការទិញសម្ភារៈកសិកម្មជាក្រុម និងសកម្មភាពបន្ថែមតម្លៃជាក្រុម។



៩ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ព័ត៌មានមូលដ្ឋានអំពីការទូទាត់ថវិកាសកម្មភាពក្រុម (ប្រាក់ចំណេញ/ការខាតបង់) មុនពេលការបណ្ដុះបណ្ដាលវគ្គ** សាលាអាជីវកម្មកសិកម្ម : <br><br> **សម្គាល់** ៖ មុនពេលកិច្ចប្រជុំនេះ អ្នកសម្របសម្រួលគួរធានាថា ប្រធានក្រុម ឬ គណនេយ្យករ បាននាំយកមកជាមួយនូវព័ត៌មានដែលបានស្នើសុំដូចខាងក្រោម៖ <br><br> ចូររៀបចំតម្លើងផ្ទាំងក្រដាសធំមួយសន្លឹក ដែលមានគំរូទម្រង់ទូទាត់ថវិកាមួយ ជាមួយនឹងចំណងជើង ៖ ប្រភេទសហគ្រាស , សកម្មភាព/ប្រាក់ចំណូល , សកម្មភាព/ថ្លៃចំណាយ , ប្រាក់ចំណេញ/ការខាតបង់ នៅលើជញ្ជាំង។ <br><br> ចូរធ្វើការប្រមូលផ្ដុំគំនិតជាមួយសិក្ខាកាមអំពីស្ថានភាពដែលទាក់ទងទៅនឹងប្រាក់ចំណូល ថ្លៃចំណាយ ប្រាក់ចំណេញ/ការខាតបង់ សម្រាប់សកម្មភាពក្រុម ទាក់ទងទៅនឹងសហគ្រាសដែលពួកគេបានជ្រើសរើសក្នុងឆ្នាំកន្លងទៅ។ ប្រធានក្រុម ឬ គណនេយ្យករ គួរមានព័ត៌មានទាំងអស់នេះ។ ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ។ <br><br> សូមឱ្យសិក្ខាកាមចម្លងព័ត៌មានអំពី "ការទូទាត់ថវិកាសកម្មភាពក្រុមមុនពេលការបណ្ដុះបណ្ដាលវគ្គសាលាអាជីវកម្មកសិកម្ម" នេះទៅក្នុងលំហាត់ ៧.១ នៃសៀវភៅលំហាត់របស់ពួកគេ។ <br><br> ចូរនិយាយថា វគ្គបន្ទាប់ នឹងជួយដល់ពួកគេដើម្បីឱ្យទទួលបានប្រាក់ចំណេញច្រើនជាងមុន សម្រាប់សហគ្រាសដែលមានលក្ខណៈជាក្រុមរបស់ពួកគេ។ | ផ្ទាំងក្រដាសធំជាមួយនឹងទម្រង់ទទេស្អាតមួយអំពីការទូទាត់ថវិកា <br><br>  <br> លំហាត់ ៧.១ ៖ ទម្រង់ទូទាត់ថវិកាសម្រាប់បំពេញ |

| | | |
|---|---|---|
| | ទស្សនកិច្ចសិក្សា។<br><br>ការវិភាគគួរកំណត់ឱ្យបាននូវវិស័យដែលកសិដ្ឋាន ឬស្រែចម្ការរបស់ពួកគេ (ឬ ក្រុមរបស់ពួកគេ) កំពុងមានដំណើរការប្រព្រឹត្តទៅបានល្អ និងមិនបានល្អ។ សិក្ខាកាមគួរផ្តល់នូវមូលហេតុមួយ សម្រាប់ភាពខុសគ្នាទាំងនោះ ដោយនិយាយតាមលំនាំដូចជា ស្ថានភាពរបស់ខ្ញុំ"(ឬស្ថានភាពក្រុមរបស់ខ្ញុំ) ខុសគ្នាពីស្ថានភាពសហគ្រាស ដែលពួកយើងចុះធ្វើទស្សនកិច្ចសិក្សា ព្រោះ...”។<br><br>ចូរសួរទៅកាន់សិក្ខាកាមឱ្យនិយាយថា តើយុទ្ធសាស្ត្រណាមួយដែលល្អសម្រាប់ពួកគេ (ឬក្រុមរបស់ពួកគេ) សម្រាប់ឆ្នាំបន្ទាប់។ ចូរលើកទឹកចិត្តឱ្យមានការពិភាក្សា។ សិក្ខាកាមគួរដាក់សញ្ញា (v) មួយនៅក្បែរយុទ្ធសាស្ត្រដែលពួកគេចង់អនុវត្តតាម នៅក្នុងផែនការផ្ទាល់ខ្លួន (ឬផែនការក្រុម) របស់ពួកគេ នៅក្នុងឆ្នាំបន្ទាប់នេះ។ បន្ទាប់មក ចូរសួរទៅកាន់សិក្ខាកាម ថាតើក្រុមរបស់ពួកគេចង់អនុវត្តយុទ្ធសាស្ត្រអ្វីនៅក្នុងឆ្នាំបន្ទាប់។<br><br>ជាចុងក្រោយ សូមឱ្យសិក្ខាកាមធ្វើការពិនិត្យកែសម្រួល ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ពួកគេ ក្នុងលំហាត់ ៦.២ និងលំហាត់ ៦.៣ រាប់បញ្ចូលទាំងគំនិតយោបល់ថ្មីៗបន្ថែមទៀតផងដែរ។ | |
| ៣ | **ការវាយតម្លៃកិច្ចប្រជុំ៖** ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗ ដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br><br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br><br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកានៃវគ្គសាលាអាជីវកម្មកសិកម្មនៅពេលអនាគត។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ចូរសួរទៅកាន់សិក្ខាកាម ថាតើជម្រើសសកម្មភាពជាក្រុមទាំងនេះ នឹងរួមចំណែកដល់ការទទួលបានប្រាក់ចំណេញរបស់ក្រុមដោយរបៀបណា។ ចូរសរសេរចម្លើយរបស់ពួកគេ ក្រោមជម្រើសនីមួយៗនៅលើផ្ទាំងក្រដាសធំ។<br>ចូរធ្វើការបញ្ជាក់ជាមួយសិក្ខាកាម ថាតើជម្រើសនៃការធ្វើសកម្មភាពជាក្រុមណាខ្លះ ដែលពួកគេចាប់អារម្មណ៍ និងសូមឱ្យពួកគេបំពេញលំហាត់ ៧.៣ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ ចូរនិយាយថា អ្នកនឹងបន្តធ្វើការសិក្សាទៅលើជម្រើសដែលពួកគេបានជ្រើសរើសឱ្យបានលម្អិត នៅក្នុងវគ្គបន្ទាប់។ | <br>លំហាត់ ៧.៣៖ ការកំណត់រក និង ការដោះស្រាយ បញ្ហាខ្សែសង្វាក់ ផ្គត់ផ្គង់ |
| ៤ | **ទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ក្រុម៖**<br>ចូរពន្យល់ថា សមាសធាតុទី១ នៃផែនការសហគ្រាសមួយ គឺត្រូវធ្វើការសម្រេចចិត្តទៅលើទស្សនវិស័យ និង គោលដៅរបស់សហគ្រាស។<br>ចូរសួរទៅកាន់សិក្ខាកាម ថាតើពួកគេយល់ដូចម្តេចដែរ ចំពោះពាក្យថា ទស្សនវិស័យ និងគោលដៅ? ចូរប្រាប់ឱ្យពួកគេពិនិត្យមើលនិយមន័យនៅក្នុងលំហាត់ ៧.៤ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរពន្យល់ថា ទស្សនវិស័យមួយ អាចលើកទឹកចិត្តពួកគេឱ្យពង្រីកការគិតរបស់ពួកគេក្នុងការធ្វើអ្វីម៉្យាងឱ្យកាន់តែប្រសើរជាងមុន សម្រាប់ខ្លួនពួកគេ និង ក្រុមរបស់ពួកគេ។ ចូរនិយាយថា ជាទូទៅ ក្រុមដែលគ្មានទស្សនវិស័យ បន្តស្ថិតនៅកម្រិតដដែលក្នុងមួយជីវិតរបស់ពួកគេ ដោយឡែក ក្រុមដែលមានទស្សនវិស័យ និងគោលដៅ រមែងតែងធ្វើឱ្យស្ថានភាពក្រុមរបស់ពួកគេមានភាពប្រសើរឡើង។<br>នៅក្នុងអនុក្រុមរបស់ពួកគេ ចូរសូមឱ្យពួកគេឆ្លើយទៅនឹងសំនួរដូចខាងក្រោម៖<br>១. តើការផលិត និង ប្រាក់ចំណេញរបស់ក្រុម នឹងមានរូបភាពយ៉ាងដូចម្តេច ក្នុងរយៈពេល៥ឆ្នាំទៅមុខទៀត?<br>២. តើនៅក្នុងរដូវកាលនេះ ក្រុមមានគោលដៅផលិតអ្វី និង គ្រោងទទួលបានប្រាក់ចំណេញប៉ុន្មានដែរ? | <br>លំហាត់ ៧.៤៖ និយមន័យនៃ ទស្សនវិស័យ គោលដៅ និង យុទ្ធសាស្ត្រ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ២ | **ការវិភាគបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់៖**<br>ចូររំលឹកសិក្ខាកាមថា នៅពេលពិភាក្សាអំពីការធ្វើកសិកម្មក្នុងលក្ខណៈជាអាជីវកម្ម ពួកគេគួរទទួលស្គាល់ថា មានខ្សែសង្វាក់តួអង្គមួយចំនួនចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការ អាជីវកម្មកសិកម្មជាក់លាក់មួយ។<br><br>ចូរអញ្ជើញសិក្ខាកាមឱ្យធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ និងបំពេញតួអង្គផ្សេងៗគ្នា នៅក្នុងខ្សែសង្វាក់សហគ្រាសដែលពួកគេបានជ្រើសរើសទៅក្នុងប្រអប់ទទេ ក្នុងលំហាត់ ៧.២ នៃសៀវភៅលំហាត់របស់ពួកគេ (ពួកគេអាចត្រឡប់ទៅមើលលំហាត់ ៤.៦ ដែលនិយាយអំពីការសិក្សាទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យ ប្រសិនបើពួកគេធ្លាប់បានធ្វើលំហាត់នេះពីមុនមក)។ ចូរស្នើសុំឱ្យអនុក្រុមនីមួយៗ សរសេរវាយនាមបញ្ហាដែលអាចកើតនៅកម្រិតតួអង្គនីមួយៗ។ (ដើម្បីសន្សំសំចៃពេលវេលា ចូរស្នើសុំឱ្យអនុក្រុមនីមួយៗ ជ្រើសរើសយកតួអង្គតែមួយប៉ុណ្ណោះ)។ សម្រាប់រាល់គ្រប់បញ្ហានីមួយៗ សូមណែនាំឱ្យសិក្ខាកាមផ្ដល់មតិយោបល់អំពីដំណោះស្រាយចំពោះបញ្ហាទាំងនោះ។ ចូរបង់លេខទៅលើបញ្ហា និងដំណោះស្រាយដើម្បីឱ្យមានភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់គ្នា។<br><br>ចូរស្នើសុំឱ្យតំណាងក្រុមមួយរូប រាយការណ៍អំពីគំនិតយោបល់របស់ពួកគេចំពោះបញ្ហា និងដំណោះស្រាយទៅកាន់ក្រុមធំ និងលើកទឹកចិត្តឱ្យមានការពិភាក្សា និងប្រមូលយកគំនិតចុងក្រោយ។ ចូរសរសេរាល់គំនិតទាំងអស់នៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ | ផ្ទាំងក្រដាសធំ ជាមួយនឹង ចំណងជើងអំពី ខ្សែសង្វាក់ផ្គត់ផ្គង់<br><br><br><br>លំហាត់ ៧.២ ៖ ការកំណត់រក និង ការដោះស្រាយ បញ្ហាខ្សែសង្វាក់ ផ្គត់ផ្គង់ |
| ៣ | **សកម្មភាពក្រុមដើម្បីដោះស្រាយបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់៖**<br>ចូរសួរទៅកាន់សិក្ខាកាម តើដំណោះស្រាយ និងឱកាសណាខ្លះនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដែលគេអាចយកមកអនុវត្តក្នុងលក្ខណៈជាការធ្វើសកម្មភាពជាក្រុម។<br><br>សកម្មភាពដែលគេអាចយកមកធ្វើការពិភាក្សាបាន គួររួមមានដូចជា៖<br>➢ ការធ្វើទីផ្សារជាក្រុមដើម្បីទទួលបានតម្លៃកាន់តែខ្ពស់<br>➢ ការទិញសម្ភារៈកសិកម្មជាក្រុមដើម្បីទទួលបានតម្លៃកាន់តែទាប<br>➢ ការធ្វើកិច្ចសន្យាជាក្រុម ដើម្បីកំណត់តម្លៃឱ្យនៅថេរ<br>➢ ការតភ្ជាប់បណ្ដាញទំនាក់ទំនងក្រុម ជាមួយសេវាផ្សព្វផ្សាយ និងសេវាឥណទាន<br>➢ ការបន្ថែមតម្លៃជាក្រុម | ផ្ទាំងក្រដាសធំ ជាមួយនឹង ចំណងជើងអំពី ខ្សែសង្វាក់ផ្គត់ផ្គង់ |

| | | |
|---|---|---|
| ៦ | **ការភ្ជាប់បណ្តាញទំនាក់ទំនងជាមួយសេវាបច្ចេកទេស ដើម្បីគណនាសេចក្តីត្រូវការផលិត និងសេចក្តីត្រូវការសម្ភារៈកសិកម្ម ព្រមទាំងធ្វើឱ្យប្រាក់ចំណេញកាន់តែមានភាពប្រសើរឡើង ៖**<br><br>សូមអញ្ជើញបុគ្គលិកផ្សព្វផ្សាយមួយរូប ដែលមកពីស្ថាប័នផ្តល់ប្រឹក្សាដទៃទៀត ដើម្បីឱ្យមកពន្យល់អំពីបច្ចេកទេសនៃ "ការអនុវត្តល្អ" និងសេចក្តីត្រូវការសម្ភារៈកសិកម្ម ដែលជួយដោះស្រាយបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់។ អន្តរាគមន៍ទាំងនេះ គួរមានភាពសមស្របទៅនឹងប្រព័ន្ធកេ្សត្របរិស្ថានរបស់កសិករ និង មានភាពសមស្របទៅតាមលក្ខណៈបច្ចេកទេស សេដ្ឋកិច្ច បរិស្ថាន និង សង្គមរបស់កសិករផងដែរ។ ត្រូវធានាថា ការផ្តល់ដំបូន្មានបច្ចេកទេស/ដំបូន្មានអំពីខ្សែសង្វាក់ផ្គត់ផ្គង់ត្រូវមានលក្ខណៈខ្លី និងច្បាស់លាស់ និងត្រូវធានាថា អ្នកផ្តល់យោបល់មានខិត្តប័ណ្ណ និង/ឬ ផ្ទាំងបដារមួយចំនួន ដើម្បីជាជំនួយគាំទ្រដល់ការផ្តល់អនុសាសន៍។<br><br>បញ្ចប់បទបង្ហាញបច្ចេកទេសនេះ ដោយរៀបចំបង្ហាញអំពីថវិកាសម្រាប់ "ការអនុវត្តល្អ" មួយដែលត្រូវបានរៀបចំទុកជាមុន និងពិភាក្សាដោយសង្ខេបថាតើសកម្មភាពអ្វីខ្លះ ដែលគេអាចអនុវត្តទៅបាន ដើម្បីទទួលបានប្រាក់ចំណេញល្អប្រសើរ។<br><br>ចូរធ្វើការពិភាក្សានៅក្នុងក្រុមធំ ដើម្បីឱ្យឃើញថាតើសិក្ខាកាមឯកភាពទៅនឹងសកម្មភាព "ការអនុវត្តល្អ" ដែលគេបានផ្តល់អនុសាសន៍ តម្លៃលក់ ការប្រើប្រាស់សម្ភារៈកសិកម្ម និង ថ្លៃចំណាយដែរឬទេ ឬ ពួកគេមានបំណងចង់ធ្វើការផ្លាស់ប្តូរអ្វីម៉្យាង ដើម្បីធ្វើឱ្យផែនការផលិត និងផែនការទិញសម្ភារៈកសិកម្មនេះ កាន់តែមានភាពសមស្របទៅនឹងស្ថានភាពរបស់ពួកគេ។ ចូរធ្វើការកែសម្រួលក្នុងករណីចាំបាច់ ដើម្បីរៀបចំថវិកាសម្រាប់ "ការអនុវត្តដែលកសិករបានឯកភាព" ។<br><br>បន្ទាប់មក ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការងារនៅក្នុងអនុក្រុមតូចៗរបស់ពួកគេ ដើម្បីប្រៀបធៀប ទៅលើប្រាក់ចំណេញជារួម "មុនពេល" ចូលរួមវគ្គសាលាអាជីវកម្មកសិកម្ម ក្នុងលំហាត់ ៧.៥ (ក) ជាមួយនឹងប្រាក់ចំណេញ | ខិត្តប័ណ្ណ និង ផ្ទាំងបដារ បច្ចេកទេស សម្រាប់គាំទ្រ អនុសាសន៍<br><br><br>លំហាត់ ៧.៥ (ខ) ៖ ថវិកាសម្រាប់ "ការអនុវត្តល្អ"<br><br><br>លំហាត់ ៧.៥ (គ) ៖ ការបំពេញឧទាហរណ៍អំពីថវិកាសម្រាប់ការអនុវត្តដែល " កសិករបានឯកភាព" |

| | | |
|---|---|---|
| | ៣. តើពួកគេមានបំណងចង់អនុវត្តយុទ្ធសាស្ត្រក្រុម (សកម្មភាព) អ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យរយៈពេលវែងរបស់ពួកគេ និងគោលដៅសម្រាប់វដ្តកាលនេះ?<br><br>ចូរស្នើសុំឱ្យសមាជិកក្រុមធ្វើការចែករំលែកទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ពួកគេជាមួយសមាជិកដទៃទៀតនៅក្នុងក្រុមធំ។ ចូរសរសេរសង្ខេបនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរប្រាប់សិក្ខាកាមថា ពួកគេគួរឯកភាពទៅលើទស្សនវិស័យមួយរបស់សហគ្រាសគោលដៅ និងយុទ្ធសាស្ត្រ សម្រាប់សកម្មភាពក្រុមដែលពួកគេបានជ្រើសរើស និងកត់ត្រាចំណុចទាំងអស់នេះទុកនៅក្នុងលំហាត់ ៧.៤ នៃសៀវភៅលំហាត់របស់ពួកគេ ដើម្បីជាការណែនាំសម្រាប់ពួកគេនៅក្នុងវគ្គបន្ទាប់។ | |
| ៥ | **ការផលិតកសិផល និងការប្រើប្រាស់សម្ភារៈកសិកម្មរបស់សមាជិកក្រុមមុនពេលចូលរួមវគ្គសាលាអាជីវកម្មកសិកម្ម ៖**<br><br>ចូររៀបចំតម្លើងផ្ទាំងក្រដាសធំមួយសន្លឹក ដែលមានទម្រង់ទូទាត់ថវិកា ជាមួយនឹង ចំណងជើង ៖ ប្រភេទសហគ្រាស , ប្រាក់ចំណូល , ថ្លៃចំណាយ , ប្រាក់ចំណេញ/ ការខាតបង់ នៅលើជញ្ជាំង។<br><br>ចូរប្រាប់សិក្ខាកាមថា ដើម្បីស្វែងរកសេចក្តីត្រូវការក្នុងការធ្វើទីផ្សារជាក្រុម និង សេចក្តីត្រូវការសម្ភារៈកសិកម្ម ជាដំបូង ពួកគេត្រូវក្រឡេកមើលទៅលើសេចក្តីត្រូវការរបស់សមាជិកក្រុមនីមួយៗ បន្ទាប់មក ត្រូវធ្វើការបូកបញ្ចូលគ្នាដើម្បីទទួលបានតួលេខសរុបសម្រាប់ក្រុម។ ចូរប្រាប់សិក្ខាកាមថា វគ្គបន្ទាប់មកទៀតនេះ នឹងផ្តោតយកចិត្តទុកដាក់ទៅលើការកំណត់រកសេចក្តីត្រូវការផលិត និងសេចក្តីត្រូវការសម្ភារៈកសិកម្មរបស់សមាជិកក្រុមនីមួយៗ។<br><br>ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយសិក្ខាកាម អំពីស្ថានភាពជាមធ្យមរបស់សមាជិកក្រុម ទាក់ទងទៅនឹងការផលិត ប្រាក់ចំណូល ថ្លៃចំណាយ ប្រាក់ចំណេញ/ការខាតបង់ សម្រាប់សហគ្រាសដែលពួកគេបានជ្រើសរើសមុនពេលចូលរួមវគ្គ សាលាអាជីវកម្មកសិកម្ម។ ចូរស្វែងរកឱ្យមានការឯកភាពជារួមមួយ។ សូមឱ្យសិក្ខាកាមសរសេរអំពីស្ថានភាពនេះ នៅក្នុងលំហាត់ ៧.៥ (ក) "ការរៀបចំថវិកាសហគ្រាសដែលបានជ្រើសរើសមុនពេលចូលរួម វគ្គ សាលាអាជីវកម្មកសិកម្ម"។ | <br>លំហាត់ ៧.៥<br>(ក) ៖<br>ទម្រង់ថវិកា<br>សកម្មភាពក្រុម<br>មុនពេលចូលរួម<br>វគ្គសាលា<br>អាជីវកម្មកសិកម្ម |

| | | |
|---|---|---|
| | ក្រុមធំ។ ចូរសរសេររាល់ចម្លើយរបស់ពួកគេ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក និងស្វែងរកការឯកភាពទៅលើចម្លើយទាំងនោះ។<br><br>ចូរធ្វើការបូកសរុប ដោយការសួរសំនួរ ថាតើគម្រោងធ្វើទីផ្សារជាក្រុមរបស់គន្នា មានតម្លៃសក្តិសមនឹងធ្វើដែរឬក៏អត់។ ចូរសួរទៅកាន់សិក្ខាកាម ថាតើពួកគេចង់ក្លាយខ្លួនជាចំណែកមួយនៃគម្រោងស្រដៀងគ្នានេះ ដែរឬទេ។ ប្រសិនបើពួកគេចង់ តើហេតុអ្វីបានជាពួកគេចង់? ប្រសិនបើពួកគេមិនចង់ តើហេតុអ្វីបានជាពួកគេមិនចង់? សូមឱ្យសិក្ខាកាមចម្លងចម្លើយរបស់ពួកគេទៅក្នុងសៀវភៅលំហាត់។ | <br>លំហាត់ ៧.៧៖ កម្រងសំនួរករណីសិក្សាអំពីការធ្វើទីផ្សារជាក្រុម |
| ៧.២ | **កម្រងសំនួរអំពីការធ្វើទីផ្សារជាក្រុម៖**<br><br>ចូរប្រាប់ឱ្យសិក្ខាកាមពិនិត្យមើលតារាងកម្រងសំនួរ នៅក្នុងលំហាត់ ៧.៨ នៃសៀវភៅលំហាត់របស់ពួកគេ។ បន្ទាប់មក ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយក្រុម ដោយឆ្លើយទៅនឹងសំនួរខាងក្រោម៖<br><br>➢ តើនរណាខ្លះចង់លក់ផលិតផលរបស់ពួកគេ?<br>➢ តើពួកគេចង់លក់ផលិតផលអ្វី និងក្នុងតម្លៃប៉ុន្មាន?<br>➢ តើពួកគេនឹងផលិតផលិតផលរបស់ពួកគេ ក្នុងគុណភាពកម្រិតណា?<br>➢ តើពួកគេចង់លក់ផលិតផលរបស់ពួកគេនៅពេលណា?<br>➢ តើពួកគេចង់លក់ផលិតផលរបស់ពួកគេនៅឯណា (កសិដ្ឋាន ឬ ស្រែចម្ការ កន្លែងប្រមូលទិញផលិតផល ឬ ទីផ្សារ) ក្នុងតម្លៃប៉ុន្មាន?<br><br>បន្ទាប់មក ចូរសួរទៅកាន់សិក្ខាកាម ថាតើមានអ្នកដទៃទៀតនៅក្នុងក្រុមរបស់ពួកគេ (ពុំមែនត្រឹមតែសមាជិកក្រុម សាលាអាជីវកម្មកសិកម្មប៉ុណ្ណោះទេ) មានបំណងចូលរួម នៅក្នុងផែនការធ្វើសកម្មភាពទីផ្សារជាក្រុមដែរឬទេ។<br><br>ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ប្រសិនបើពួកគេ មិនដឹងចម្លើយច្បាស់ ចូរសូមឱ្យពួកគេធ្វើការប៉ាន់ប្រមាណ ដោយផ្អែកទៅលើបទពិសោធន៍ធ្វើទីផ្សារជាក្រុមរបស់ពួកគេកន្លងមក។ | <br>លំហាត់ ៧.៨៖ តារាងយុទ្ធសាស្រ្តធ្វើទីផ្សារជាក្រុម |

| | | |
|---|---|---|
| | ដែលទទួលបានពី "ការអនុវត្តដែលកសិករបានឯកភាព" ក្នុងលំហាត់ ៧.៦(គ)។<br><br>បន្ទាប់មក ចូរបំពេញនៅក្នុងចន្លោះទំនេរ ក្នុងលំហាត់ ៧.៦ ដោយដំបូងត្រូវចាប់ផ្ដើមសរសេរអំពីប្រាក់ចំណេញដែលទទួលបានពី "ការអនុវត្តដែលកសិករបានឯកភាព" បន្ទាប់មក ត្រូវធ្វើការដកចេញនូវ "ប្រាក់ចំណេញ/ការខាតបង់ មុនពេលចូលរួមក្នុងវគ្គសាលាអាជីវកម្មកសិកម្ម" ពីចំនួននោះ ដើម្បីរកឱ្យឃើញនូវកំណើននៃប្រាក់ចំណេញ ប្រសិនបើពួកគេអនុវត្តតាមបច្ចេកទេសថ្មីៗមួយចំនួន។<br><br>ចូរធ្វើការពិភាក្សា ថាតើសិក្ខាកាមពេញចិត្តទៅនឹងការកើនឡើងនៃប្រាក់ចំណេញរបស់សហគ្រាសពួកគេដែរឬទេ។ ប្រសិនបើពួកគេពេញចិត្ត ពួកគេអាចប្រើប្រាស់ការប៉ាន់ប្រមាណតួលេខផលិត និងការប៉ាន់ប្រមាណសេចក្ដីត្រូវការសម្ភារៈកសិកម្ម ដើម្បីគណនាអំពីសេចក្ដីត្រូវការក្នុងការធ្វើទីផ្សារជាក្រុម និងការទិញសម្ភារៈកសិកម្ម។ | <br>លំហាត់ ៧.៦៖ ការប្រៀបធៀបរវាងមុនពេល និងក្រោយពេលចូលរួមវគ្គ សាលាអាជីវកម្មកសិកម្ម |
| ៧ | **ការណែនាំអំពីការធ្វើទីផ្សារជាក្រុម៖**<br><br>ចូរសួរទៅកាន់សិក្ខាកាម ថាតើពួកគេធ្លាប់ចូលរួមជាផ្នែកមួយនៃគម្រោងធ្វើទីផ្សារជាក្រុម ឬ ពួកគេធ្លាប់ដឹងអំពីគម្រោងបែបនេះ ដែរឬទេ។ តើមានអត្ថប្រយោជន៍អ្វីខ្លះ នៅក្នុងគម្រោងបែបនេះ? តើគម្រោងបែបនេះ មានបញ្ហាអ្វីខ្លះ? | |
| ៧.១ | **ករណីសិក្សាអំពីការធ្វើទីផ្សារជាក្រុម៖**<br><br>ចូរប្រាប់សិក្ខាកាមថា ក្នុងរយៈពេលប៉ុន្មាននាទីខាងមុខនេះ អ្នកនឹងអានឱ្យពួកគេស្ដាប់នូវករណីសិក្សា អំពីការធ្វើទីផ្សារជាក្រុមរបស់គន្ធា នៅក្នុងលំហាត់ ៣.៥ នៃសៀវភៅលំហាត់របស់ពួកគេ។ មុនពេលដែលអ្នកអានអំពីសាច់រឿងនេះ ចូរប្រាប់ឱ្យសិក្ខាកាមពិនិត្យមើលកម្រងសំនួរនៅក្នុងលំហាត់ ៧.៧ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរពិនិត្យមើលសំនួរទាំងនោះ ដើម្បីធានាថាពួកគេយល់សំនួរ បន្ទាប់មក ចូរធ្វើការបែងចែកមួយ ឬពីរសំនួរទៅឱ្យសិក្ខាកាម ឬ អនុក្រុមនីមួយៗ។<br><br>សូមឱ្យសិក្ខាកាមស្ដាប់សាច់រឿង និង សរសេរចម្លើយសម្រាប់សំនួរដែលបានបែងចែកទៅឱ្យពួកគេ។ នៅចុងបញ្ចប់នៃសាច់រឿងនេះ ចូរសូមឱ្យសិក្ខាកាមនីមួយៗធ្វើសេចក្ដីរាយការណ៍ អំពីចម្លើយរបស់ពួកគេទៅកាន់ | <br>លំហាត់ ៣.៥៖ ករណីសិក្សា "ការធ្វើការងាររួមគ្នាធ្វើឱ្យសមាជិកនីមួយៗទទួលបានផលកាន់តែច្រើន" |

| | | |
|---|---|---|
| | ចំពោះការធ្វើកសិដ្ឋាន ឬ ការដាំដុះ កសិផលលក្ខណៈសរីរាង្គ ដែលអ្នកទិញផលិតផលត្រូវការឱ្យមានការប្រកាន់ខ្ជាប់ ការអនុវត្តយ៉ាងតឹងរឹងនៅក្នុងការផលិត។<br><br>ចូរប្រាប់សិក្ខាកាមថា ការប្រើប្រាស់ផែនទីកសិដ្ឋាន ឬ ស្រែចម្ការ គឺជាបច្ចេកទេសគ្រប់គ្រងមួយដែលមានសារៈប្រយោជន៍ សម្រាប់ជួយដល់ពួកគេក្នុងការប្រៀបធៀប ការប្រើប្រាស់ដីនៅក្នុងឆ្នាំនីមួយៗ ដើម្បីជួយដល់ការធ្វើផែនការឆ្លាស់ការដាំដុះដំណាំកសិផល និងសេចក្ដីសម្រេចចិត្តដទៃទៀតនៅក្នុងការងារគ្រប់គ្រង។<br><br>ចូរផ្ដល់រយៈពេលចំនួន ១៥-៣០នាទី ជូនដល់សិក្ខាកាមដើម្បីគូរផែនទីរបស់ពួកគេ និង ដើរត្រួតពិនិត្យតាមក្រុម ដើម្បីផ្ដល់ជំនួយក្នុងករណីចាំបាច់។ នៅពេលដែលការគូរផែនទី ត្រូវបានបញ្ចប់រួចរាល់ ចូរសូមឱ្យសិក្ខាកាមដែលមានផែនទីច្បាស់បំផុត ឡើងធ្វើការបង្ហាញផែនទី និងរៀបរាប់អំពីតំបន់ផលិតជូនដល់ក្រុមទាំងមូល។ | |
| ៧.៤ | **ការកំណត់រកអ្នកទិញផលិតផល៖**<br><br>(**សម្គាល់** ៖ មុនពេលកិច្ចប្រជុំនេះ អ្នកសម្របសម្រួល ព្រមជាមួយនឹងសិក្ខាកាមដែលឈានមុខគេ គួរកំណត់រក និង ធ្វើការចងក្រងព័ត៌មានអំពីអ្នកទិញផលិតផលសំខាន់ៗ ដែលក្រុមអាចលក់ផលិតផលទៅឱ្យអ្នកទិញទាំងនោះ៖ អ្នកទិញផលិតផលដែលអាចមកចូលរួមនៅក្នុងកិច្ចប្រជុំសាលាអាជីវកម្មកសិកម្មនេះ ឬ អាចនិយាយតាមទូរស័ព្ទ តាមរយៈ "កិច្ចប្រជុំតាមទូរស័ព្ទពីចម្ងាយដោយបំពងសម្លេងតាមឧគ្គោសនស័ព្ទ"។ ត្រូវធានាថា អ្នកទិញអាចផ្គត់ផ្គង់ផលិតដែលត្រូវបានជ្រើសរើស មានគុណភាព និងបរិមាណដែលក្រុម ត្រូវការ និងដឹងអំពីតម្លៃ ការបញ្ចុះតម្លៃ និងការលើកទឹកចិត្តដទៃទៀតដែល ពួកគេអាចផ្ដល់ជូនក្រុមបាន។)<br><br>ចូរធ្វើការប្រមូលផ្ដុំគំនិតជាមួយសិក្ខាកាម ដើម្បីស្វែងរកឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកទិញផលិតផលដែលពួកគេចង់លក់ផលិតផលរបស់ពួកគេទៅឱ្យ។ ចូរ បន្ថែមគំនិតផ្ទាល់ខ្លួនរបស់អ្នកមួយចំនួន ប្រសិនបើចំណុចទាំងនោះមិនទាន់មានរៀបរាប់នៅឡើយ។ ចូរសរសេរព័ត៌មាននៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ចូរស្នើសុំឱ្យសិក្ខាកាម ចម្លងព័ត៌មាន | <br>លំហាត់ ៧.១០៖ តារាងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកទិញផលិតផល |

| | | |
|---|---|---|
| | ស្នើសុំឱ្យពួកគេ ចម្លងតារាងយុទ្ធសាស្ត្រធ្វើទីផ្សារជាក្រុមពីផ្ទាំងក្រដាសធំទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។<br><br>**សម្គាល់៖** អ្នកចូលរួមនៅក្នុងគម្រោង សាលាអាជីវកម្មកសិកម្ម អាចត្រូវទៅជួបនិយាយជាមួយសមាជិកក្រុមដទៃទៀត ដើម្បីបញ្ជាក់អំពីចំណាប់អារម្មណ៍របស់ពួកគេ ក្នុងការចូលរួមនៅក្នុងផែនការសកម្មភាពធ្វើទីផ្សារជាក្រុម។ ពួកគេគួរសរសេរបញ្ជីរាយនាមមួយ អំពីអ្នកដែលមានចំណាប់អារម្មណ៍នៅក្នុងទម្រង់តារាងយុទ្ធសាស្ត្រធ្វើទីផ្សារជាក្រុម ក្នុងលំហាត់ ៧.៨ បន្ទាប់មក ត្រូវយកតួលេខទាំងនេះទៅកាន់កិច្ចប្រជុំលើកក្រោយ។ | |
| ៧.៣ | **ផែនទីកសិដ្ឋាន ឬ ស្រែចម្ការ ដែលបង្ហាញអំពីផ្ទៃដីផលិតរបស់ក្រុម៖**<br><br>ចូរធ្វើការបែងចែកសិក្ខាកាមទៅតាមអនុក្រុមរបស់ពួកគេ។ ចូរស្នើសុំឱ្យពួកគេគូរផែនទី អំពីទីតាំងមូលដ្ឋាននៃការធ្វើទីផ្សារជាក្រុមរបស់ពួកគេ ដោយរៀបរាប់អំពីឈ្មោះសហគ្រាស និង ប្រភេទផលិតផលផ្សេងៗគ្នាដែលពួកគេផលិត ផ្ទៃដី និងទិន្នផលគ្រោងទុក។ ពួកគេក៏គួរសរសេរឈ្មោះអ្នកជិតខាងរបស់ពួកគេផងដែរ ដើម្បីជួយក្នុងការកំណត់ទីកន្លែងផ្ទៃដី។ ចូរសរសេរព័ត៌មាននេះ នៅក្នុងលំហាត់ ៧.៩ នៃសៀវភៅលំហាត់របស់ពួកគេ។ បុគ្គលនីមួយៗគួរគូសបញ្ជាក់អំពីទីតាំង និង ទំហំនៃវិភាគទាន របស់ពួកគេចំពោះសហគ្រាសក្រុម ដែលពួកគេបានជ្រើសរើសនៅលើផែនទី។ ខណៈពេលដែលពួកគេកំពុងធ្វើសកម្មភាពនេះ ពួកគេមិនគួរបារម្ភអំពីភាពសុក្រឹត្យ ឬ ការគូរឱ្យត្រូវទៅតាមមាត្រដ្ឋានឡើយ។ ការគូររូបភាពសាមញ្ញៗ គឺគ្រប់គ្រាន់សម្រាប់ប្រើប្រាស់បានហើយ។<br><br>ប្រសិនបើសិក្ខាកាមធ្វើការដាំដុះដំណាំកសិផល ផែនទីផលិតកម្មគួរផ្តល់ឈ្មោះដំណាំ កសិផលដែលពួកគេនឹងធ្វើការដាំដុះ ចំនួនផ្ទៃដីដែលពួកគេនឹងធ្វើការដាំដុះ និង ទិន្នផល ដែលពួកគេសង្ឃឹមថានឹងទទួលបាន។ ប្រសិនបើពួកគេបានជ្រើសរើសយកសហគ្រាស ចិញ្ចឹមសត្វពាហនៈ ផែនទីគួរបង្ហាញអំពី ទីកន្លែងដែលពួកគេនឹងធ្វើការចិញ្ចឹមសត្វពាហនៈទាំងនោះ ទំហំនៃកសិដ្ឋាន ប្រភេទ និង ចំនួនសត្វពាហនៈដែលពួកគេនឹងធ្វើការចិញ្ចឹម និងផលិតផលដែលពួកគេនឹងផលិត។<br><br>ចូរផ្តល់ដំបូន្មានដល់សិក្ខាកាមថា ប្រធានក្រុមចាំបាច់ត្រូវមានផែនទីទាំងនេះមួយច្បាប់ ដើម្បីឱ្យពួកគេអាចចុះធ្វើការត្រួតពិនិត្យទីកន្លែងផលិត ដើម្បីត្រួតពិនិត្យគុណភាព។ ចំណុចនេះមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេស | <br>លំហាត់ ៧.៩៖ ការគូររូបភាព ផែនទីកសិដ្ឋាន ឬ ស្រែចម្ការផ្ទាល់ខ្លួនរបស់អ្នក |

| | | |
|---|---|---|
| | ផលិតផលអាចផ្តល់ឥណទានជាមុន សម្រាប់ទិញសម្ភារៈកសិកម្ម និងអនុញ្ញាតឱ្យក្រុមសងត្រឡប់មកវិញ នៅពេលលក់ផលិតផលបានដែរឬទេ?”<br><br>សិក្ខាកាមឈានមុខ គួរព្យាយាមចរចាដើម្បីទទួលបានតម្លៃមួយដែលកៀកទៅនឹងតម្លៃដែលក្រុមចង់បាន។<br><br>ចូរសរសេររាយនាមនៅលើផ្ទាំងក្រដាសដោយឡែក ក្រោមឈ្មោះរបស់អ្នកទិញនូវតម្លៃដែលពួកគេផ្តល់ជូន នៅពេលដែលពួកគេចង់លក់។<br><br>ប្រាប់ឱ្យសិក្ខាកាមបញ្ចូលតម្លៃទៅក្នុងតារាងបញ្ជីរាយនាមទំនាក់ទំនង ក្នុងសៀវភៅលំហាត់របស់ពួកគេ។ | |
| ៧.៦ | **គុណសម្បត្តិ និងគុណវិបត្តិរបស់អ្នកទិញនីមួយៗ៖**<br><br>សូមឱ្យអនុក្រុមទាំងអស់ពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់អ្នកទិញនីមួយៗ បន្ទាប់មក សូមឱ្យអនុក្រុមនីមួយៗឡើងរាយការណ៍ជូនក្រុមធំ។ ចូរសរសេរគំនិតរបស់ពួកគេ ក្រោមឈ្មោះរបស់អ្នកទិញដែលពាក់ព័ន្ធ ព្រមទាំងតម្លៃ។ សូមឱ្យសិក្ខាកាមចម្លងព័ត៌មានទៅក្នុងលំហាត់ ៧.១២ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៧.១២៖ គុណសម្បត្តិ និងគុណវិបត្តិនៃអ្នកទិញដែលបានទាក់ទង |
| ៧.៧ | **កម្រងសំនួរអំពីការធ្វើទីផ្សារជាក្រុម ៖**<br><br>ចូរធ្វើការប្រមូលផ្តុំគំនិតដើម្បីស្វែងរកចម្លើយ ចំពោះសំនួរខាងក្រោម។ សំនួរទាំងនេះ មានរាយនាមនៅក្នុងកម្រងសំនួរអំពីការធ្វើទីផ្សារជាក្រុម ក្នុងលំហាត់ ៧.១៣ នៃសៀវភៅលំហាត់។ ចូរសរសេរចម្លើយនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>១. តើអ្នកនឹងធ្វើការជ្រើសរើសយកច្រកចេញទៅកាន់ទីផ្សារ ឬ អ្នកទិញណាខ្លះ? ហេតុអ្វី?<br>២. តើអ្នកចង់ធ្វើកិច្ចព្រមព្រៀងមិនផ្លូវការ ឬ កិច្ចសន្យាលាយលក្ខណ៍អក្សរ ជាមួយអ្នកទិញដែលត្រូវបានជ្រើសរើសដែរឬទេ? ហេតុអ្វី?<br>៣. តើថ្លៃចំណាយ ដើម្បីនាំយកផលិតផលទៅកាន់ចំណុចលក់ | <br>លំហាត់ ៧.១៣៖ កម្រងសំនួរអំពីការធ្វើទីផ្សារជាក្រុម |

| | | |
|---|---|---|
| | ទាំងនោះ ទៅក្នុងតារាងទំនាក់ទំនងលម្អិតរបស់អ្នកទិញផលិតផល នៅក្នុងលំហាត់ ៧.១០ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៧.៥ | **ការភ្ជាប់ទំនាក់ទំនងជាមួយអ្នកទិញផលិតផល៖**<br>(សកម្មភាពនេះ អាចធ្វើក៏បាន ឬ មិនធ្វើក៏បាន ៖ ចូរចាប់ផ្ដើមវគ្គនេះ ជាមួយនឹងមេរៀនទី៨ ៖ ការចរចាអំពីកិច្ចព្រមព្រៀងមិនផ្លូវការ និង កិច្ចសន្យាផ្លូវការ។ ក្រោយពេលសិក្សាមេរៀនទី៨ រួចរាល់ ចូរជ្រើសរើសសិក្ខាកាមដែលបានបង្ហាញឱ្យឃើញអំពីជំនាញ និង ចំណេះដឹងចរចាពូកែបំផុត ដើម្បីធ្វើកិច្ចសម្ភាសន៍ដូចមានរៀបរាប់ខាងក្រោម។)<br>ចូរស្នើសុំឱ្យសិក្ខាកាមដែលឈានមុខគេធ្វើការសម្ភាសន៍អ្នកទិញផលិតផល ដែលត្រូវបានជ្រើសរើសឱ្យចូលរួម និង មានវត្តមាននៅក្នុងកិច្ចប្រជុំ ឬ និយាយជាមួយពួកគេតាមទូរស័ព្ទ ដែលបំពងសម្លេងតាមឧគ្ឃោសនស័ព្ទ ដើម្បីឱ្យក្រុមទាំងអស់អាចស្ដាប់ឮ។<br>ពួកគេគួរផ្ដោតការពិភាក្សាទៅលើចំណុចខាងក្រោម៖<br>១. តើពួកគេចង់លក់ផលិតផលអ្វី?<br>២. តើពួកគេចង់លក់ផលិតផលក្នុងបរិមាណច្រើនប៉ុណ្ណា?<br>៣. តើពួកគេនឹងផលិតផលិតផលរបស់ពួកគេ ក្នុងគុណភាពកម្រិតណា?<br>៤. តើពួកគេចង់លក់ផលិតផលនៅកន្លែងណា?<br>៥. តើពួកគេចង់លក់ផលិតផលនៅពេលណា?<br>៦. តើពួកគេចង់បានតម្លៃប៉ុន្មាន?<br>និងអាចសួរសំនួរដទៃទៀត ប្រសិនបើវាមានភាពពាក់ព័ន្ធ ដូចជា៖<br>៧. តើអ្នកទិញផលិតផល អាចផ្ដល់ឥណទានជាមុន សម្រាប់ទិញសម្ភារៈកសិកម្ម ដោយអនុញ្ញាតឱ្យក្រុមសងត្រឡប់ទៅវិញនៅចុងរដូវកាលបានដែរឬទេ?<br>សិក្ខាកាមដែលឈានមុខគេ អាចប្រាប់អ្នកទិញនូវចំណុចមួយចំនួនដូចខាងក្រោម ៖<br>១. "ក្រុមរបស់ខ្ញុំចង់លក់ស្រូវផ្ការំដួលសុទ្ធចំនួន ១០០តោន នៅឯកន្លែងប្រមូលទិញផលិតផលក្នុងភូមិរបស់ពួកគេ នៅខែវិច្ឆិកា។ តើអ្នកទិញអាចផ្ដល់តម្លៃខ្ពស់បំផុត ក្នុងកម្រិតណា?" "តើអ្នកទិញ | <br>លំហាត់ ៧.១១៖ ការសម្ភាសន៍អ្នកទិញផលិតផល |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | **សម្គាល់ ៖**<br>**ប្រាក់ចំណូល** ទទួលបានពីបរិមាណផលិតផលដែលក្រុមលក់បាន គុណនឹង តម្លៃដែលក្រុមលក់ផលិតផល។<br>**ថ្លៃចំណាយចម្បងៗ** រួមមានដូចជា ៖ បរិមាណផលិតផលដែលក្រុមប្រមូលពីកសិករ គុណនឹងតម្លៃដែលក្រុមផ្តល់ជូនទៅឱ្យកសិករ និង ថ្លៃចំណាយសម្រាប់ការធ្វើទីផ្សារ (ការដឹកជញ្ជូន ការរក្សាទុកកម្លាំងពលកម្ម)។<br>**លទ្ធផល (ការចំណេញ ឬ ការខាតបង់)** គឺជាចំនួនទឹកប្រាក់ដែលក្រុមទទួលបាន តាមរយៈការសម្របសម្រួលសកម្មភាពធ្វើទីផ្សារជាក្រុម។ តើសិក្ខាកាមពេញចិត្តទៅនឹងលទ្ធផលដែរឬទេ? | |
| ៨ | **ការទិញសម្ភារៈ ឬ ឧបករណ៍ជាក្រុម៖**<br>ចូរចាប់ផ្តើមវគ្គនេះ ដោយការស្នើសុំឱ្យសិក្ខាកាមរៀបរាប់អំពីបទពិសោធន៍របស់ពួកគេ ក្នុងការទិញសម្ភារៈ ឬឧបករណ៍ក្នុងលក្ខណៈជាបុគ្គល និងក្នុងលក្ខណៈជាក្រុមពី កសិករ ឈ្មួញ អ្នកផ្គត់ផ្គង់ អ្នកលក់រាយ និងអ្នកផលិតដទៃទៀត។<br>ចូរធ្វើការប្រមូលផ្តុំគំនិត តើគុណសម្បត្តិ និងគុណវិបត្តិនៃការទិញសម្ភារៈជាក្រុម មានអ្វីខ្លះ? ចូរសរសេរចំណុចសំខាន់ៗរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br>ចូរធ្វើការសង្ខេបដោយសួរទៅកាន់សិក្ខាកាមថា តើពួកគេចាប់អារម្មណ៍ក្នុងការទិញសម្ភារៈជាក្រុម ដែរឬទេ? ហេតុអ្វី? | |
| ៨.១ | **ការគណនាជាមូលដ្ឋានទៅលើសេចក្តីត្រូវការសម្ភារៈរបស់ក្រុម និងថ្លៃចំណាយ មុនពេលធ្វើសកម្មភាពក្រុម៖**<br>ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការងារជាអនុក្រុមតូចៗ និង ពិនិត្យមើលទៅលើថវិកា "ការអនុវត្តដែលកសិករបានឯកភាព" របស់សហគ្រាសដែលពួកគេបានជ្រើសរើស នៅក្នុងលំហាត់ ៧.៥ (គ) នៃសៀវភៅលំហាត់របស់ពួកគេ និងរៀបរាប់អំពី ៖<br>➢ ឈ្មោះសម្ភារៈដែលពួកគេត្រូវការ<br>➢ ចំនួនសម្ភារៈនីមួយៗដែលពួកគេត្រូវការប្រើប្រាស់នៅក្នុងផ្ទៃដីមួយ | |

| | | |
|---|---|---|
| | ផលិតផល (ការដឹកជញ្ជូន ការរក្សាទុក កម្លាំងពលកម្ម) រួមមានអ្វីខ្លះ?<br>៤. តើនរណាខ្លះនឹងធ្វើការរៀបចំជំហានខាងលើ?<br>៥. តើក្រុមកសិករនឹងទាមទារកម្រៃចំនួនប៉ុន្មាន សម្រាប់ការផ្តល់សេវាខាងលើ និង ដើម្បីទទួលបានប្រាក់ចំណេញមួយចំនួនសម្រាប់បែងចែកជូនដល់សមាជិក ដែលមានភាគហ៊ុននៅក្នុងក្រុម?<br>៦. តើអ្នកនឹងធ្វើការកត់ត្រាព័ត៌មានអំពីការលក់ ប្រាក់ចំណូល និងព័ត៌មានដទៃទៀត ដោយរបៀបណា?<br>៧. តើអ្នកនឹងធ្វើការបែងចែកប្រាក់ចំណូលរបស់ក្រុម ក្នុងចំណោមសមាជិកក្រុមទាំងអស់ ដោយរបៀបណា?<br>សូមឱ្យសិក្ខាកាមចម្លងចម្លើយពីផ្ទាំងក្រដាសធំ ទៅក្នុងលំហាត់ ៧.១៣ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៧.៨ | **តារាងសង្ខេបអំពីផែនការធ្វើទីផ្សារជាក្រុម ៖**<br>ចូរសង្ខេបចម្លើយរបស់សិក្ខាកាមទៅក្នុងតារាងសង្ខេបអំពី ការធ្វើទីផ្សារជាក្រុម នៅលើផ្ទាំងក្រដាសមួយសន្លឹកដែលត្រូវបានរៀបចំទុកជាមុន។ សូមឱ្យសិក្ខាកាមចម្លងខ្លឹមសារនៅលើផ្ទាំងក្រដាសនេះ ទៅក្នុងលំហាត់ ៧.១៤ នៃសៀវភៅលំហាត់របស់ពួកគេ។<br>សូមឱ្យសិក្ខាកាមដាក់តម្លៃនៃ "ការលក់ពីកន្លែងប្រមូលផលិតផល" ទៅក្នុងថវិកា សម្រាប់ "ការអនុវត្តដែលកសិករបានឯកភាព" របស់ពួកគេ (លំហាត់ ៧.៥ (គ) នៃសៀវភៅលំហាត់) ដើម្បីពិនិត្យមើល តើប្រាក់ចំណេញមានការកើនឡើងដល់កម្រិតណា តាមរយៈតម្លៃដែលមានការកើនឡើងដោយសារការធ្វើទីផ្សារជាក្រុម។ | <br>លំហាត់ ៧.១៤៖ តារាងសង្ខេបអំពីផែនការធ្វើទីផ្សារជាក្រុម |
| ៧.៩ | **ផែនការថវិកាសម្រាប់ការធ្វើទីផ្សារជាក្រុម៖**<br>សូមឱ្យសិក្ខាកាមពិនិត្យមើលទម្រង់ថវិកាសម្រាប់ការធ្វើទីផ្សារជាក្រុម នៅក្នុងលំហាត់ ៧.១៥ នៃសៀវភៅលំហាត់របស់ពួកគេ។<br>សូមឱ្យសិក្ខាកាមបំពេញតារាងដែលនិយាយអំពីប្រាក់ចំណូល ថ្លៃចំណាយ និងប្រាក់ចំណេញ/ការខាតបង់ សម្រាប់សកម្មភាពធ្វើទីផ្សារជាក្រុម។ | <br>លំហាត់ ៧.១៥៖ ថវិកាសម្រាប់ការធ្វើទីផ្សារជាក្រុម |

| | | |
|---|---|---|
| | **សម្គាល់ ៖** ចំណុចទាំង៣ចុងក្រោយនេះ គេហៅថា "ថ្លៃចំណាយសម្រាប់ការធ្វើទីផ្សារ"។<br><br>ចូរបូករាល់ថ្លៃចំណាយទាំងអស់បញ្ចូលគ្នា ដើម្បីទទួលបានតម្លៃសម្ភារៈដែលមកដល់ "កសិដ្ឋាន ឬ ស្រែចម្ការ" ដែលកសិករនីមួយៗចំណាយនៅពេលនេះ។ ចូរសរសេរតម្លៃទាំងនេះ ទៅក្នុងគូឡោនទី៥ នៃតារាង។<br><br>➢ ចូរគុណចំនួនសរុបបញ្ចូលគ្នា ដើម្បីទទួលបានថ្លៃចំណាយសរុបនៃសេចក្តីត្រូវការសម្ភារៈ <u>មុនពេល</u>ធ្វើសកម្មភាពទិញជាក្រុម។ | |
| ៨.២ | **ការប៉ាន់ប្រមាណទៅលើការបញ្ចុះតម្លៃសម្រាប់ការទិញជាក្រុម៖**<br><br>ចូរស្នើសុំឱ្យកសិករធ្វើការប៉ាន់ប្រមាណ ថាតើពួកគេអាចទទួលបានការបញ្ចុះតម្លៃចំនួនប៉ុន្មាន ប្រសិនបើពួកគេធ្វើការចរចាជាក្រុម ដើម្បីទិញសម្ភារៈ? ចូរសរសេរចម្លើយរបស់ពួកគេ និងគណនា ដើម្បីស្វែងរកអត្រាបញ្ចុះតម្លៃជាមធ្យម។ ចូរប្រើប្រាស់អត្រានេះ ដើម្បីគណនាស្វែងរកការប៉ាន់ប្រមាណទៅលើចំនួនទឹកប្រាក់ដែលក្រុមអាចសន្សំបាន នៅពេលដែលពួកគេទិញសម្ភារៈជាក្រុម។<br><br>**សម្គាល់៖** សេចក្តីត្រូវការសម្ភារៈសរុប <u>គុណនឹង</u>អត្រាបញ្ចុះតម្លៃ = ប្រាក់ដែលសន្សំបាន។<br><br>ចូរនិយាយថា ប្រាក់មួយចំនួននៃប្រាក់ដែលបានសន្សំនេះ អាចផ្តល់ជូនទៅឱ្យប្រធានក្រុមកសិករសម្រាប់ការរៀបចំកិច្ចសន្យាទិញសម្ភារៈ និងផ្តល់ប្រយោជន៍មួយចំនួនទៅឱ្យសមាជិកក្រុមកសិករ ក្នុងលក្ខណៈជាការបែងចែកភាគលាភផល។<br><br>ចូរបញ្ចប់ការពិភាក្សាដោយសួរទៅកាន់សិក្ខាកាមថា៖<br><br>តើពួកគេចាប់អារម្មណ៍ក្នុងការទិញសម្ភារៈជាក្រុមដែរឬទេ?<br>ប្រសិនបើពួកគេនិយាយថា "ចាប់អារម្មណ៍" ពួកគេគួរបន្តបោះជំហានឆ្ពោះទៅរកការធ្វើផែនការទិញសម្ភារៈជាក្រុម។ | |

| | | |
|---|---|---|
| | ឯកតា (ហិកតា ឬ ម៉ែត្រការ៉េ) ឬ នៅក្នុងមាន់ ចំនួន........ក្បាល ឬ គោ ចំនួន..........ក្បាល។ <br><br> បំពេញចម្លើយរបស់ពួកគេទៅលើផ្ទាំងក្រដាសធំមួយសន្លឹក ដែលត្រូវបានរៀបចំទុកជាមុនក្នុងទម្រង់មួយដែលដូចគ្នាទៅនឹងលំហាត់ ៧.១៦ "តារាងសេចក្តីត្រូវការសម្ភារៈកសិកម្ម និងថ្លៃចំណាយ ដោយពុំមានសកម្មភាពទិញសម្ភារៈជាក្រុម" នៃសៀវភៅលំហាត់របស់ពួកគេ។ <br><br> ចូរសរសេរឈ្មោះសម្ភារៈនៅក្នុងគូឡោនទី១ និងចំនួនសម្ភារៈនៅក្នុងគូឡោនទី២? <br><br> ➢ សូមឱ្យសិក្ខាកាម ធ្វើការប៉ាន់ប្រមាណចំនួនកសិករដែលអាចចង់ចូលរួមនៅក្នុងសកម្មភាពទិញសម្ភារៈជាក្រុម ព្រមទាំងធ្វើការប៉ាន់ប្រមាណទៅលើផ្ទៃដីរបស់ពួកគេ។ ចូរសរសេរព័ត៌មាននេះ នៅក្នុងគូឡោនទី៣ នៃតារាង។ **(សម្គាល់៖** កសិករពុំចាំបាច់ត្រូវតែជាសមាជិកនៃវគ្គបណ្តុះបណ្តាលសាលាអាជីវកម្មកសិកម្ម ឬ សមាជិកក្រុមឡើយ។ រាល់កសិករទាំងអស់នៅក្នុងតំបន់របស់ពួកគេ សុទ្ធសឹងតែអាចចូលរួមបាន ដោយសារតែកាលណាមានកសិករកាន់តែច្រើន វានឹងនាំឱ្យមានការបញ្ចុះតម្លៃកាន់តែច្រើន និងទទួលបានថ្លៃសេវាសម្របសម្រួលកាន់តែច្រើន សម្រាប់សកម្មភាពទិញសម្ភារៈជាក្រុម)។ <br><br> ➢ ចូរធ្វើការគណនាចំនួនសរុបនៃសម្ភារៈកសិកម្មនីមួយៗដែលគេត្រូវការ នៅក្នុងគូឡោនទី៤។ <br><br> ➢ ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេចំណាយប្រាក់ចំនួនប៉ុន្មានសម្រាប់ការទិញសម្ភារៈនីមួយៗនៅពេលនេះ។ ចូររំលឹកពួកគេថាតម្លៃលក់នៅឯ កសិដ្ឋាន" ឬ ស្រែចម្ការ ៖ គួររាប់បញ្ចូល " <br><br> • តម្លៃដែលពួកគេចំណាយសម្រាប់សម្ភារៈ កសិកម្ម និង <br> • ការដឹកជញ្ជូនទៅកាន់ទីផ្សារ និងមកពីទីផ្សារវិញ <br> • តម្លៃនៃការទទួលទានអាហារនៅឯទីផ្សារ ប្រសិនបើពួកគេបានទទួលទានអាហារនៅទីនោះ <br> • និងអាចរាប់បញ្ចូលថ្លៃពេលវេលារបស់ពួកគេ |  <br> លំហាត់ ៧.៥ (គ)៖ ថវិកាសម្រាប់ការអនុវត្តដែលកសិករបានឯកភាព <br><br>  <br> លំហាត់ ៧.១៦៖ តារាងសេចក្តីត្រូវការសម្ភារៈកសិកម្ម និងថ្លៃចំណាយដោយពុំមានសកម្មភាពទិញសម្ភារៈជាក្រុម |

| | | |
|---|---|---|
| | នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៨.៥ | **ការនិយាយជាមួយអ្នកផ្គត់ផ្គង់សម្ភារៈ**<br><br>(សកម្មភាពនេះ អាចធ្វើក៏បាន ឬ មិនធ្វើក៏បាន ៖ ចូរចាប់ផ្តើមវគ្គនេះ ជាមួយនឹងមេរៀនទី៨ ៖ ការចរចាអំពីកិច្ចព្រមព្រៀងមិនផ្លូវការ និងកិច្ចសន្យាផ្លូវការ។ នៅចុងបញ្ចប់នៃមេរៀននេះ ចូរជ្រើសរើសសិក្ខាកាមដែលបានបង្ហាញឱ្យឃើញអំពីជំនាញ និងចំណេះដឹងចរចាពូកែបំផុត ដើម្បីធ្វើកិច្ចសម្ភាសន៍ដូចមានរៀបរាប់ខាងក្រោម។)<br><br>ចូរស្នើសុំឱ្យសិក្ខាកាមដែលឈានមុខគេធ្វើការសម្ភាសន៍អ្នកផ្គត់ផ្គង់សម្ភារៈ ដែលបានជ្រើសរើសឱ្យចូលរួម និងមានវត្តមាននៅក្នុងកិច្ចប្រជុំ ឬ និយាយជាមួយពួកគេតាមទូរស័ព្ទដែលបំពងសម្លេងតាមឧគ្ឃោសនស័ព្ទ ដើម្បីឱ្យក្រុមទាំងអស់អាចស្តាប់ឮ។<br><br>ពួកគេគួរផ្តោតការពិភាក្សាទៅលើចំណុចខាងក្រោម៖<br><br>១. តើពួកគេចង់ទិញផលិតផលអ្វី?<br>២. តើពួកគេចង់បានសម្ភារៈក្នុងបរិមាណច្រើនប៉ុណ្ណា?<br>៣. តើពួកគេត្រូវការគុណភាពកម្រិតណា?<br>៤. តើពួកគេចង់ទិញនៅកន្លែងណា - “ចំណុចប្រមូលផ្តុំឬ ទីផ្សារ ”?<br>៥. តើពួកគេចង់ទិញនៅពេលណា?<br>៦. តើពួកគេចង់ទិញក្នុងតម្លៃប៉ុន្មាន?<br>និងអាចសួរសំនួរដទៃទៀត ប្រសិនបើវាមានភាពពាក់ព័ន្ធ ដូចជា៖<br>៧. តើអ្នកផ្គត់ផ្គង់សម្ភារៈ អាចផ្តល់ឥណទានជាសម្ភារៈកសិកម្មជាមុន ដោយអនុញ្ញាតឱ្យក្រុមសងត្រឡប់ទៅវិញនៅចុងរដូវកាលបានដែរឬទេ?<br><br>សិក្ខាកាមដែលឈានមុខគេ អាចប្រាប់អ្នកលក់នូវចំណុចមួយចំនួនដូចខាងក្រោម ៖<br><br>“ក្រុមរបស់ខ្ញុំចង់ទិញជី **ដេអាប៉េ** ចំនួន ១០តោន នៅឯចំណុចប្រមូលផ្តុំកណ្តាលក្នុងភូមិរបស់ពួកគេ នៅខែវិច្ឆិកា។ តើអ្នកលក់អាចផ្តល់តម្លៃដែល | <br>លំហាត់ ៧.១៨៖ កម្រងសំនួរសម្រាប់អ្នកផ្គត់ផ្គង់សម្ភារៈ |

| | | |
|---|---|---|
| ៨.៣ | **កម្រងសំនួរអំពីការធ្វើផែនការទិញសម្ភារៈជាក្រុម៖**<br>សូមឱ្យសិក្ខាកាមពិនិត្យមើលកម្រងសំនួរនៅក្នុងលំហាត់៧.១៧ នៃសៀវភៅលំហាត់ របស់ពួកគេ។ ចូរសួរសំនួរខាងក្រោមទៅកាន់ក្រុម ៖<br>➢ តើពួកគេចង់ទិញសម្ភារៈដែលពួកគេត្រូវការពីកន្លែងណា (នៅឯកសិដ្ឋាន ឬ ស្រែចម្ការ , ចំណុចប្រមូលផ្តុំកណ្តាល ឬទីផ្សារ)?<br>➢ តើពួកគេចង់ទិញសម្ភារៈដែលពួកគេត្រូវការនៅពេលណា?<br>➢ តើពួកគេចង់ទិញក្នុងតម្លៃប៉ុន្មាន?<br>ចូរសរសេរចម្លើយនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ប្រសិនបើពួកគេមិនដឹងចម្លើយ ចូរស្នើឱ្យពួកគេធ្វើការប៉ាន់ប្រមាណមួយ ដោយផ្អែកលើបទពិសោធន៍របស់ពួកគេ ក្នុងការទិញសម្ភារៈកន្លងមក។ ចូរបាប់ឱ្យសិក្ខាកាមចម្លងចម្លើយនៃសំនួរទាំងនេះ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៧.១៧៖ កម្រងសំនួរអំពីការទិញសម្ភារៈជាក្រុម |
| ៨.៤ | **ការកំណត់រកអ្នកផ្គត់ផ្គង់សម្ភារៈ**<br>**(សម្គាល់៖** មុនពេលកិច្ចប្រជុំនេះ អ្នកសម្របសម្រួល ព្រមជាមួយនឹងសិក្ខាកាមដែលឈានមុខគេ គួរកំណត់រក និង ធ្វើការចងក្រងព័ត៌មានអំពីអ្នកលក់ផលិតផលសំខាន់ៗ ដែលក្រុមអាចទិញផលិតផលពីអ្នកលក់ទាំងនោះ អ្នកលក់ផលិតផលដែលអាចមកចូលរួមនៅក្នុងកិច្ចប្រជុំសាលាអាជីវកម្មកសិកម្មនេះ ឬ អាចនិយាយតាមទូរស័ព្ទ តាមរយៈ "កិច្ចប្រជុំតាមទូរស័ព្ទពីចម្ងាយដោយបំពងសម្លេងតាមឧគ្ឃោសនស័ព្ទ"។ ត្រូវធានាថាអ្នកលក់អាចផ្គត់ផ្គង់ផលិតដែលបានជ្រើសរើស ដឹងអំពីគុណភាពផលិតផលរបស់ពួកគេ បរិមាណដែលពួកគេអាចលក់បាន និងតម្លៃដែលពួកគេអាចផ្តល់ជូននៅពេលវេលាផ្សេងៗគ្នានៅក្នុងឆ្នាំ ព្រមទាំងការបញ្ចុះតម្លៃសម្រាប់ការទិញជាក្រុម និងការលើកទឹកចិត្តដទៃទៀត។)<br>ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយសិក្ខាកាម ដើម្បីស្វែងរកឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកផ្គត់ផ្គង់សម្ភារៈ ដែលពួកគេចង់ទិញពីអ្នកទាំងនោះ។ ចូរបន្ថែមគំនិតផ្ទាល់ខ្លួនរបស់អ្នកមួយចំនួន ប្រសិនបើចំណុចទាំងនោះមិនទាន់មានរៀបរាប់នៅឡើយ។ ចូរសរសេរព័ត៌មាននៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ចូរស្នើសុំឱ្យសិក្ខាកាម ចម្លងព័ត៌មានទាំងនោះទៅក្នុងតារាងទំនាក់ទំនងលម្អិតរបស់អ្នកផ្គត់ផ្គង់សម្ភារៈ នៅក្នុងលំហាត់៧.១៧ | <br>លំហាត់ ៧.១៧៖ តារាងទំនាក់ទំនងលម្អិតរបស់អ្នកផ្គត់ផ្គង់សម្ភារៈ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | (ការដឹកជញ្ជូន ការរក្សាទុក កម្លាំងពលកម្ម) រួមមានអ្វីខ្លះ?<br>២. តើនរណាខ្លះនឹងធ្វើការរៀបចំជំហានខាងលើ?<br>៣. តើ ក្រុមកសិករ នឹងទាមទារកម្រៃចំនួនប៉ុន្មានសម្រាប់ការផ្តល់សេវាខាងលើ?<br>៤. តើអ្នកនឹងធ្វើការកត់ត្រាព័ត៌មានអំពី សម្ភារៈដែលត្រូវការ ការប្រមូលប្រាក់សម្រាប់ទិញសម្ភារៈ ការទូទាត់ប្រាក់ទៅឱ្យអ្នកផ្គត់ផ្គង់ និងព័ត៌មានដទៃទៀត ដោយរបៀបណា?<br>៥. តើអ្នកនឹងធ្វើការបែងចែកប្រាក់ចំណេញរបស់ក្រុម ក្នុងចំណោមសមាជិកក្រុមទាំងអស់ ដោយរបៀបណា?<br>សូមឱ្យសិក្ខាកាមចម្លងចម្លើយពីផ្ទាំងក្រដាសធំ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៧.២០៖ សំនួរ១-៥ កម្រងសំនួរអំពីការទិញជាក្រុម |
| ៨.៨ | **តារាងសង្ខេបផែនការទិញសម្ភារៈជាក្រុម ៖**<br>ចូរសង្ខេបចម្លើយរបស់សិក្ខាកាម ទៅក្នុងតារាងសង្ខេបអំពីផែនការទិញសម្ភារៈជាក្រុម នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ដែលបានរៀបចំទុកជាមុន។ សូមឱ្យសិក្ខាកាមចម្លងខ្លឹមសារនៅលើផ្ទាំងក្រដាសនេះ ទៅក្នុងលំហាត់ ៧.២១ នៃសៀវភៅលំហាត់របស់ពួកគេ។<br>ចូរប្រាប់ឱ្យសិក្ខាកាមបញ្ចូលតម្លៃសម្ភារៈ "ការទិញជាក្រុមនៅឯចំណុចប្រមូលផ្តុំ" ទៅក្នុងថវិកាសម្រាប់ "ការអនុវត្តដែលកសិករបានឯកភាព" (លំហាត់ ៧.៥ (គ) នៃសៀវភៅលំហាត់) ដើម្បីឱ្យឃើញថា តើសម្ភារៈមានតម្លៃថោកជាងមុនដល់កម្រិតណា និងធ្វើឱ្យសិក្ខាកាមចំណេញបានប្រាក់ចំនួនប៉ុន្មាន។ | <br>លំហាត់ ៧.២១៖ តារាងសង្ខេបផែនការទិញ សម្ភារៈជាក្រុម |
| ៨.៩ | **ផែនការថវិកាទិញសម្ភារៈជាក្រុម៖**<br>សូមឱ្យសិក្ខាកាមពិនិត្យមើលទម្រង់ថវិកាសម្រាប់ទិញសម្ភារៈជាក្រុម នៅក្នុងលំហាត់ ៧.២២ នៃសៀវភៅលំហាត់របស់ពួកគេ។<br>សូមឱ្យសិក្ខាកាមបំពេញប្រាក់ចំណូលដែលទទួលបានពីសកម្មភាពក្រុម ថ្លៃចំណាយ និង ប្រាក់ចំណេញ/ការខាតបង់។ | <br>លំហាត់ ៧.២២៖ ថវិកាសម្រាប់ទិញសម្ភារៈជាក្រុម |

| | | |
|---|---|---|
| | ប្រសើរបំផុត ក្នុងកម្រិតណា?” “តើយើងអាចសុំសម្ភារៈកសិកម្មយកមកប្រើប្រាស់ជាមុន និង ទូទាត់ប្រាក់សម្រាប់សងត្រឡប់ទៅវិញ នៅរដូវប្រមូលផលបានដែរឬទេ?”<br><br>ពួកគេ គួរព្យាយាមចរចា ដើម្បីទទួលបានតម្លៃមួយ ដែលកៀកទៅនឹងតម្លៃដែលក្រុមចង់បាន។<br><br>ចូរសរសេរវាយនាមនៅលើផ្ទាំងក្រដាសដោយឡែក ក្រោមឈ្មោះរបស់អ្នកលក់នូវតម្លៃដែលពួកគេផ្ដល់ជូន។<br><br>ប្រាប់ឱ្យសិក្ខាកាមបញ្ចូលតម្លៃទាំងនោះទៅក្នុងគូឡោនទី៥ នៃតារាងបញ្ជីរាយនាមទំនាក់ទំនងអ្នកផ្គត់ផ្គង់សម្ភារៈ ក្នុងលំហាត់ ៧.១៧ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៨.៦ | **គុណសម្បត្តិ និងគុណវិបត្តិនៃអ្នកផ្គត់ផ្គង់សម្ភារៈនីមួយៗ៖**<br><br>សូមឱ្យអនុក្រុមទាំងអស់ធ្វើការពិភាក្សាអំពីគុណសម្បត្តិ និង គុណវិបត្តិនៃអ្នកផ្គត់ផ្គង់នីមួយៗ។<br><br>សូមឱ្យអនុក្រុមនីមួយៗឡើងរាយការណ៍ទៅឱ្យក្រុមធំ។ ចូរសរសេរគំនិតរបស់ពួកគេ ក្រោមឈ្មោះរបស់អ្នកផ្គត់ផ្គង់សម្ភារៈដែលពាក់ព័ន្ធ ព្រមទាំងតម្លៃ។<br><br>➢ ចូរសួរទៅកាន់ក្រុមថា តើពួកគេនឹងជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារៈមួយណា និង ហេតុអ្វី?<br><br>➢ ចូរសួរទៅកាន់ពួកគេថា តើពួកគេចង់រៀបចំឱ្យមាននូវកិច្ចព្រមព្រៀងមិនផ្លូវការ ឬកិច្ចសន្យាលាយលក្ខណ៍អក្សរជាមួយអ្នកផ្គត់ផ្គង់សម្ភារៈទាំងនោះ ដែរឬទេ។<br><br>សូមឱ្យសិក្ខាកាមចម្លងព័ត៌មាននេះ ទៅក្នុងលំហាត់ ៧.១៩ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៧.១៩៖ គុណសម្បត្តិ និង គុណវិបត្តិនៃអ្នកផ្គត់ផ្គង់សម្ភារៈ ដែលបានទាក់ទង |
| ៨.៧ | **ការទិញសម្ភារៈ**<br><br>ចូរធ្វើការប្រមូលផ្ដុំគំនិតដើម្បីស្វែងរកចម្លើយចំពោះសំនួរខាងក្រោម នៅក្នុងលំហាត់ ៧.២០ នៃសៀវភៅលំហាត់។ ចូរសរសេរចម្លើយនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>១. តើថ្លៃចំណាយដើម្បីយកសម្ភារៈពីកន្លែងលក់សម្ភារៈ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ចែករំលែក ប្រាក់ចំណេញដែលទទួលបានពីការបន្ថែមតម្លៃ នៅក្នុងចំណោមសមាជិកក្រុម ដែរឬទេ?<br>នៅពេលដែលអនុក្រុមបានបញ្ចប់ការពិភាក្សានេះ ចូរសូមឱ្យក្រុមនីមួយៗ ចែករំលែក ចម្លើយរបស់ពួកគេជាមួយក្រុមធំ។ ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។ ចូរប្រាប់ឱ្យសិក្ខាកាមចម្លងចម្លើយទៅក្នុងលំហាត់ ៧.២៣ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៩.១ | **ការសិក្សាអំពីលទ្ធភាពក្នុងការទទួលបានជោគជ័យចំពោះការបន្ថែមតម្លៃ៖**<br>ចូរប្រាប់សិក្ខាកាមថា ពួកគេគួរមានភាពច្បាស់លាស់ថា គំនិតនៃការបន្ថែមតម្លៃរបស់ពួកគេ អាចធ្វើទៅបានប្រកបដោយជោគជ័យ។ ចូរនិយាយថា ពួកគេគួរធ្វើការសិក្សាដាច់ដោយឡែកមួយ អំពីលទ្ធភាពក្នុងការទទួលបានជោគជ័យចំពោះការបន្ថែមតម្លៃជាក្រុម ដើម្បីធ្វើឱ្យប្រាកដថា គំនិតរបស់ពួកគេនឹងទទួលបានប្រាក់ចំណេញ និងផ្តល់ជាប្រយោជន៍ចំពោះសមាជិកទាំងអស់ដែលជាម្ចាស់ភាគហ៊ុននៅក្នុងក្រុម។<br>សំនួរចម្បងៗនៃការសិក្សាអំពីលទ្ធភាពក្នុងការទទួលបានជោគជ័យរួមមានដូចជា៖<br>១. តើក្រុមមានទស្សនវិស័យ គោលដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ដែរឬទេ?<br>២. តើប្រព័ន្ធគ្រប់គ្រងបរិស្ថាន មានភាពសមស្របដែរឬទេ?<br>៣. តើគេអាចដោះស្រាយបញ្ហាបន្ថែមតម្លៃបានដែរឬទេ?<br>៤. តើពួកគេអាចទទួលបានព័ត៌មានបច្ចេកទេស និងសេវាផ្សព្វផ្សាយដែរឬទេ?<br>៥. តើមានធនធានដែរឬទេ?<br>៦. តើមានទីផ្សារមួយដ៏ល្អសម្រាប់ផលិតផលរបស់ពួកគេដែរឬទេ?<br>៧. តើសកម្មភាពបន្ថែមតម្លៃបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន ដែរឬទេ?<br>៨. តើពួកគេអាចការពារខ្លួនពួកគេពីគ្រោះមហន្តរាយ និងហានិភ័យបានដែរឬទេ? | <br>លំហាត់ ៧.២៤៖ បញ្ជីផ្ទៀងផ្ទាត់អំពីលទ្ធភាពនៃការទទួលបានជោគជ័យចំពោះការបន្ថែមតម្លៃ |

| | | |
|---|---|---|
| | **សម្គាល់ ៖**<br><br>**ប្រាក់ចំណូលទទួលបាន**ពីបរិមាណសម្ភារៈដែលក្រុមលក់ទៅឱ្យកសិករ គុណនឹងតម្លៃដែលកសិករផ្តល់ឱ្យក្រុម។<br><br>**ថ្លៃចំណាយចម្បងៗ**រួមមានដូចជា ៖ បរិមាណសម្ភារៈដែលក្រុមប្រមូលពីអ្នកផ្គត់ផ្គង់សម្ភារៈ គុណនឹងតម្លៃដែលក្រុមផ្តល់ជូនអ្នកផ្គត់ផ្គង់សម្ភារៈ និងថ្លៃចំណាយសម្រាប់ការទិញសម្ភារៈ (ការដឹកជញ្ជូន ការរក្សាទុក កម្លាំងពលកម្ម)។<br><br>**លទ្ធផល** (**ការចំណេញ ឬ ការខាតបង់**) គឺជាចំនួនទឹកប្រាក់ដែលក្រុមទទួលបាន តាមរយៈការសម្របសម្រួលសកម្មភាពទិញសម្ភារៈជាក្រុម។<br><br>តើសិក្ខាកាមពេញចិត្តទៅនឹងលទ្ធផលដែរឬទេ? ហេតុអ្វី? | |
| ៩ | **ជម្រើសនៃការបន្ថែមតម្លៃជាក្រុម៖**<br><br>នៅក្នុងការរៀបចំត្រៀមលក្ខណៈសម្រាប់វគ្គនេះ អ្នកសម្របសម្រួល (ឬអនុក្រុមសហគ្រាសនីមួយៗ) គួរយកគំរូផលិតផលដែលបានជ្រើសរើស និងបានកែច្នៃនៅតាមដំណាក់កាលផ្សេងៗគ្នានៃខ្សែសង្វាក់ផ្គត់ផ្គង់។<br><br>សូមឱ្យអនុក្រុមនីមួយៗពិភាក្សាអំពី៖<br>➢ តើគេអាចបន្ថែមតម្លៃទៅលើផលិតផលរបស់ពួកគេជាក្រុម បានដោយរបៀបណា? ពួកគេគួរកំណត់រកអ្វីដែលអាចធ្វើបាន ដូចជា ការប្រមូលផល ការបោកបែន ការសម្ងួត ការបែងចែកខ្នាត ការរក្សាទុក ការកិនស្រូវ ការវេចខ្ចប់ ការដឹកជញ្ជូន ការកែច្នៃផលិតផលឱ្យបានត្រឹមត្រូវ និង ធ្វើការបង្ហាញទៅកាន់អតិថិជនឱ្យមានភាពទាក់ទាញនៅឯកន្លែងលក់ផលិតផល។<br>➢ តើតម្លៃមានភាពខុសគ្នាដូចម្តេច នៅដំណាក់កាលនីមួយៗ? ចូរប្រាប់ពួកគេថា ភាពខុសគ្នានៃតម្លៃ គឺស្ថិតនៅត្រង់តម្លៃដែលបានបន្ថែម។<br>➢ តើនរណាជាអ្នកធ្វើការបន្ថែមតម្លៃ? តើពួកគេអាចបង្កើតការងារសម្រាប់ខ្លួនពួកគេបានដែរឬទេ? តើការបន្ថែមតម្លៃនេះ ត្រូវតែធ្វើដោយមនុស្សម្នាក់ផ្សេងទៀតឬ?<br>➢ តើពួកគេចង់បន្ថែមតម្លៃទៅលើផលិតផលរបស់ពួកគេជាក្រុម និង | <br>លំហាត់ ៧.២៣៖ កម្រងសំនួរអំពីការបន្ថែមតម្លៃជាក្រុម |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ការដឹកជញ្ជូន ការរក្សាទុក កម្លាំងពលកម្ម។<br><br>**លទ្ធផល (ការចំណេញ ឬ ការខាតបង់)** គឺជាចំនួនទឹកប្រាក់ដែលក្រុមទទួលបានតាមរយៈការសម្របសម្រួលសកម្មភាពបន្ថែមតម្លៃជាក្រុម។ (ផលចំណេញក្នុងមួយឯកតា = លទ្ធផលចំណេញសរុប ចែកនឹងចំនួនឯកតា)<br><br>តើសិក្ខាកាមពេញចិត្តទៅនឹងលទ្ធផលដែរឬទេ? ហេតុអ្វី?<br><br>សូមឱ្យសិក្ខាកាមបំពេញចម្លើយរបស់ពួកគេទៅនឹងសំនួរទាំងនេះ នៅក្នុងលំហាត់ ៧.២៥ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ១០ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br><br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br><br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គ សាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | ៩. តើសកម្មភាពបន្ថែមតម្លៃ គឺជាសកម្មភាពដែលអាចទទួលយកបានចំពោះបុរស និងស្ត្រី ដែរឬទេ?<br>១០. តើមានឧបសគ្គរាំងស្ទះផ្នែកសង្គម ឬ វប្បធម៌ ដែរឬទេ?<br>១១. តើគំនិតក្នុងការបន្ថែមតម្លៃធ្វើឱ្យទទួលបានប្រាក់ចំណេញដែរឬទេ?<br>១២. តើពួកគេមានថវិកាដែលស្របទៅនឹងសេចក្តីត្រូវការលំហូរសាច់ប្រាក់ ដែរឬទេ?<br><br>ចូរពិភាក្សាអំពីចំណងជើងទាំងនេះជាមួយសិក្ខាកាម ហើយបន្ទាប់មកចូរស្នើសុំឱ្យពួកគេ បំពេញបញ្ជីផ្ទៀងផ្ទាត់ នៅក្នុងលំហាត់ ៧.២៤ នៃសៀវភៅលំហាត់របស់ពួកគេ។ ប្រសិនបើពួកគេមិនដឹងចម្លើយចំពោះសំនួរទាំងនេះ អ្នកសម្របសម្រួលគួរជួយដល់ពួកគេ ឱ្យធ្វើការស្រាវជ្រាវបន្ត តាមរយៈការអនុវត្តតាមដំណើរការនៃការសិក្សា ទៅលើលទ្ធភាពក្នុងការទទួលបានជោគជ័យក្នុងមេរៀនទី៤។<br><br>ចូរសួរសំនួរ ថាតើពួកគេពេញចិត្តទៅនឹងលទ្ធភាពនៃការទទួលបានជោគជ័យចំពោះសកម្មភាពបន្ថែមតម្លៃនេះ ដែរឬទេ? ហេតុអ្វី? ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក និងប្រាប់ឱ្យពួកគេចម្លងចម្លើយទាំងនោះទៅក្នុងលំហាត់ ៧.២៤ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៩.២ | **ផែនការថវិកាបន្ថែមតម្លៃជាក្រុម៖**<br>សូមឱ្យសិក្ខាកាមពិនិត្យមើលទម្រង់ថវិកាសម្រាប់ការបន្ថែមតម្លៃជាក្រុម នៅក្នុងលំហាត់ ៧.២៥ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>សូមឱ្យសិក្ខាកាមបំពេញប្រាក់ចំណូលដែលទទួលបានពីការបន្ថែមតម្លៃ ថ្លៃចំណាយ និងប្រាក់ចំណេញ/ការខាតបង់។<br><br>**សម្គាល់ ៖**<br><br>**ប្រាក់ចំណូលទទួលបាន**ពីបរិមាណផលិតផលបន្ថែមតម្លៃដែលក្រុមលក់បាន គុណនឹងតម្លៃដែលពួកគេទទួលបានសម្រាប់ផលិតផលនោះ។<br><br>**ថ្លៃចំណាយចម្បងៗ**រួមមានដូចជា ៖ បរិមាណវត្ថុធាតុដើមដែលក្រុមទិញពីអ្នកផ្គត់ផ្គង់ គុណនឹងតម្លៃវត្ថុធាតុដើម និងថ្លៃចំណាយដទៃទៀត ដូចជា | <br><br>លំហាត់ ៧.២៥៖ ផែនការថវិកាបន្ថែមតម្លៃ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ចូរចាប់ផ្ដើមការពិភាក្សា ដោយសួរសំនួរខាងក្រោមទៅកាន់សិក្ខាកាម ៖<br>➢ តើការសម្ដែងតួនេះ និយាយអំពីអ្វី?<br>➢ តើភាគីទាំងពីរនេះ បានឈានទៅដល់ការព្រមព្រៀងមួយដែរឬទេ?<br>➢ តើកសិករព្រមទទួលយកតម្លៃដែលឈ្មួញផ្ដល់ឱ្យ ដែរឬទេ?<br>➢ តើឈ្មួញព្រមផ្ដល់ជូនទៅតាមតម្លៃដែលកសិករបានទាមទារដែរឬទេ?<br>➢ តើភាគីទាំងសងខាងបានសម្រុះសម្រួលគ្នា និង ឈានទៅដល់ការឯកភាពព្រមព្រៀងមួយ ដែលមានលក្ខណៈគួរជាទីពេញចិត្តចំពោះភាគីទាំងសងខាង ដែរឬទេ? | |
| ១.២ | សូមឱ្យក្រុមធ្វើការត្រួតពិនិត្យឡើងវិញទៅលើការព្រមព្រៀងគ្នា នៅក្នុងការសម្ដែងតួអង្គ នៅពេលដែលពួកគេធ្វើការចរចាគ្នា។ តើពួកគេរីករាយទៅនឹងការព្រមព្រៀង ដែលពួកគេបានឯកភាពគ្នានេះ ដែរឬទេ? ប្រសិនបើពួកគេពុំមានភាពរីករាយទេនោះ ពួកគេគួរពិភាក្សាទៅលើដំណើរការនេះជាថ្មីម្ដងទៀត និងព្យាយាមផ្ដល់មតិយោបល់ អំពីល័ក្ខខ័ណ្ឌព្រមព្រៀងដទៃទៀតដែលមានលក្ខណៈគួរជាទីពេញចិត្តចំពោះសិក្ខាកាមគ្រប់រូប។ | |
| ២ | **និយមន័យនៃការចរចា៖**<br>សូមឱ្យសិក្ខាកាមធ្វើការប្រមូលផ្ដុំគំនិតអំពីអត្ថន័យនៃពាក្យ "**ការចរចា**" តើពួកគេធ្លាប់មានបទពិសោធន៍ចរចាអំពីអ្វីម៉្យាងដែរឬទេ? ចុះចំណែកឯការចរចាតម្លៃនៅឯហាងលក់ទំនិញវិញ? តើពួកគេធ្លាប់ចរចាតម្លៃនៅពេលដែលពួកគេទិញសំលៀកបំពាក់ ដែរឬទេ? ចុះចំណែកឯការចរចាអំពីការរៀបអាពាហ៍ពិពាហ៍វិញ? តើការចរចាផ្ដល់នូវប្រយោជន៍ដូចម្ដេចខ្លះ? តើមានអ្វីខ្លះដែលពាក់ព័ន្ធនៅក្នុងដំណើរការចរចា?<br>ចូរពិនិត្យនិយមន័យនៃពាក្យ"**ចរចា**" នៅក្នុងលំហាត់៨.១ នៃសៀវភៅលំហាត់សម្រាប់សិក្ខាកាម ។ ចូរប្រាប់ឱ្យសិក្ខាកាមបន្ថែមនូវគំនិតផ្សេងៗដទៃទៀត ។ | <br>លំហាត់ ៨.១៖ និយមន័យនៃការចរចា |
| | **ចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ធ្វើការចរចា៖**<br>ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេត្រូវការឱ្យមានចំណេះដឹងអ្វីខ្លះ ដើម្បីធ្វើឱ្យជំហររបស់ពួកគេនៅក្នុងការចរចាមួយកាន់តែមានភាពប្រសិទ្ធិភាព។<br>ចូរសរសេរចម្លើយ របស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក និងលើក | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី៨ ៖ ការចរចាទៅលើកិច្ចសន្យាទិញ និងលក់



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងយល់អំពីចំណេះដឹង និងជំនាញដែលចាំបាច់ ដើម្បីឱ្យក្លាយជាអ្នកចរចាដ៏ល្អម្នាក់។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ជំនាញចរចា៖** (សកម្មភាពសម្តែងតួ គេអាចធ្វើក៏បាន ឬមិនធ្វើក៏បាន)<br><br>លំហាត់នេះ អាចចាប់ផ្តើមជាមួយនឹងការសម្តែងតួអង្គមួយ។ អ្នកត្រូវសុំឱ្យសិក្ខាកាមចំនួន ៥នាក់ ដែលក្នុងនោះ ២នាក់ ដើរតួជាអ្នកទិញ (ឈ្មួញ) និង ៣នាក់ទៀត ដើរតួជាអ្នកលក់ (កសិករ)។ សិក្ខាកាមទាំង៥នាក់នេះ គួរជ្រើសរើសមុនពេលកិច្ចប្រជុំ និងពន្យល់អំពីតួអង្គរបស់ពួកគេ ដើម្បីឱ្យពួកគេបានដឹងជាមុនផងដែរ។ ពួកគេគួរមានពេលវេលាសម្រាប់ហាត់សមការសម្តែងតួនេះ។ ព័ត៌មានលម្អិត ត្រូវបានផ្តល់ជូនដូចខាងក្រោម៖<br><br>**តួអង្គ ៖ កសិករចំនួន ៣នាក់ និងឈ្មួញចំនួន ២នាក់**<br><br>កសិករទើបតែបានបញ្ចប់ការប្រមូលផលរបស់ពួកគេ។ នៅក្នុងភូមិមានផលិតផលកសិកម្មជាច្រើន។ មានឈ្មួញជាច្រើនមកក្នុងភូមិដើម្បីផ្តល់តម្លៃ និងល័ក្ខខ័ណ្ឌផ្សេងៗគ្នា។<br><br>**បញ្ហា៖** កសិករទាំង៣នាក់ កំពុងធ្វើការងារជាមួយគ្នា ដោយខិតខំព្យាយាមធ្វើយ៉ាងណាឱ្យពួកគេទទួលបានតម្លៃកាន់តែប្រសើរ សម្រាប់ផលិតផលរបស់ពួកគេ។ ឈ្មួញទាំងពីរនាក់ កំពុងធ្វើការងារជាមួយគ្នា ដោយខិតខំព្យាយាមធ្វើយ៉ាងណាឱ្យពួកគេទិញផលិតផលបានក្នុងតម្លៃទាបបំផុត។<br><br>**សកម្មភាព៖** តួអង្គនៃភាគីទាំងសងខាងធ្វើការចរចា រហូតដល់ពួកគេឯកភាពទៅលើតម្លៃមួយដែលអាចទទួលយកបាន និងព្រមព្រៀងទៅលើល័ក្ខខ័ណ្ឌនានា។ | |
| ១.១ | ចូរប្រាប់ឱ្យសិក្ខាកាមមើលការសម្តែងតួអង្គនេះដោយប្រុងប្រយ័ត្ន ដោយពួកគេនឹងត្រូវធ្វើការពិភាក្សា ក្រោយពេលបញ្ចប់ការសម្តែងតួអង្គនេះ ។ សូមឱ្យតួអង្គទាំង៥នាក់ ចាប់ផ្តើមការសម្តែងតួអង្គរបស់ពួកគេ។<br><br>នៅពេលដែលបញ្ចប់ការសម្តែង ចូរថ្លែងអំណរគុណដល់តួអង្គទាំងអស់។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| ៣.២ | ចូរកំណត់រកសមាជិកក្នុងក្រុមដែលមានជំនាញរឹងមាំបំផុត នៅក្នុងផ្នែកនីមួយៗ ដើម្បីឱ្យពួកគេអាចតំណាងឱ្យក្រុមនៅក្នុងការចរចា ប្រសិនបើពួកគេមានឆន្ទៈក្នុងការធ្វើការងារនោះ។<br><br>សូមឱ្យអ្នកដែលមានជំនាញ និងចំណេះដឹងចរចាខ្សោយ សរសេរអំពីវិធីក្នុងការពង្រឹងចំណេះដឹង និង ជំនាញរបស់ពួកគេនៅក្នុងគូឡោនចុងក្រោយ "គំនិតសម្រាប់កែលម្អ"។<br><br>សូមឱ្យសិក្ខាកាមធ្វើសេចក្តីរាយការណ៍ត្រឡប់ទៅកាន់ក្រុមធំវិញ ជាមួយនឹងការផ្តល់មតិយោបល់ពីសមាជិកក្រុម ដើម្បីធ្វើការកែលម្អ។ ចូរផ្តល់មតិយោបល់ថា អ្នកដែលមានជំនាញចរចាខ្សោយ អាចសូមឱ្យអ្នកដែលមានជំនាញ និងចំណេះដឹងខ្លាំងជាង ជួយដល់ពួកគេក្នុងការពង្រឹងចំណេះដឹង និងជំនាញរបស់ពួកគេ។ | |
| ៣.៣ | ចូរធ្វើការសង្ខេបដោយនិយាយថា ឥឡូវនេះ ក្រុមបានកំណត់រកឃើញសមាជិកដែលមានសមត្ថភាពគ្រប់គ្រាន់ សម្រាប់តំណាងឱ្យក្រុមក្នុងការចរចាទៅលើកិច្ចព្រមព្រៀងមិនផ្លូវការ ឬ កិច្ចសន្យាផ្លូវការរួចហើយ។ សូមជូនពរឱ្យពួកគេទទួលបានសំណាងល្អ នៅក្នុងសកម្មភាពនេះ។ | |
| ៤ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គ សាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | ទឹកចិត្តឱ្យមានការពិភាក្សា។<br>បន្ទាប់មក ចូរសួរទៅកាន់សិក្ខាកាមថា តើគេត្រូវការជំនាញអ្វីខ្លះ ដើម្បីឱ្យក្លាយជាអ្នកចរចាម្នាក់ដ៏ល្អ។<br>ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក និងលើកទឹកចិត្តឱ្យមានការពិភាក្សា។<br>បន្ទាប់មក ចូរធ្វើការប្រៀបធៀបគំនិតរបស់ពួកគេ ជាមួយបញ្ជីវាយនាមនៅក្នុងលំហាត់ ៨.២ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរបន្ថែមគំនិតដទៃទៀតដែលពុំមានកត់ត្រា នៅក្នុងសៀវភៅលំហាត់។ | <br>លំហាត់ ៨.២៖ ដំបូន្មានដើម្បីឱ្យការចរចាទទួលបានជោគជ័យ |
| ៣ | **ការវាយតម្លៃទៅលើជំនាញចរចារបស់សិក្ខាកាម៖**<br>ចូរប្រាប់សិក្ខាកាមថា ឥឡូវនេះ ពួកគេមានបញ្ជីវាយនាមចំនួន២យ ៖ បញ្ជីមួយគឺជាបញ្ជីវាយនាមអ្វីដែលពួកគេត្រូវដឹង ដើម្បីពង្រឹងជំហររបស់ពួកគេនៅក្នុងការចរចា។ បញ្ជីមួយទៀត គឺជាជំនាញដែលចាំបាច់ ដើម្បីឱ្យក្លាយជាអ្នកចរចាម្នាក់ប្រកបដោយជោគជ័យ ។ នៅផ្នែកបន្ទាប់នៃលំហាត់នេះ សិក្ខាកាមនឹងត្រូវធ្វើការវាយតម្លៃ ថាតើពួកគេមានព័ត៌មាន និងជំនាញចាំបាច់ ដើម្បីធ្វើការចរចាប្រកបដោយប្រសិទ្ធភាព ដែរឬទេ ។<br>ចូរធ្វើការរៀបចំបែងចែកសិក្ខាកាមជាក្រុមតូចៗ ដែលក្រុមនីមួយៗមានសមាជិកចំនួន ២នាក់។ ចូរស្នើសុំឱ្យពួកគេផ្តល់ពិន្ទុទៅលើខ្លួនឯង ចំពោះចំណេះដឹង និងជំនាញរបស់ពួកគេ ក្នុងការក្លាយខ្លួនជាអ្នកចរចាម្នាក់ ដោយធៀបទៅនឹងលក្ខណៈវិនិច្ឆ័យនីមួយៗនៅក្នុងសៀវភៅលំហាត់។<br>ចូរប្រាប់ឱ្យពួកគេធ្វើការបង្ហាញដោយសញ្ញា √ (ឬ សញ្ញាទឹកមុខញញឹម) នៅក្នុងសៀវភៅលំហាត់របស់ពួកគេ ប្រសិនបើពួកគេមានភាពជឿជាក់ ឬដាក់សញ្ញាខ្វែង (ឬសញ្ញាទឹកមុខក្រៀមក្រំ) ប្រសិនបើពួកគេមិនមានភាពជឿជាក់ សញ្ញាទឹកមុខស្មើ មានន័យថា ជំនាញរបស់ពួកគេមិនខ្សោយពេក ហើយក៏មិនមានភាពជឿជាក់ពេក។ សូមឱ្យសមាជិកនីមួយៗឡើងអានការវាយតម្លៃរបស់ពួកគេទៅកាន់អ្នកដទៃទៀត។ ចូរលើកទឹកចិត្តឱ្យមានការពិភាក្សានៅក្នុងក្រុម ដើម្បីឱ្យមានការវាយតម្លៃមួយដ៏ស្មោះត្រង់។ | <br>លំហាត់ ៨.៣៖ ការវាយតម្លៃទៅលើចំណេះដឹង និងជំនាញចរចា |
| ៣.១ | នៅពេលដែលសិក្ខាកាមបានបញ្ចប់ធ្វើការវាយតម្លៃចំណេះដឹង និង ជំនាញរបស់ពួកគេ ចូរសូមឱ្យក្រុមនីមួយៗធ្វើការចែករំលែកជាមួយក្រុមធំ អំពីជំនាញរបស់ពួកគេដែលមានភាពរឹងមាំ ឬជឿជាក់បំផុត។ | |

| | | |
|---|---|---|
| | សួរទៅកាន់សិក្ខាកាម ថាតើពួកគេចង់ចុះកិច្ចសន្យាផលិតកម្មកសិកម្មដែលមានលក្ខណៈផ្លូវការ ឬ មិនផ្លូវការ ដែរឬទេ។ ប្រសិនបើពួកគេឆ្លើយថាពួកគេចង់ចូរបន្តទៅវគ្គបន្ទាប់។ | |
| ២ | **ការរៀបចំបង្កើតកិច្ចសន្យា៖**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា តើប្រភេទសេវាកម្មអ្វីខ្លះដែលត្រូវការមាន កិច្ចសន្យា? ចូរសរសេររាយនាមប្រភេទសេវាកម្មទាំងនោះ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយសិក្ខាកាម ថាតើពួកគេគួរផ្តោតលើចំណុចអ្វីខ្លះនៅពេលធ្វើកិច្ចសន្យាមួយ ។ ចូរសរសេរគំនិតរបស់ពួកគេ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ។<br><br>សូមឱ្យពួកគេពិនិត្យមើលចំណុចខាងក្រោម ដែលមានរាយនាមនៅក្នុងលំហាត់ ៩.៣ នៃសៀវភៅលំហាត់របស់ពួកគេ។ សូមឱ្យអនុក្រុមនីមួយៗជជែកគ្នាអំពីចំណុចចំនួន១ ឬ២ ដើម្បីឱ្យចំណុចទាំងអស់នោះត្រូវបានយកមកធ្វើការពិភាក្សា។ ១០ នាទីក្រោយមក សូមឱ្យក្រុមនីមួយៗធ្វើការពន្យល់អំពីការយល់ឃើញរបស់ពួកគេ ចំពោះចំណុចនីមួយៗនៅក្នុងក្រុមធំ។ ចូរលើកទឹកចិត្តឱ្យមានការពិភាក្សា និងផ្តល់ជំនួយនៅពេលដែលចាំបាច់។<br><br>១. **ឈ្មោះផលិតផល៖** រៀបរាប់អំពីផលិតផលរបស់អ្នកឱ្យបានច្បាស់លាស់។<br>២. **បរិមាណផលិតផល៖** ចំណុចនេះ សំដៅចំពោះចំនួនផលិតផលដែលត្រូវផលិត ឬផ្តល់ជូន ។ ឧទាហរណ៍ដូចជា បរិមាណ ៥ តោនក្នុងកសិករមួយនាក់ ឬបរិមាណសរុប ១០០តោន សម្រាប់ក្រុមទាំងមូល ឬ ជី ៣០០បាវ ។<br>៣. **ពេលវេលានៃកិច្ចសន្យា៖** ជាធម្មតា រយៈពេលនេះ ចាប់ផ្តើមពីកាលបរិច្ឆេទចុះហត្ថលេខានៅលើកិច្ចសន្យា រហូតដល់កាលបរិច្ឆេទផ្តល់ផលិតផល និងទូទាត់ប្រាក់។<br>៤. **ស្តង់ដារគុណភាព** ៖ តើល័ក្ខខ័ណ្ឌតម្រូវផ្នែកគុណភាពមានអ្វីខ្លះ? ឧទាហរណ៍: ទំហំ ពណ៌ សំណើម និងចំណាត់ថ្នាក់ ។ | ផ្ទាំងក្រដាសធំ និងប៊ិច<br><br><br><br>លំហាត់ ៩.៣ ៖ ព័ត៌មានលម្អិតនៃកិច្ចសន្យា |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី៩ ៖ ការបង្កើតកិច្ចសន្យាសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងយល់អំពីដំណើរការ ដែលពាក់ព័ន្ធក្នុងការរៀបចំកិច្ចសន្យា សម្រាប់ការទិញ និងការលក់។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **និយមន័យនៃកិច្ចសន្យា៖ ៖ ចូរសួរទៅកាន់សិក្ខាកាមថា**<br>➢ តើពួកគេយល់ដូចម្តេចចំពោះពាក្យថា កិច្ចសន្យា? សូមពិនិត្យមើល និយមន័យ នៅក្នុងលំហាត់ ៩.១ នៃសៀវភៅលំហាត់។<br>➢ សូមឱ្យសិក្ខាកាមផ្តល់ឧទាហរណ៍អំពីពេលវេលាដែលពួកគេបានធ្វើ កិច្ចសន្យាទិញ និងលក់បែបផ្លូវការ ឬមិនផ្លូវការ។<br>➢ តើគេធ្លាប់លក់ផលិតផលប្រភេទណាខ្លះ ឬផ្តល់សេវាអ្វីខ្លះក្រោម កិច្ចសន្យារបស់ពួកគេ?<br>សូមឱ្យសិក្ខាកាមធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ ដើម្បីពិភាក្សាទៅលើ សំនួរខាងក្រោម ដែលមានរាយនាមនៅក្នុងលំហាត់ ៩.២។ ចូរធ្វើការបែងចែក១ ឬ ២សំនួរ ក្នុងមួយក្រុម ដើម្បីសន្សំពេលវេលា។<br>១. តើការមានកិច្ចសន្យាលាយលក្ខណ៍អក្សរជាមួយអ្នកទិញ និងអ្នកលក់ ផ្តល់នូវប្រយោជន៍អ្វីខ្លះ?<br>២. តើកិច្ចសន្យាផ្ទាល់មាត់ ផ្តល់នូវប្រយោជន៍អ្វីខ្លះ?<br>៣. តើកិច្ចសន្យាលាយលក្ខណ៍អក្សរ មានលក្ខណៈល្អប្រសើរជាងកិច្ចសន្យាផ្ទាល់មាត់ ដែរឬទេ? ហេតុអ្វី?<br>៤. តើការមានកិច្ចសន្យាលាយលក្ខណ៍អក្សរ នៅក្នុងចំណោម សមាជិកក្រុម ផ្តល់នូវប្រយោជន៍អ្វីខ្លះ?<br>៥. តើអ្វីខ្លះជាទិដ្ឋភាពអវិជ្ជមាននៃការមានកិច្ចសន្យាលាយលក្ខណ៍អក្សរ?<br>៦. តើមានអត្ថប្រយោជន៍ដែរឬទេ ចំពោះការចុះទៅជួបពិភាក្សាជាមួយ អ្នកលក់ ឬអ្នកទិញ អំពីល័ក្ខខ័ណ្ឌនៃកិច្ចសន្យា? ហេតុអ្វី?<br>សូមឱ្យប្រធានក្រុមធ្វើការចែករំលែកគំនិតរបស់ពួកគេ ជាមួយក្រុមធំ។ | <br>លំហាត់ ៩.១៖ និយមន័យនៃ កិច្ចសន្យា<br><br>លំហាត់ ៩.២៖ កម្រងសំនួរអំពី កិច្ចសន្យា |

| | | |
|---|---|---|
| | រាយការណ៍អំពីវិវាទនានាដែលអាចកើតមាន ។<br>១២. **ការរៀបចំធានារ៉ាប់រង៖** រៀបចំធានាទៅលើផលិតផលពីហានិភ័យមួយចំនួន ដូចជាអគ្គិភ័យ ទឹកជំនន់ គ្រោះរាំងស្ងួត ការខូចខាតនៅក្នុងការដឹកជញ្ជូន។<br>១៣. **ទោសប្បញ្ញត្តិ៖** ក្នុងករណីដែលមិនអនុវត្តទៅតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា។ | |
| ៣ | បែងចែកសិក្ខាកាមឱ្យធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ និង សូមឱ្យពួកគេធ្វើកិច្ចសន្យាសាមញ្ញមួយ ដោយប្រើប្រាស់ព័ត៌មានខាងលើ ។ សូមឱ្យពួកគេបំពេញនៅក្នុងចន្លោះទទេ ក្នុងលំហាត់ ៩.៤ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរធ្វើការគូសបញ្ជាក់ថា វាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបញ្ចូលនូវរាល់ទិដ្ឋភាពទាំងអស់ខាងលើ នៅពេលរៀបចំសេចក្តីព្រាង កិច្ចសន្យាជាមួយនឹងល័ក្ខខ័ណ្ឌនានាដែលក្រុមចង់បាន ។<br><br>សូមឱ្យប្រធានក្រុមដែលត្រូវបានជ្រើសរើស រាយការណ៍អំពីគំនិតរបស់ពួកគេ និងលើកទឹកចិត្តឱ្យមានការពិភាក្សា។<br><br>ចូរសង្ខេបគំនិតរបស់ក្រុមទៅក្នុងសេចក្តីព្រាងកិច្ចសន្យាមួយ សម្រាប់ប្រើប្រាស់ដើម្បីធ្វើការចរចា ។ សូមឱ្យសិក្ខាកាមចម្លងគំនិតទាំងនោះ ទៅក្នុង លំហាត់ ៩.៤ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ៩.៤ ៖ ទម្រង់សេចក្តីព្រាងកិច្ចសន្យា |
| ៤ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួល គួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះគួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកានៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

៥. **ការអនុវត្តការធ្វើផលិតកម្ម៖** ចំណុចនេះ សំដៅចំពោះរបៀបផលិតផលិតផល ឧទាហរណ៍ការប្រើប្រាស់តែលាមកសត្វ ឬការធ្វើកសិកម្មបែបសរីរាង្គ ការមិនប្រើប្រាស់ប្រភេទថ្នាំសម្លាប់សត្វល្អិត និងការប្រើប្រាស់ពូជសុទ្ធ។

៦. **ការរៀបចំបញ្ជូនផលិតផល៖** តើគេគួរបញ្ជូនផលិតផល ទៅកន្លែងណា ពេលណា ដោយនរណា និង របៀបណា។ ឧទាហរណ៍ ទីកន្លែងជាក់លាក់ ពេលវេលា ទម្រង់នៃការដឹកជញ្ជូន ការវេចខ្ចប់ អ្នកដែលបង់ថ្លៃដឹកជញ្ជូន ។ ផលិតផលដែលងាយខូច ដូចជាផ្លែឈើ និងបន្លែ អាចត្រូវការការវេចខ្ចប់សមស្រប ការរក្សាទុក និងល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូនពិសេស។

៧. **ការរៀបចំកំណត់តម្លៃ៖** តើគេនឹងផ្តល់តម្លៃប៉ុន្មាន និងក្រោមល័ក្ខខ័ណ្ឌអ្វីខ្លះ? ឧទាហរណ៍ តម្លៃផ្អែកលើគុណភាព និងតម្លៃផ្អែកលើបរិមាណ។

៨. **នីតិវិធីនៃការទូទាត់ប្រាក់៖**
តើកសិករនឹងទទួលបានការទូទាត់ប្រាក់ពីអ្នកទិញ ដោយរបៀបណា និងនៅពេលណា? ឧទាហរណ៍ ការទូទាត់ជាសាច់ប្រាក់ជូនភ្លាមៗ បន្ទាប់ពីទទួលបានផលិតផល ការទូទាត់ប្រាក់ក្នុងរយៈពេលប៉ុន្មានថ្ងៃ ឬប៉ុន្មានខែក្រោយ ការទូទាត់ប្រាក់ដោយ មូលប្បទានប័ត្រ។

៩. **កិច្ចគាំទ្របច្ចេកទេស៖** សេវាផ្តល់ប្រឹក្សាយោបល់ និងមានកិច្ចគាំទ្រសម្រាប់ការជួសជុល និងថែទាំ ។ ឧទាហរណ៍ អាចរួមមានដូចជាខិត្តប័ណ្ណ ឬការចុះធ្វើទស្សនកិច្ចជាលក្ខណៈបុគ្គល ដើម្បីបង្ហាញអំពីរបៀបប្រើជី ឬថ្នាំសម្លាប់សត្វល្អិត ឬមានជាងដែលអាចជួសជុលគ្រឿងចក្រ ឬផ្តល់សេវាលើបញ្ហាបច្ចេកទេសដទៃទៀត ។

១០. **ការលើកទឹកចិត្តដទៃទៀត៖** នេះគឺជាប្រយោជន៍បន្ថែម ដែលអ្នកលក់ ឬអ្នកទិញអាចផ្តល់ជូនបាន ។ ឧទាហរណ៍ ការផ្តល់ម៉ូតូមួយគ្រឿងដោយឥតគិតថ្លៃ ប្រសិនបើអ្នកទិញជី លើសពី ១០០ តោន ឬការផ្តល់ឥណទានសម្រាប់សម្ភារៈកសិកម្ម។

១១. **ល័ក្ខខ័ណ្ឌនៃការដោះស្រាយវិវាទ៖**
នេះគឺជាវិន័យសម្រាប់ដោះស្រាយ ភាពមិនឯកភាពគ្នា រវាងកសិករ និងអ្នកទិញ។ គេគួរបញ្ចូលព័ត៌មានអំពីទីកន្លែងសម្រាប់

មួយនេះ។

សូមឱ្យសិក្ខាកាមរាយនាមអំពីចំណុចសំខាន់ៗ ដែលត្រូវបង្ហាញនៅក្នុងផែនការអាជីវកម្មសហគ្រាសជាក្រុម ។ ចូរណែនាំពួកគេអំពីចំណងជើងខាងក្រោម ដែលមានរាយនាម នៅក្នុងលំហាត់ ១០.២ នៃសៀវភៅលំហាត់របស់ពួកគេ។

១. ឈ្មោះក្រុមអាជីវកម្ម
២. ប្រភេទសហគ្រាស
៣. រយៈពេលដែលផែនការគ្របដណ្តប់
៤. ចំនួនមនុស្សដែលចូលរួម (បុរស/ស្ត្រី)
៥. បញ្ជីរាយនាមប្រធានក្រុម តួនាទីរបស់ពួកគេ និងលេខទូរស័ព្ទទំនាក់ទំនង
៦. ផ្ទៃដីរបស់ក្រុម
៧. ទស្សនវិស័យ និងគោលដៅរបស់ក្រុម
៨. ការសង្ខេបអំពីសំណើរបស់កសិករនីមួយៗ ឱ្យមានការផ្លាស់ប្តូរបច្ចេកទេស ក្រោយពេលភ្ជាប់ទំនាក់ទំនងជាមួយសេវាបច្ចេកទេសតាមរយៈ សាលាអាជីវកម្មកសិកម្ម
៩. ការប្រៀបធៀបថវិកាសហគ្រាស មុនពេលមានសាលាអាជីវកម្មកសិកម្ម និង "ការអនុវត្តដែលកសិករបានឯកភាព" ក្រោយពេលមានការបណ្តុះបណ្តាលសាលាអាជីវកម្មកសិកម្ម ដែលបានពិភាក្សាអំពីប្រយោជន៍ ដែលទទួលបានពីការភ្ជាប់ទំនាក់ទំនងជាមួយសេវាបច្ចេកទេស សកម្មភាពធ្វើទីផ្សារជាក្រុម និងសកម្មភាពទិញសម្ភារៈជាក្រុម
១០. ការសង្ខេបអំពីផែនការយុទ្ធសាស្ត្រធ្វើទីផ្សារជាក្រុម
១១. ការគ្រោងទុកទៅលើប្រាក់ចំណូលសរុប ថ្លៃចំណាយសរុប និងប្រាក់ចំណេញដែលទទួលបានពីការធ្វើសកម្មភាពទីផ្សារជាក្រុម
១២. ការសង្ខេបអំពីផែនការយុទ្ធសាស្ត្រក្នុងការទិញសម្ភារៈជាក្រុម



លំហាត់ ១០.២៖ ចំណងជើងសម្រាប់សរសេរផែនការអាជីវកម្មសហគ្រាសជាក្រុម

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី១០៖ ការរៀបចំផែនការអាជីវកម្មសហគ្រាសជាក្រុម



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងអាចរៀបចំយុទ្ធសាស្ត្រសម្រាប់ការផលិតជាក្រុម ការទិញសម្ភារៈ ការបន្ថែមតម្លៃ និងការធ្វើទីផ្សារជាក្រុមសម្រាប់ផលិតផលរបស់ពួកគេ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **សេចក្តីផ្តើម៖**<br>ស្វាគមន៍សិក្ខាកាម ដែលបានចូលរួមនៅក្នុងផ្នែកដែលមានសារៈសំខាន់យ៉ាងខ្លាំង នៃវគ្គសាលាអាជីវកម្មកសិកម្ម ។ ក្នុងអំឡុងពេលនៃវគ្គនេះ សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យធ្វើការសង្ខេបនូវរាល់យុទ្ធសាស្ត្ររបស់ពួកគេ និង ធ្វើការរៀបចំចវិការួមគ្នា ទៅក្នុងផែនការអាជីវកម្មសហគ្រាសជាក្រុម។<br>សូមសួរទៅកាន់សិក្ខាកាមថា ហេតុអ្វីបានជាវាមានសារៈប្រយោជន៍ក្នុងការដែលត្រូវមាន ផែនការអាជីវកម្មមួយ ?<br>ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br>ឧទាហរណ៍មួយចំនួនអាចមានដូចជា៖ ផែនការសង្ខេបនូវរាល់សកម្មភាព និងចវិការបស់ក្រុមទៅក្នុងឯកសារត្រឹមតែ ២-៣ទំព័រ ដើម្បីមើលឃើញអំពីអ្វីដែលក្រុមគ្រោងធ្វើក្នុងរយៈពេល១ឆ្នាំដូចជា ៖ ដើម្បីដឹងអំពីប្រាក់ចំណេញដែលក្រុមគ្រោងសម្រេចឱ្យបាន ដើម្បីរៀបចំជារបាយការណ៍ឱ្យបានច្បាស់លាស់ជូនដល់អាជ្ញាធរ និងអង្គការដទៃទៀតអំពីសកម្មភាពអាជីវកម្មដែលក្រុមគ្រោងនឹងធ្វើ ដើម្បីឱ្យអាចបង្ហាញជូនដល់អ្នកផ្តល់ប្រាក់កម្ចី ថាតើក្រុមនឹងទទួលបានប្រាក់ចំណេញច្រើនដល់កម្រិតណា ហើយធនាគារប្រហែលជានឹងអាចឱ្យពួកគេខ្ចីប្រាក់មួយចំនួន។<br>សូមឱ្យសិក្ខាកាមចម្លងបញ្ជីរាយនាមចុងក្រោយ ទៅក្នុងលំហាត់ ១០.១ នៃសៀវភៅលំហាត់របស់ពួកគេ។ | <br>លំហាត់ ១០.១៖ គោលបំណងនៃផែនការអាជីវកម្មសហគ្រាសជាក្រុម |
| ២ | **ទម្រង់សម្រាប់ផែនការអាជីវកម្មសហគ្រាសជាក្រុម៖**<br>**សម្គាល់៖**<br>អ្នកសម្របសម្រួលគួរសរសេរសេចក្តីព្រាងផែនការអាជីវកម្មសហគ្រាសជាក្រុមមួយ មុនពេលចាប់ផ្តើមវគ្គនេះ ដើម្បីឱ្យពួកគេកាន់តែមានភាពងាយស្រួល ក្នុងការណែនាំសិក្ខាកាមឱ្យសរសេរឯកសារដ៏មានសារៈប្រយោជន៍ | |

| | | |
|---|---|---|
| | ថវិកាជូនដល់ក្រុមពីអ្នកផ្តល់ប្រាក់កម្ចីណាមួយដែរឬទេ?<br>ចូរធ្វើការត្រួតពិនិត្យឡើងវិញទៅលើការសិក្សាស្រាវជ្រាវកាលពីមុន អំពីប្រភពថវិកា នៅក្នុងមេរៀនទី៥។ ចូរប្រាប់សិក្ខាកាមថា ការទៅជួបពិភាក្សាជាមួយស្ថាប័នហិរញ្ញវត្ថុជាក្រុម អាចទទួលបានជោគជ័យច្រើនជាងការទៅជួបពួកគេក្នុងលក្ខណៈជាបុគ្គល ជាពិសេស ប្រសិនបើពួកគេអាចបង្ហាញធនាគារអំពីផែនការអាជីវកម្មរបស់ពួកគេ។ | ល័ក្ខខ័ណ្ឌតម្រូវ ផ្នែកថវិកា<br><br>មេរៀនទី៥ ប្រភពថវិកា |
| ៤ | **ការរៀបចំបង្កើតផែនការសកម្មភាពក្រុម៖**<br>ចូរប្រាប់សិក្ខាកាមថា ឥឡូវនេះ យុទ្ធសាស្ត្រក្រុម និងផែនការអាជីវកម្មរបស់ពួកគេ ត្រូវបានរៀបចំរួចរាល់ហើយ ដូច្នេះ នឹងមានភារកិច្ចជាច្រើនដែលពួកគេត្រូវធ្វើដើម្បីអនុវត្តផែនការរបស់ពួកគេ។<br>សូមឱ្យសិក្ខាកាមពិនិត្យមើលទម្រង់សម្រាប់ "ការរៀបចំផែនការសកម្មភាព" នៅក្នុងលំហាត់ ១០.៥ នៃសៀវភៅលំហាត់របស់ពួកគេ និងពន្យល់ថា ទម្រង់នេះ នឹងអនុញ្ញាតឱ្យពួកគេសរសេររាយនាមអំពី តើសកម្មភាពក្រុមនឹងត្រូវអនុវត្តអ្វីខ្លះ នៅពេលណា នៅកន្លែងណា និង ដោយនរណា។<br>ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយសិក្ខាកាម អំពីភារកិច្ចជាក់លាក់ដែលត្រូវធ្វើដើម្បីអនុវត្តផែនការរបស់ពួកគេ។<br>ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក ក្នុងទម្រង់មួយដែលស្រដៀងគ្នាទៅនឹងលំហាត់ ១០.៥។<br>ក្នុងករណីចាំបាច់ ចូរបន្ថែមសកម្មភាពខាងក្រោមនេះ នៅពីក្រោមចំណងជើងនីមួយៗ៖<br>**ផែនការធ្វើទីផ្សារជាក្រុម៖**<br>➢ រៀបចំការប្រមូលផលិតផល<br>➢ វាយតម្លៃថា អ្វីៗត្រូវបានធ្វើឡើងស្របទៅតាមល័ក្ខខ័ណ្ឌគុណភាព និង ល័ក្ខខ័ណ្ឌនិយ័តកម្ម<br>➢ បញ្ជាក់អំពីទីផ្សារ និង កិច្ចសន្យា<br>➢ បញ្ជាក់អំពីទម្រង់នៃការដឹកជញ្ជូនផ្សេងៗគ្នា | <br>លំហាត់ ១០.៥៖ ការរៀបចំបង្កើតផែនការសកម្មភាពក្រុម |

| | | |
|---|---|---|
| | ១៣. ការគ្រោងទុកទៅលើប្រាក់ចំណូលសរុប ថ្លៃចំណាយសរុប និង ប្រាក់ចំណេញដែលទទួលបានពីសកម្មភាពទិញសម្ភារៈកសិកម្មជាក្រុម<br>១៤. ការសង្ខេបអំពីផែនការយុទ្ធសាស្ត្រនៃបន្ថែមតម្លៃជាក្រុម<br>១៥. ការគ្រោងទុកទៅលើប្រាក់ចំណូលសរុប ថ្លៃចំណាយសរុប និង ប្រាក់ចំណេញ ដែលទទួលបានពីសកម្មភាពបន្ថែមតម្លៃជាក្រុម<br>១៦. រាយនាមបុគ្គល/ក្រុមហ៊ុន ដែលក្រុមបានចុះកិច្ចសន្យាជាមួយ<br>១៧. លំហូរសាច់ប្រាក់ និង ថវិកាដែលបង្ហាញអំពីប្រាក់ចំណូល និង ចំណាយសរុប ប្រាក់ចំណេញ/ការខាតបង់ ក្នុងមួយខែ និង សរុបក្នុងមួយឆ្នាំ ដែលទទួលបានពីការធ្វើសកម្មភាពនីមួយៗជាក្រុម (ការធ្វើទីផ្សារ ការទិញសម្ភារៈ ការបន្ថែមតម្លៃ)<br><br>សូមឱ្យសិក្ខាកាមធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ ដើម្បីសរសេរអំពីផែនការអាជីវកម្មសហគ្រាសជាក្រុមរបស់ពួកគេ ក្រោមលំហាត់ ១០.៣ ។ ចូរប្រាប់ពួកគេ ឱ្យប្រើប្រាស់ឯកសារយោងរបស់លំហាត់នេះ (តារាង និង សេចក្ដីពណ៌នាលាយលក្ខណ៍អក្សរ) ដើម្បីណែនាំពួកគេក្នុងការស្វែងរកព័ត៌មានសំខាន់ៗ ដែលពួកគេត្រូវការសម្រាប់សរសេរនៅខាងក្រោមសំនួរនីមួយៗ។ ដើម្បីសន្សំពេលវេលា ចូរបែងចែកពីរ ឬបីចំណុចផ្សេងៗគ្នា ដើម្បីឱ្យអនុក្រុមនីមួយៗបំពេញ ។<br><br>សូមឱ្យអនុក្រុមរាយការណ៍អំពីចម្លើយរបស់ពួកគេទៅកាន់ក្រុមធំ ដើម្បីពិភាក្សា និង ស្វែងរកការឯកភាព ។ ចូរសរសេរចម្លើយដែលបានឯកភាពគ្នានៅលើផ្ទាំងក្រដាសធំមួយសន្លឹក ដើម្បីឱ្យសិក្ខាកាមចម្លងតាមក្រោយ ។ | <br>លំហាត់ ១០.៣៖<br>ធ្វើផែនការអាជីវកម្ម<br>សហគ្រាសជាក្រុម<br>ផ្ទាល់ខ្លួនរបស់អ្នក |
| ៣ | **លក្ខខ័ណ្ឌតម្រូវ និង ប្រភពថវិកាសម្រាប់ផែនការអាជីវកម្មសហគ្រាសជាក្រុម៖**<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលលក្ខខ័ណ្ឌតម្រូវនៃការផ្ដល់ថវិកាជូនដល់ក្រុម ដោយឆ្លើយទៅនឹងសំនួរនៅក្នុងលំហាត់ ១០.៤ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>ចូរសួរសំនួរទៅកាន់សមាជិកក្រុម ថាតើពួកគេមានប្រាក់គ្រប់គ្រាន់ដែរឬទេ សម្រាប់ផ្គត់ផ្គង់ដល់ការធ្វើសហគ្រាសជាក្រុម ។ ប្រសិនបើពួកគេពុំមានប្រាក់គ្រប់គ្រាន់ទេនោះ តើគេមានលទ្ធភាពក្នុងការទទួលបានការផ្គត់ផ្គង់ | <br>លំហាត់ ១០.៤៖ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | ពួកគេបានរៀបរាប់នៅក្នុងទស្សនវិស័យ និងគោលដៅរបស់ពួកគេ ដែលគេអាចធ្វើការវាស់ស្ទង់បាន ដើម្បីវាស់វែងអំពីការរីកចម្រើន ។ ឧទាហរណ៍មួយចំនួនដែលរួមមាន ៖ ការបង្កើនប្រាក់ចំណេញដល់ក្រុម បង្កើនការបែងចែកភាគលាភជូនដល់សមាជិកដែលជាម្ចាស់ភាគហ៊ុន, ដើម្បីបង្កើនតម្លៃផលិតផល ដើម្បីធ្វើឱ្យតម្លៃសម្ភារៈកសិកម្មទាបជាងមុនសម្រាប់សមាជិកក្រុម ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយតួអង្គនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឱ្យបានកាន់តែច្រើន ។ លទ្ធផលសំខាន់ៗទាំងនេះ អាចត្រូវបានគេយកមកសរសេរថាជាសូចនាករ ដោយធ្វើការកត់សម្គាល់ទៅលើការប្រែប្រួលចំពោះប្រាក់ចំណេញរបស់ក្រុម ការបែងចែកភាគលាភ តម្លៃ-ផលិតផល តម្លៃសម្ភារៈ ការផ្សាភ្ជាប់ទំនាក់ទំនងខ្សែសង្វាក់ផ្គត់ផ្គង់ជាបន្តបន្ទាប់ ។ ឧទាហរណ៍ លទ្ធផលទាំងនេះ អាចឡើងចុះ ឬ ស្ថិតនៅកម្រិតដដែល ។<br><br>សូមឱ្យអនុក្រុមលើកឡើងនូវគំនិតនានា សម្រាប់ពិភាក្សានៅក្នុងក្រុមធំ ។ បញ្ចូលការសង្ខេបគំនិតរបស់ពួកគេនៅក្នុងតារាង ដែលបានរៀបចំនៅលើផ្ទាំងក្រដាសធំមួយសន្លឹក ក្នុងទម្រង់មួយដែលស្រដៀងគ្នាទៅនឹងតារាងនៅក្នុងលំហាត់ ១០.៦ នៃសៀវភៅលំហាត់។<br><br>បន្ទាប់មក ចូរសូមឱ្យសិក្ខាកាមបំពេញនៅក្នុងគោលដៅផែនការអាជីវកម្មកសិកម្មជាក្រុមរបស់ពួកគេ ដែលទាក់ទងទៅនឹងសូចនាករទាំងនេះក្នុងគូឡោនទី២ ។<br><br>ចូរនិយាយថា នៅចុងបញ្ចប់នៃរយៈពេលផែនការនេះ ពួកគេអាចបំពេញសមិទ្ធិផលជាក់ស្តែងរបស់ពួកគេ នៅក្នុងគូឡោនទី៣ ។ នៅពេលនោះ ពួកគេអាចមើលឃើញ ថាតើពួកគេសម្រេចបាននូវគោលដៅរបស់ពួកគេដែរឬអត់ ។ | |
| ៦ | ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេបានចម្លងផែនការអាជីវកម្មកសិកម្ម ផែនការថវិកា និងលំហូរសាច់ប្រាក់ ព្រមទាំងផែនការសកម្មភាពរបស់ពួកគេដែលបានសម្រេចចុងក្រោយ ទៅក្នុងសៀវភៅលំហាត់របស់ពួកគេ រួចរាល់ហើយឬនៅ ។ ប្រសិនបើពួកគេបានចម្លងរួចរាល់ហើយ ចូរសូមឱ្យពួកគេចុះហត្ថលេខាព្រមព្រៀងទៅលើផែនការទាំងនេះ ។ ប្រធានក្រុម និងអនុប្រធាន គួរត្រួតពិនិត្យ និងជម្រុញអោយសមាជិកនីមួយៗចុះហត្ថលេខាលើផែនការអាជីវកម្មរបស់ពួកគេ ដើម្បីបញ្ជាក់ទៅលើការព្រមព្រៀង។ | |

| | | |
|---|---|---|
| | ➢ បញ្ជាក់អំពីពេលវេលានៃការផ្តល់ផលិតផល<br>➢ រៀបចំលំហូរថវិកាចេញ-ចូល<br><br>**ការទិញសម្ភារៈជាក្រុម៖**<br>➢ គណនាអំពីសេចក្តីត្រូវការសម្ភារៈ<br>➢ ធ្វើការបញ្ជាក់ជាមួយអ្នកផ្គត់ផ្គង់ និងតម្លៃវត្ថុនីមួយៗ<br>➢ រៀបចំហិរញ្ញវត្ថុសម្រាប់ទិញសម្ភារៈ<br>➢ ចេញការបញ្ជាទិញសម្ភារៈពីអ្នកផ្គត់ផ្គង់<br>➢ រៀបចំមធ្យោបាយដឹកជញ្ជូនដើម្បីប្រមូល និងផ្តល់សម្ភារៈ<br>➢ រៀបចំលំហូរថវិកាចេញ-ចូល<br><br>**ការបន្ថែមតម្លៃជាក្រុម៖**<br>➢ ប្រមូលផលិតផលដើម?<br>➢ បំពេញការងារដើម្បីបន្ថែមតម្លៃ?<br>➢ ធ្វើទីផ្សារសម្រាប់ផលិតផល ឬ សេវាកម្មដែលបានបន្ថែមតម្លៃ?<br><br>**សម្រាប់កម្លាំងពលកម្ម៖**<br>➢ ពិនិត្យទៅលើពេលវេលាដែលសមាជិកក្រុមទំនេរ<br>➢ កំណត់រកសេចក្តីត្រូវការជួលកម្លាំងពលកម្ម និង កម្លាំងពលកម្មដែលមាន<br>➢ ផ្តល់ការបណ្តុះបណ្តាលជូនដល់កម្លាំងពលកម្ម ដើម្បីឱ្យស្របទៅតាមល័ក្ខខ័ណ្ឌជំនាញដែលត្រូវការ<br><br>លើកទឹកចិត្តឱ្យមានការពិភាក្សា និងស្វែងរកការឯកភាពជារួមនៅក្នុងក្រុម ដើម្បីធ្វើផែនការសកម្មភាពមួយ។<br><br>សូមឱ្យសិក្ខាកាមចម្លងខ្លឹមសារនៅក្នុងផ្ទាំងក្រដាស ទៅក្នុងទម្រង់ផែនការសកម្មភាពក្រុម ក្រោមលំហាត់ ១០.៥ នៃសៀវភៅលំហាត់របស់ពួកគេ។ | |
| ៥ | **ការវាយតម្លៃសូចនាករ៖**<br><br>សូមឱ្យសិក្ខាកាមគិតអំពីរបៀបដែលពួកគេនឹងធ្វើការវាស់ស្ទង់ ទៅលើភាពជោគជ័យ ឬ បរាជ័យរបស់សហគ្រាសអាជីវកម្មរបស់ពួកគេ ។<br><br>ចូរពន្យល់ថា សូចនាករគឺជាសញ្ញាដើម្បីបង្ហាញថា តើសិក្ខាកាមសម្រេចបាននូវគោលដៅ និងទស្សនវិស័យរបស់ពួកគេដែរឬទេ ។ សូមឱ្យសិក្ខាកាមធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ ដើម្បីគិតអំពីលទ្ធផលសំខាន់ៗ ដែល | <br>លំហាត់ ១០.៦៖ តារាងសូចនាករវាយតម្លៃ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី១១ ៖ ការរក្សាកំណត់ត្រា



**គោលបំណង**

ដើម្បីបង្កលក្ខណៈឱ្យសិក្ខាកាមផ្តល់តម្លៃ និងយល់អំពីសារៈសំខាន់នៃការរក្សាកំណត់ត្រានៃការធ្វើកសិកម្មឱ្យបានត្រឹមត្រូវ ព្រមទាំងដឹងអំពីវិធីប្រើប្រាស់កំណត់ត្រាទាំងនេះឱ្យបានសមស្រប ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ទិដ្ឋភាពទូទៅនៃការរក្សាកំណត់ត្រា៖**<br><br>ចូរបែងចែកសិក្ខាកាមឱ្យធ្វើការងារជាគូ ដើម្បីសាកសួរគ្នាទៅវិញទៅមកអំពីសំនួរខាងក្រោម ដែលមានសរសេរនៅលើផ្ទាំងក្រដាសធំមួយសន្លឹកដែលបានរៀបចំទុកជាមុន៖<br><br>តើកាលពីឆ្នាំមុន អ្នកផលិតប្រភេទកសិផលនីមួយៗរបស់អ្នកបានច្រើនប៉ុណ្ណា ? តើអ្នកទទួលបានតម្លៃពិតប្រាកដចំនួនប៉ុន្មាន សម្រាប់ការលក់ផលិតផលរបស់អ្នក ? តើអ្នកប្រើប្រាស់សម្ភារៈកសិកម្មអស់ចំនួនប៉ុន្មាន និងតើសម្ភារៈទាំងនោះមានតម្លៃប៉ុន្មាន ? តើកាលពីឆ្នាំមុន អ្នកទទួលបានប្រាក់ចំណេញ/ខាតបង់ចំនួនប៉ុន្មាន? តើអ្នកត្រូវចំណាយប្រាក់ចំនួនប៉ុន្មាន ក្នុងខែនីមួយៗសម្រាប់សហគ្រាសកសិដ្ឋាន ឬ ស្រែចម្ការរបស់អ្នក ? តើអ្នកមានបំណងចង់ធ្វើការផ្លាស់ប្តូរអ្វីខ្លះ ដើម្បី ធ្វើឱ្យអាជីវកម្មរបស់អ្នកមានភាពប្រសើរជាងនេះនៅឆ្នាំក្រោយ ?<br><br>១០នាទីក្រោយមក ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេមានបញ្ហាក្នុងការឆ្លើយទៅនឹងសំនួរណាមួយដែរឬទេ ។ ប្រសិនបើមាន ចូរសួរទៅកាន់ពួកគេថាតើពួកគេត្រូវធ្វើអ្វី ដើម្បីឆ្លើយសំនួរឱ្យបានកាន់តែងាយស្រួល និងត្រឹមត្រូវ ។ ចូរណែនាំសិក្ខាកាមអំពីសារៈសំខាន់នៃការធ្វើកំណត់ត្រា ដើម្បីជួយដល់ពួកគេក្នុងការគ្រប់គ្រងអាជីវកកម្ម ។<br><br>➢ ចូរសូមឱ្យសិក្ខាកាមធ្វើការពិណ៌នាថា តើកំណត់ត្រាគឺជាអ្វី។<br>➢ បន្ទាប់មក ចូរសូមឱ្យពួកគេផ្តល់ឧទាហរណ៍អំពីកំណត់ត្រាផ្សេងៗគ្នាដែលពួកគេស្គាល់។<br>➢ សូមឱ្យសិក្ខាកាមពិនិត្យមើលនិយមន័យនៃពាក្យថា កំណត់ត្រា និង | ផ្ទាំងក្រដាសធំដែលត្រូវបានរៀបចំទុកជាមុនជាមួយនឹងសំនួរណែនាំ<br><br><br><br>លំហាត់ ១១.១ ៖ និយមន័យនៃកំណត់ត្រា |

| | | |
|---|---|---|
| ៧ | ចូរបញ្ចប់កិច្ចប្រជុំ ដោយធ្វើការគូសបញ្ជាក់ថា ឥឡូវនេះសិក្ខាកាមមាន "ការងារជាច្រើនដែលត្រូវធ្វើ" ជាលក្ខណៈបុគ្គល និងជាក្រុម ។ ចូររំលឹកពួកគេថា ពួកគេត្រូវជួបពិភាក្សាជាមួយគ្រួសាររបស់ពួកគេ អំពីផែនការសកម្មភាពបុគ្គល និង ផែនការសកម្មភាពក្រុមរបស់ពួកគេ ដើម្បីបញ្ជាក់អំពីទំហំនៃការផលិត ការទិញសម្ភារៈកសិកម្ម ការរួមចំណែកកម្លាំងពលកម្ម និងការរួមចំណែកចាំបាច់ដទៃទៀត ដើម្បីធ្វើឱ្យផែនការទទួលបានជោគជ័យ ។ ចូរនិយាយថា ពួកគេគួរខិតខំអនុវត្តតាមផែនការ ក្នុងអំឡុងពេលនៃដំណាក់កាលអនុវត្ត ។ នៅពេលដែលពួកគេមានអារម្មណ៍ថា ពួកគេត្រូវការពិភាក្សាអំពីអ្វីម៉្យាងពួកគេគួរទាក់ទងប្រធានក្រុមអាជីវកម្មកសិកម្មរបស់ពួកគេ ឬសមាជិកក្រុមដទៃទៀត ។ | |
| ៨ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គ សាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និង មាតិកា នៃវគ្គ សាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | ចូរនិយាយថា នៅចំណុចបន្តបន្ទាប់នៃវគ្គនេះ អ្នកនឹងខិតខំផ្តល់ការណែនាំជូនដល់ពួកគេ ឱ្យរៀនសូត្រអំពីប្រព័ន្ធកំណត់ត្រាសាមញ្ញ និងច្បាស់លាស់មួយ ដែលនឹងមានសារៈប្រយោជន៍សម្រាប់ពួកគេ ក្នុងលក្ខណៈជាបុគ្គលក៏ដូចជាសម្រាប់ក្រុមទាំងមូល ដើម្បីរក្សាកំណត់ត្រាទាំងនោះ ។ | |
| ៤ | **ប្រភេទកំណត់ត្រាអាជីវកម្ម៖**<br>ចូរប្រាប់សិក្ខាកាមថា នៅក្នុងវគ្គនេះ អ្នកនឹងផ្តោតយកចិត្តទុកដាក់ទៅលើរបៀបសរសេរកំណត់ត្រា ដែលមានបញ្ជាក់នៅក្នុងលំហាត់ ១១.៣។<br>ចូរបែងចែកសិក្ខាកាមឱ្យធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ និង សួរអំពីប្រភេទកំណត់ត្រាដែលពួកគេគិតថា ចាំបាច់សម្រាប់ក្រុមអាជីវកម្មសរបស់ពួកគេ ។ ចូរសរសេរគំនិតទាំងនេះនៅលើក្តារខៀន ។<br>ឥឡូវនេះ ចូរពិនិត្យមើលបញ្ជីរាយនាមកំណត់ត្រាខាងក្រោម នៅក្នុងលំហាត់១១.៣ ។<br>១. កំណត់ត្រាអំពីការផលិត<br>២. កំណត់ត្រាអំពីប្រាក់ចំណូល<br>៣. កំណត់ត្រាអំពីថ្លៃចំណាយ<br>៤. កំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់)<br>៥. កំណត់ត្រាអំពីលំហូរសាច់ប្រាក់<br>៦. កំណត់ត្រាអំពីទ្រព្យសម្បត្តិ/បំណុល<br>ចូររៀបរាប់អំពីកំណត់ត្រានីមួយៗទាំងនេះដោយសង្ខេប ។ គំនិតភាគច្រើនរបស់សិក្ខាកាមអំពីកំណត់ត្រា គួរបញ្ចូលឧទាហរណ៍ទាំងនេះ ។<br>ចូរប្រាប់សិក្ខាកាមថា ឥឡូវនេះ យើងនឹងពិនិត្យមើលកំណត់ត្រាទាំងនេះឱ្យបានលម្អិត ដើម្បីឱ្យដឹងថា តើយើងនឹងត្រូវបំពេញកំណត់ត្រាទាំងនោះដោយរបៀបណា ។ | <br>លំហាត់ ១១.៣៖<br>ប្រភេទកំណត់ត្រាសម្រាប់កសិដ្ឋាន ឬ ស្រែចម្ការ និងកំណត់ត្រាអាជីវកម្ម |
| ៥ | **ចូរផ្តល់សៀវភៅកំណត់ត្រាមួយ ជូនដល់សិក្ខាកាម៖**<br>មុនពេលកិច្ចប្រជុំនេះ ចូរទិញសៀវភៅកំណត់ត្រាមួយក្បាល សម្រាប់ | |

| | | |
|---|---|---|
| | ឧទាហរណ៍នៅក្នុងលំហាត់ ១១.១ នៃសៀវភៅលំហាត់របស់ពួកគេ ។ ចូរបន្ថែមចម្លើយរបស់ពួកគេទៅក្នុងបញ្ជីរាយនាម ប្រសិនបើចំណុច ទាំងនោះ មិនទាន់ត្រូវបានរៀបរាប់នៅឡើយ ។ | |
| ២ | **កំណត់ត្រាអាចជួយបង្ការការឈ្លោះប្រកែកគ្នានៅក្នុងគ្រួសារ៖**<br><br>ចូរធ្វើការរៀបចំទុកជាមុនឱ្យមានអ្នកស្ម័គ្រចិត្តចំនួន២នាក់ ឱ្យធ្វើការសម្តែងតួអង្គមួយ ។ សូមឱ្យសិក្ខាកាមពិនិត្យមើលលំហាត់ ១១.២ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ ។<br><br>**សម្គាល់៖** ចូរផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ជូនដល់អ្នកស្ម័គ្រចិត្ត ដើម្បីឱ្យពួកគេពិនិត្យមើលអត្ថបទសម្រាប់ការសម្តែង និងធ្វើកាសម្តែង ។ បន្ទាប់មក ចូរសួរទៅកាន់សិក្ខាកាម ៖<br>តើមានរឿងអ្វីកើតឡើងនៅក្នុងការសម្តែងតួអង្គនេះ?<br>១. ហេតុអ្វីបានជាកូណាជឿថា ប្រពន្ធរបស់គាត់ប្រើប្រាស់ប្រាក់មិនបានត្រឹមត្រូវ?<br>២. តើជម្លោះដែលមានលក្ខណៈស្រដៀងគ្នានេះ អាចកើតឡើងនៅក្នុងគ្រួសាររបស់ពួកគេ និង នៅក្នុងក្រុមសហគ្រាសមួយដែរឬទេ?<br>៣. តើអ្វីទៅដែលអាចជួយដោះស្រាយបញ្ហានេះបាន?<br><br>ចូរភ្ជាប់ចម្លើយរបស់ពួកគេទៅនឹងសេចក្តីត្រូវការ ក្នុងការរក្សាកំណត់ត្រាឱ្យបានត្រឹមត្រូវ ដើម្បីជាភស្តុតាងបញ្ជាក់អំពីការចំណាយប្រាក់ និងការសន្សំប្រាក់។ | <br>លំហាត់ ១១.២៖<br>ការសម្តែងតួអង្គអំពីការរក្សាកំណត់ត្រា |
| ៣ | **ហេតុអ្វីបានជាកសិករមិនរក្សាកំណត់ត្រា?**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា ហេតុអ្វីបានជាកសិករមួយចំនួនមិនរក្សាកំណត់ត្រា ។ គេអាចផ្តល់ការពន្យល់មួយចំនួនដូចខាងក្រោម៖<br>➢ សិក្ខាកាមមិនដឹងអំពីសារៈសំខាន់នៃកំណត់ត្រា<br>➢ ពួកគេមិនដឹងអំពីរបៀបរៀបចំកំណត់ត្រា<br>➢ ពួកគេពិបាកយល់អំពីការធ្វើកំណត់ត្រា<br>➢ ពួកគេពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំកំណត់ត្រា<br><br>ចូរសួរទៅកាន់កសិករថា តើគេអាចដោះស្រាយការលំបាកទាំងនេះបានដោយរបៀបណា? | |

ការរៀបកំណត់ត្រា

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | សូមឱ្យសិក្ខាកាមបំពេញនូវឧទាហរណ៍ផ្ទាល់ខ្លួនរបស់ពួកគេមួយចំនួន ទៅក្នុងតារាងអំពីការផលិត ដើម្បីបង្ហាញថា ពួកគេដឹងអំពីវិធីបំពេញតារាង ។<br><br>ចូរផ្តល់ឱ្យសិក្ខាកាមនីមួយៗនូវសៀវភៅកំណត់ត្រាទទេមួយក្បាល ។ សូមឱ្យពួកគេសរសេរឈ្មោះអាជីវកម្ម ដែលពួកគេបានជ្រើសរើស (ឧទាហរណ៍ "ស្រូវ") ។ ចូរប្រាប់ពួកគេថា វាជាការល្អដែលត្រូវមាន<u>សៀវភៅមួយក្បាលសម្រាប់កំណត់ត្រាសហគ្រាសនីមួយៗ</u> ។ ការធ្វើបែបនេះ នាំឱ្យព័ត៌មានពុំមានភាពឡូកឡំគ្នាជាមួយសហគ្រាសដទៃទៀត ដែលនាំឱ្យមានការពិបាកក្នុងការតាមដាន។<br><br>សូមឱ្យសិក្ខាកាមបើកទំព័រទី១ នៃសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ និងគូសចំនួនគូឡោនដូចគ្នា (៦គូឡោន) ដូចនៅក្នុងទម្រង់កំណត់ត្រាអំពីការផលិត។ បន្ទាប់មក ចូរសូមឱ្យពួកគេចម្លងចំណងជើងនៅក្នុងតារាងអំពីការផលិតដូចគ្នានោះ ទៅក្នុងសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ ។ ឥឡូវនេះ ពួកគេមានតារាងកំណត់ត្រាអំពីការផលិតផ្ទាល់ខ្លួនរបស់ពួកគេហើយ ។ | |
| ៧ | **កំណត់ត្រាអំពីប្រាក់ចំណូល៖**<br><br>ចូរចាប់ផ្តើមការពិភាក្សាអំពីការប្រើប្រាស់កំណត់ត្រាអំពីប្រាក់ចំណូល ។<br><br>ចូរសួរទៅកាន់សិក្ខាកាម ថាហេតុអ្វីបានជាពួកគេត្រូវមានកំណត់ត្រាអំពីប្រាក់ចំណូល ។ ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក ។<br><br>ចូររៀបរាប់ថា វាមានសារៈសំខាន់ខ្លាំងណាស់ដែលយើងត្រូវដឹងអំពីចំនួនទឹកប្រាក់ដែលហូរចូល ដើម្បីឱ្យពួកគេអាចដឹងអំពីចំនួនទឹកប្រាក់ដែលពួកគេអាចចំណាយទៅលើជីវភាពរស់នៅ និងថ្លៃចំណាយអាជីវកម្ម ។ ការដឹងអំពីប្រាក់ចំណូល ក៏ជួយដល់ពួកគេ ក្នុងការរៀបចំផែនការសម្រាប់ឆ្នាំបន្ទាប់ផងដែរ ។<br><br>សូមឱ្យសិក្ខាកាមចម្លងមូលហេតុសម្រាប់ការដែលត្រូវមានកំណត់ត្រាអំពីប្រាក់ចំណូល ទៅក្នុងលំហាត់ ១១.៥ នៃសៀវភៅលំហាត់របស់ពួកគេ ។ | <br>លំហាត់ ១១.៥៖ កំណត់ត្រាអំពីប្រាក់ចំណូល |

| | | |
|---|---|---|
| | សិក្ខាកាមនីមួយៗ ។ សៀវភៅកំណត់ត្រា គួរមានទំហំប្រមាណ ២៥សង់ទីម៉ែត្រ គុណនឹង ២០សង់ទីម៉ែត្រ និងមានចំនួនប្រមាណ ៥០ទំព័រ ។ សៀវភៅលំហាត់ដែលគេប្រើប្រាស់ទូទៅនៅតាមសាលារៀនមានលក្ខណៈល្អគ្រប់គ្រាន់ ដែលអាចយកមកប្រើប្រាស់បានផងដែរ ។ ចូរកាត់ក្បាលសៀវភៅខាងលើ ចំនួន១សង់ទីម៉ែត្រ ដើម្បីសរសេរចំណងជើងសម្រាប់ធ្វើការបែងចែកប្រភេទកំណត់ត្រាទាំង ៦ ដូចតទៅ៖ ១០% នៃចំនួនទំព័រសរុប គឺសម្រាប់កត់ត្រាអំពីការផលិត, ២០% នៃទំព័រសរុប គឺសម្រាប់កត់ត្រាអំពីប្រាក់ចំណូល, ៤០% នៃទំព័រសរុប គឺសម្រាប់កត់ត្រាអំពីថ្លៃចំណាយ និង ១០% សម្រាប់កត់ត្រានីមួយៗចំនួន៣ទៀត ។ | ទិញសៀវភៅកំណត់ត្រាសម្រាប់សិក្ខាកាមនីមួយៗ |
| ៦ | **កំណត់ត្រាអំពីការផលិត៖**<br>ចូរសួរទៅកាន់សិក្ខាកាមថា ហេតុអ្វីបានជាវាជាការល្អ ដែលគេត្រូវមានកំណត់ត្រាអំពីការផលិត ? ចូរសរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាសធំមួយសន្លឹក។<br><br>ចូរបន្ថែមគំនិតរបស់ពួកគេ ប្រសិនបើគំនិតទាំងនោះមិនទាន់មានរៀបរាប់នៅឡើយ ។ ចូរពន្យល់ពួកគេថា កំណត់ត្រានេះ បង្ហាញអំពីការផលិតជាក់ស្តែងនៅក្នុងផ្ទៃដីមួយឯកតា ។ កំណត់ត្រានេះ ជួយឱ្យកសិករយល់ថាតើពួកគេសម្រេចបាននូវគោលដៅផលិតដែលពួកគេបានគ្រោងទុកដែរឬទេ ។ កំណត់ត្រារបស់ពួកគេ ក៏អាចប្រើប្រាស់ដើម្បីធ្វើការប្រៀបធៀបអំពីផលិតភាពការងាររបស់កសិដ្ឋាន ឬស្រែចម្ការមួយ ជាមួយកសិដ្ឋាន ឬ ស្រែចម្ការដទៃទៀត ដើម្បីឱ្យឃើញថា តើកសិដ្ឋាន ឬ ស្រែចម្ការមួយណា ដែលមានលក្ខណៈប្រសើរបំផុត ។<br><br>ចូរផ្តល់មតិយោបល់ថា ប្រសិនបើសិក្ខាកាមមិនទទួលបានទិន្នផលល្អប្រសើរ នៅក្នុងកសិដ្ឋាន ឬ ស្រែចម្ការរបស់ពួកគេទេនោះ ពួកគេគួរសួរទៅកាន់ទីប្រឹក្សាបច្ចេកទេស ថាហេតុអ្វីបានជាដូច្នេះ និងខិតខំព្យាយាមដោះស្រាយបញ្ហាទាំងនោះ ដើម្បីឱ្យពួកគេអាចទទួលបានទិន្នផលល្អជាងនេះនៅរដូវកាលបន្ទាប់ ។<br><br>សូមឱ្យសិក្ខាកាមចម្លងមូលហេតុសម្រាប់ការដែលត្រូវមានកំណត់ត្រាអំពីការផលិត ទៅក្នុងលំហាត់ ១១.៤ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>ចូររៀបរាប់អំពីចំណងជើងនីមួយៗនៅក្នុងលំហាត់ ១១.៤ ដែលនិយាយអំពីតារាងកំណត់ត្រាអំពីការផលិត ។ | <br>លំហាត់ ១១.៤៖ កំណត់ត្រាអំពីការផលិត |

<table>
<tr>
<td>៨</td>
<td>កំណត់ត្រាអំពីថ្លៃចំណាយ (រាប់បញ្ចូលកម្លាំងពលកម្ម) ៖<br><br>ចូរសួរទៅកាន់សិក្ខាកាម ថាហេតុអ្វីបានជាពួកគេគួររក្សាកំណត់ត្រាអំពីថ្លៃចំណាយ ។ ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសមួយសន្លឹក ។<br><br>ចូរពន្យល់បន្ថែមថា កំណត់ត្រាអំពីថ្លៃចំណាយ មានសារៈសំខាន់ដោយសារតែកំណត់ត្រានេះ ប្រាប់ពួកគេអំពីចរន្តថវិការបស់ពួកគេ ថាតើថវិការបស់ពួកគេបានចេញទៅណា ឬ នឹងត្រូវចេញទៅប្រភពណា ។ ចូរនិយាយថា សិក្ខាកាមអាចធ្វើការវិភាគទៅលើថ្លៃចំណាយរបស់ពួកគេនៅចុងរដូវកាល ដើម្បីពិនិត្យមើលអំពីវិធីដែលពួកគេអាចកាត់បន្ថយថ្លៃចំណាយ និងបង្កើនប្រាក់ចំណេញ នៅពេលរៀបចំថវិកាសហគ្រាសសម្រាប់ជុំបន្ទាប់ នៃការរៀបចំផែនការ ។<br><br>សូមឱ្យសិក្ខាកាមចម្លងមូលហេតុ ចំពោះការដែលត្រូវមានកំណត់ត្រាអំពីថ្លៃចំណាយទៅក្នុងលំហាត់ ១១.៦ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលទម្រង់ "កំណត់ត្រាអំពីថ្លៃចំណាយ" នៅក្នុងលំហាត់ ១១.៦ នៃសៀវភៅលំហាត់របស់ពួកគេ។ ចូរពន្យល់អំពីទម្រង់នេះដូចខាងក្រោម ៖<br><br>១. ចូរកត់ត្រាកាលបរិច្ឆេទចំណាយថវិកា នៅក្នុងគូឡោនទី១។<br>២. នៅក្នុងគូឡោនទី២ ចូររៀបរាប់អំពីសម្ភារៈដែលបានទិញ ឬសេវាដែលបានទទួល រាប់បញ្ចូលទាំងសកម្មភាពពលកម្មនានាផងដែរ។<br>៣. នៅក្នុងគូឡោនទី៣ ចូរសរសេរអំពីគុណភាព ដោយមិនភ្លេចកត់ត្រាអំពីចំនួនឯកតា ដូចជា ចំនួនគីឡូក្រាម , ចំនួនបាវ , មាន់ចំនួនប៉ុន្មានក្បាល។ល។សម្រាប់កម្លាំងពលកម្ម ចូរកត់ត្រាចំនួនថ្ងៃដែលបុរស (ប) ធ្វើពលកម្ម និង ចំនួនថ្ងៃដែលស្ត្រី (ស) ធ្វើពលកម្ម ដើម្បីបង្ហាញអំពីទំហំការងារដែលបុរស និងស្ត្រីបានធ្វើ ។<br>៤. កត់ត្រាអំពីតម្លៃឯកតានៅក្នុងគូឡោនបន្ទាប់ ។<br>៥. បន្ទាប់មក ចូរធ្វើការគណនាថ្លៃចំណាយសរុប ដែលគេគួរយក</td>
<td><br>លំហាត់ ១១.៦៖<br>កំណត់ត្រាអំពីថ្លៃចំណាយ</td>
</tr>
</table>

សូមឱ្យសិក្ខាកាមបើកសៀវភៅលំហាត់របស់ពួកគេ ដើម្បីពិនិត្យមើលទម្រង់ "កំណត់ត្រាអំពីប្រាក់ចំណូល" ក្នុងលំហាត់១១.៥ ។ ចូរពន្យល់អំពីចំណុចខាងក្រោម ៖

១. ចំណងជើងទី១ "កាលបរិច្ឆេទ" ផ្តល់នូវកាលបរិច្ឆេទនៃការលក់ផលិតផល ។

២. បញ្ជាក់អំពីប្រភេទផលិតផល ក្រោមចំណងជើងទី២ "ផលិតផលដែលបានលក់/គុណភាព" ។

៣. ត្រូវបញ្ចូលចំនួនផលិតផលដែលបានលក់ នៅក្រោម "បរិមាណ" ។ សូមកុំភ្លេចបញ្ចូលចំនួនឯកតា ឧទាហរណ៍ដូចជា ចំនួនគីឡូក្រាម, លីត្រ, បាវ ។ល។

៤. "តម្លៃឯកតា" គឺជាតម្លៃដែលអ្នកទិញផ្តល់ជូន សម្រាប់ផលិតផលមួយឯកតា ។

៥. ចំណងជើងបន្ទាប់ គឺ "ប្រាក់ចំណូលសរុប" ។ កាលពីវគ្គមុនយើងបានរៀនសូត្រថា "ប្រាក់ចំណូលសរុប" ត្រូវបានគណនាដោយការគុណតម្លៃទីផ្សារ ទៅនឹងបរិមាណផលិតផលដែលបានលក់។

៦. ចំណងជើងចុងក្រោយគឺ "មតិយោបល់" ដូច្នេះចូរសូមឱ្យសិក្ខាកាមសរសេរអំពីការសង្កេតនានាដែលពួកគេបានកត់សម្គាល់ នៅពេលដែលពួកគេធ្វើទីផ្សារផលិតផលរបស់ពួកគេ ។

ចូរពន្យល់ថា កំណត់ត្រាអំពីប្រាក់ចំណូល គួរត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលលក់ផលិតផល ដើម្បីឱ្យតួលេខប្រាក់ចំណូលមានភាពសុក្រឹត្យ ។ ចូរស្នើរឱ្យសិក្ខាកាមបំពេញ ឧទាហរណ៍ផ្ទាល់ខ្លួនមួយចំនួនរបស់ពួកគេ នៅក្នុងតារាងអំពីប្រាក់ចំណូលនៃលំហាត់ ១១.៦ ដើម្បីបង្ហាញថា ពួកគេដឹងអំពីរបៀបបំពេញតារាង។

សូមឱ្យសិក្ខាកាមពិនិត្យមើលផ្នែកទី២ នៃសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ និងគូសចំនួនគូឡោនដូចគ្នា (៦គូឡោន) ទៅនឹងទម្រង់កំណត់ត្រាអំពីប្រាក់ចំណូលដូច្នោះដែរ ។ បន្ទាប់មក សូមឱ្យពួកគេចម្លងចំណងជើងនៅក្នុងតារាងប្រាក់ចំណូល និងទៅក្នុងសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ ។ ឥឡូវនេះក្រុមមានតារាងកំណត់ត្រាអំពីប្រាក់ចំណូលផ្ទាល់ខ្លួនរបស់ ពួកគេហើយ ។

| | | |
|---|---|---|
| | បង្ហាញកំណត់ត្រា អំពីការខាតបង់/ប្រាក់ចំណេញ ជូនដល់ធនាគារ ដើម្បីជួយដល់ពួកគេក្នុងការទទួលបានប្រាក់កម្ចី ។ នៅចុងបញ្ចប់នៃវដ្តផលិតកម្ម ពួកគេអាចសង្ខេបអំពីការផលិតប្រាក់ចំណូល និងថ្លៃចំណាយរបស់ពួកគេនៅក្នុងតារាង ដើម្បីគណនា ថាតើពួកគេពិតជាទទួលបានប្រាក់ចំណេញដែរឬទេ ។<br><br>សូមឱ្យសិក្ខាកាមចម្លងមូលហេតុ ដែលពួកគេត្រូវមានកំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់) ទៅក្នុងលំហាត់ ១១.៧ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលឧទាហរណ៍នៃកំណត់ត្រាអំពីប្រាក់ចំណេញ/ការខាងបង់ នៅក្នុងលំហាត់ ១១.៧ នៃសៀវភៅលំហាត់របស់ពួកគេ និងពន្យល់អំពីចំណងជើង និងរបៀបដែលតួលេខត្រូវបានគេគណនា ។ ចូរកត់សម្គាល់ថា រាល់ប្រាក់ចំណូលទាំងអស់ត្រូវបានកត់ត្រា រាប់បញ្ចូលទាំងផលិតផលដែលត្រូវបានផ្តល់ជាអំណោយ ឬទទួលទានផងដែរ។ ជាធម្មតាថ្លៃចំណាយពុំបានរាប់បញ្ចូលកម្លាំងពលកម្មគ្រួសារឡើយ លើកលែងតែពួកគេចំណាយប្រាក់ដើម្បីជួលកម្លាំងពលកម្ម ។<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលផ្នែកទី៤ នៃសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ និងគូសចំនួនគូឡោនដូចគ្នា ទៅនឹងទម្រង់កំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់) ដូច្នោះដែរ ។ បន្ទាប់មក សូមឱ្យពួកគេចម្លងចំណងជើងនៅក្នុងតារាង ប្រាក់ចំណេញ/ការខាតបង់ និងទៅក្នុងសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ។ ឥឡូវនេះ ពួកគេមានតារាងកំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់) ផ្ទាល់ខ្លួនរបស់ពួកគេហើយ ។ | |
| ១០ | **កំណត់ត្រាអំពីលំហូរសាច់ប្រាក់៖**<br><br>ចូរសួរទៅកាន់សិក្ខាកាមថា ហេតុអ្វីបានជាពួកគេគួររក្សាកំណត់ត្រាអំពីលំហូរសាច់ប្រាក់ ។ ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសមួយសន្លឹក ។<br><br>ចូររំលឹកសិក្ខាកាមថា កំណត់ត្រាអំពីលំហូរសាច់ប្រាក់ គ្រាន់តែកត់ត្រាអំពីសាច់ប្រាក់ដែល**ហូរចូល** និងសាច់ប្រាក់ដែល**ហូរចេញ** ព្រមទាំងកាល | <br>លំហាត់ ១១.៨៖ |

| | | |
|---|---|---|
| | ចំនួនឯកតា គុណនឹងតម្លៃឯកតា។<br>៦. នៅក្នុងគូឡោនចុងក្រោយ ចូរសរសេរមតិយោបល់អំពីគុណភាព និង ពេលវេលា ដើម្បីជួយឱ្យអ្នកសម្រេចចិត្ត ថាតើអ្នកនឹងទិញសម្ភារៈ ឬ សេវាកម្មដដែលនៅលើកក្រោយដែរឬទេ។<br><br>ចូរពន្យល់ថា គេត្រូវបំពេញគូឡោនទាំងអស់ រាល់ពេលដែលខ្ទង់ចំណាយណាមួយបានកើតឡើង ។ ប្រសិនបើសិក្ខាកាមមិនធ្វើដូច្នេះភ្លាមៗទេនោះ ពួកគេនឹងភ្លេចអំពីខ្លឹមសារលម្អិត។<br><br>ចូរសូមឱ្យពួកគេបំពេញឧទាហរណ៍ផ្ទាល់ខ្លួនមួយចំនួនរបស់ពួកគេ ទៅក្នុងតារាងថ្លៃចំណាយនៃលំហាត់ ១១.៦ ដើម្បីបង្ហាញថា ពួកគេដឹងអំពីវិធីបំពេញតារាង ។<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលផ្នែកទី៣ នៃសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ និងគូស ចំនួនគូឡោនដូចគ្នា (៦គូឡោន) ទៅនឹងទម្រង់កំណត់ត្រាអំពីថ្លៃចំណាយដូច្នោះដែរ ។ បន្ទាប់មកសូមឱ្យពួកគេចម្លងចំណងជើងនៅក្នុងតារាងថ្លៃចំណាយដូចគ្នានោះ ទៅក្នុងសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ។ ឥឡូវនេះ ក្រុមមានតារាងកំណត់ត្រាអំពីថ្លៃ ចំណាយផ្ទាល់ខ្លួនរបស់ពួកគេហើយ ។ | |
| ៩ | **កំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់) ៖**<br>ចូរសួរទៅកាន់សិក្ខាកាមថា ហេតុអ្វីបានជាពួកគេគួររក្សាកំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់)។ ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសមួយសន្លឹក។<br><br>ចូរពន្យល់ថា គេអាចប្រើប្រាស់កំណត់ត្រាអំពីប្រាក់ចំណូល និង កំណត់ត្រាអំពីថ្លៃចំណាយ ដើម្បីគណនា ថាតើសហគ្រាសទទួលបានប្រាក់ចំណេញ ឬមានការខាតបង់ ដែលចំណុចនេះមានបញ្ជាក់នៅក្នុងកំណត់ត្រា អំពីការទូទាត់ថវិកា ។<br><br>ចូរសង្កត់ធ្ងន់ថា ការគណនានេះ គួរធ្វើឡើងនៅដើមរដូវកាល ដើម្បីពិនិត្យមើលថា តើអាជីវកម្មនឹងទទួលបានប្រាក់ចំណេញដែរឬទេ ។ ប្រសិនបើពិនិត្យឃើញថា អាជីវកម្មនឹងមិនទទួលបានប្រាក់ចំណេញទេនោះ មិនត្រូវចាប់ផ្ដើមធ្វើអាជីវកម្មនោះជាដាច់ខាត! វាក៏ជួយក្នុងការកំណត់គោលដៅផលិតប្រាក់ចំណូល និង ថ្លៃចំណាយផងដែរ ដើម្បីឱ្យគេអាចធ្វើការត្រួតពិនិត្យទៅលើដំណើរការអាជីវកម្ម ធៀបទៅនឹងកត្តាទាំងនេះ ។ សិក្ខាកាមអាច | <br>លំហាត់ ១១.៧៖ កំណត់ត្រាអំពីការទូទាត់ថវិកា (ប្រាក់ចំណេញ/ការខាតបង់) |

ចូរសួរទៅកាន់សិក្ខាកាមថា តើពួកគេយល់ឃើញដូចម្តេចដែរ ចំពោះពាក្យថា “បំណុល” និង “ទ្រព្យសម្បត្តិ” ? ចូរផ្តល់និយមន័យខាងក្រោម អំពីពាក្យទាំងនេះ។ និយមន័យនេះ មានសរសេរបញ្ជាក់នៅក្នុងលំហាត់ ១១.៩ នៃសៀវភៅលំហាត់របស់ពួកគេ។

**ទ្រព្យសម្បត្តិ** គឺជាអ្វីដែលកសិករមាន។

**បំណុល** គឺជាអ្វីដែលកសិករជំពាក់អ្នកដទៃ។

ចូរសួរទៅកាន់សិក្ខាកាម ថាហេតុអ្វីបានជាពួកគេគិតថា ពួកគេគួររក្សាកំណត់ត្រាអំពីទ្រព្យសម្បត្តិ និងបំណុល ។ ចូរសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសមួយសន្លឹក ។

ចូរលើកទឹកចិត្តឱ្យពួកគេនិយាយថា កំណត់ត្រានេះ អាចជួយឱ្យពួកគេដឹងអំពីទ្រព្យសម្បត្តិដែលពួកគេមាន ព្រមទាំងតម្លៃនៃទ្រព្យសម្បត្តិទាំងនោះ ។ វាក៏ជួយឱ្យគេបានដឹងអំពីចំនួនទឹកប្រាក់ដែលក្រុមជំពាក់អ្នកដទៃផងដែរ ។ លទ្ធផលដែលបានធ្វើការទូទាត់រួចរាល់ (ទ្រព្យសម្បត្តិដកបំណុល) បង្ហាញថាតើក្រុមមានទ្រព្យសម្បត្តិច្រើនជាងចំនួនទឹកប្រាក់ ដែលក្រុមជំពាក់គេដែរឬទេ ។

សូមឱ្យសិក្ខាកាមចម្លងមូលហេតុដែលពួកគេចាំបាច់ត្រូវមានកំណត់ត្រាអំពីទ្រព្យសម្បត្តិ និងបំណុល ទៅក្នុងលំហាត់ ១១.៩ នៃសៀវភៅលំហាត់របស់ពួកគេ ។

ចូរពិនិត្យមើលឧទាហរណ៍នៃការបញ្ចូលទ្រព្យសម្បត្តិ និងបំណុល នៅក្នុងលំហាត់ ១១.៩ នៃសៀវភៅលំហាត់របស់ពួកគេ ។

សូមឱ្យសិក្ខាកាមពិនិត្យមើលផ្នែកចុងក្រោយ នៃសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ និងគូសចំនួនគូឡោនដូចគ្នា ទៅនឹងទម្រង់កំណត់ត្រាអំពីទ្រព្យសម្បត្តិ/បំណុល ដូច្នោះដែរ ។ បន្ទាប់មក សូមឱ្យពួកគេចម្លងចំណងជើងនៅក្នុងតារាងទ្រព្យសម្បត្តិ/បំណុល ដូចគ្នានោះ ទៅក្នុងសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ ។ ឥឡូវនេះពួកគេមានតារាងកំណត់ត្រាអំពីទ្រព្យសម្បត្តិ/បំណុលផ្ទាល់ខ្លួនរបស់ពួកគេហើយ។



លំហាត់ ១១.៩៖ កំណត់ត្រាអំពីទ្រព្យសម្បត្តិ និងបំណុលរបស់ក្រុម

| | | |
|---|---|---|
| | បរិច្ឆេទ នៃលំហូរសាច់ប្រាក់ទាំងនេះប៉ុណ្ណោះ ។ សិក្ខាកាមមិនគួរបញ្ចូលប្រតិបត្តិការទាំងឡាយណា ដែលមិនពាក់ព័ន្ធទៅនឹងសាច់ប្រាក់ឡើយ (ឧទាហរណ៍៖ ការផ្តល់ស្រូវអង្ករ ឬ កម្លាំងពលកម្មគ្រួសារ ដែលឥតគិតថ្លៃសម្រាប់ជាអំណោយ) ។ តួលេខដែលត្រូវដាក់នៅក្នុងលំហូរសាច់ប្រាក់ អាចមានប្រភពចេញពីថវិការបស់ពួកគេ ដែលបានរៀបចំមុនពេលចាប់ផ្តើមធ្វើអាជីវកម្ម ។ ថវិកាទាំងនេះរៀបរាប់អំពីកាលបរិច្ឆេទទទួលបានប្រាក់ចំណូល និងកាលបរិច្ឆេទចំណាយប្រាក់ ។<br><br>កាលបរិច្ឆេទអាចណែនាំពួកគេក្នុងការបញ្ចូលទិន្នន័យទៅក្នុងខែដែលត្រឹមត្រូវនៃតារាងលំហូរសាច់ប្រាក់របស់ពួកគេ ។ ចូរប្រាប់ពួកគេថា កំណត់ត្រាអំពីលំហូរសាច់ប្រាក់ នឹងជួយឱ្យកសិករដឹងអំពីចំនួនទឹកប្រាក់ដែលគេត្រូវការក្នុងខែនីមួយៗ សម្រាប់ផ្គត់ផ្គង់សហគ្រាសរបស់ពួកគេ ។ ចំណុចនេះអាចជួយដល់ការរៀបចំផែនការសម្រាប់សេចក្តីត្រូវការសាច់ប្រាក់របស់ពួកគេ ។<br><br>សូមឱ្យសិក្ខាកាមចម្លងមូលហេតុ ដែលគេត្រូវការឱ្យមាននូវ កំណត់ត្រាអំពីលំហូរសាច់ប្រាក់ ទៅក្នុងលំហាត់ ១១.៨ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>បន្ទាប់មក ចូរសូមឱ្យសិក្ខាកាមបំពេញទម្រង់លំហូរសាច់ប្រាក់ ជាមួយនឹងព័ត៌មានដែលទទួលបានពីកំណត់ត្រាអំពីប្រាក់ចំណេញ/ការខាតបង់ នៅក្នុងលំហាត់មុន ។ ចូរធ្វើដំណើរត្រួតពិនិត្យជុំវិញក្រុម ដើម្បីធានាថាពួកគេធ្វើសកម្មភាពនេះបានត្រឹមត្រូវ ។<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលផ្នែកទី៥ នៃសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ និងគូសចំនួនគូឡោនដូចគ្នាទៅនឹងទម្រង់កំណត់ត្រាអំពីលំហូរសាច់ប្រាក់ដូច្នោះដែរ ។<br><br>**សម្គាល់៖** រយៈពេល (ឧ. ចំនួនខែ) គឺអាស្រ័យទៅលើ អាជីវកម្មដែលពួកគេកំពុងធ្វើ ។ បន្ទាប់មកសូមឱ្យពួកគេចម្លងចំណងជើងនៅក្នុងតារាងលំហូរសាច់ប្រាក់ និងទៅក្នុងសៀវភៅកំណត់ត្រាថ្មីរបស់ពួកគេ ។ ឥឡូវនេះពួកគេមានតារាងកំណត់ត្រាអំពី លំហូរសាច់ប្រាក់ផ្ទាល់ខ្លួនរបស់ពួកគេហើយ ។ | កំណត់ត្រាអំពីលំហូរសាច់ប្រាក់ |
| ១១ | **កំណត់ត្រាអំពីទ្រព្យសម្បត្តិ និងបំណុលរបស់ក្រុម៖** | |

# មេរៀនទី១២៖ ការត្រួតពិនិត្យទៅលើដំណាក់កាលអនុវត្តរបស់សហគ្រាស



**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចធ្វើការត្រួតពិនិត្យឡើងវិញទៅលើផែនការ អាជីវកម្មជាក្រុម ធៀបទៅនឹងដំណើរការជាក់ស្តែង និងធ្វើការផ្លាស់ប្តូរផែនការក្នុងករណីចាំបាច់ ដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់ក្រុម។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ការទទួលបានការឯកភាពទៅលើដំណើរការត្រួតពិនិត្យដំណាក់កាលអនុវត្ត និង កាលវិភាគវគ្គបណ្តុះបណ្តាល៖**<br><br>ចូរស្វាគមន៍សិក្ខាកាមដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ។ ចូរនិយាយថា ពួកគេបានរៀនសូត្រអំពីចំណុចជាច្រើន ដែលអាចជួយដល់បុគ្គល និងក្រុមក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ សម្រាប់ដំណើរការផលិតកម្មរដូវនេះ ។ ការជ្រើសរើសប្រភេទអាជីវកម្មដែលអាចទទួលបានជោគជ័យ ការរៀបចំកសិដ្ឋានសម្រាប់ផលិត និងការរៀបចំផែនការអាជីវកម្មជាក្រុម និងការរៀបចំឱ្យមាននូវប្រព័ន្ធរក្សាកំណត់ត្រាសម្រាប់អាជីវកម្មគឺជាចំណុចដែលសំខាន់បំផុត។<br><br>ចូរនិយាយថាវគ្គបន្តបន្ទាប់នេះគឺការ "ត្រួតពិនិត្យ" នឹងរៀបចំឡើងសម្រាប់ជាការណែនាំដល់ក្រុមកសិករ តាមដំណាក់កាលអនុវត្តផែនការអាជីវកម្ម ដើម្បីពិនិត្យមើល ថាតើផែនការរបស់ពួកគេកំពុងមានដំណើរការប្រព្រឹត្តទៅបានល្អប្រសើរដែរឬទេ ។ ប្រសិនបើដំណើរការប្រព្រឹត្តទៅមិនទាន់បានល្អប្រសើរទេនោះ សិក្ខាកាមអាចពិភាក្សា ដើម្បីស្វែងរកវិធីដោះស្រាយបញ្ហា ដើម្បីឱ្យគេអាចសម្រេចបាននូវគោលដៅដែលបានកំណត់នៅក្នុងផែនការរបស់ពួកគេ ។<br><br>ចូរប្រាប់សិក្ខាកាមថា ឥឡូវនេះពួកគេត្រូវឯកភាពទៅលើកាលវិភាគកំណត់ពេលវេលា "**ត្រួតពិនិត្យ**" ដំណាក់កាលអនុវត្តសហគ្រាសអាជីវកម្មទាំងមូល ។ ពួកគេអាចពិចារណាធ្វើការជួបជុំគ្នាមួយខែម្តងដើម្បី៖ | <br>លំហាត់ ១២.១ ៖ ការត្រួតពិនិត្យទៅលើកាលវិភាគដំណាក់កាលអនុវត្ត |

| | | |
|---|---|---|
| ១២ | ចូរប្រាប់សិក្ខាកាមថា ឥឡូវនេះ ពួកគេត្រូវចាប់ផ្ដើមរក្សាកំណត់ត្រាអំពីសហគ្រាស កសិដ្ឋាន ឬស្រែចម្ការ និងក្រុមសហគ្រាសរបស់ពួកគេ ព្រមទាំងរាយការណ៍អំពីលទ្ធផលរបស់ពួកគេ នៅឯកិច្ចប្រជុំត្រួតពិនិត្យដែលត្រូវបានកំណត់រៀបចំនៅក្នុងរយៈ ពេលអនុវត្តសហគ្រាសដែលពួកគេបានជ្រើសរើស ។ | |
| ១៣ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្ដប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួល គួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

| | | |
|---|---|---|
| | និងបង្ហាញថា សកម្មភាពមានលក្ខណៈដូចគ្នា (គូឡោនទី១)។ ចូរនិយាយថា ទម្រង់គ្រួតពិនិត្យអាចជួយដល់សិក្ខាកាមធ្វើការប្រៀបធៀបសកម្មភាពនីមួយៗ ប្រាក់ចំណូល និងថ្លៃចំណាយ រវាងអ្វីដែលបានគ្រោងទុក និងអ្វីដែលបានកើតឡើងជាក់ស្តែង ។ ពួកគេអាចធ្វើសកម្មភាពបែបនេះដោយ ៖<br>គូឡោនទី២៖ បំពេញនៅក្នុងប្រាក់ចំណូល ថ្លៃចំណាយ និង ប្រាក់ចំណេញ/ការខាតបង់ ដែលបានគ្រោងទុក សម្រាប់ខែដែលពួកគេផ្តោតយកចិត្តទុកដាក់ ដោយចម្លងតួលេខពីកំណត់ត្រាអំពីលំហូរសាច់ប្រាក់។<br>គូឡោនទី៣៖ បំពេញនៅក្នុងប្រាក់ចំណូល ថ្លៃចំណាយ និងប្រាក់ចំណេញ ឬការខាតបង់ជាក់ស្តែង ពីកំណត់ត្រារបស់គណនេយ្យករក្រុម។<br>គូឡោនទី៤៖ គណនាអំពីភាពខុសគ្នា រវាងគូឡោនទី២ និងគូឡោនទី៣។<br>គូឡោនទី៥៖ សរសេរអំពីមូលហេតុនៃភាពខុសគ្នា និង ដំណោះស្រាយចំពោះបញ្ហា ដែលបានជួបប្រទះ។<br>គូឡោនទី៦៖ សរសេរអំពីថវិកាគ្រោងទុកសម្រាប់ខែបន្ទាប់ ។ ចំណុចនេះគួរបញ្ចូលការផ្លាស់ប្តូរចំពោះផែនការដែលបានពិភាក្សានៅក្នុងគូឡោនទី៥។ | |
| ៣ | **ការបញ្ចប់កិច្ចប្រជុំ៖**<br>សូមឱ្យសិក្ខាកាមពិនិត្យមើលទម្រង់គ្រួតពិនិត្យនៅក្នុងលំហាត់ ១២.២ នៃសៀវភៅលំហាត់របស់ពួកគេ និងផ្តល់មតិយោបល់ថា ពួកគេគួរប្រើប្រាស់ទម្រង់នេះ និងដំណើរការគ្រួតពិនិត្យនៅក្នុងកិច្ចប្រជុំគ្រួតពិនិត្យនីមួយៗ។<br>ចូរផ្តល់មតិយោបល់ថា គណនេយ្យកររបស់ក្រុម គួរជាអ្នករៀបចំកិច្ចប្រជុំគ្រួតពិនិត្យនិមួយៗ ដោយសារពួកគេដឹងអំពីព័ត៌មានលម្អិតនៃប្រាក់ចំណូល និងចំណាយរបស់ក្រុមច្បាស់ជាងអ្នកដទៃទៀតនៅក្នុងក្រុម ។ គណនេយ្យករអាចបំពេញនៅក្នុងគូឡោនទី២ និងគូឡោនទី៣ ឱ្យបានរួចជាស្រេចមុនពេលចូលរួមកិច្ចប្រជុំ ដើម្បីសន្សំពេលវេលាក្នុងអំឡុងពេលនៃកិច្ចប្រជុំ ។ អ្នកសម្របសម្រួលអាចជួយដល់គណនេយ្យករ នៅក្នុងដំណើរការកិច្ចប្រជុំគ្រួតពិនិត្យ ។<br>ចូរបញ្ជាក់អំពីពេលវេលា និង ទីកន្លែងសម្រាប់កិច្ចប្រជុំគ្រួតពិនិត្យលើក | <br>លំហាត់ ១២.២ ៖<br>ទម្រង់គ្រួតពិនិត្យ |

| | | |
|---|---|---|
| | • ត្រួតពិនិត្យទៅលើកំណត់ត្រាអំពីប្រាក់ចំណូល និង ថ្លៃចំណាយរបស់ក្រុមពួកគេ និងប្រៀបធៀបកំណត់ត្រាទាំងនេះជាមួយផែនការអាជីវកម្មរបស់ពួកគេ ។<br>• ធ្វើការពិភាក្សាក្រៅផ្លូវការ និងចែករំលែកបទពិសោធន៍មួយចំនួនទាក់ទងទៅនឹងការគ្រប់គ្រងកសិដ្ឋាន ឬ ស្រែចម្ការ និងការធ្វើអាជីវកម្មជាក្រុមរបស់ពួកគេ ។<br>សូមឱ្យសិក្ខាកាមបំពេញកាលវិភាគនៅក្នុងលំហាត់ ១២.១ នៃសៀវភៅលំហាត់របស់ពួកគេ ដោយធ្វើការកត់ត្រាអំពី៖<br>➢ កាលបរិច្ឆេទរៀបចំកិច្ចប្រជុំ<br>➢ អ្វីដែលពួកគេចង់ពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនោះ<br>➢ ទីកន្លែងរៀបចំកិច្ចប្រជុំ<br>➢ ពេលវេលារៀបចំកិច្ចប្រជុំ | |
| ២ | **ការយល់ដឹងអំពីការប្រើប្រាស់ទម្រង់ត្រួតពិនិត្យ៖**<br>ចូរធ្វើការរៀបចំទុកជាមុននូវផ្ទាំងក្រដាសធំចំនួន២សន្លឹក៖<br>១. លំហូរសាច់ប្រាក់នៃផែនការអាជីវកម្មសហគ្រាសជាក្រុម ដែលដកស្រង់ចេញពីលំហាត់ ១០.៣ ។<br>២. គំរូទម្រង់ត្រួតពិនិត្យដែលដកស្រង់ចេញពីលំហាត់ ១២.២ នៃសៀវភៅលំហាត់សម្រាប់សិក្ខាកាម ។ ចូរចម្លងសកម្មភាពពីគូឡោនទី១ នៅក្នុងតារាងលំហូរសាច់ប្រាក់ (លំហាត់ ១០.៣) ទៅក្នុងគូឡោនទី១ នៃទម្រង់ត្រួតពិនិត្យ ដោយត្រូវធានាថាសកម្មភាពមានលក្ខណៈដូចគ្នាទាំងស្រុង ។<br>ចូររៀបចំតម្លើងតារាងលំហូរសាច់ប្រាក់ និង ថវិកានៃផែនការអាជីវកម្មសហគ្រាសជាក្រុម ។ សូមឱ្យសិក្ខាកាមពន្យល់ តើទម្រង់នេះបង្ហាញអំពីអ្វី ។<br>ចូរណែនាំសិក្ខាកាមឱ្យនិយាយថា៖"ទម្រង់នេះរៀបរាប់អំពីលំហូរសាច់ប្រាក់ពីមួយខែទៅមួយខែ សម្រាប់សហគ្រាសជាក្រុម និងរាយនាមអំពីប្រាក់ចំណូលសរុប ថ្លៃចំណាយសរុប និង ប្រាក់ចំណេញ/ការខាតបង់ សម្រាប់ខែនីមួយៗ ព្រមទាំងសង្ខេបអំពីប្រាក់ចំណូលសរុប ថ្លៃចំណាយ និងប្រាក់ចំណេញ/ការខាតបង់សម្រាប់រយៈពេលនៅក្នុងផែនការទាំងមូលផងដែរ" ។<br>ចូររៀបចំតម្លើងទម្រង់ត្រួតពិនិត្យ (១២.២) នៅក្បែរទម្រង់លំហូរសាច់ប្រាក់ | ផ្ទាំងក្រដាសធំដែលបង្ហាញអំពីលំហូរសាច់ប្រាក់របស់ក្រុម លំហាត់ ១០.៣៖ ទម្រង់ត្រួតពិនិត្យដែលបានស្នើឡើងពីលំហាត់១២.២ |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី១៣ ៖ ការវាយតម្លៃទៅលើដំណើរការផែនការអាជីវកម្មរបស់កសិករលក្ខណៈបុគ្គល និងផែនការអាជីវកម្មសហគ្រាសជាក្រុម



**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងដឹងអំពីវិធីវាយតម្លៃសហគ្រាសអាជីវកម្មជាលក្ខណៈបុគ្គល និង សហគ្រាសអាជីវកម្មដែលមានលក្ខណៈជាក្រុមរបស់ពួកគេ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ការរៀបចំត្រៀមលក្ខណៈ**<br><br>សូមឱ្យសិក្ខាកាមនាំយកមកនូវកំណត់ត្រាអំពីការផលិត ប្រាក់ចំណូល ថ្លៃចំណាយ និង ប្រាក់ចំណេញ ឬការខាតបង់ នៃផែនការកសិដ្ឋាន ឬ ស្រែចម្ការរបស់ពួកគេ ដែលមានលក្ខណៈបុគ្គល និងផែនការអាជីវកម្មសហគ្រាស ដែលមានលក្ខណៈជាក្រុមទៅកាន់កិច្ចប្រជុំនេះ ។ ចូរធ្វើការ ពិនិត្យផ្ទៀងផ្ទាត់ជាមួយគណនេយ្យកររបស់ក្រុម ដើម្បីធានាថាពួកគេមានចម្លើយសម្រាប់ឆ្លើយតបទៅនឹងសំនួរវាយតម្លៃរបស់ក្រុម (សូមប្រាប់ឱ្យគណនេយ្យករពិនិត្យមើលតារាងសូចនាករ អំពីការវាយតម្លៃសហគ្រាសជាក្រុម និងសំនួរនៅក្នុងលំហាត់ ១៣.៣) ។ | <br>លំហាត់ ១៣.៣៖ តារាងសូចនាករអំពីការវាយតម្លៃសហគ្រាសជាក្រុម |
| ២ | **និយមន័យនៃការវាយតម្លៃ៖**<br>ចូរធ្វើការប្រមូលផ្តុំគំនិតជាមួយសិក្ខាកាម អំពីអត្ថន័យនៃពាក្យ "ការវាយតម្លៃ" ។ សូមឱ្យសិក្ខាកាមពិនិត្យមើលនិយមន័យនៅក្នុងលំហាត់ ១៣.១ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>ការវាយតម្លៃ គឺជាការប៉ាន់ប្រមាណជាប្រចាំ ចំពោះផលប៉ះពាល់របស់សហគ្រាសមួយទៅលើជីវិតរស់នៅរបស់បុគ្គលកសិករ និងក្រុម ។<br><br>ការវាយតម្លៃសួរសំនួរចំនួនពីរ៖<br><br>១. តើសហគ្រាសសម្រេចបាននូវគោលបំណងរបស់ខ្លួនដែរឬទេ?<br>២. តើអ្វីខ្លះដែលបានធ្វើឱ្យសហគ្រាសទទួលបានជោគជ័យ ឬ | <br>លំហាត់ ១៣.១៖ និយមន័យនៃការវាយតម្លៃ |

| | | |
|---|---|---|
| | ក្រោយ ។ ចូរធ្វើការសង្កត់ធ្ងន់ចំពោះគណនេយ្យកររបស់ក្រុមថា ពួកគេគួរនាំយកមកជាមួយនូវកំណត់ត្រាដែលមានភាពច្បាស់លាស់ និងមានបច្ចុប្បន្នភាពទៅកាន់កិច្ចប្រជុំលើកក្រោយ អាស្រ័យដោយកំណត់ត្រាទាំងនោះ មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ដំណើរការត្រួតពិនិត្យអាជីវកម្មដែលមានលក្ខណៈជាក្រុម ។ | |
| ៤ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញ ទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និង មាតិកា នៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | ពួកគេ នៅក្នុងគូឡោនទី ៣ "ជាក់ស្តែង" ។<br><br>នៅក្នុងគូឡោនទី៤ ចូរស្នើសុំឱ្យសិក្ខាកាមធ្វើការគណនាស្វែងរកភាពខុសគ្នារវាងលទ្ធផលរំពឹងទុក (គូឡោនទី២) និងលទ្ធផលជាក់ស្តែង (គូឡោនទី៣) ។<br><br>ចូរធ្វើការសង្ខេប ដោយសូមឱ្យសិក្ខាកាមឆ្លើយទៅនឹងសំនួរខាងក្រោម៖<br><br>១. តើសហគ្រាសសម្រេចបាននូវគោលដៅរបស់ខ្លួនដែរឬទេ?<br>២. តើអ្វីខ្លះដែលបានធ្វើឱ្យសហគ្រាសទទួលបានជោគជ័យ ឬបរាជ័យ?<br>៣. តើពួកគេនឹងធ្វើសហគ្រាសនេះ ម្តងទៀត ដែរឬទេ? ហេតុអ្វី?<br>៤. តើពួកគេនឹងធ្វើការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីធ្វើឱ្យសហគ្រាសនេះចំណេញកាន់តែច្រើន? | |
| ៤ | **ការវាយតម្លៃលទ្ធផលផែនការអាជីវកម្មសហគ្រាសជាក្រុម៖**<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើល នៅក្នុងលំហាត់ "តារាងសូចនាករវាយតម្លៃ" ១០.៥ នៃសៀវភៅលំហាត់របស់ពួកគេ ។ ចូរសូមឱ្យសមាជិកក្រុមដែលត្រូវបានជ្រើសរើស ឆ្លើយទៅនឹងសំនួរខាងក្រោម និងសរសេរចម្លើយរបស់ពួកគេ នៅក្នុងតារាងលើផ្ទាំងក្រដាសធំមួយសន្លឹក ក្នុងទម្រង់ដូចគ្នាទៅនឹងទម្រង់នៅក្នុងលំហាត់ ១៣.៣ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>តើអ្វីខ្លះជាសូចនាករដែលត្រូវបានជ្រើសរើស ដើម្បីវាយតម្លៃសហគ្រាសដែលមានលក្ខណៈជាក្រុម? ចូរសរសេរសូចនាករទាំងនោះនៅក្នុងគូឡោនទី១ ។<br><br>តើគោលដៅដែលបានបង្ហាញនៅក្នុងផែនការក្រុមមានអ្វីខ្លះ ? ចូរសរសេរគោលដៅទាំងនោះនៅក្នុងគូឡោនទី២ ។<br><br>តើអ្វីទៅជាលទ្ធផលជាក់ស្តែង សម្រាប់ចំណងជើងនីមួយៗទាំងនេះ? ចូរសរសេរលទ្ធផលទាំងនោះនៅក្នុងគូឡោនទី៣។<br><br>សូមឱ្យសិក្ខាកាមចម្លងតារាងនេះ ទៅក្នុងលំហាត់ ១៣.៣ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>នៅក្នុងគូឡោនទី៤ ចូរសូមឱ្យពួកគេធ្វើការគណនាដើម្បីស្វែងរកភាពខុសគ្នារវាងលទ្ធផលរំពឹងទុក (គូឡោនទី២) និងលទ្ធផលជាក់ស្តែង (គូឡោនទី៣) ។ | <br>លំហាត់ ១០.៥៖ តារាងសូចនាករវាយតម្លៃ<br><br><br>លំហាត់ ១៣.៣៖ តារាងវាយតម្លៃសហគ្រាសដែលមានលក្ខណៈជាក្រុម |

| | | |
|---|---|---|
| | បរាជ័យ?<br><br>ចូរផ្តល់ដំបូន្មានជូនដល់សិក្ខាកាមថា នៅក្នុងវគ្គបន្តបន្ទាប់ទៀតនេះ ពួកគេនឹងត្រូវខិតខំធ្វើការវាយតម្លៃសហគ្រាសដែលពួកគេបានជ្រើសរើស។ | |
| ៣ | ការត្រួតពិនិត្យឡើងវិញទៅលើផែនការ សហគ្រាសលក្ខណៈបុគ្គល ធៀបទៅនឹងគោលដៅដែលបានកំណត់នៅក្នុងថវិកា សម្រាប់ "ការអនុវត្តដែលកសិករបានឯកភាព" នៃលំហាត់ ៧.៥ (គ) ៖<br><br>សូមឱ្យសិក្ខាកាមពិនិត្យមើលថវិកាសម្រាប់ "ការអនុវត្តដែលកសិករបានឯកភាព" នៅក្នុងលំហាត់ ៧.៥ (គ) នៃសៀវភៅលំហាត់របស់ពួកគេ ។ សូមឱ្យសមាជិកក្រុមដែលត្រូវបានជ្រើសរើស អានអំពីគោលដៅ "ការអនុវត្តដែលកសិករបានឯកភាព" ដែលឆ្លើយតបទៅនឹងសំនួរខាងក្រោម ។ ចូរសរសេរចម្លើយរបស់ពួកគេទៅក្នុងតារាងមួយ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ដែលមានទម្រង់ដូចគ្នា ទៅនឹងលំហាត់ ១៣.២ គូឡោនទី២ នៃសៀវភៅលំហាត់របស់ពួកគេ។<br><br>១. តើសហគ្រាសនោះមានប្រភេទជាសហគ្រាសអ្វី?<br>២. តើគេរំពឹងថានឹងទទួលបានទិន្នផលចំនួនប៉ុន្មាន?<br>៣. តើគេរំពឹងថាលក់ផលិតផលបានតម្លៃប៉ុន្មាន?<br>៤. តើគេរំពឹងថានឹងទទួលបានប្រាក់ចំណូលសរុបចំនួនប៉ុន្មាន?<br>៥. តើថ្លៃចំណាយសរុបមានចំនួនប៉ុន្មាន?<br>៦. តើគេរំពឹងថានឹងទទួលបានប្រាក់ចំណេញ/ការខាតបង់ចំនួនប៉ុន្មាន?<br>៧. តើពួកគេបានភ្ជាប់ទំនាក់ទំនងជាមួយខ្សែសង្វាក់ផ្គត់ផ្គង់ចំនួនប៉ុន្មាន?<br>៨. តើលទ្ធផលនេះ នាំឱ្យមានការប្រែប្រួលដូចម្តេចខ្លះចំពោះជីវិតរស់នៅរបស់កសិករ?<br><br>ចូរសូមឱ្យសិក្ខាកាមចម្លងគោលដៅទាំងនេះទៅក្នុង តារាងវាយតម្លៃសហគ្រាសលក្ខណៈបុគ្គលនៅក្នុងលំហាត់ ១៣.២ គូឡោនទី២ នៃសៀវភៅលំហាត់របស់ពួកគេ ។<br><br>សិក្ខាកាមគួរសរសេរអំពីលទ្ធផលនៃកសិដ្ឋាន ឬ ស្រែចម្ការផ្ទាល់ខ្លួនរបស់ | <br>លំហាត់ ៧.៥ (គ) ៖ ថវិកាសម្រាប់ការអនុវត្តដែលកសិករបានឯកភាព<br><br><br>លំហាត់ ១៣.២៖ តារាងវាយតម្លៃសហគ្រាសកសិករលក្ខណៈបុគ្គល |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី១៤ ៖ ការជ្រើសរើសសហគ្រាសមួយសម្រាប់រដូវកាលបន្ទាប់



**គោលបំណង**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមនឹងអាចធ្វើការជ្រើសរើសក្នុងលក្ខណៈជាប្រព័ន្ធនូវសហគ្រាសដែលសមស្រប និងធ្វើឱ្យពួកគេទទួលបានប្រាក់ចំណេញសម្រាប់រដូវកាលធ្វើកសិដ្ឋាន ឬ ស្រែចម្ការលើកក្រោយ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | ចូរស្វាគមន៍សិក្ខាកាមដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ និងប្រាប់ពួកគេថា នៅក្នុងមេរៀននេះ ពួកគេនឹងត្រូវពិភាក្សាអំពីការរៀបចំធ្វើផែនការសហគ្រាសកសិដ្ឋាន ឬ ស្រែចម្ការលក្ខណៈបុគ្គល ឬ លក្ខណៈជាក្រុមសម្រាប់រដូវកាលបន្ទាប់។ | |
| ២ | ចូរប្រាប់សិក្ខាកាមថា នៅពេលនេះផែនការអាជីវកម្ម សម្រាប់ការធ្វើកសិដ្ឋាន ឬ ស្រែចម្ការ និងផែនការអាជីវកម្មជាក្រុមរបស់ពួកគេ អាចមានលក្ខណៈដូចកាលពីមុន ឬ អាចមានការប្រែប្រួលមួយចំនួននៅក្នុងផែនការនេះ ។ បើទោះជាស្ថិតក្នុងករណីណាមួយក៏ដោយ ពួកគេគួរបន្តអនុវត្តទៅមុខក្នុងលក្ខណៈជាប្រព័ន្ធតាមរយៈលំហាត់ខាងក្រោម៖<br><br>**លំហាត់ ១៤.១៖** ជ្រើសរើសសហគ្រាសដែលពួកគេចាប់អារម្មណ៍ និងសរសេរអំពីសហគ្រាសនេះ នៅក្នុងចន្លោះដែលផ្តល់ជូនក្នុងសៀវភៅលំហាត់ ។<br><br>**លំហាត់ ១៤.២៖** ត្រួតពិនិត្យលទ្ធភាពនៃការទទួលបានជោគជ័យនៃសហគ្រាសដែលបានជ្រើសរើស (ជាមួយនឹងចំណងជើងពីមេរៀនទី៤) ។<br><br>**លំហាត់ ១៤.៣៖** ត្រួតពិនិត្យឡើងវិញទៅលើចំណងជើងផែនការអាជីវកម្មសហគ្រាសជាក្រុម (មេរៀនទី៧ និង មេរៀនទី១០) ដើម្បីឱ្យទទួលបានតម្លៃកាន់តែប្រសើរចំពោះផលិតផលសម្រាប់លក់ តម្លៃកាន់តែទាបជាងមុនសម្រាប់សម្ភារៈកសិកម្ម និងសេវាកម្ម និងការបែងចែកភាគលាភកាន់តែប្រសើរសម្រាប់សមាជិកក្រុមដែលមាន ភាគហ៊ុននៅក្នុងនោះ ។<br><br>សូមឱ្យសិក្ខាកាមធ្វើការត្រួតពិនិត្យឡើងវិញទៅលើមេរៀនទាំងនេះ នៅក្នុង | <br>លំហាត់ ១៤.១, ១៤.២, និង ១៤.៣<br><br>ពីមេរៀនទី៤ , លំហាត់ ៤.១ និង មេរៀនទី៧ និង មេរៀនទី១០ |

| | | |
|---|---|---|
| | ចូរធ្វើការសង្ខេបដោយសូមឱ្យពួកគេឆ្លើយទៅនឹងសំនួរខាងក្រោម៖<br>១. តើក្រុមបានអនុវត្តតាមផែនការរបស់ខ្លួនដែរឬទេ? ហេតុអ្វី?<br>២. តើក្រុមបានទទួលលទ្ធផលរំពឹងទុកដែរឬទេ? ប្រសិនបើមិនបានទទួលលទ្ធផល រំពឹងទុក សូមបញ្ជាក់អំពីមូលហេតុ។<br>៣. តើក្រុមគួរធ្វើអ្វីដើម្បីដោះស្រាយបញ្ហាដែលពួកគេជួបប្រទះ?<br>៤. តើផ្នែកណាខ្លះនៃផែនការដែលមានដំណើរការប្រព្រឹត្តទៅបានល្អ? ហេតុអ្វី?<br>៥. តើពួកគេមានបំណងចង់សាកល្បងធ្វើអ្វីជាថ្មីម្តងទៀតនៅរដូវកាលក្រោយ? ហេតុអ្វី? | |
| ៥ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗ ដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ ។ ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេនៅលើសៀវភៅកត់ត្រាមួយ ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកានៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

## ផ្នែកទី៣ ៖ មេរៀននៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម

# មេរៀនទី១៥ ៖ ការត្រួតពិនិត្យឡើងវិញទៅលើផែនការយុទ្ធសាស្ត្រអាជីវកម្មថ្មី



**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចធ្វើការត្រួតពិនិត្យឡើងវិញទៅលើផែនការអាជីវកម្មថ្មីរបស់ពួកគេ ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | មុនពេលកិច្ចប្រជុំនេះ ចូរស្នើឱ្យកសិករឈានមុខ មួយរូបធ្វើការសម្របសម្រួលកិច្ចប្រជុំលើកក្រោយនេះ ។ ចូរបង្រៀនពួកគេអំពីដំណើរការ និងមាតិកានៃកិច្ចប្រជុំ ដោយប្រើប្រាស់សៀវភៅនេះ និងសៀវភៅលំហាត់សម្រាប់ជាការណែនាំ ។ | |
| ២ | **ចូរស្នើឱ្យអនុក្រុមនីមួយៗធ្វើការបង្ហាញគំនិតរបស់ពួកគេ សម្រាប់យុទ្ធសាស្ត្រចំនួនពីរ ៖**<br>១. ផែនការអាជីវកម្មសហគ្រាសរបស់កសិករលក្ខណៈបុគ្គល និង<br>២. ផែនការអាជីវកម្មសហគ្រាសជាក្រុម<br>កសិករដែលជាអ្នកសម្របសម្រួលគួរសង្ខេបអំពីគំនិតរបស់អនុក្រុមនីមួយៗ នៅលើផ្ទាំងក្រដាសធំមួយសន្លឹក ។ ចូរលើកទឹកចិត្តឱ្យមានវគ្គសំនួរ ចម្លើយ នៅចុងបញ្ចប់នៃការបង្ហាញនីមួយៗ ។<br>សូមឱ្យសិក្ខាកាមធ្វើការពិចារណា ៖ តើសកម្មភាពដែលពួកគេបានស្នើឡើងមានភាពសមស្របដែលអាចអនុវត្តទៅបានដែរឬទេ? តើមានសកម្មភាពសម្រាប់បុគ្គលធ្វើដែរឬទេ? តើមានសកម្មភាពសម្រាប់ក្រុមធ្វើរួមគ្នាដែរឬទេ? តើពួកគេមានបានដកចេញ ឬ មិនបានបញ្ចូលចំណុចណាមួយដែរឬទេ? ចូរព្យាយាមស្វែងរកការឯកភាពជារួមនៅក្នុងក្រុម ។<br>ចូរសង្ខេបអំពីយុទ្ធសាស្ត្រសហគ្រាសអាជីវកម្មជាលក្ខណៈបុគ្គល និង យុទ្ធសាស្ត្រសហគ្រាសអាជីវកម្មជាក្រុម ដែលបានឯកភាពគ្នានៅលើផ្ទាំងក្រដាសធំមួយសន្លឹក ។ សូមឱ្យសិក្ខាកាមចម្លងខ្លឹមសារទៅក្នុងលំហាត់ ១៥.១ នៃសៀវភៅលំហាត់របស់ពួកគេ ។ | <br>លំហាត់ ១៥.១ ៖ យុទ្ធសាស្ត្រសហគ្រាសលក្ខណៈ បុគ្គល និងសហគ្រាសលក្ខណៈជាក្រុម |

| | | |
|---|---|---|
| | សៀវភៅលំហាត់របស់ពួកគេ ដោយធ្វើការសង្កត់ធ្ងន់ថា សិក្ខាកាមគួរពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយទៅលើលំហាត់នីមួយៗដែលមានរៀបរាប់ខាងលើ ជាពិសេសលំហាត់ដែលនិយាយអំពីថវិកា និងលំហូរសាច់ប្រាក់ ។<br><br>ចូរលើកទឹកចិត្តសិក្ខាកាម ឱ្យធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ ដើម្បីសរសេរយុទ្ធសាស្ត្រសម្រាប់ផែនការអាជីវកម្មលក្ខណៈបុគ្គល និង ផែនការអាជីវកម្មជាក្រុមនៅក្នុងសប្ដាហ៍នេះ ។ ចូរស្នើសុំឱ្យប្រធានអនុក្រុមធ្វើការសង្ខេបគំនិតនីមួយៗ ទៅក្នុងសេចក្ដីព្រាងផែនការយុទ្ធសាស្ត្ររបស់អនុក្រុមនៅក្នុងសប្ដាហ៍នេះ ។ | |
| ៣ | ចូរធ្វើការបញ្ចប់កិច្ចប្រជុំ ដោយកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំលើកក្រោយ ដែលសិក្ខាកាមគួរបង្ហាញ និងត្រួតពិនិត្យឡើងវិញទៅលើគំនិតរបស់ពួកគេ សម្រាប់រៀបចំបង្កើតផែនការសហគ្រាសថ្មី។ | |
| ៤ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br><br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្ដប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br><br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេ នៅលើសៀវភៅកត់ត្រាមួយ ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

# មេរៀនទី១៦ ៖ ការវាយតម្លៃវគ្គ សាលាអាជីវកម្មកសិកម្ម និងការបញ្ចប់វគ្គ



**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចធ្វើការវាយតម្លៃទៅលើដំណើរការ និងមាតិកា នៃវគ្គសាលាអាជីវកម្មកសិកម្ម ព្រមទាំងចូលរួមនៅក្នុងពិធីបញ្ចប់វគ្គសិក្សា ។



៣ម៉ោង

| | ជំហាន | ធនធានសម្ភារៈ |
|---|---|---|
| ១ | **ការវាយតម្លៃទៅលើអត្ថប្រយោជន៍នៃវគ្គបណ្តុះបណ្តាលកសិករអំពីសាលាអាជីវកម្មកសិកម្ម៖**<br>ចូរចាប់ផ្តើមកិច្ចប្រជុំនេះ ដោយស្វាគមន៍សិក្ខាកាមដែលបានវិលត្រឡប់មកចូលរួមវគ្គសាលាអាជីវកម្មកសិកម្ម និងប្រាប់ពួកគេអំពីគោលបំណងនៃវគ្គនេះ។ | វិញ្ញាបនបត្របញ្ជាក់ការសិក្សាដែលត្រូវបានរៀបចំទុកជាមុន |
| ២ | **សំនួរវាយតម្លៃ៖**<br>ចូររៀបចំសិក្ខាកាមឱ្យធ្វើការងារនៅក្នុងអនុក្រុមរបស់ពួកគេ ។ សូមឱ្យក្រុមពិភាក្សាអំពី តើមេរៀនវគ្គ សាលាអាជីវកម្មកសិកម្ម មានប្រសិទ្ធភាពដល់កម្រិតណា និងបានជួយដល់ពួកគេដូចម្តេចខ្លះ នៅពេលអនុវត្តចំពោះកសិដ្ឋាន ឬស្រែចម្ការ និងក្រុមកសិកររបស់ពួកគេ ។ គោលបំណងនៃលំហាត់នេះ គឺដើម្បីស្វែងរកធ្វើការកែលម្អទៅលើមេរៀនវគ្គសាលាអាជីវកម្មកសិកម្ម សម្រាប់ពេលអនាគត ។ ចូរសូមឱ្យអនុក្រុមទាំងអស់ឆ្លើយទៅនឹងសំនួរខាងក្រោម ដែលមានសរសេរ នៅក្នុងលំហាត់ ១៦.១ នៃសៀវភៅលំហាត់របស់ពួកគេ។<br>១. តើ សាលាអាជីវកម្មកសិកម្ម គឺជាដំណើរការមួយដែលមានសារៈប្រយោជន៍ដែរឬទេ? ហេតុអ្វី?<br>២. តើអ្វីទៅជាប្រធានបទសំខាន់បំផុតដែលពួកគេបានរៀនសូត្រ?<br>៣. តើប្រធានបទណាខ្លះដែលពួកគេចង់ឱ្យដកចេញ? ហេតុអ្វី?<br>៤. តើពួកគេចង់ផ្តល់មតិយោបល់ឱ្យមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីធ្វើឱ្យវគ្គសាលាអាជីវកម្មកសិកម្ម កាន់តែមានប្រសិទ្ធភាព? | <br>លំហាត់ ១៦.១៖ សំនួរវាយតម្លៃវគ្គសាលាអាជីវកម្មកសិកម្ម |

| | | |
|---|---|---|
| ៣ | បញ្ចប់វគ្គរៀបចំផែនការនេះ ដោយសូមឱ្យក្រុមសរសេរផែនការរបស់កសិករលក្ខណៈបុគ្គល និងផែនការលក្ខណៈជាក្រុមឱ្យបានលម្អិត សម្រាប់រដូវកាលក្រោយ ដោយផ្អែកលើការពិភាក្សាខាងលើ ។ ផែនការនេះគួរបង្ហាញជូនដល់ក្រុមក្រោយពេលដែលពួកគេបានធ្វើការជ្រើសរើស ។ | |
| ៤ | សូមអញ្ជើញសិក្ខាកាមឱ្យចូលរួមនៅក្នុងវគ្គបញ្ចប់ដែលនោះ គឺជាការវាយតម្លៃវគ្គសាលាអាជីវកម្មកសិកម្ម និងពិធីបញ្ចប់ការសិក្សា ។ ចូរកំណត់ពេលវេលា និង ទីកន្លែងសម្រាប់កិច្ចប្រជុំលើកចុងក្រោយនេះ ។ | |
| ៥ | **ការវាយតម្លៃកិច្ចប្រជុំ៖**<br>ចូរចំណាយពេលវេលាប៉ុន្មាននាទី ដើម្បីពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗដែលត្រូវបានគ្របដណ្តប់នៅក្នុងវគ្គនេះ។<br>ស្នើសុំឱ្យសិក្ខាកាមឆ្លើយសំនួរដូចខាងក្រោម៖<br>➢ តើមានចំណុចល្អអ្វីខ្លះអំពីវគ្គសាលាអាជីវកម្មកសិកម្ម នេះ?<br>➢ តើមានចំណុចអ្វីខ្លះដែលមិនសូវល្អអំពីវគ្គនេះ?<br>➢ តើគេអាចកែលម្អវគ្គនេះបានដោយរបៀបណា?<br>អ្នកសម្របសម្រួលគួរសរសេរចម្លើយរបស់ពួកគេ នៅលើសៀវភៅកត់ត្រាមួយ ។ ចម្លើយទាំងនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អដំណើរការ និងមាតិកា នៃវគ្គសាលាអាជីវកម្មកសិកម្ម នៅពេលអនាគត។ | |

| | | |
|---|---|---|
| | ធានាថា សិក្ខាកាមគ្រប់រូបមានឱកាសក្នុងការចែករំលែកគំនិត និងអារម្មណ៍របស់ពួកគេ និងត្រូវកត់ត្រាអំពីគំនិតរបស់ពួកគេ។ | |
| ៣ | **ការធ្វើតេស្តឡើងវិញទៅលើការអង្កេតដាក់ពិន្ទុ ចំពោះការប៉ាន់ប្រមាណសេចក្តីត្រូវការបណ្តុះបណ្តាល** (TNA) **៖**<br><br>ចូររំលឹកសិក្ខាកាមថា នៅពេលចាប់ផ្តើមវគ្គ សាលាអាជីវកម្មកសិកម្ម ពួកគេត្រូវបានស្នើសុំឱ្យដាក់ពិន្ទុខ្លួនឯងចំពោះចំណេះដឹងរបស់ពួកគេ អំពីប្រធានបទផ្សេងៗគ្នានៃវគ្គ សាលាអាជីវកម្មកសិកម្ម ។ ចូរចែកទម្រង់ដាក់ពិន្ទុម្តងទៀត (គ្រាន់តែវាយនាមប្រធានបទដែលបានបង្រៀនពួកគេប៉ុណ្ណោះ) ។ ចូរសូមឱ្យពួកគេធ្វើការវាយតម្លៃចំណេះដឹងរបស់ពួកគេ ដោយធៀបទៅនឹងប្រធានបទទាំងនេះជាថ្មីម្តងទៀត ។<br><br>ចូរប្រមូលទម្រង់ដាក់ពិន្ទុរបស់ពួកគេ ក្រោយរយៈពេលមួយដ៏សមស្រប ។<br><br>ចូរថ្លែងអំណរគុណដល់សិក្ខាកាម ចំពោះកិច្ចខិតខំរបស់ពួកគេ នៅក្នុងលំហាត់នេះ ។ | ទម្រង់ដាក់ពិន្ទុទៅលើការប៉ាន់ប្រមាណសេចក្តីត្រូវការបណ្តុះបណ្តាល **(TNA)** ពីមេរៀនទី១ |
| ៤ | **និរន្តរភាពនៃក្រុមកសិករ (CBO):**<br><br>ចូរសួរសំនួរខាងក្រោម៖<br><br>១. តើដំណើរការនៃវគ្គ សាលាអាជីវកម្មកសិកម្ម បានជួយធ្វើឱ្យក្រុមមាននិរន្តរភាពដែរឬទេ? តើវាបានជួយធ្វើឱ្យក្រុមមាននិរន្តរភាពដោយរបៀបណា?<br>២. តើក្រុមនឹងបន្តជួបជុំគ្នា ដើម្បីរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍន៍សហគ្រាសជាក្រុមនៅពេលអនាគតត ដែរឬទេ? | <br>លំហាត់ ១៦.២ ៖ សំនួរអំពីនិរន្តរភាពនៃវគ្គសាលាអាជីវកម្មកសិកម្ម |
| ៥ | ចូរថ្លែងអំណរគុណដល់សិក្ខាកាម ចំពោះការចូលរួមដ៏សកម្មរបស់ពួកគេនៅក្នុងវគ្គសាលាអាជីវកម្មកសិកម្ម។ ចូរបញ្ចប់កិច្ចប្រជុំដោយការជូនពរដល់កសិករឱ្យទទួលបានពរបវរមហាប្រសើរនិងសូមឱ្យពួកគេបន្តផ្សព្វផ្សាយចំណេះដឹងដែលបានរៀនសូត្រនេះ ទៅអ្នកដទៃទៀត ។<br><br>សូមឱ្យអាជ្ញាធរមូលដ្ឋានចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា។<br><br>រៀបចំពិធីជប់លៀងតូចមួយ សម្រាប់អបអរដល់ការបញ្ចប់វគ្គនេះ។ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា<br><br>ទទួលទានអាហាររួមគ្នា |



# សៀវភៅសម្រាប់អ្នកសម្របសម្រួល

## សាលាអាជីវកម្មកសិកម្ម កម្មវិធីបណ្តុះបណ្តាល


អង្គការស្បៀង
និងកសិកម្មនៃសហប្រជាជាតិប្រចាំ
ប្រទេសកម្ពុជា ការិយាល័យអង្គការ
FAO ប្រចាំរាជធានីភ្នំពេញ
អគារលេខ ៥ ផ្លូវ ៣៧០
សង្កាត់បឹងកេងកង១
រាជធានីភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣-២១៦
៥៦៦ ទូរសារ: (៨៥៥)
២៣-២១៦ ៥៤៧
អ៊ីមែល: fao-kh@fao.org


សហភាពអឺរ៉ុប


អត្ថបទបោះពុម្ពនេះ
ត្រូវបានផលិតឡើងដោយមាន
ការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។



មាតិការអត្ថបទដែលស្តែងចេញនៅក្នុងការបោះពុម្ពនេះ
គឺជាការទទួលខុសត្រូវរបស់អង្គការ
ស្បៀង និងកសិកម្មនៃសហប្រជាជាតិ
(FAO) តែមួយគត់
និងពុំចាំបាច់ត្រូវឆ្លុះ
បញ្ចាំងអំពីទស្សនៈ
របស់សហភាពអឺរ៉ុបឡើយ។